# រឿង

# មួយខែក្បែរមច្ចុរាជ

**និពន្ធ គូររូប និង រចនាក្រប ដោយ**

អ្នកស្រី កែវ ចន្ទ័បូរណ៍
រដ្ឋមីនីសូតា សហរដ្ឋអាមេរិក
Pannalai Krang Meas
P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
www.angkorwat.com
www.camboda.com
www.chanbokeo.com

សូមទាក់ទង

016-318-023
012-774-751

ខែមករា ឆ្នាំ២០០៧

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO . COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

| | |
|---|---|
| ១- រឿង សំនៀងស្នេហ៍កវី | ២- រឿង និស្ស័យស្នេហ៍ |
| ៣- រឿង ផ្កាយវង្វេងមេឃ | ៤- រឿង ស្នាមញញឹម |
| ៥- រឿង កុលាបស្ទឹងខៀវ | ៦- រឿង ក្លិនផ្កាមាលតី |
| ៧- រឿង លិខិតមរតកសម្ងាត់ | ៨- រឿង បំណុលជីវិត |
| ៩- រឿង ចរណៃដួងទ័យា | ១០- រឿង អំបែងអណ្តែត |
| ១១- រឿង បើសិននៅមានថ្ងៃស្អែក | ១២- រឿង លំអងផ្កាស្នេហ៍ |
| ១៣- រឿង សារាណីយមាតា | ១៤- រឿង ទារុណដួងចិត្ត |
| ១៥- រឿង ស្អែកចាកផុតទៅ | ១៦- រឿង តន្ត្រីបេះដូង |
| ១៧- រឿង មួយខែក្បែរមច្ចុរាជ | ១៨- រឿង ខ្មើយវាសនា |
| ១៩- រឿង បើអាចបង្វិលផែនដី | ២០- រឿង លីវបុរេកាល |
| ២១- រឿង ត្រៃមិត្ររតននារី | ២២- រឿង មួយពាន់ទំព័រ |
| ២៣- រឿង អាមេរិកដែនដីមាស | ២៤- រឿង អាធ្រាតថ្ងៃរះ |
| ២៥- រឿង បក្សីសួនសុបិន | ២៦- រឿង ពិជេដ្ឋភាណុមា |
| ២៧- រឿង មេឃដ៏សក្តិសិទ្ធិ | ២៨- រឿង ផ្ការីកក្រៅសួន |
| ២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ | ៣០- រឿង អនង្គលាភា |
| ៣១- រឿង ក្រមុំព្រៃកូនខ្លា | ៣២- រឿង ពណ្ណរាយពេជ្រ |
| ៣៣- រឿង បទុមបឹងបិសាច | ៣៤- រឿង ផ្ការាជបឹងរាំង |
| ៣៥- រឿង ស្រីនាថភួងមាលា | ៣៦- រឿង រាត្រីសន្យា |
| ៣៧-រឿង ថ្វីបើជើងមេឃនៅឆ្ងាយ | ៣៨- រឿង មេឃរងា |
| ៣៩- រឿង អន្ទាក់ហឹង្សា | ៤០- រឿង ពិដោរផ្ការោយ |
| ៤១- រឿង បេះដូងសុក្រិត | ៤២- រឿង វាយោដួងចិត្ត |

ISBN: 99950-79-09-7

CHANBOKEO.COM

# សូមឧទ្ទិសស្នាដៃជូនចំពោះ

- លោកឪពុក ប៊ុនថង អ្នកម្ដាយ កែវយឿង
- លោកឪពុកក្មេក មេងស្រួង និងអ្នកម្ដាយក្មេក កូវសារ៉ាន់
- លោក មេងស្រួងសុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យ ជាបុត្រី
- បណ្ឌិត យូគិមទូយ សាស្ត្រាចារ្យ គិមមាសកូយ អ៊ាបសំភី អួននឿង
- អ្នកស្រី នៅសារិម វិទ្យុវីអូអេ សម្លេងសហរដ្ឋអាមេរិក
- អ្នកស្រី ប៉ិចសង្វារ៉ាន វិទ្យុបារាំងអន្តរជាតិ
- លោក លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោករើនរស់ អ្នកគ្រូ ជិនយ៉ាហាន អ្នកគ្រូម៉ៀចសុខារី អ្នកគ្រូ ចាន់ មណី
- លោកអ៊ុមសុនាថ លោកជិនសៅរិន លោកជាសយនា សារពត៌មាន កោះសន្តិភាព
- លោកខុតារាឫទ្ធិ នាយកកម្មវិធីសម្ភហកម្មនូហាច ភ្នំពេញ
- សាស្ត្រាចា

 រ្យ យូសុភា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម



អ្នកស្រី កែវ ចន្ទ័បូរណ៍

# ទស្សនៈអ្នកនិពន្ធ

នៅក្នុងរយៈកាលដែលកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម បំបែរចុងកាំភ្លើងដាក់គ្នាក្នុងផ្ទៃដីកម្ពុជារវាងឆ្នាំ១៩៧៩ ប្រជាពលរដ្ឋខ្មែរស្លូតត្រង់ជាច្រើនសែននាក់ បានរត់ភៀសខ្លួនពីស្រុកកំណើតចូលទៅក្នុងប្រទេសថៃតាមច្រកណងចាន់ ណងសាមិត គោកធ្លុង ភូមិភាគពាយ័ព្យនៃប្រទេសខ្មែរ ។ រឿង"មួយខែក្បែរមច្ចុរាជ"នេះ លាតត្រដាងអំពីការតស៊ូដ៏រន្ធត់ពិតៗរបស់បុរសនារីពីររូបដែលបានឆ្លងកាត់ទារុណភាពក្រោមនឹមកៀបសង្កត់របស់សង្គ្រាម ភាពទុរ្ភិក្ស និងពពួកខ្មាន់កាំភ្លើង ក្នុងខណៈដែលគេស្វែងរកត្រើយសន្តិសុខ និងសេរីភាពសំរាប់ជីវិតរបស់គេ ។

អ្នកនិពន្ធខ្ញុំសូមទទួលនូវមតិយោបល់អំពីប្រិយមិត្តអ្នកអានទាំងឡាយតាមរយៈអាសយដ្ឋានដូចខាងក្រោមនេះ ៖

Pannalai Kraing Meas
P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
www.chanbokeo.com

សូមប្រិយមិត្តប្រកបតែវឌ្ឍនសុខនិងសុវត្ថិភាពរាល់ទិវារាត្រី !

អ្នកស្រី កែវ ចន្ទ័បូរណ៍

ខែមករា ឆ្នាំ២០០៧

CHANBOKEO . COM

# ធំព័រកំណាព្យ

==================================================================

## វត្ថុអច្ឆរិយៈ

ក្នុងរឿងបុរាណមនុស្សចេះហោះ　　នាគហង្សគ្រុឌអស់យក្សអសុរី
ហោះហើរលើកភ្នំឆ្លងជលស័យ　　សិល្ប៍ច្បាំងខ្ញុំរដឹកក្រើកមេឃ ។
នៅពេលបច្ចុប្បន្នមនុស្សអស់ឫទ្ធិ　　លែងចេះហោះពិតគួរសង្វេគ
ថៃដន្យមនុស្សមានវត្ថុឯក　　អាចផលិតដែកឲ្យហោះបាន ។
ដែកហោះដឹកមនុស្សដឹកឥវ៉ាន់　　ឆ្លងទ្វីបមិនភន្តមិនដែលខាន
ផលិតដែកឲ្យអណ្តែតបាន　　លើសមុទ្រគ្រាណាដឹកសព្វមុខ ។
មនុស្សចេះផលិតជាយន្តហោះ　　វិទ្យុទូរទស្សន៍យន្តយានផ្ទុក
ទូរសព្ទឆ្លងទ្វីបមើលឃើញមុខ　　កុំព្យូទ័រស្ដុកស្ដម្ភសាស្ត្រា ។
នោះព្រោះមនុស្សមានទ្រព្យវរលក្ខណ៍　　មានអច្ឆរិយៈយ៉ាងអស្ចារ្យ
គឺជាគំនិតនិងប្រាជ្ញា　　ជាសិល្ប៍ស្រាយការយ៉ាងប្រសិទ្ធិ ។
ខួរក្បាលជាទ្រព្យអច្ឆរិយៈ　　កុំអោយស៊ីយធ្លាក់ភពវិបរិត
គួរណាស់ប្រើខួរអោយសុក្រិត　　បំរើជីវិតអោយថ្កុំថ្កើង ។

CHANBOKEO.COM

# ពុតគ្រូខូចច្បាប់

ពុតកំហុសគ្រូ កុំឡើយត្រាប់
ស្រង់តែក្បួនច្បាប់គ្រូប្រដៅ
ថៃ្ងដន្យ គ្រូអើយ ! ធ្វើម្ដេចទៅ
ច្បាប់គ្រូប្រដៅ គ្រូបែរខាន ។
បើច្បាប់គ្រូមានប្រសិទ្ធភាព
ម្ដេចគ្រូលង់ស្ទៀតពុតពេញប្រាណ
ម្ដេចមិនស្រង់ច្បាប់មកដាស់ប្រៀន
បង្រៀនខ្លួនឯងមុនប្រៀនសិស្ស ?
បើគ្រូរៀនច្បាប់ចាប់មិនបាន
សិស្សម្ដេចនឹងហ៊ានត្រង់ត្រិះរិះ
គ្រូប្រព្រឹត្តច្បាប់យ៉ាកដល់ម្លេ៎ះ
តើអោយសិស្សខ្មេះម្ដេចនឹងកើត ?
ច្នេះសិស្សសូមអោបដៃឈរមើល៍
រង់ចាំទង្វើគ្រូពិសោធន៍
គ្រូធ្វើអ្វីខ្លះអោយសិស្សកោត
នោះសិស្សលែងឆោតត្រង់ច្បាប់រៀន ! !

**ពុតគ្រូខូចច្បាប់ ត្រាប់ម្ដេចនឹងបាន ? ច្បាប់គ្រូកល្យាណ ពឹងគម្រូល្អ !**

CHANBOKEO . COM

# ចង់ចេះឲ្យល្អច ចង់ស្រួចឲ្យតម្រឹម

ចង់ចេះឲ្យល្អចគួចគេងគិត
សត្រាក្រមក្រិត្យនិត្យន័យអំថ
ដកស្រង់វិភាគកៀកពិចារណ៍
ល្អចរៀនខ្លឹមសារថ្លាចិញ្ចាច ។
ល្អចមើលបែបបទខ្ពត់វិន័យ
ល្អចគន់ស្នាដៃកវីប្រាជ្ញ
ល្អចល្បងសរសេរស្មេរឥតខ្លាច
ចងក្រងជាបាច់ចែកញាតិអាន ។
ចង់ស្រួចតម្រេះចេះតម្រឹម
តម្រង់ស្រង់ខ្លឹមផ្ទឹមកល្យាណ
តម្រៀបសាស្ត្រាសារលំអាន
តម្រេកតាមដានអានវិភាគ ។
តម្រឹមកាត់អស់សោះមន្ទិល
ឱហាតមិនខ្ជិលវិលបែរកៀក
សិក្សាវិជ្ជាកៀរចំរៀក
វែកញែកហែកច្រៀកភាគក្រមក្រិត្យ ។
ត្រងយកតែខ្លឹមនឹមប្រពៃ
ក្រេបអស់ស្នាដៃក្រែបណ្ឌិត
តម្រឹមចៀរកាត់ខ្ជាត់ឧក្រិដ្ឋ
សម្រួចជីវិតពិតរុងរឿង ។

CHANBOKEO.COM

# ទាហាន

ស្លៀកឯកសណ្ឋានស្ពាយកាំភ្លើង
ដើបភក្ត្រាឡើងយ៉ាងក្លាហាន
សំរែកជ័យឃោសន៍ខ្ទ័រភូមិស្ថាន
ជូនលោកទាហានចេញប្រយុទ្ធ ។
អនិច្ចាពេលលោកដួលក្នុងព្រៃ
ជីវិតក្សិណក្ស័យយ៉ាងតក់ស្លុត
ខេមរាភ្លេចគុណលោកប្រយុទ្ធ
ដេញខ្មាំងឧក្រិដ្ឋពីទឹកដី ។
ឯទាហានខ្លះគ្រោះពិការ
វិលចូលរង្គាខ្វះជើងដៃ
គ្រប់គ្នាបែរភ្លេចលោកប្រពៃ
ការពារទឹកដីផុតអាសន្ន ។
នេះឬសំណាងជាត្រើយផល
ខេមរានិមលភ្លេចនឹកគុណ
ពេលឈឺស្បថស្បៀងរីបន់
ដល់ជងឺស្រន់ឆ្មេចដើរហួស ។
ឯណាគុណធម៌ជាជាតិខ្មែរ
អ្នកក្រុងអ្នកស្រែគ្រប់សក្តិយស
ពេលស្រុកសាន្តត្រាណបែរឆ្លោតឆ្លោះ
ភ្លេចអ្នករំដោះឲ្យផុតភ័យ ?

# ផ្កាយ

ផ្កាយអើយផ្កាយរះភ្លឺព្រិចៗ
ពណ្ណរាយដូចពេជ្រឯវេហាស៍
យប់គ្មានដួងខែលិចម្លេះណា
បានផ្កាយរះថ្លាកំដរលោក ។
ពិតមែនតែផ្កាយតូចល្អិតក្រៃ
តែផ្តល់រស្មីយ៉ាងជ័យជោគ
ឃើញពន្លឺផ្កាយស្បើយវិយោគ
មនុស្សសត្វក្នុងលោកក្សេមក្សាន្តចិត្ត ។
មិនខុសពលរដ្ឋជនសាមញ្ញ
ក្នុងសង្គមមិញមានទឹកចិត្ត
សីលធម៌ភ្លឺថ្លាសាស្ត្រាក្រិត្យ
វិជ្ជាគំនិតភ្លឺដូចផ្កាយ ។
ពិតមែនប្រទេសយើងក្រីក្រ
ទុរគតទន់ទោរខ្វះពណ្ណរាយ
បើសិនពលរដ្ឋភ្លឺដូចផ្កាយ
ប្រទេសចាកឆ្ងាយលិចល្ងង់ខ្លៅ ។

CHANBOKEO . COM

# ឫសគល់សន្តិភាព

ឫសគល់សន្តិមានបួនបែប
បើសិនយើងសេពជីវិតសុខ
មួយចេះអរគុណជាត្រីមុខ
ពេលញាតិអ្នកស្រុកប្រព្រឹត្តល្អ ។
ពីរគឺដឹងខុសចេះសូមទោស
មិនពើបំផ្លើសបែរខ្នងចរ
ខុសហើយចេះកែប្រែមកល្អ
ញាតិចោមជូនពរបវរជ័យ ។
ទីបីវិសេសចេះប្រសើរ
ប្រព្រឹត្តទង្វើពិតប្រពៃ
នោះគឺយើងចេះអធ្យាស្រ័យ
ដល់ញាតិប្រុសស្រីពេលខុសឆ្គង ។
មិនប្រើកំហឹងរឹងទោសៈ
ចៀសវាងមោហៈដាក់ញាតិផង
ដោះស្រាយបញ្ហាដោយប្រាជ្ញអង្គ
មិនប្រើកម្លាំងពាលដូចសត្វ ។
នោះសន្តិភាពនឹងកើតមាន
ភពស្ងួគ៌ភិមានវង្សសម្បត្តិ
សង្គមប្រសើរល្អពេកក្កាត់
ជាតិរស់សុខគាប់ជាប់អង្វែង ។

CHANBOKEO.COM

# ក្លិនក្រអូប

មាលតីក្រអូបស្រូបមិនណាយ
ពិដោរផ្កាសាយគួរនៃបនិត្យ
មិនថាផ្ការីកស្រពោនស្វិត
គន្ធាប្រណិតមិនផ្លាស់ប្ដូរ ។
ក្លិនផ្កាមាលតីដូចកេរ្តិ៍ឈ្មោះ
អ្នកប្រាជ្ញថ្កើងយសក្នុងនគរ
ក្រងសព្វសាស្ត្រាចារយារយូរ
ចែកចាយហែហូរដល់កូនចៅ ។
ក្លិនផ្កាក្រអូបអប់ដួងចិត្ត
អោយស្រានៃបរិតផុតហ្មងសៅ
មិនស្មើក្រអូបឈ្មោះប្រាជ្ញនៅ
ទោះម្ចាស់ឃ្លាតទៅកូនចៅនឹក ។
មាលតីក្រអូបស្រូបមិនស្មើ
ក្លិនប្រាជ្ញប្រសើររសពន្លឹក
ក្លិនសាស្ត្រវិជ្ជាអ្នកប្រាជ្ញហ្វឹក
នាំឆ្លងផុតទឹកជ្រោះកម្លៅ ។

CHANBOKEO.COM

# ដៃពីរ

ដៃពីរសំខាន់ចំពោះមនុស្ស
ដៃប្រើសាងឈ្មោះរស់ថ្កុំថ្កើង
ដៃឆ្ការដីដាំដំណាំទ្រើង
ដៃធ្វើការឡើងនាំទ្រព្យធន ។
ដៃប្រើសរសេរសាងតម្រេះ
ស្រង់ស្រាវឯកទេសមិនឲ្យស៊ុន
ដៃមិននៅស្ងៀមដេកទំរន់
មិនលើកបែបន់ចាំព្រះជួយ ។
ដៃល្អធ្វើការមិនរួញរា
ដៃកាន់មុខងារជាជំនួយ
មិនផ្គុំតាមផ្លូវសុំគេជួយ
ដៃមិនរំអួយលើកសុំទាន ។
ដៃមានកិត្តិយសរស់នឹងធ្វើ
ការងារប្រសើរជួយរស់រាន
ដៃមិនលួចលុយទ្រព្យធនធាន
នាំញាតិរំខានក្នុងជីវិត ។
សិនអើយបើដៃមានប្រយោជន៍
ញាតិផងពិតស្ញើចដៃសុក្រិត
ដៃនាំកិត្តិយសឈ្មោះអម្រិត
កោសល្យវិចិត្រស្នាដៃមាស ។

CHANBOKEO.COM

# បណ្ឌិត

បណ្ឌិតពិតប្រាជ្ញមានតម្រេះ
វិជ្ជាចំណេះសព្វសាស្ត្រា
ចូលខ្លួនរៀនសូត្រក្នុងសាលា
ហ្វឹកហ្វឺនកិច្ចការប្រកួតជ័យ ។
ខំរៀនវិជ្ជាអស់ម្ភៃឆ្នាំ
ព្យាយាមសកម្មមានស្នាដៃ
ថែមការពិសោធន៍យូរឆ្នាំក្រៃ
ប្រកួតយកជ័យអស់សិស្សផង ។
បណ្ឌិតអ្នកប្រាជ្ញចេះប្រាកដ
ជំនាញវិញស្ទាត់ខ្ពស់ចំបង
មានការពិសោធន៍ជួយតម្រង់
វិជ្ជាក៏ខ្ទង់មិនផ្លូវកាត់ ។
នោះទើបហៅពិតបណ្ឌិតប្រាជ្ញ
ញាតិផងកោតខ្លាចប្រណិបតន៍
គោរពចំណោះភ្លឺពេកក្តាត់
មិនទិញផ្លូវកាត់ស្រោបសំបក ។
បណ្ឌិតមិនមែនសារិកា
គ្រាប់មាត់វោហារមិនអោយខក
បណ្ឌិតប្រាជ្ញតាន់មិនចំអក
មិនមែនសំបកដូចទីងមោង !

CHANBOKEO.COM

# ឆ្កែ

សត្វឆ្កែចិញ្ចឹមត្រឹមបាយសល់
មូសខាំរចល់ដេកផ្ទាល់ដី
យប់ឡើងយាមម្ចាស់ផុតគ្រោះភ័យ
ព្រុសឆ្អើលចោរព្រៃខានស្វែងលាភ ។
ឆ្កែការពារម្ចាស់ទាំងកូនចៅ
រក្សាញាតិផៅមានរបៀប
មិនថាយប់ថ្ងៃឆ្កែដេញរាប
ជនណាបៀនបៀតបំផ្លាញម្ចាស់ ។
ឆ្កែចេះស្គាល់គុណអ្នកចិញ្ចឹម
ញញឹមបម្រើឥតបម្រះ
មិនអកតញ្ញូដូចមនុស្សខ្លះ
ឆីឆ្អែតដៃបះវ៉ាយម្ចាស់វិញ ។
សិនមនុស្សស្គាល់គុណត្រឹមស្មើឆ្កែ
ម្ល៉េះសមជាតិខ្មែរលែងទោម្នេញ
ថៃងន្យជនខ្លះជ្រួលរមិញ
ជាន់កជាតិវិញអោយស្លាក់ស្លាប់ ។
មិនស្គាល់គុណជាតិផ្តល់កំណើត
ទឹកដីល្អឆើតសព្វភោគទ្រព្យ
ឆីឆ្អែតបែរឆ្គើនជាន់ជាតិងាប់
ខេមរាអភ័ព្វត្បិតកូនអកតញ្ញូ ។

# វគ្គទី១

## បេះដូងសុក្រិត

រដូវវស្សា ឆ្នាំ ១៩៧៩...

រសៀលថ្ងៃរៀបលិច...

ផាំង! ផាំង! ផាំង!

ស្នូរកាំភ្លើងផ្ទុះឡើងនៅលើផ្លូវជាតិលេខប្រាំ ជិតភូមិអូរស្នួត ខេត្តបាត់ដំបង ។

- អ៊ូយ!

នោះជាសម្លេងអ្នកស្រុកដែលធ្វើដំណើរតាមផ្លូវត្រូវចោរប្លន់ ។ ម្តុំនោះរាងស្ងាត់ដាច់ឆ្ងាយពីផ្ទះអ្នកស្រុកបន្តិចហើយមានគុម្ពោតព្រៃ ដើមអំពិលទឹកក្រាស់ៗ អមសងខាងផ្លូវ ដែលជាហេតុធ្វើឲ្យមនុស្ស ឧក្រិដ្ឋអាចលបលាក់ខ្លួនចាំប្លន់អ្នកដំណើរបានដោយងាយ ។

ពួកចោរប្រមូលឥវ៉ាន់រត់គេចបាត់អស់ហើយ ។ បុរសម្នាក់ដើប វារតតេះតតះចេញមកពីហ្វូងសពដែលត្រូវចោរបាញ់រះ មកជិត មិត្តរបស់ខ្លួនម្នាក់ដែលដេកស្លាប់ស្តូកស្តឹងនៅលើដី រួចហើយវាចា ទាំងទឹកភ្នែកស្រក់តក់ៗ ថា ៖

- សូមអោយបានដល់សុគតិភពផងណា៎សម្លាញ់!

គេលូកដៃទៅបិទភ្នែកឲ្យមិត្ត ហើយក៏ដើបទប់ខ្លួនដើរទាំងទុរន់ ទុរាចេញទៅ ។ នៅលើស្មារបស់គេមានរបួសឈាមហូរសស្រាក់ ជោគអាវ ។ ការពិត គេជាមនុស្សតែម្នាក់ដែលនៅសល់ពីស្លាប់ក្នុង ចំណោមមនុស្សទាំង៦នាក់ដែលត្រូវចោរប្លន់ ។ គួរអោយអនិច្ចា ណាស់! ហេតុតែខ្វះខាត ពួកគេមិនមានអ្វីទេ ក្រៅតែពីអំបិលនិង អង្ករម្នាក់មួយទៃតែប៉ុណ្ណោះ ប៉ុន្តែ ចោរទាំងនោះមិនបានប្រណី ជីវិតរបស់ពួកគេឡើយ ។ ពួកវាបានសម្លាប់ជីវិតជាច្រើននាក់ ដើម្បីប្លន់អំបិលនិងអង្ករតែប៉ុន្មានទៃ ដែលអ្នកដំណើរទាំងនោះមាន'ជាប់នឹងខ្លួនតែប៉ុណ្ណោះ ។ មើលចុះ! ពេលនេះ មនុស្សលោកបែរ

CHANBOKEO.COM

ក្លាយខ្លួនជាសត្វតិរច្ឆាន សម្លាប់គ្នា ដើម្បីតែអាហារមួយពេលៗ ។
នេះហើយឬលទ្ធផលនៃសង្គ្រាម ? នេះហើយឬសរសជាតិរបបខ្មែរ ក្រហមបដិវត្តន៍ដ៏អស្ចារ្យ បង្អត់បាយប្រជាពលរដ្ឋរហូតដល់មនុស្ស ក្លាយជាចោរហារយសម្លាប់មនុស្សដោយឥតញញើតដៃ ដើម្បីតែ ដណ្តើមអង្ករគ្នាធីចំអែតពោះដូច្នេះ ?

បុរសនោះខំប្រឹងដើររហូតដល់មាត់ទ្វារខ្ទមចាស់កំព្រូកមួយនៅ ដើមភូមិ ។ ចៃដន្យ ខ្ទមនោះរហែកធ្លុះធ្លាយនៅទំនេរចោលស្ងាត់ ជ្រងំគ្មានមនុស្សនៅទេ ។ ពេលនោះ មាណពយើងអស់កម្លាំងវិល មុខធ្វើដំណើរទៅទៀតមិនរួចសោះ ។ គេក៏ប្រាសខ្លួនលើកន្ទេលកក់ កញ្ចាស់ដែលក្រាលលើគំនរចំបើងក្នុងខ្ទម ប្រឹងធ្មេចភ្នែករំលត់ការ ឈឺចាប់នៅក្នុងខ្លួនទាំងប៉ុន្មាន ។

កំពុងតែមានអារម្មណ៍វង្វេងៗរករលត់ស្មារតីទៅហើយ ស្រាប់ តែមាណពឮសូរសម្រិបជើងដើរមកក្នុងខ្ទម ។ គេក៏បើកភ្នែករក មើល ក៏ប្រទះនឹងនារីមួយរូបស្លៀកពាក់ខោអាវពណ៌ខ្មៅចាស់កខ្វក់ មានបំណះរុំគួរអោយសង្វេគ ហើយទទូរក្រមាកណ្តាចចាស់ពណ៌ ខៀវប្រផេះ កំពុងយួរស្បោងមួយដើរចូលមក ។ លុះប្រទះនឹង វត្តមានរបស់មាណពយើងសណ្តូកជើង នៅលើកន្ទេលកក់កញ្ចាស់ នារីនោះភ្ញាក់ក្រញាង លាន់មាត់ឡើងថា ៖

- នែ៎ មិត្តស្ទីគេនេះ ! ម៉េចមកគេងលើកន្ទេលរបស់ខ្ញុំអញ្ចឹង ? ឆាប់ដើបចេញភ្លាម ! ដើបឡើង !

ថាហើយ មាណវីក៏ស្ទុះទៅទាញកន្ទេលរលាស់អោយមាណព ដើប ។ ឃើញដូច្នោះ បុរសនោះក៏ប្រឹងដើបឡើង ហើយស្រដីតប ទៅវិញថា ៖

- សូមទោសដែលខ្ញុំមិនបានដឹងថា កន្ទេលនេះមានម្ចាស់ទេ ត្បិត ស្មានថាជាកន្ទេលដែលម្ចាស់គេបោះបង់ចោល ទើបមកគេងលើ..!

ភ្លាមនោះ នារីដាក់ភ្នែកទៅឃើញតំណក់ឈាមប្រឡាក់លើ កន្ទេលរបស់នាង ក៏លាន់មាត់ថែមទៀត ៖

- អ៊ូយ ពុទ្ធោអើយ ! មានរបួសឈាមហូរពេញខ្លួន មកគេងលើ កន្ទេលរបស់ខ្ញុំ ប្រឡាក់ខ្ទេចខ្ទីអស់រលីង !

នារីនោះជ្រួញចិញ្ចើមសំដែងកិរិយាទ្រង់ខកចិត្ត បន្តិចមកក៏ បែរសម្លឹងបុរសយើង រួចស្ទុះដើបឈរឡើង ស្រដីថា ៖

CHANBOKEO.COM

- នែ៎! តើមិត្តឯងជាបក្សពួកខាងណា បានជាមានរបួសឈាម ពេញខ្លួនយ៉ាងនេះ ? មុខសៗភ្នែកលិបៗយ៉ាងនេះ សមតែជា.. ? អូហ៍! តើមិត្តជាកងទ័ពវៀតណាម វាយគ្នាជាមួយខ្មែរក្រហម រួច ហើយត្រូវរបួសមែនទេ ?

មាណពគ្រវីក្បាល ៖

- មិនមែនទេ! ខ្ញុំជាខ្មែរទេតើហ៍ កើតនៅបាត់ដំបងនេះឯង ។

- នរណាទៅជឿទៅលោកអើយ! មនុស្សសម័យនេះមានបេះដូង ឧក្រិដ្ឋណាស់ គ្មានភាពស្មោះត្រង់ក្នុងខ្លួនទេ ។

- ហើយចុះមិត្តនារីវិញនោះ តើមានបេះដូងឧក្រិដ្ឋដែរទេអីចឹង ?

នារីយើងភ្ញាក់ព្រើត បើកភ្នែកមូលក្រឡង់ កាលបើឮនរៈសួរ នាងដូច្នោះ ។ មាណវីយើងក៏តបវិញយ៉ាងលឿន ថា ៖

- ស្រេចតែមិត្តគិតទៅ!

កាលនៅសម័យនោះ ខ្មែរយើងទម្លាប់ហៅគ្នាថា"មិត្ត"តាមការ បង្ខិតបង្ខំរបស់អង្គការខ្មែរក្រហមដែលកាន់កាប់កម្ពុជាតាំងពីថ្ងៃ១៧ មេសា១៩៧៥ ។ ពេលនេះកងទ័ពវៀតណាមបានមកចូលកាន់កាប់ ទឹកដីខ្មែរហើយ ប៉ុន្តែជីវភាពប្រជាពលរដ្ឋមិនទាន់យល់ភាពសុខ សាន្តក្នុងជីវិតនៅឡើយទេ ជាពិសេសនៅតំបន់ភូមិភាគពាយ័ព្យ ខេត្តបាត់ដំបងតែម្តង ព្រោះជាកន្លែងដែលចុងកាណុងកាំភ្លើង បំបែរចំពុះប្រយុទ្ធមដាក់គ្នារវាងខ្មែរក្រហម កងទ័ពវៀតណាម និង កងទ័ពសេរីការ ព្រមទាំងមានពពួកកងចោរព្រៃចាំបបក់ជីវិតនិង ទ្រព្យរបស់អ្នកស្រុក នៅចន្លោះកងទ័ពទាំងបីមុំនោះផង ។

កាលបើបានជាប់មាត់ប្រស្រ័យការសន្ទនាជាមួយនារីយើងភ្លាម មាណពហាក់ដូចជាភ្លេចការឈឺចាប់អស់រលីង ។ គេមានអារម្មណ៍ ហាក់ដូចជាចង់ចាញ់ឈ្នះសំដីជាមួយនាងយ៉ាងណាមិនដឹង ។

- សង្ស័យតែមានបេះដូងឧក្រិដ្ឋហើយ ទើបកិរិយាមានពិរុទ្ធយ៉ាង នេះ!

(នរៈស្រដីបញ្ឆោះអោយមាណវី)

- នែ៎! កុំចេះ! នេះខ្លួនកំពុងឈាមរហាម ហើយដេកយំថ្ងូរឡើង ភ្នែកលិបមើលមិនឃើញប្រស្រី នៅមានមុខមកតវ៉ាស្ទីដែរ ?

CHANBOKEO.COM

- ឃើញមនុស្សមានឈាមពេញខ្លួនដែរ ម៉េចក៏មានមុខមកដេញ ទៀត ? ឆ្កួលមែន! បើតែយ៉ាងនេះ បើមិនអោយហៅថាជា មនុស្សបេះដូងឧក្រិដ្ឋទេ តើឲ្យថាយ៉ាងម៉េចវិញទៅព្រះអើយ ?

- យី! អ្នករបួសស្ទើរសំដីបានម្លេះ ? តិចពិបាកកេះដីអិដ្ឋ ញ៉ុកមាត់ញាត់រន្ធច្រមុះអោយដាច់ដង្ហើមតែស្នឹងតែម្ដង ឥឡូវហ្នឹង!

- ហើយចុះនារីស្ទើរ មិនសុភាពទន់ភ្លន់អីសោះ ? ឫកពានិងសំដីដូច ប្រុសបេះដាក់និយាយម៉ុងម៉ាំង ផ្គរលាន់ខែប្រាំងសុំខ្មាស!

យើញបុរសយើងសំដីខ្លាំងខែងរ៉ែងមិនព្រមចាញ់នាង មាណវី សម្លក់មាណពត្មែររួចហើយក៏ស្ទុះដើបទៅចាប់កន្ទេលទាញរលាស់ អោយបុរសដើបចេញ ។ ចៃដន្យនរ:យើងនៅឈឺចាប់ក្នុងខ្លួនផង ណាមួយចង់ឌឺ នារីមាត់ពូកែនោះផង គេមិនព្រមដើបទេ បែរជាផ្ដួលខ្លួនទំរេតពេញមួយកន្ទេលទៅវិញ ។ អត់មិនបាន នារីនោះក៏ ទាញកញ្ឆក់អស់ទំហឹងដៃធ្វើអោយកន្ទេលចាស់នោះរហែកខ្វាក ដាក់ចេញព្រុយសាញហុយកំទេចកក់ឡើងព្រោងព្រាត ។

- ស្លាប់ហើយ! ចិត្តអាក្រក់ម្លេះ ? មិនដែលឃើញទេ លោក!

បុរសនោះនិយាយបញ្ឆោះ ។

- យី! មាត់បានណាស់! របួសឈាមពេញខ្លួនហើយនៅមាត់ពូកែ ទៀត ? សង្ស័យតែរបួសពុតទេដឹង ? ឃើញទេ អ្នកធ្វើអោយ រហែកកន្ទេលរបស់ខ្ញុំខានប្រើហើយ ។

នារីស្រដីទាំងកំហឹង ។

- មកពីទេវតាឃើញមនុស្សចិត្តអាក្រក់ហ្នឹងណា៎ បានជាមិនជួយ កាន់ជើងនោះអី! ឃើញមនុស្សទុរន់ទុរាហើយមើលបំណាំ មិនតែ ប៉ុណ្ណោះ ដេញគ្នាចេញថែមទៀត!

បុរសឆ្លើយមកនារីយើងមែន តែគេនៅគេងសណ្ដូកជើងលើ កន្ទេលរហែកនោះដដែល ។ ម្ដងនេះ គេមានកិរិយាកាន់តែយ៉ាប់ ជាងមុនហើយ ទំនងអស់កម្លាំងខ្លាំងក្រៃលែង ។ ដោយនឹកសង្ស័យ មិនអស់ចិត្ត នារីនោះក៏ស្ទុះទៅទាញដៃមាណពអូសអោយដើបឡើងចង់សាក មើលថាតើនាយរបួសមែនឬអ្វី ធ្ងន់ឬក៏ស្រាល ?

ស្រាប់តែ..

- ស្លាប់ហើយ! មិត្តស្ទើរគេនេះ មានរបួសមែនតើហ៎!

បុរសនោះក៏បើកភ្នែកគ្រលួងឡើង ៖

CHANBOKEO.COM

- ឈ្មោះខ្ញុំមិនមែនមិត្តស្អីគេនេះទេ! ចង់ស្គាល់ឈ្មោះខ្ញុំទេ? នឹង អាលបានហៅអោយត្រូវផង! (នរៈយើងនិយាយបញ្ឆោះឲ្យមាណវី
ដោយសម្លេងខ្សាវ់ៗ)

- នែ៎! នរណាគេ ចង់ទៅស្គាល់ឈ្មោះនាយជ្រូកភ្នែកលិបនោះ? មើលចុះ! លិបតែភ្នែកទេ តែមាត់វិញព្រឆ្លើលភ្ញមិនលល់សូរហើយ!

ព្រនារីឆ្លើយបញ្ឆោះមកវិញ រួចហើយក៏ស្ទុះដើបដើរចេញទៅ ។ មាណពខំដើយមើលតាមនាង ស្រាប់តែនារីបែរក្រោយស្រដីថា ៖

- ម៉េចដែរ? តាមសម្លឹងអត់ដាក់ភ្នែកហ្នឹង ចង់សុំពឹងអោយជួយ រុំរបួសមែនទេ?

ស្រាប់តែម្តងនេះ បុរសបិទភ្នែកទៅវិញ នៅស្ងៀមមិនព្រម ឆ្លើយប៉ោចៗដូចមុនទៀតឡើយ ។ នារីនោះនឹកពិភាល់ក្នុងចិត្ត ក៏ ស្ទុះមកជិត ហើយស្រដីដោយសម្លេងទន់ជាងមុន ៖

- នែ៎ មិត្តភ្នែកលិប! យ៉ាងណាៗ សុំមេត្តាកុំដាច់ខ្យល់ស្លាប់នៅក្នុង ខ្ទមនេះអី! អាណិតទុកកន្លែងអោយខ្ញុំជ្រកដេកពួនផង ព្រោះបើ អ្នកដាច់ខ្យល់ស្លាប់ទៅ ខ្ញុំលីសពអ្នកទៅកប់មិនរួចទេ ។ ណាមួយខ្ញុំ អត់មានចបកាយដី ហើយខ្ញុំក៏ស្គមទៀតផង គ្មានបាយចូលពោះ ច្រើនថ្ងៃហើយ ញាំុតែដំឡូងដុត ហេវអស់កម្លាំងណាស់! ណា៎! ណា៎! អោយខ្ញុំសូមអង្វរមិត្តម្តងទៅចុះ ។

រំពេចនោះ ស្រាប់តែមាណពប្រែខ្លួន ហើយបើកភ្នែកឡើង ថែមទាំងស្រដីខ្សេវៗថា ៖

- បើមិត្តនារីឯងមិនមានបេះដូងឧក្រិដ្ឋទេ ខ្ញុំក៏មិនស្លាប់ថ្ងៃនេះដែរ
នឹងហើយឬនៅ?

នារីភ្ញាក់ព្រើត បើកភ្នែកធំៗ យល់សំដីរបស់គេភ្លាម ថាគេ កំពុងចង់អោយនាងជួយ ។ ស្រស់ស្រីយើងក៏ឈប់ហើបមាត់តវ៉ាអ្វី ជាមួយនឹងបុរសយើងតទៅទៀត ។ ភ្លាមនោះ មាណពក៏បិទភ្នែក សម្ងំទៅវិញ ។ មាណវីដើបដើរចុះដើរឡើងមួយស្របក់ ។ ឯភ្នែក វិញ សម្លឹងបុរសចម្លែកឥតឈប់ដែរ ថែមទាំងគិតថា ៖

- តើខ្ញុំគួរជួយគេឬក៏យ៉ាងណា? តើគេជាជនស្លូតត្រង់ ឬគេជាជន ឧក្រិដ្ឋខ្មែរក្រហម ឬកងទ័ពយួនដែលត្រូវអ្នកស្រុកដាក់ទោស ទើប មានរបួសរត់មកលាក់ខ្លួននៅទីនេះម្នាក់ឯង? បើយើងជួយប៉ះចំ មនុស្សល្អទៅ មិនអីទេ ។ តែបើប៉ះចោរព្រៃឬជនឧក្រិដ្ឋវិញ យើង

CHANBOKEO.COM

ពិតជាស្តាយក្រោយណាស់ ។ ប៉ុន្តែ បើយើងបញ្ឈរភ្នែកមើលវិញ តិចលោប៉ះមនុស្សសុចរិតដូចគ្នា
មិនខកទៅហើយទេហ៍ ? តើយើង ត្រូវធ្វើម៉េចអញ្ចោះហ្ន៎ ?

នារីយើងឈរអេៗមួយស្របក់ ទីបំផុតក៏សំរេចចិត្តដើរចេញ ទៅបោចស្លឹកអំពិលមួយក្តាប់ធំ
ដាំទឹកដាក់បង់អំបិល បំរុងយកមក លាងរបួសអោយបុរសនោះ ។ លុះវិលមកដល់ក្នុងខ្ទមវិញ
នារី ឃើញបុរសនោះនៅដេកស្ងៀមស្តូកស្តឹងកន្លែងដដែល ។ នាងក៏ ចាប់បង្វិលខ្លួនគេដោះអាវ
រកមុខរបួសដើម្បីលាងសំអាត ។

កំពុងតែជូតរបួស ស្រាប់តែបុរសប្រែខ្លួនធ្វើមុខជូរ ។

- នែ៎ របួសដាច់តែស្បែកត្រឹមតែម៉ាឆ្នូតទេ មិនឃើញមានត្រូវ គ្រាប់ផ្លុះសាច់កន្លែងណាសោះ
ហេតុអ្វីក៏វាយឫកធ្វើមើលតែជិត ស្លាប់អញ្ចឹង !

តែម្តងនេះ បុរសនៅស្ងៀមមិនតបតទេ ។ ការពិត គេធ្វើ ដំណើរអត់បាយតាំងពីព្រឹក
ព្រោះមានតែអង្ករដែលទើបនឹងដូរមក បាន មិនទាន់រកឆ្នាំងបានដាំបរិភោគនៅឡើយ
ទទួលពួកចោរវាប្លន់ យកអស់ទៅ ។ ដោយសារឈាមហូរពីខ្លួនផង ដោយអត់បាយផង
ដោយគេស្ពាំងស្គមស្រាប់ផង គេទ្រាំទ្រមិនបានមិនបាន ទើបរាង
កាយហាក់ដូចជាទុរន់ទុរាខុសធម្មតា ថ្វីបើរបួសនោះមិនជាធ្ងន់ធ្ងរ ប៉ុន្មានក៏ដោយ ។

ដោយរកក្រណាត់រុំរបួសអោយមាណពមិនបាន នារីយើងក៏ដាច់
ចិត្តដោះក្រមាចាស់របស់នាងពីក្បាល យកទៅរុំដើមដៃនឹងស្មារបស់ នរៈយើង
ដើម្បីឃាត់មុខរបួសកុំអោយឈាមចេះតែហូរចេញមក ទៀត ។ រំពេចនោះ
ស្រាប់តែមានភ្លៀងធ្លាក់ឈ្ងួ ដូចគេចាក់ទឹកពី លើមេឃ សម្រក់តំណក់ទឹកតាមដំបូលស្បូវដាច
ចូលមកក្នុងខ្ទម តក់ៗខាងនេះ តក់ៗខាងនោះ ។ នារីយើងក៏ដើបគេចមិនអោយ
ទឹកភ្លៀកស្រក់ទទឹកខ្លួន ។ លុះបែរទៅបុរសយើងវិញ នាងឃើញ
ទឹកស្រក់ពីដំបូលទៅលើកន្ទេលមាណពច្រើនកន្លែង ក៏ស្ទុះទៅជួយ លើកគ្រាហ៍នាយឡើង
ដើម្បីប្តូរកន្លែងទៅគេងលើគំនរចំបើងម្ខាង ទៀតដែលមានសុវត្ថិភាពជាងមុន ។
មើលទៅអាការៈរបស់នាយ ម្នាក់នោះក៏ហាក់ដូចជាទន់ខ្សោយខ្លាំងដែរ ។ គេជ្រួញមុខប្រឹងរំលត់
ការឈឺចាប់ជាច្រើនដង តែក៏មិនឮថ្ងូរអ្វីចេញមកមួយម៉ាត់ឡើយ ។
មាណវីក៏នៅអង្គុយធ្វើភ្នែកម៉ក់ៗ សម្លឹងបុរសចម្លែក ដោយកិរិយា ស្ងៀមស្ងាត់ ។ បន្តិចមក
នាងក៏ទន់ត្របកភ្នែកងោកងុយ ទំនង អស់កម្លាំង ។ ទីបំផុត

CHIANBOKEO.COM

នាទីយើងក៏ប្រាសគេងលើគំនរចំបើងក្បែរ នរៈដែរ ព្រោះមានតែទីនោះទេ ដែលគ្មានទឹកភ្លៀងស្រក់ទទឹក ។

*ooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី២
# កូនមាន់និងជ្រូក

មាន់រងាវចីនង...

មេឃចាប់ផ្ដើមមានពន្លឺព្រាងៗហើយ...

មាណពភ្ញាក់ឡើងបើកភ្នែកសម្លឹងពិភពលោកសាជាថ្មីស្រាប់តែ ភ្ញាក់ព្រើត ត្បិតប្រទះឃើញមាណវីគេងកំពុងលង់លក់ស្ងៀមស្ងាត់ ក្បែរខ្លួនរបស់គេ ។ នរៈញីភ្នែកសម្លឹងភក្ត្រនារីយ៉ាងយូរអស់ចិត្ត អស់ចង់ ។ មែនហើយ! កាលពីម្សិលមិញ គេមិនបានចាប់ភ្លឹកនឹង សង្កេតរូបរាងសោភ័ណនារីមួយរូបនោះទេ ព្រោះអស់កម្លាំងពេកណាមួយកំពុងតែឈឺមុខរបួសផង ។ ពេលនេះ គេបានឆ្អែតសំរាក ពេញមួយយប់ ភ្ញាក់ឡើង គេហាក់ដូចជាមានអារម្មណ៍គ្រាន់បើជាង ពីម្សិលច្រើនណាស់ ។ បុរសយើងគេងសង្កេតភិនភាគនារីម្នាក់ឯង រួចហើយក៏លួចគិតក្នុងចិត្តស្ងាត់ៗ ថា ៖

- ពិតមែនតែនាងសម្បុរខ្មៅហើយស្គាំងស្គមស្លេកស្លាំង តែនាងមានសោភ័ណគួរអោយចាប់អារម្មណ៍ណាស់ នឹងទេ ? ហើយអោយ ខ្ញុំសុំអរគុណនាងផង ដែលមានចិត្តសប្បុរសជួយរុំរបួសអោយខ្ញុំ... ការពិត នាងមានចិត្តល្អដែរតើហ៍ ថ្វីបើនាងមានសំដីញ៉ុងញ៉ាំងដាក់ ខ្ញុំបន្តិចក៏ដោយ...

មាណពក៏លួចញញឹមតែម្នាក់ឯង ។ ទោះបីពេលនោះ របួសរបស់នាយមិនទាន់ធូរស្រាលនៅឡើយ ប៉ុន្តែ កាលបើគេមាននារី

CHANBOKEO.COM

ស្រស់ស្អាតម្នាក់មកគេងប្រឃខ្លួនយ៉ាងនេះ គេមានចិត្តរំភើបប្លែក យ៉ាងណាមិនដឹងទេ បេះដូងគេរំភើបក្ដុកក្ដាក់រកថាមិនត្រូវសោះ ស្ទើរតែភ្លេចបាត់នូវអារម្មណ៍ឈឺចាប់ទាំងឡាយអស់រលីងតែម្ដង..

ភ្លាមនោះ មាណវីប្រែខ្លួនឡើងបើកភ្នែក ស្រាប់តែប្រទះនឹង ក្រសែភ្នែកមាណពយើង ក៏ស្ទុះហក់ក្រោកឡើងគេចទីងសឹងបាក់ក រហ័សជាផ្លេកបន្ទោរ ទៅអង្គុយនៅឆ្ងាយបន្តិច តែក៏មិនជាឆ្ងាយ ប៉ុន្មាន ព្រោះអីនៅទីផ្សេងទៀតក្នុងខ្ទម មានសុទ្ធតែទឹកភ្លៀងដក់ សើមពាសពេញទាំងអស់ ៖

- នែ៎កូនទន្សាយ! ភ្ញាក់ផ្អើលអីហ្នឹង?

មាណពសួរ ។ នារីយើងព្វដូច្នោះ បើកភ្នែកម្លូលក្រឡង់ ៖

- នរណាគេកូនទន្សាយ?
- បើមិនមែនកូនទន្សាយទេ តើជាអ្វីទៅវិញ មាន់ក្រញាសមែនទេ មិត្តប្អូន?
- តែផ្ដាស! នរណាជាមាន់ក្រញាសនោះ?
- គឺ... នរណាដែលមានសក់រួញអង្កាញ់ៗ គួរអោយស្រឡាញ់ មើលម៉ាភ្លែត ច្រឡំស្មានថាជាមាន់ក្រញាសនោះអី!

រំពេចនោះ មាណវីសម្លក់នរៈស្ទើរតែអស់គ្រាប់ភ្នែកខ្មៅ ព្រោះ ខ្ញាញ់នឹងការបញ្ឆោះដៀមដាមរបស់បុរសយើង ។

- ហើយមិត្តនារីសម្លក់ខ្ញុំនេះ ព្រោះលួចស្រឡាញ់ ឬសម្លក់លួច ខ្ញាញ់ បានជាមិនពព្រិចភ្នែកអីបន្តិចអញ្ចឹង?

ភ្លាមនោះ ស្រាប់តែនាងផ្ទុះសំណើចសើចខឹកៗរអឹកឡើង ។

- អស់សំណើចរឿងអីហ្នឹង? (បុរសសួរ)
- គឺសើចរឿងជ្រូកភ្នែកលិបយល់ច្រឡំថាខ្លួនសង្ហានោះអី! បើ និយាយពីនាយជ្រូកទីប៉ូចកាយសិស្សលោកគ្រូថាំងចេងវិញ ក៏គួរឲ្យ ស្នេហ៍ជាងនេះបន្តិចដែរ ត្បិតមានសាច់មានឈាមទ្រលុកទ្រលន់ ។ ចម្លែកអីតែជ្រូកមួយនេះ ភ្នែកក៏លិប ស្គមនោះក៏មហាស្គម ស ស្លេក អត់មានឈាមម៉ាតំណក់ មិនដឹងថាគួរឲ្យស្នេហ៍ត្រង់ណាសោះ ហើយ លោកអើយ!
- ដឹងអីថា! នរណាទៅដឹង? យប់មិញ ជ្រូកគេងម្នាក់ឯងសុខៗ ស្រាប់តែមានកូនមាន់ក្រញាសពីណាមកទេ វង្វេងផ្លូវមកត្បុលគេង

CHIANBOKEO.COM

កៀនក្លៀកជ្រូកភ្នែកលិបអស់ពេញម៉ាយប់... ហ៊ឹ..! គួរឲ្យអាណិត កូនមាន់មួយនោះដល់ហើយ! ហេតុតែគ្នារងា... ទើបសុខចិត្តទ្រាំ គេង ហិតក្លិនក្លៀកជ្រូកភ្នែកលិប ទាល់ភ្លឺ មាន់រងាវ មិនខ្វីភ្ញាក់!

រំពេចនោះ ស្រាប់តែនារីយើងធ្វើមុខក្រហមងាំង ព្រោះនាយ យើងចាប់នាងចំចំណុចខ្សោយ ។ នាងក៏ល្មោកមុខសំយុងសក់ បាំងមុខដោយក្ដីខ្មាសអៀន ព្រោះអត់ក្រមាទុំលាក់ បន្តិចមក ក៏បែរឆ្លើយវិញថា ៖

- អនិច្ចាតែជ្រូកមួយនោះទេ ដែលវង្វេងទ្រុង មកបន្លំខ្លួនគេង ក្នុងគំនរចំបើងសំបុកមាន់ មិនតែប៉ុណ្ណោះ ចង់អុងអាត់វាតទី រួច ដេញម្ចាស់គេចោលទៀត... គួរអោយអណោចអធម្មណាស់!

ម្ដងនេះ បុរសយើងបិទមាត់ដូចគេចុកម្ដង ព្រោះនាយបានមក ដណ្ដើមទីរបស់គេមែន ។ បន្តិចមក គេក៏បន្ទន់សំដី ឈប់លលេង នឹងនារីយើងទៀត ៖

- អញ្ចឹង អោយខ្ញុំសុំអរគុណមិត្តនារីផងណា៎ ដែលជួយសង្គ្រោះខ្ញុំ លើកនេះ ។ ពេលនេះ ខ្ញុំមិនមានអ្វីតបស្នងមិត្តនារីទេ ប៉ុន្តែ បើ មានឱកាស សុំអោយខ្ញុំបានសងគុណមិត្តនារីខ្លះៗវិញផងណា៎!

ភ្លាមនោះ គេក៏ប្រឹងដើបឈរឡើង បំរុងដើរចេញពីខ្ទម ។

- ហើយចុះមិត្តបំរុងចេញទៅណា៎ដែរ ? (នារីម្នាក់នោះសួរ)
- គ្មានទីដៅទេ...! ខ្ញុំគិតថាធ្វើដំណើរទៅសេរីសោភ័ណ ។
- ឮថាផ្លូវនោះគ្រោះថ្នាក់ណាស់ ? ហេតុអ្វីប្រថុយទៅអញ្ចឹង ?
- ខ្ញុំគ្មានទីជ្រើសរើសទេ! ឪពុកម្ដាយបងប្អូនស្លាប់អស់ហើយ នៅ សល់តែម្នាក់ឯង ។ ខ្ញុំមិនដឹងថាត្រូវធ្វើដូចម្ដេចទៀតទេ ចេះតែ ដើរៗ រសាត់អណ្ដែតទៅ ស្លាប់ឬរស់តាមតែដំណើរ...
- ហេតុអ្វីក៏ស្រដី មើលតែជីវិតលោកនេះ ចង្អៀតគ្មានច្រកចេញ អញ្ចឹង ?
- មានន័យថា ជីវិតរបស់មិត្តនារីប្រសើរជាងខ្ញុំហើយ ទើបអាចរក ច្រកចេញឃើញ ?
- នរណាថា ? ឪពុកម្ដាយបងប្អូនរបស់ខ្ញុំត្រូវគេសម្លាប់អស់រលីង សល់តែខ្ញុំម្នាក់ដែលរត់រួចមក ផ្ទះក៏គ្មាន ញាតិក៏គ្មាន តើមានអ្វីទៅ ដែលបញ្ជាក់ថាមានប្រសើរជាងគ្នានោះ ?

នរៈទុចង៉ក់ បែរមករកមាណវីយើង ៖

- អញ្ចឹង យើងមិនខុសគ្នាទេ...! ប៉ុន្តែ មើលទៅមិត្តនារីហាក់ដូច ជាមានទឹកចិត្តរឹងប៉ឹងជាងខ្ញុំឆ្ងាយណាស់ ។

CHANBOKEO.COM

- បើខ្ញុំមិនប្រឹងជួយខ្លួនឯង តើមាននរណាគេមកជួយបានទៅ ? រង់ចាំព្រះយាងមកប្រស់ជីវិតអោយភ្លឺស្វាងហ្អែស ? ទៅមិនរួចទេ ខ្មែរវាល់លាននាក់កំពុងរងទុក្ខខ្លោចផ្សាខ្លាំងណាស់ ។ នរណាៗក៏ ទទូចបន់ស្រុំព្រះអង្គយាងមកប្រស់ជីវិត ផ្តល់ក្តីសង្ឃឹមរបស់ពួកគេ ដែរ ។ តើព្រះអង្គមានឱកាសឯណានឹងមកស្តាប់បំណាន់របស់ខ្ញុំ ? គឺមានតែប្រឹងជួយខ្លួនឯងតែប៉ុណ្ណោះ ជាពិសេស កាលបើយើង មានដៃមានជើង មានសតិប្រាជ្ញ ហេតុអ្វីមិនប្រើវាអោយមាន ប្រយោជន៍ឡើង ? ហេតុអ្វីត្រូវចុះចាញ់ជីវិតផង ?

មាណពស្តាប់ប្រយោគនេះចប់ក៏ជ្រួញចិញ្ចើមឡើង ឧទានថា ៖

- មិត្តនារីពិតជាមានស្មារតីរឹងប៉ឹងគួរអោយសរសើរណាស់ ។

ពោលចប់ គេក៏បែរសម្លឹងមុខមាណវីដោយក្រសែភ្នែកភ្លឺថ្លា ផ្លេកៗ ទំនងដូចជាពេញចិត្តនឹងភាពមោះមុតរបស់នារីយើង ។ នារីក៏ស្រដីបន្តថា ៖

- មិត្តឃ្លានអាហារទេ ? ម្រិលមិញ ខ្ញុំបានជីកដំឡូងពីចំការដែល គេបោះបង់ចោលបានមួយស្បោងធំឯណោះ! ចាំខ្ញុំបង្កាត់ភ្លើងដុត ចែកគ្នាទទួលទាន នឹងអាលមានកម្លាំងនឹងប្រឈមមុខជាមួយជីវិត តទៅទៀត ។

នរៈយើងញញឹមឡើង ដោយឃើញនារីបន្ទន់ឥរិយាជាងមុន ។

នៅជុំវិញគំនរភ្នក់ភ្លើងហុយៗ កៀនខ្មមកញ្ជាស់ទ្រុឌទ្រោម...

មាណពហែកដំឡូងដុតទទួលបណ្តើរ លួចសម្លឹងមុខនារីមួយ រូបនោះបណ្តើរ ថែមទាំងលួចគិតក្នុងចិត្តថា ៖

- ការពិត នាងជាមនុស្សមានចិត្តសប្បុរសណាស់តើហ៎ គ្រាន់តែ នាងមានសំដីទ្រគោះបោះបោកមិនសូវពិរោះបន្តិច ។

ស្រាប់តែនាងយកដៃមកបក់ភ្នែកមាណព ហើយស្រដីថា ៖

- នែ៎! កើតអីហ្នឹង បានជាអង្គុយភ្លឹក មិនព្រិចភ្នែកសោះ ? វិញ្ញាណហ្នឹង អាល័យហោះទៅជួបសង្សារនៅឯណាហ្អ៎ស ?

នរៈភ្ញាក់ព្រើត ញញឹមឡើង ៖

- គឺ...ខ្ញុំកំពុង...ចង់ដឹងឈ្មោះមិត្តនារីហ្នឹងណា៎...

- ហ្អ៎ក! ចង់ដឹងធ្វើអី កាលបើដឹងរួចទៅហើយហ្នឹង ?

- អូហ៎ ? ហើយខ្ញុំដឹងពីអង្កាល់ ?

CHANBOKEO.COM

- បើមិនដឹង ម៉េចក៏ហៅខ្ញុំចំឈ្មោះល្អម្ល៉េះ អំបាញ់មិញនេះ ?
- ថាម៉េច ? ខ្ញុំហៅមិត្តនារីចំឈ្មោះ ?
- ចា៎ស ! មែនហើយ !

មាណពអេះក្បាលរកនឹក បន្តិចមកក៏ញញឹមហើយតបថា ៖

- នាងឈ្មោះកូនមាន់មែនទេ ?
- គឺស្រដៀងៗហ្នឹង !
- អញ្ចឹងមានតែ... (ស្រាប់តែនាយបើកភ្នែកធំៗហើយសើចកក្អឹក ឡើង) ឈ្មោះកូនមាន់ក្រញាស មែនទេ ?

មាណវីភ្ញាក់ព្រើត ឧទានតបវិញ ៖

- ឆ្លាតដែរតើហ៎ មិត្តជ្រូកឯងនេះ ! ហើយចុះមិត្តឈ្មោះអីដែរ ?

ស្រាប់តែមាណពយកដៃច្រត់ចង្កា សើចកខឹកៗឡើង ៖

- ការពិត យើងស្គាល់ឈ្មោះគ្នាទៅវិញទៅមកហើយតើហ៎ មានចាំ បាច់សួរឈ្មោះគ្នាទៀតធ្វើអី ?
- ពុទ្ធោ ! មិត្តឯងឈ្មោះជ្រូក ?
- បើមែននោះ យ៉ាងម៉េចដែរ ?
- ស្រេចហើយ ភ្នែកលិបហើយឈ្មោះជ្រូកទៀត ជាន់រូបដល់សូរ !

មាណពក៏សើចកខឹកឡើង កាលបើឃើញនារីលាន់មាត់ដោយក្តី ភ្ញាក់ផ្អើល ។ ពេលនោះ គេមានអារម្មណ៍ថា ការឈឺចាប់ផ្លូវកាយ របស់គេបានរលាយទៅអស់រលីង គ្មានសល់ ជាពិសេសតាំងពី ប្រទះវត្តមានរបស់នារីយើងមក ។ ពេលនេះ គេលួចគយគន់នាង លួចពិចារណារូបនាង កាន់តែច្រើនឡើង ញឹកញាប់ឡើងហើយ ។

ភ្លាមនោះ មានអ្នកដំណើរពីរបីនាក់ដើរចូលមក ៖

- អឺ ! ម្ចាស់ខ្ទម ! សុំទឹកទទួលទានបន្តិចបានទេ ?

បុរសម្នាក់ពោលឡើង ។ នារីឈ្មោះកូនមាន់ក្រញាស ក៏ដើប ទៅដួសទឹកពីពាងចាស់ក្រោយខ្ទមមួយត្រឡោកមកហុចឲ្យ ៖

- នេ៎ះទឹក ពូ ! អញ្ជើញពិសា !

ពូម្នាក់នោះទទួលទឹកហើយ ក៏យកហុចបន្តចែកកូននិងប្រពន្ធ ដែលធ្វើដំណើរជាមួយគ្នា ។

- ពូមីងធ្វើដំណើរទៅស្រុកវិញមែនទេ ?

គាត់គ្រវីក្បាល ៖

CHANBOKEO.COM

- អត់ទេ! ពូគិតនាំគ្នារត់ទៅរកស៊ីនៅទល់ដែន ។ ឮថាទីនោះមាន
អង្គការកាកបាទក្រហមអន្តរជាតិចែកអង្ករចែកថ្នាំ ហើយប្រពន្ធពូ កើតរបេង ឯពូវិញកើតម្រេញ
ទើបចង់នាំគ្នាទៅព្យាបាលផង ។
- ប៉ុន្តែ ខ្ញុំឮដំណឹងថាតាមផ្លូវគ្រោះថ្នាក់ណាស់ពូ!
- ពូក៏ឮល្បីអញ្ចឹងដែរ ប៉ុន្តែបើនៅស្រុកខ្មែរមានតែស្លាប់ប៉ុណ្ណោះ ព្រោះអង្ករក៏គ្មាន ផ្ទះក៏គ្មាន
ហើយទ្រព្យតូចតាចតាមខ្លួនក៏គ្មាន... ដូច្នេះហើយមានតែប្រថុយៗទៅ ក្រែងលោបានផុតស្លាប់...
- អញ្ចឹង! ខ្ញុំសូមជូនពរអោយពូនិងគ្រួសារ បានសុខសប្បាយ តាមផ្លូវ ។
រំពេចនោះ កុមារតូចកូនរបស់ពូមីងអ្នកដំណើរនោះ សម្លឹង មើលទៅគំនរដំឡូងដុតភ្លៀកៗ
ហើយលួចយកដៃអង្រួនឪពុក ។ នីតាយើងយល់ភ្លាម ក៏ស្រវាហែកស្លឹកចេញពីចំហៀងខ្ទម
ខ្ទប់ឲ្យ ដោយក្តីអាណិតអាសូរចំពោះក្មេងដ៏សែនស្គាំងស្គមនោះ ។
- នេះដំឡូងដុតពីរបីដុំ! អូនតូចយកទុកញ៉ាំតាមផ្លូវចុះណ៎!
កុមារលូកដៃស្រវាទទួលយ៉ាងលឿន ទំនងឃ្លានខ្លាំង ។
- អរគុណណាស់ នាង! សូមអោយនាងបានសុខចំរើនណ៎ក្មួយ!
ពូម្នាក់នោះ ស្រដីហើយក៏នាំប្រពន្ធកូនចេញទៅ ។
មិត្តជ្រូកលួចមើលគ្រប់កាយវិការនារី ហើយលួចជ្រួញចិញ្ចើម តែម្នាក់ឯង ។
លុះអ្នកដំណើរទាំងនោះចេញទៅបាត់ គេក៏សួរនារី យើងថា ៖
- នែ៎ កូនមាន់! មានដែលគិតទេថា ចង់ទៅរកស៊ីនៅទល់ដែនអ្វី នឹងគេ
ក្រែងលោប្រទះជីវភាពប្រសើរជាងនេះ ?
- រកស៊ី ? ខ្ញុំជាស្រីអញ្ចឹង ទៅរកស៊ីស្អីនៅទល់ដែននោះ ?
- គឺទៅរែកតវ៉ាន់រត់ពន្ធយកសោហ៊ុយនោះអី ក្រែងលោមានលាភ មានជ័យ
រកទ្រព្យបានមានដើមទុនចិញ្ចឹមជីវិតភ្លឺស្វាងជាងនេះ ។ មើលចុះ រស់នៅក្នុងខ្ទមរហែក
ហើយដើរតែជីកដំឡូង ដាំដំឡូង បរិភោគយ៉ាងនេះ ជីវិតមិនចំរុងចំរើនទេណ៎!
- នរណាថាខ្ញុំចង់រស់នៅជីវិតបែបនេះ ? ការពិត ខ្ញុំទើបតែរត់
គេចមកពីក្រញាំដៃខ្មែរក្រហមនៅភូបនិម្មិត ។ ពេលនេះ ខ្ញុំចង់តែ
ធ្វើដំណើរត្រឡប់ទៅស្រុកវិញនៅបាត់ដំបងវិញ ទើបតែដើរបាន មកដល់អូរស្គួតព្រឹកម្សិលមិញ
ហើយចូលស្នាក់នៅខ្ទមនេះតែម្តង!
- អញ្ចឹងទេហ៍! មានន័យថា កូនមាន់ឯងធ្វើដំណើរបញ្ច្រាសទិស របស់ខ្ញុំហើយ!

CHANBOKEO.COM

- អូហ៍ ហើយមិត្តជ្រូក បំរុងទៅណាដែរហ្នឹង ?

- ដំបូងគិតថា ចង់ទៅរកស៊ីត្រឹមសេរីសោភ័ណទេ តែកាលបើបាន ឮសំដីពូអ្នកស្រុកអំបាញមិញនោះ ខ្ញុំហាក់ដូចជាមានអារម្មណ៍ថាចង់ ទៅដល់ទល់ដែនតែម្តង ទៅរកស៊ីផង ហើយចង់ទៅរកផ្លូវផង ក្រែងលោអាចចេញទៅរស់នៅប្រទេសក្រៅបានទៀត ។

- ទៅប្រទេសក្រៅ ? ហេតុអ្វីមិនចង់រស់នៅស្រុកខ្លួនឯងអញ្ចឹង ?

- នរណាថាខ្ញុំមិនចង់រស់នៅស្រុករបស់ខ្លួននោះ ? ការពិត ខ្ញុំចង់ រស់នៅទីនេះណាស់ ព្រោះជាស្រុកកំណើតរបស់ខ្ញុំ ។ ប៉ុន្តែកូនមាន់ អើយ! មិត្តដឹងស្រាប់ហើយតើហ៍ ផ្ទះក៏អស់ ក្រុមគ្រួសារញាតិមិត្ត ក៏ស្លាប់គ្មានសល់ អ្វីក៏គ្មានសល់ដែរសំរាប់ខ្ញុំ តើអោយខ្ញុំទ្រាំបញ្ឈរ ភ្នែកមើលជីវិតដុនដាបរបស់ខ្លួនឯងយ៉ាងណា ? ពេលនេះ ស្រុក ទេសក៏កំពុងជ្រួលច្របល់ សាលារៀនក៏បិទដដែល ការងារក៏ គ្មានធ្វើ គ្រាប់កាំភ្លើងនៅផ្ទុះរាល់ថ្ងៃ ស្រុកទេសទុរ្ភិក្ស មិនដឹងថា អនាគតប្រទេសជាតិយើងនឹងក្លាយជាយ៉ាងណា ? ខ្ញុំចង់ទៅរៀន... ខ្ញុំចង់មានចំណេះ ខ្ញុំចង់ជួយខ្លួនឯងអោយរុងរឿង ប៉ុន្តែ ខ្ញុំមាន អារម្មណ៍ត្រមង់ត្រមោចកណ្តោចកណ្តែងណាស់... មិនដឹងថានឹងរក ច្រកចេញជួយខ្លួនឯងបែបណាទេ ទើបចេះតែធ្វើដំណើររសាត់ អណ្តែតតាមតែយថាកម្មអញ្ចឹងទៅ...

កូនមាន់ក្រញាស ស្តាប់មិត្តជ្រូកនិយាយបណ្តើរ ដុតដំឡូង បណ្តើរ ទំនងគិតពិចារណា ។ មួយស្របក់មក នាងក៏ស្រដីថា ៖

- ខ្ញុំក៏ចង់ត្រឡប់ចូលរៀនវិញដែរ បើសិនមានឱកាស ។ ពេល នេះ ខ្ញុំក៏មានតែម្នាក់ឯងដូចមិត្តជ្រូកអញ្ចឹង... ហើយក៏កំពុងគិតថា តើ ទៅអនាគត ខ្ញុំគួរមានគម្រោងជួយខ្លួនយ៉ាងណា ។ ពេលនេះ សង្គ្រាមនិងទុរ្ភិក្សកំពុងវាតទីពេញផ្ទៃខេត្របាត់ដំបង ។ ភាពជ្រួល ច្របល់កើតឡើងគ្រប់ទីកន្លែង ។ ម្នាក់ៗស្រវារកតែរស់រៀងៗខ្លួន គ្មាននរណាមានពេលគិតសំរាប់ថ្ងៃស្អែកទេ ។ សូម្បីតែរូបខ្ញុំក៏ហាក់ ដូចជាវិលវល់ដែរ មិនដឹងថាត្រូវធ្វើយ៉ាងណាទេទើបប្រសើរ ។

សន្ទនាមកដល់ត្រឹមនេះ អ្នកទាំងពីរក៏មានអារម្មណ៍សោកសៅ ជាអតិបរិមាន ។ បេះដូងរបស់គេក៏រណ្តំឡើង ដោយការឈឺចាប់ និងសោកស្តាយដែលគេបានបាត់បង់ឪពុកម្តាយ ក្រុមគ្រួសារនិងផ្ទះ សម្បែង ដូចគ្នា ។

CHANBOKEO.COM

កំពុងតែស្ថិតនៅក្នុងភាពស្ងៀមស្ងាត់ ស្រាប់តែអ្នកទាំងពីរឮ
សូរសម្រិបជើងមនុស្សមកដល់មុខខ្ទមទៀតហើយ ។

- អឺម្ចាស់ផ្ទះ! សុំទឹកទទួលទានបន្តិចបានទេ?

សម្លេងបុរសម្នាក់កូកហៅ ។ អ្នកទាំងពីរបែរទៅរក ក៏ប្រទះ
ឃើញបុរសក្មេងៗបីនាក់និងនារីមួយរូបដើរមកដល់ ។ មិត្តជ្រូក
ក្រឡេកឃើញពួកគេភ្លាមក៏ស្ទុះងើបឡើងទាំងឈើទាំងជា ទៅទទួល ពួកគេយ៉ាងលឿន ៖

- ខេង! ឆាល់! ត្រោក! ប្អូនផៃ?

គេស្រែកហៅអ្នកទាំងបួន ។ ស្រាប់តែទាំងអស់គ្នាលាន់មាត់ ព្រមតែម្តង ៖

- នាយជ្រូកលីវ?
- មែនហើយ! ហើយអ្នកទាំងអស់នាំគ្នាទៅណាដែរហ្នឹង?

ទាំងប្រាំនាក់រីករាយណាស់ដែលបានជួបគ្នាវិញ ។ គេរត់ទះស្មា គ្នាយ៉ាងរំភើប ។

- ពួកយើងកំពុងមានដំណើរទៅទល់ដែន! (នាយខេងតប)
- មែនហើយ!ខ្មែរក្រហមនៅចេញចូលច្រវាត់ច្រវែងពេញស្រុក ភូមិយើងឯបវិលនៅឡើយ
មិនអាចឲ្យយើងត្រឡប់ចូលភូមិបាន ទេ ។ ដំបូង ពួកយើងគិតថាទៅរកស៊ីនៅបាត់ដំបង
ប៉ុន្តែពីរខែ កន្លងមកនេះ យើងរកធ្វើអ្វីមិនសមប្រកបទេ គ្មានដើមទុន គ្មាន ផ្សារជួញដូរ
គ្មានការងារ គ្មានសាលារៀនបើក សង្គមស្ងៀមស្ងាត់ ណាស់
បន្ទាប់ពីមនុស្សម្នាជាច្រើនស្លាប់អស់ទៅ ។ ពេលនេះ យើងទាល់ច្រកពេក មិនដឹងថា
ត្រូវធ្វើម៉េចទៀត ទើបបបួលគ្នា
រត់ទៅទល់ដែន រត់ពន្ធតវាន់ចិញ្ចឹមជីវិត (នាយឆាល់ឆ្លើយបន្ត)
- រីឯខ្ញុំក៏ទាល់ច្រកដូចគ្នា ទើបនាំអូនផៃមកជាមួយ បំរុងថានឹងធ្វើ ដំណើរទៅជាយដែនដែរ
(នាយត្រោកបន្ទរ)
- ហើយចុះត្រោកឯងនិងផៃរៀបការនឹងគ្នាហើយឬនៅ?

នាយជ្រូកលីវ សួរ ។ ត្រោកឆ្លើយវិញថា ៖

- នៅទេ! បំរុងថានឹងចាប់ដៃរៀបគូជាគ្រួសារហើយ ទទួលផ្ទុះ សង្គ្រាមហើយ
ពួកខ្មែរក្រហមក៏បែកខ្ចាត់ខ្ចាយ បងប្អូនសាច់ញាតិក៏ រត់បែករប៉ាត់រប៉ាយអស់ទៅ
ទើបមិនបានរៀបចំអីនៅឡើយ ។

CHANBOKEO COM

- អញ្ជឹង ត្រោកនិងប្អូនផៃ គួរចាប់ដៃជាគូស្រករថ្ងៃនេះតែម្តងទៅ ចាំពួកយើងធ្វើជាមេបាអោយណា៎ (ជ្រូកលីវចំអន់)

ឮដូច្នោះ ត្រោកនិងផៃ សំដែងកិរិយាហាក់ដូចជាទឹករាយផង អៀនផង ។ ភ្លាមនោះ ពួកគេទាំងអស់គ្នាបែរភ្នែកមើលទៅនាង កូនមាន់ក្រញាសដែលកំពុងឈ្ងោកឌុតដំឡូង ។ នាយខេងយកដៃ កេះជ្រូកលីវ សួរខ្សិបៗថា ៖

- សង្សារឬប្រពន្ធហ្នឹង ? ឯងនៅជាមួយពួកយើង ជាកងចល័ត យុវជនរាប់ឆ្នាំមិនឃើញរកបានអីមួយសោះ គ្រាន់តែបែកពួកយើង ពីរបីអាទិត្យ ស្រាប់តែកញ្ឆក់បានមួយភ្លាម ស្រស់អីស្រស់ គួរឲ្យ ស្រឡាញ់ដល់ហើយ !
- តែផ្តាស ! គេមិនមែនជាសង្សារខ្ញុំទេ ។ ម្សិលមិញខ្ញុំត្រូវចោរ បាញ់របួស បាននាងជួយសង្គ្រោះទេតើហ៎ ! នេះសូម្បីតែឈ្មោះ របស់នាង ក៏ខ្ញុំមិនស្គាល់ផង ។ ប៉ុន្តែ ស្រស់យ៉ាងហ្នឹង បើបានធ្វើ សង្សារមែន គឺខ្ញុំច្បាស់ជាទឹកមុខប៉ុនជញ្ជាំងព្រះវិហារមិនខានឡើយ (ជ្រូកលីវឆ្លើយទាំងមានសំណើចកខឹកៗផង)
- នារីរូបស្រស់នោះនៅទំនេរមែនហ្អែស ? បើអញ្ជឹង មានន័យថា ខ្ញុំមានសិទ្ធិទាក់ទងនាងបាន មិនថាអញ្ជឹងហ៎្អែស ?(ខេងស្រដី)
- សាកមើលទៅ ក្រែងដុះ (ជ្រូកលីវញញឹម) តែខ្ញុំសុំផ្តាំថា នាង ដូចជាឆ្លាសបន្តិចហើយ ។ សូមប្រយត្ន័មើលមុខមើលក្រោយផង ណា៎ ក្រែងលោះត់មិនទាន់ ។

ភ្លាមនោះ ស្រាប់តែនាយឆាល់កេះ ប្រាប់បន្ថែមថា ៖

- មានឆាល់ម្នាក់ទៀត សុំដាក់ពាក្យចូលប្រកួតផង ប្រណាំងគ្នា សាកមើល ថាតើនរណាអាចយកឈ្នះជ័យលាភីទទួលបេះដូងរបស់ ធីតារូបស្រស់ម្នាក់នោះបាន ។

ទាំងអស់គ្នាក៏ញញឹមឡើង ស្រាប់តែនាងផៃលូកដៃកេះ ទាំងបី នាក់ ព្រមទាំងស្រដីថា ៖

- យ៉ាងណាៗ សុំបងៗរក្សាព្រំដែនថ្លៃថ្នូរអោយនារីផងណា៎ !
- ហើយប្អូនផៃឯង ឃើញបងៗជាមនុស្សយ៉ាប់ៗតាំងពីអង្កាល់ដែរ ហ្នឹង បានជាស្រដីបែបនេះ ? (ជ្រូកលីវឆ្លើយ)
- នរណាទៅដឹង ចិត្តបុរសៗនោះ ? (នាងផៃឆ្លើយ)
- បើមិនជឿ ចាំតែមើលទៅ ! ហើយបើឃើញបងដើរផ្លូវខុស ចាំ ប្អូនផៃជួញទាញដៃបំបែរផងណា៎ ! (នាយខេងបន្ទរ)

CHANBOKEO.COM

បន្តិចមក នាយជ្រូកលីវក៏ណែនាំមិត្តអោយស្គាល់នារីកូនមាន់ ក្រញាស ។ ទាំងអស់គ្នាភ្ញាក់ផ្អើលណាស់ កាលបើមាណវីទទួលខ្លួន ថាមានឈ្មោះដូច្នោះ ព្រោះអីជាឈ្មោះចម្លែក ដែលគេមិនដែលឮ នរណាមានឈ្មោះដូចហ្នឹងពីមុនមក ។

មួយសន្ទុះធំក្រោយមក ពួកគេក៏រៀបរបចេញដំណើរបន្តទៅ ទៀត ។

- ទៅជាមួយគ្នាទេ ជ្រូកលីវ ? (នាយឆាល់សួរ)

មាណពឮហើយ ក៏បែរមើលទៅកូនមាន់ក្រញាស ទំនងគិត បន្តិចមក ក៏សួរនារីថា ៖

- កូនមាន់! តើខ្ញុំគួរទៅជាមួយពួកគេ ឬមិនគួរ ?

មាណវីភ្ញាក់ព្រើត ឆ្លើយរឹងថា ៖

- ខ្ញុំមិនដឹងទេ មិត្តជ្រូកអើយ! ពេលនេះ មិត្តបានជួបគ្នីគ្នាហើយ គួរតែវិលទៅរស់នៅជុំគ្នាវិញទៅ ធ្វើដំណើរមានគ្នីគ្នាដូច្នេះកក់ក្ដៅ ផង ព្រោះមានគេជួយមើលថែរក្សារបួសមិត្តតាមផ្លូវផង ។

- ហើយចុះកូនមាន់វិញនោះ ?

- ខ្ញុំមិនទាន់ដឹងទេ! គិតថា ចង់ធ្វើដំណើរទៅរកម្ដាយធំដែលរស់ នៅឯបាត់ដំបង ។

- ចុះឧបមាថា រកគាត់មិនឃើញ តើកូនមាន់គិតយ៉ាងណា ?

- មានគិតយ៉ាងណា ? រស់តាមតែដំណើរអញ្ចឹងទៅណ៎ា!

កូនមាន់នឹកចម្លែកចិត្តដែលមាណពសួរនាងមិនអស់មិនហើយ.. រំពេចនោះ ជ្រូកលីវសួរនាងទៀតហើយ ៖

- ចុះបើខ្ញុំបបួលកូនមាន់ទៅទល់ដែនជាមួយពួកយើងដែរ តើមិត្ត គិតយ៉ាងណាដែរ ?

កូនមាន់ក្រញាសបែរសម្លឹងមុខគ្រប់ៗគ្នា មួយស្របក់ក៏ឆ្លើយ វិញថា ៖

- សូមទោសណ៎ា! ខ្ញុំមិនអាចទៅបានទេ! ខ្ញុំចង់ស្វែងរកម្ដាយធំ របស់ខ្ញុំសិន ។ ថ្វីបើខ្ញុំលែងមានឪពុកម្ដាយបងប្អូន ប៉ុន្តែម្ដាយធំជា សាច់ញាតិតែម្នាក់គត់ដែលនៅសល់ ហើយគាត់ក៏គ្មានកូនចៅឯណា ដែរ ។ បើសិនខ្ញុំអាចរកគាត់ឃើញ នោះយើងមិនរស់តែលតោល ទៀតឡើយ ។ អរគុណមិត្តជ្រូក និងមិត្តទាំងអស់គ្នាដែលមា ចិត្ត បបួលខ្ញុំពេលនេះ! សូមអ្នកទាំងអស់ធ្វើដំណើរទៅ អោយបានសុខ សប្បាយ ។

CHANBOKEO.COM

ទាំងអស់គ្នាក៏លានារីចេញទៅ ។ នាយជ្រូកលីវយើងក៏លើកដៃបក់បោយលានាងកូនមាន់ក្រញាស ដើរចេញទៅតាមពីក្រោយមិត្ត របស់គេទាំងបួននាក់ ។ យូរៗម្តង គេលួចបែរក្រោយសម្លឹងមើល នារីយើងមិនអស់មិនហើយ ។

ចំណែកកូនមាន់វិញ ក៏មានអារម្មណ៍ហេងហោងក្នុងខ្លួនយ៉ាង ណាមិនដឹង ដែលពួកគេធ្វើដំណើរចេញទៅ ទុកចោលនូវភាព ស្ងាត់ជ្រងំជុំវិញបរិវេណទីខ្ទមដែលនាងស្នាក់នៅ ធ្វើឲ្យនារីរន្ធត់ចិត្ត លួចរលីងរលោងទឹកភ្នែកតែម្នាក់ឯង ដោយសេចក្តីអណោចអធម្ម កណ្តោចកណ្តែងក្នុងឱរា ។

ooooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី៣
# ទឹកចិត្ត

ថ្ងៃត្រង់ហើយ...

នៅខាងក្នុងខ្ទមកញ្ជាស់ទ្រុឌទ្រោម...

កូនមាន់ក្រញាសអង្គុយផ្ទែកខ្នងនឹងបំពង់ឫស្សីសសរខ្ទម ភ្នែកវិញសម្លឹងទៅដំបូលស្លឹកត្នោតដែលចាស់ធ្លុះធ្លាយ ទម្លាយអារម្មណ៍ទៅតាមប្រហោងដំបូលទៅលើមេឃ ទំនងស្រែកយំហៅព្រលឹង ឪពុកម្ដាយឲ្យមកថ្នាក់ថ្នមលួងលោមចិត្តរបស់នារីដែលកំពុងតែ កំព្រារងា... មែនហើយ! ពេលនេះនាងនៅតែម្នាក់ឯង ក្នុងខ្ទម កញ្ជាស់ស្ងាត់ជ្រងំ ជុំវិញខ្ទមសុទ្ធតែស្មៅដុះលិចត្រឹមក ។ ដើម ចេកដើមល្ហុងកៀនខ្ទម ក៏ប្រឹងងកកដុះទាំងបង្ខំ ព្រោះត្រូវស្មៅដុះ ទន្ទ្រានជាន់លិចស្ទើរបាត់អស់ ។ សូម្បីតែពេលនោះជារដូវវស្សា ហើយក៏ដោយ ក៏ទិដ្ឋភាពដែលនារីឃើញជុំវិញខ្លួន សុទ្ធតែក្រៀមក្រំឥតន័យគ្រប់យ៉ាងទាំងអស់ រួមទាំងបេះដូងរបស់នារីផង ។

ការពិត នាងមានកំណើតជាអ្នកបាត់ដំបង ថែដន្យក្រុមគ្រួសារបាននាំគ្នាធ្វើដំណើរបំរុងទៅលេងអារញ្ញពេលចូលឆ្នាំ ទទួលស្រុកទេសមិនស្រួលក៏នាំគ្នាធ្វើដំណើរបកមកផ្ទះវិញ ហើយក៏ត្រូវខ្មែរក្រហមឃាត់ជាប់នៅម្ដុំកូបនិមិត្តនៅខែមេសា១៩៧៥នោះតែម្ដង ។ ក្រោយមកឪពុកម្ដាយរបស់នាងបានត្រូវពួកអង្គការខ្មែរក្រហម អូសយកទៅសម្លាប់ទាំងពីរនាក់ដោយមិនដឹងមូលហេតុ ។ ឯប្អូន ពីរនាក់ទៀត ក៏ត្រូវស្លាប់ដោយសារអត់បាយនៅសល់តែនាងម្នាក់ ឯងដែលរត់គេចរួចជីវិតរហូតដល់សព្វថ្ងៃនេះ ។

CHANBOKEO.COM

កំពុងតែលង់ក្នុងការស្រម័យទៅដល់អតីតកាល ធីតាយើងបាន ឮសម្រិបជើងមនុស្សដើរចូលមករកខ្ទមនាងទៀតហើយ ចៃដន្យ ពេលនេះ នាងបែរជាមានអារម្មណ៍ថាអស់កម្លាំង អស់ទឹកចិត្តនឹង រាក់ទាក់ជាមួយនរណាហើយ ។ ថ្វីបើនាងបានបរិភោគដំឡូងដុតពី ព្រឹកមកខ្លះហើយ ក៏នាងនៅមានអារម្មណ៍ថា រសេះរសោះដៃជើង ក្រៃលែង លែងមានចិត្តចង់ឃើញមុខនរណារលើង ។ នាងអង្គុយ ផ្អែកសសរធ្វើធ្មឹងមិននិយាយស្តី ។ ស្រាប់តែនាងឮសម្លេងមនុស្ស ប្រុសពីរនាក់និយាយភាសាចម្លែក ស្តាប់មិនបានសោះ ។ ម្តងនេះ នារីភ្ញាក់ព្រើត បើកភ្នែកប្រឹងស្មារតីវិលមកពិភពលោកជុំវិញខ្លួននា បច្ចុប្បន្នវិញ ស្រាប់តែប្រទះបុរសពីរនាក់ក្នុងឯក សណ្ឋានទាហាន ដើរស្ពាយកាំភ្លើងដើរចូលដុប ទំនងរកកន្លែង ដើម្បីដោះទុក្ខសត្វ ។ នាងក៏នឹកភ័យភើតពោះតែម្តង ខ្លាចពួកគេមកធ្វើបាប ក៏ប្រឹងអត់ ដង្ហើមនៅស្ងៀមឡើងបែកញើសស្រាក់ៗ ។ បន្តិចមក បុរសពីររូប នោះក៏ដើរចេញទៅវិញ ទំនងមិនបានចាប់ភ្លឹកនឹងវត្តមានរបស់នារី យើងទេ ។ នាងក៏ដកដង្ហើមយូបន្ធូរចោលនូវក្តីភិតភ័យក្នុងឱរា ។

បន្ទាប់ពីប្រមូលស្មារតីបានមកហើយ មាណវីក៏ងើបឈរឡើង បំរុងនឹងដើរចេញពីខ្ទម ធ្វើដំណើរបន្តទៅទៀត ស្រាប់តែវាក់អើ នឹងទាហានពីររូបដដែលនោះ នៅឈរជ្រងោពាំងផ្លូវ មិនអោយ នាងដើរចេញទៅ ។ នារីភ័យភើតប្រហោងពោះធ្លុងតែម្តង កាល បើបានឃើញវត្តមានពួកគេទាំងពីរនោះសាជាថ្មី ។

ភ្លាមនោះ នាយម្នាក់ស្រដីឡើងដាក់នាងជាភាសាបរទេស តែ ធិតាស្តាប់មិនយល់ទេ ។ រីឯម្នាក់ទៀតក៏ស្រដីបន្ថែមមួយរ៉ាវយ៉ាង វែងបន្ថែម ។ នាងក៏នៅតែស្តាប់មិនបានដដែល មិនដឹងថាគេ ចង់និយាយប្រាប់នាងឬសួរនាង ថាម៉េចឡើយ ។

ដោយក្តីភិតភ័យ នារីយើងក៏ដកជើងថយក្រាកៗ ចូលទៅក្នុង ខ្ទមវិញ ។ ទាហានពីរនាក់នោះក៏ដើរតាមពីក្រោយ ស្រែកសម្លុត ស្មារតីនារីខ្លាំងៗ តែនាងមិនព្រមបញ្ឈប់កំស្ទួលជើងរត់ទេ បែរជា បន្ថែមល្បឿនលើសដើម ចេញពីខ្ទមតាមទ្វារចំហៀង សំដៅទៅ ព្រៃចំការដែលមានស្មៅដុះទ្រប់ទ្រុល ។ ទាហានម្នាក់ក៏ស្រែកគំហក គម្រាមម្តងទៀត តែនារីនៅតែរត់មិនបង្អង់ជើងដដែល ។

ផាំង! ទាហាននោះបាញ់សម្លុតនារី ។ កូនមាន់ក្រញាសដួល ប្រួសទៅដី មិនមែនដោយសាររបួសទេ តែដោយសារការភិតភ័យ តក់ស្លុតតក្កមា ។ រំពេចនោះ

CHANBOKEO.COM

ពួកគេក៏ស្ទុះមកទាន់ ចាប់ដៃនារីបាន ទះកំភ្លៀងនាងវិលខ្វាល់ ថែមទាំងគំហកអោយជាច្រើនម៉ាត់ទៀត យ៉ាងខ្ញ័រខ្ញារ ។ កាលបើគេប្រើកម្លាំងបាយ និងកម្លាំងគ្រាប់កាំភ្លើង ដូច្នោះ តើនរណាមួយមិនតក់ស្លុតស្មារតីនោះ ? មាណវីលើកដៃជូត ឈាមដែលហូររឹមៗពីច្រមុះ ហើយលើកដៃសំពះឡើង អង្វរយ៉ាង គ្រលួច ៖

- លែងខ្ញុំទៅ ! កុំធ្វើបាបខ្ញុំអី !... លែងខ្ញុំណា៎ !

ប៉ុន្តែ នៅកណ្តាលចំការដ៏ស្ងាត់ មានតែស្មៅស៊ុបទ្រុប និងដើម ចេកដើមល្ហុងដែលដុះទ្រុឌទ្រោម តើមាននរណាអាចមើលឃើញ នឹងស្ទុះមកជួយនាងបានទៅ ? ទីបំផុត នាងត្រូវតែរើបម្រះយ៉ាង អស់ទំហឹង ដើម្បីការពារជីវិត និងសុវត្ថិភាពរបស់នាង ។

ផាំង ! ផាំង ! ក្អឹក ! ទាហានម្នាក់ទះកំភ្លៀងនាងផង ទាត់ នាងផងទាំងកំរោលដែលគេខឹងព្រោះនាងរើបម្រះ ។ ភ្លាមនោះ ស្រាប់តែពួកវាទម្លាក់កាំភ្លើងចោល ហើយស្ទុះមកស្រវាបោចអាវ បោចសំពត់របស់នាងចេញពីខ្លួន ។ ដោយខោអាវនោះចាស់រុំរោយ បំណះស្រាប់ផង គេមិនបាច់ប្រើកម្លាំងច្រើនទេ វាក៏រហែកចេញ មកយ៉ាងងាយ បណ្តាលអោយកេរ្តិ៍ខ្មាសនារីអណ្តែតលេចធ្លោឡើង មក ប្រឡេងកែវភ្នែកពួកគេ បង្កជាអារម្មណ៍អោយពួកគេរិតតែ ស្រើបស្រាលទ្រាំលែងបានតែម្តង ។

នារីយើងស្រែកផង រើបម្រះផង យ៉ាងពេញទំហឹង ដង្ហោយ ហៅរកដួងព្រលឹងឪពុកម្តាយរបស់នាងអោយមកជួយ យ៉ាងគ្រលួច កាត់ផ្ទៃចំការ ។

ផ្ទូង ! ផ្ទូង ! ផាំង !

សូរកាំភ្លើងផ្ទុះឡើងពីរបីគ្រាប់ជាប់ៗគ្នា ។ មាណវីងើបមុខ ឡើង ឃើញទាហានទាំងពីរនាក់ព្រលែងដៃពីនាង ដួលត្បោលៗ ទៅខាងៗ ឆ្វារពោះចង្ក្រង ដង្ហក់ខ្យល់ដកចង្កាមាន់ បាញ់ឈាម ចេញពីមាត់ព្រលៗ ។ ធីតាស្ទុះងើបឡើង ស្រវារកសំពត់ដាច របស់នាងមកបិទបាំងកេរ្តិ៍ខ្មាសយ៉ាងរហ័ស ទាំងភិតភ័យផង ខ្មាស អៀនផង ត្បិតមិនដឹងថា អ្នកដែលកំពុងមកជួយសង្គ្រោះនាងនោះ ជានរណាទេ ។ ពេលនេះនាងមានអារម្មណ៍ ច្របូកច្របល់តក់ស្លុត ជាទីបំផុត ។ ទឹកភ្នែកក៏ហូរស្រក់ចុះមកដោយឯកឯង ។ កំពុងតែ ឈ្លោកមុខអាមាសនឹងភាពអាក្រាតរបស់ខ្លួន ឡើងញ័រដៃញ័រជើង ស្រាប់តែធីតាចាប់ភ្លឹកថា មានមនុស្សម្នាក់បានមកដល់ ទម្លាក់ក្រមា មកដណ្តប់រុំខ្លួនអោយនាង

CHANBOKEO.COM

ហើយបោះអាវចាស់មួយទៀតមកអោយ រួចគេក៏គេចចេញទៅវិញយ៉ាងលឿន ។ មាណវីភ្ញាក់ព្រើត ពេល បានទទួលក្រមានោះ ព្រោះចំណាំបានថា នោះជាក្រមាចាស់របស់ នាង ដែលដោះរុំរបួសអោយបុរសម្នាក់កាលពីម្សិលមិញ ។

- នាយជ្រូកភ្នែកលិប ?

និតាឧទានខ្សិបៗក្នុងមាត់តែម្នាក់ឯង ត្រេកអរផង ខ្មាសផង និយាយមិនរួច បានត្រឹមតែទឹកភ្នែករលីងរលោង ។ លុះស្រវាបាន ក្រមារុំខ្លួនត្រឹមត្រូវវិញរួចហើយ នាងក៏ទាញអាវដែលបុរសទុក អោយនោះមកដណ្តប់ថែមពីលើខ្លួនទៀត ទើបស្ទុះដើបចេញទៅ ទាំងញ័រជង្គង់ទទ្រើកដោយភាពតក់ស្លុតនៅក្នុងចិត្ត ។ នៅក្បែរខ្ទម នារីយើងឃើញបុរសយើងអង្គុយ នៅលើដង្គត់ឈើមួយ បែរខ្នង មករកនាង ។ កាលបើឮសូរិបជើងដើរចូលមកដល់ គេក៏ស្រដី តិចៗឡើងថា ៖

- កូនមាន់... ខ្ញុំសោកស្តាយណាស់ ដែលខ្ញុំមិនបាននៅរក្សានាង ដូចនាងធ្លាប់បានរក្សាខ្ញុំ...!

កូនមាន់ក្រញាសយកដៃជូតទឹកភ្នែក ហើយស្រដីទាំងញាប់ញ័រ តបទៅវិញថា ៖

- កុំនឹកសោកស្តាយក្នុងចិត្តធ្វើអី ? អ្វីៗមិនមែនជាកំហុសមិត្ត ជ្រូកទេ ។ ម្តេចក៏បន្ទោសខ្លួនឯងអញ្ចឹង ? វាជាគ្រោះថ្នាក់តើហ៎...!

នាយជ្រូកឈ្ងោកមុខ ហើយសួរខ្សិបៗថា ៖

- កូនមាន់... មិនទទួលគ្រោះថ្នាក់ធ្ងន់ធ្ងរទេ មែនទេ ?
- គឺ... សំណាងល្អណាស់ ដែលមិត្តជ្រូកមកទាន់ពេល...
- មើលទៅទីនេះ គ្មានសុវត្ថិភាពសំរាប់កូនមាន់ទៀតទេ ប្រហែល ជាត្រូវចាកចេញពីទីនេះបណ្តោះអាសន្នហើយ ក្រែងមានពួកគេមក តាមសងសឹក ។
- ប៉ុន្តែ ខ្ញុំ...

នារីទុចង៉ក់ មិនហ៊ានស្តី ព្រោះពេលនេះ នាងមិនមានសម្លៀក បំពាក់ត្រឹមត្រូវនឹងចេញធ្វើដំណើរទៅណាបានឡើយ ។ ភ្លាមនោះ បុរសយើងស្រដីឡើង ទំនងយល់ពីអារម្មណ៍របស់នាង ៖

- បើកូនមាន់មិនប្រកាន់ទេ នាងស្លៀកខោរបស់ខ្ញុំសិនទៅ ចាំទៅ ដល់ភូមិអ្នកស្រុកខាងមុខ ចាំយើងដោះស្រាយតាមដំណើរទៀត ។

ជ្រូកលីវក៏ដោះខោបោះអោយកូនមាន់ស្លៀក រួចហើយក៏ទៅ បោចសម្បារចេកយកមកវេញជាខ្សែ ឲ្យនារីក្រវាត់ចងចង្កេះខោ

CHANBOKEO.COM

ព្រោះខោនោះរលុងហើយជើងស៊ុលយុលបន្តិច ។ ដោយសភាព ទាល់ច្រក កូនមាន់ក្រញាសក៏ជូតទឹកភ្នែក លូកដៃទទួលយកខោ របស់ជ្រូកលីវមកស្លៀកបិទបាំងកាយរបស់នាង ។

បន្តិចមក កូនមាន់ក៏ម្ងូរជើងខោឡើង ដើរចេញពីខ្ទម ក៏ប្រទះ ឃើញជ្រូកលីវនៅសល់តែខោខ្លីមួយកំណាត់ភ្លៅ លែងខ្លួនទទេ ។ នាងក៏ហុចក្រមារបស់នាងអោយទៅនរៈវិញ ៖

- មិត្តជ្រូក យកក្រមានេះរុំខ្លួនសិនទៅ! កុំលែងខ្លួនទទេ ប្រយត្ន័ ផ្តាសាយ ព្រោះមានរបួសលើខ្លួនមិនទាន់ជាផង ហើយខែនេះសំបូរ ភ្លៀងណាស់ទៀតផង ។

ជ្រូកលីវលូកដៃទទួលយកក្រមាវិញ កាលបើឮសំដីសមហេតុ សមផលរបស់កូនមាន់ ។ បន្តិចមកអ្នកទាំងពីរក៏ដើរចេញពីខ្ទម ។ - មិត្តនាំខ្ញុំទៅណាហ្នឹង ?

- ក្រែងកូនមាន់ចង់ទៅបាត់ដំបង មិនមែនទេ ?

កូនមាន់ក្រញាសឈ្ងោកមុខ នឹកទៅដល់រឿងហេតុអំបាញមិញ មុននេះ ដែលធ្វើអោយនាងតក់ស្លុតញ័រដៃញ័រជើងមិនទាន់បាត់នៅ ឡើយ ។ នាងក៏សួរទៅជ្រូកលីវថា ៖

- មិត្តដឹងទេ ថាពួកទាហានបែបនោះនៅសល់តាមផ្លូវទៀតទេ ?

- ប្រហែលជាមិនអត់ទេ...

លុះក្រឡេកឃើញភាពតក់ស្លុតអណ្តែតមកលើផ្ទៃមុខនារី ជ្រូក លីវក៏និយាយកម្លាបន្ថែមថា ៖

- តែបើយើងធ្វើដំណើរមានគ្នីគ្នា ប្រហែលជាពួកគេមិនហ៊ានឆ្លៀត ឱកាសធ្វើផ្តេសផ្តាសអញ្ចឹង ទេដឹង ?

កូនមាន់ក្រញាសដើរឈ្ងោកៗ យឺតៗ ទំនងគិត ។ បន្តិចមក នារីក៏សួរទៀតថា ៖

- មិត្តជ្រូក! ព្រឹកមិញនឹកឃើញយ៉ាងម៉េចបានជាចេញទៅហើយ ត្រឡប់មករកខ្ញុំវិញ ?

- គឺ... មកពីខ្ញុំចង់យកក្រមាដែលនាងរុំរបួសអោយនោះមកសង វិញ ក្រែងកូនមាន់ត្រូវការប្រើ ។

- តែប៉ុនហ្នឹងទេហ៏ ?

- បា៎ទ! (មាណពឯកក្បាល)

- អរគុណណាស់ដែលត្រឡប់មកវិញ... កុំអី...

នារីយើងទុចដ៏ក់ ដោយក្តីរន្ធត់ញាប់ញ័រ ។

- កុំរំលឹកទៀតអី! (ជ្រូកលីវស្រដីកាត់) យើងនិយាយគ្នាពីរឿង ទៅមុខទៀតវិញ ។

CHANBOKEO.COM

មាណវីញញឹមឡើង កាលបើដឹងថា មាណពយល់ទុក្ខធុរៈក្នុង ចិត្តរបស់នាង ។ តាមការពិត ជ្រូកលីវយកក្រមាមកសងនាងវិញ នោះគ្រាន់តែជាលេសទេ ។ ព្រឹកមិញនេះ គ្រាន់តែគេបែកចេញពី នារីទៅ មាណពក៏កើតការពិភាល់ក្នុងចិត្ត នៅមិនសុខ ចេះតែចង់ត្រឡប់ក្រោយ មករកកូនមាន់ក្រញាស ។ បន្ទាប់មក គេក៏សុំបែក ផ្លូវពីមិត្តភក្តិ ធ្វើដំណើរត្រឡប់ក្រោយវិញមែន ។ លុះគេដើរមក ដល់ខ្ទមចាស់នោះ ក៏ឮសូរសម្រែកនារីហៅរកមនុស្សជួយ ។ បុរស ក៏ហក់រឹងទៅ ឃើញនារីស្ថិតនៅក្រោមចង្កូមខ្លាពីរក្បាល ទើប ស្រវាទាញកាំភ្លើងដែលទាហានចម្លែកពីរនាក់នោះ បោះចោលក្នុង ស្មៅលើកឡើងបាញ់ផ្ទងៗភ្លាម ព្រោះគ្មានពេលគិតច្រើន ។ បន្ទាប់ មក គេក៏គេចខ្លួនចេញមកវិញ ដើម្បីអោយកូនមាន់បានស្លៀកពាក់ ដណ្តប់ខ្លួនអោយត្រឹមត្រូវវិញ ។

- មិតជ្រូក! ខ្ញុំគិតថា ខ្ញុំចង់ដូរចិត្ត! (កូនមាន់និយាយ)
- ដូរចិត្តយ៉ាងម៉េចវិញអញ្ចឹង ?
- គឺខ្ញុំលែងចង់ធ្វើដំណើរទៅបាត់ដំបងទៀតហើយ ព្រោះខ្លាចជួប ពពួកទាហានបែបនោះតាមផ្លូវជាថ្មីទៀត ។
- ចៀសមិនរួចទេ បែរទៅទិសណាក៏មានទាហានដែរ មានពីរបី ម៉ូដឯណោះ ។ ម៉ូដខ្មៅ ម៉ូដបៃតង ម៉ូដក្រឡេក្រឡា.. និងម៉ូដចោរ ព្រៃ គេចទៅណាក៏មិនរួចខ្លួនដែរ ។

ថៃដន្យ ផ្លូវដែលអ្នកទាំងពីរកំពុងដើរមានសភាពស្ងាត់ជ្រងំ ។ តាមផ្លូវមានសាកសពសពដេកស្តូកស្តឹងរាយប៉ាយ ខ្លះស្លាប់យូរ ខ្លះ ទៀត ទើបតែស្លាប់ថ្មីៗ មិនដឹងថាសាកសពទាំងនោះជាមនុស្សរង គ្រោះដោយចោរប្លន់ឬដោយប្រការណាទៀតទេ ។ នឹកចុះនឹកឡើង មិនអស់ចិត្ត កូនមាន់ក្រញាសក៏ទុចដំណើរ សួរជ្រូកលីវថា ៖

- មិត្តជ្រូក ពីអូរស្វួតទៅបាត់ដំបង និងពីអូរស្វួតទៅសេរីសោភ័ណ ផ្លូវណាជិតជាង ?
- ទៅសេរីសោភ័ណប្រហែលឆាប់ដល់ជាង ។
- បើអញ្ចឹង យើងទៅសេរីសោភ័ណវិញ ។
- មានរឿងអីហ្នែស កូនមាន់ បានដូរចិត្ត ?
- គឺ... ខ្ញុំខ្លាច... ឃើញសាកសពតាមផ្លូវច្រើនយ៉ាងនេះ មានចាស់ មានថ្មីៗ មានន័យថា ផ្លូវនេះពុំមានសុវត្ថិភាពទេ ។
- ផ្លូវទៅសេរីសោភ័ណក៏មានសាកសពតាមផ្លូវដូចគ្នាដែរ ។

CHANBOKEO . COM

កូនមាន់ក្រញាសយកដៃឈ្លីថ្ងាស ។

- ហ៊ឺ! ខ្ញុំមានអារម្មណ៍ដូចជាមិនស្រួលខ្លួនសោះ ។

- បើអញ្ចឹងយើងដើរត្រឡប់ក្រោយទៅអូរស្គួតវិញទៅ ។

ភ្លាមនោះ អ្នកទាំងពីរក៏នាំគ្នាដើរបកក្រោយវិញ ។ លុះដើរផុត អូរស្គួតបន្តិច ក៏ព្រលប់ល្មម ។ យប់នោះ គេបានរត់ចូលទៅ ជ្រកនៅក្រោលគោរបស់អ្នកស្រុកម្នាក់បណ្ដោះអាសន្ន ត្បិតមានភ្លៀងធ្លាក់ស្រិចៗផង ។ កំពុងតែអង្គុយផ្អែកបង្គោលចងគោទល់ ខ្នងគ្នា ស្រាប់តែម្ចាស់ផ្ទះអុជចន្លុះ ដើរចេញពីផ្ទះ ស្រែកសួរថា ៖

- នរណាគេហ្នឹង ?

កូនមាន់ដើបឡើងយ៉ាងរហ័ស ឆ្លើយថា ៖

- គឺ...ខ្ញុំជាអ្នកដំណើរ ចូលជ្រកភ្លៀង ចាស!

- អូហ៍ ហេតុអ្វីទៅចូលក្រោលគោទៅវិញ ? កន្លែងនោះមិន ស្អាតទេ ។ មក៎! ចូលមកក្រោមផ្ទះសិនមក ចៅ!

តាចាស់មួយរូបយកចន្លុះឈ្មួលផ្លូវ ឲ្យអ្នកទាំងពីរដើរចូលទៅ ក្រោមផ្ទះដ៏តូចរបស់គាត់ ។ នៅទីនោះមានគ្រែរនាបឫស្សីមួយ ។

- សំណាក់ត្រង់ហ្នឹងសិនទៅណ៎ាចៅអើយ ។

តាចាស់បានយកខ្នើយចាស់មួយមកហុចអោយ ។

- តាយាយក្រណាស់ គ្មានអ្វីប្រើទេ ។ នេះជាខ្នើយរបស់ប្រពន្ធតា ចែកអោយចៅទាំងពីរប្រើម៉ាយប់សិន ។

កូនមាន់និងជ្រូកលីវមើលមុខគ្នា ព្រោះតាចាស់ច្រឡំស្មានថា អ្នកទាំងពីរជាប្ដីប្រពន្ធនឹងគ្នា ។ បន្ទាប់មក តាចាស់ក៏ឡើងទៅ សំរាន្ត ឯខាងលើផ្ទះបាត់ទៅ ។

ពេលនោះ ជ្រូកលីវគិតក្នុងចិត្តម្នាក់ឯងថា ៖

- ថ្វីបើខ្មែរក្រហមបំផ្លាញជីវិតខ្មែរមែនតែមិនអាចបំផ្លាញទឹកចិត្ត សប្បុរសធម៌ដែលខ្មែរធ្លាប់មានចំពោះគ្នានោះទេ... មើលតែទឹកចិត្ត សប្បុរសរបស់លោកតាមួយរូបនេះចុះ គាត់មិនបានទទួលឥទ្ធិពល ផ្ដាច់សរសៃឈាមរបស់របបក្រហមអ្វីបន្តិចឡើយ ។

...................................

CHANBOKEO.COM

យប់ជ្រៅបន្តិចហើយ...

សៀងចង្រិតយំច្រិចៗ ឆ្លើយឆ្លងនឹងសម្លេងកំភ្លើងធំ លាន់ឮ មកពីទីសខាងលិចល្ងើយៗ... កូនមាន់នៅអង្គុយសំកុកមិនព្រម ទំរេតខ្លួន ព្រោះមិនចង់គេងលើគ្រែជាមួយគ្នានឹងជ្រូកលីវ ។

- កូនមាន់! នាងគេងលើខ្នើយនេះទៅ សំរាកយកកម្លាំងនឹងអាល គិតពីដំណើរព្រឹកស្អែកទៀត ។

ជ្រូកលីវស្រដីហើយក៏ផ្ដេកខ្លួនធ្មេចគេងនៅម្ខាង ។ មួយសន្ទុះ ក៏បែរមកវិញ ឃើញកូនមាន់នៅតែអង្គុយសំកុកដដែល ។ គេក៏ និយាយបញ្ឆោះបន្សោកថា ៖

- កូនមាន់! ស្មគ្រែអង្គុយយាមខ្ញុំដល់ភ្លឺមែនទេ? បើដូច្នេះ ខ្ញុំសុំ យកខ្នើយនេះកើយហើយណា៎!

ថាហើយជ្រូកលីវក៏លូកដៃទៅទាញខ្នើយ ស្រាប់តែ ផាច់! កូន មាន់យកដៃនាងទះដៃជ្រូកលីវ ៖

- នរណាថាខ្ញុំអង្គុយសំកុកយាមជ្រូកនោះ? ឆាប់ដកដៃចេញភ្លាម!

រួចហើយ នាងក៏កញ្ឆក់យកខ្នើយមកដាក់គេងភ្លាមតែម្ដង ។ ឃើញកូនមាន់ចាញ់ល្បិចកល ជ្រូកលីវលួចញញឹមតែម្នាក់ឯង រួច ធ្វើពើជាលាន់មាត់ថា ៖

- បើបានជាគេងហើយ យ៉ាងណាៗកុំបែរមុខមកហិតក្លិនក្លៀកជ្រូក លីវភ្ញែកលិបទៅបានហើយណា៎!

- គ្មាននរណាគេចង់ហិតទេ ពុទ្ធោអើយ! កុំថាដល់គេងហិត សូម្បី តែអង្គុយមិនបាននឹកចង់ហិត ក៏ឈ្ងួលដល់ច្រមុះដែរ ឈ្លក់ម្ដងៗ ដេកសន្លប់ ថ្ងៃរះមិនដែលដឹង...

- អូហ៍ អញ្ចឹងតើហ៍ បានព្រឹកមិញគេងលង់លក់ រហូតជ្រូកលីវ លួចមើបអស់ពីរបីខ្សឺតហើយ អត់ឃើញមានដឹងខ្លួនអីបន្តិច!

- ព្រះអើយ? ថាម៉េចហ្នឹង? មិត្តជ្រូកប្រព្រឹត្តផ្ដេសផ្ដាសអញ្ចឹង មែនហ្អែស?

កូនមាន់ក្រញាសស្ទុះងើបឡើងយ៉ាងរហ័ស សួរជ្រូកលីវ ។

- អូយ៎! កុំភ្ញាក់ផ្អើលពេកមើល! ខ្ញុំនិយាយលេងទេ ។ មុខដូច កូនមាន់ក្រញាសអញ្ចឹង គ្មានត្រង់ណាអោយបេតីសោះលោកអើយ! ថែមលុយទៀត ក៏មិនមើបផង!

ផាច់! កូនមាន់យកដៃទះស្មាជ្រូកលីវ ដោយឃ្នាន់ខ្នាញ់ ដែល នាយលលេងនារីមិនឈប់សោះ ។

- អ៊ូយ! (ជ្រូកលីវលាន់មាត់)

កូនមាន់ភ្ញាក់ព្រើត ព្រោះវាយច្រឡំ មិនបានគិតដល់ស្នាមរបួស របស់នាយជ្រូកលីវ ៖

CHIANBOKEO.COM

- អ៊ូហ៍! សូមទោសណា៎ជ្រូកភ្នែកលិប! ខ្ញុំវាយលេង ច្រឡំប៉ះមុខ របួសលើស្មារបស់មិត្ត!
- នរណាថា ? មុខរបួសនៅស្មាឆ្វេង ហើយកូនមាន់វាយចំស្មាស្ដាំ ធ្វើម៉េចនឹងត្រូវមុខរបួសកើត ?
- ពុទ្ធោអើយ! យ៉ាប់មែន! (កូនមាន់លាន់មាត់) តិចខ្ញុំវាយថែម ទៀតអីលូវហ្នឹង!
-អ៊ូយ! ឈប់! អោយខ្ញុំសុំអង្វរទៅចុះណា៎!

យើញជ្រូកលីវចុះចាញ់ កូនមាន់ក៏ប្រាសខ្លួនលើខ្នើយ បែរមុខ ចេញ សម្ងំស្ងៀមស្ងាត់ ឈប់និយាយរកនរៈយើងតទៅទៀត ។ បែរមកជ្រូកលីវវិញ គេលួចក្រឡួចមាត់គេងញញឹមតែម្នាក់ឯង ។ ថ្វីបើស្នាមរបួសលើស្មានៅរំខានរូបគេនៅឡើយ តែជ្រូកលីវបែរជា ភ្លេចការឈឺចាប់អស់រលីងទៅហើយ ព្រោះគេ... អាល័យតែចាប់អារម្មណ៍លើនារីយើងជាអតិបរមា រកថាមិនត្រូវទាល់តែសោះ...
- តើខ្ញុំមានវាសនាបានគេងជិតនាងរហូតមួយជីវិតទេហ្ន៎ ?

ជ្រូកលីវលួចគិតវង្វេងតែម្នាក់ឯង រហូតលង់លក់ក្នុងរាត្រី...

ooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី៨
# ក្លោងទ្វារមរណៈ

សូរគ្រាប់កាំភ្លើងធំៗលាន់សូរគ្រឹមៗពីទិសខាងលិច រហូតដល់ ព្រហាមស្រាងៗថ្ងៃរះជាថ្មី...

កូនមាន់ប្រែខ្លួនឡើង បើកភ្នែក ស្រាប់តែឃើញជ្រូកលីវនៅអង្គុយចុងជើងសើចញឹមៗដាក់នាង ។

- នែ៎! មិត្តជ្រូកភ្នែកលិប! សើចញញឹមស្អីទាំងព្រឹក ? ភ្នែក តូចៗយ៉ាងនេះស្រាប់ផង ខំសើចអញ្ចឹង ប្រយត្ន័បាត់ភ្នែកអស់ រក មើលផ្លូវអ្វីលែងឃើញទៅ!

ស្រាប់តែគេឆ្លើយវិញយ៉ាងរហ័សថា ៖

- ជ្រូកលីវមិនភ័យទេព្រោះឥឡូវមានគ្នាពីរនាក់ហើយ ។ បើមើល ផ្លូវមិនឃើញ ទុកអោយកូនមាន់ភ្នែកមូលៗធំៗនោះ គេជួយមើល ផ្លូវ ហើយដឹកដៃជ្រូកទៅ រួចគ្នាស្រេច ។
- ជួយមិនបានទេ មិត្តជ្រូកអើយ! ភ្នែកអ្នកណា មើលផ្លូវអោយ អ្នកហ្នឹងហើយ!
- ពុទ្ធោអើយ! ចិត្តអាក្រក់យ៉ាងនេះ តិចឈប់ស្រឡាញ់ឥឡូវ!
- ហើយខ្ញុំជួលអោយជ្រូកឯងមកស្រឡាញ់កូនមាន់ពីអង្កាល់ ?
- បើមិនជួលទេ ហេតុអីកូនមាន់ខំយកចិត្តជ្រូកលីវ ?
- ពីអង្កាល់ ?
- គឺថ្ងៃមុនដែលចាប់ជ្រូករុំរបួសអោយហើយគេងយាមម៉ាយប់នោះ អី! លុះព្រឹកឡើងដុតដំឡូងអោយញាំទៀត យី! ចេះធ្វើពើមិនដឹង អី អញ្ចឹងកើត ?

CHANBOKEO.COM

- តែផ្កាស! កូនមាន់ធ្វើដូច្នេះព្រោះអាណិតឃើញរសាត់អណ្តែត ម្នាក់ឯងទេ
មិនបានលួចស្រឡាញ់អីបន្តិចសោះហើយ ។ ភ្នែកលិប យ៉ាងនេះ ទុកធ្វើក្រមុំស្រុកចិនទៅចុះណា៎!
ខ្ញុំអត់មានប្រចណ្ឌអី បន្តិចទេ ព្រលឹង!

ឮកូនមាន់និយាយឌឺដង ជ្រូកលីវអស់សំណើចកក្អឹកតែម្តង ។

រំពេចនោះ ស្រាប់តែតាយាយម្ចាស់ផ្ទះចុះពីលើផ្ទះមក ។

- ម៉េចហើយ ចៅៗទាំងពីរ! យប់មិញមូសធ្វើទុក្ខទេ?

- ចា៎ស! អត់ទេ តា!

តាយាយទាំងពីរនាក់សម្លឹងមុខអ្នកទាំងពីរ នឹកចម្លែកចិត្តព្រោះ
ឃើញគេពុំមានសម្លៀកបំពាក់សមរម្យ ។ ដូនចាស់ក៏ចែកអាវចាស់
មួយបន្លាស់ដល់កូនមាន់ក្រញាស ។

- ខ្ញុំមិនអី! មើលទៅយាយ ក៏ខ្វះខាតដែរ! (កូនមាន់ឆ្លើយ)

- យកមួយសំរាប់នេះទៅប្រើទៅ ចៅអើយ គ្រាន់បើជាជាងស្លៀក
ខោអាវមនុស្សប្រុសអោយគ្នាដើរខ្លួនទទេដែរណា៎! កុំប្រកែកអី!

មិនអោយអាក់សទ្ធា នារីក៏សុខចិត្តលូកដៃទទួលយកពីដូនចាស់ មកផ្លាស់ ។ បន្តិចមក
នាងក៏ដើបឡើង ស្ទុះទៅរកថាំងរែកទឹក ។

- ធ្វើអ្វីហ្នឹងចៅស្រី?

- គឺខ្ញុំរែកទឹកជូនយាយតាវិញ ព្រោះចៅគ្មានអ្វីសងគុណតាយាយ
ដែលចិត្តល្អចំពោះចៅយ៉ាងនេះទេ ។

ថាហើយ កូនមាន់ក៏ស្ទុះទៅរែកទឹកជូនតាយាយចាក់ពាងពីរបី នោះឡើងពេញដល់មាត់
រួចហើយក៏យកខោអាវរបស់ជ្រូកលីវបំរុង ទៅបោកគក់ ។

- ស្លាប់ហើយកូនមាន់! កុំបោកគក់ខ្លាំងពេករហែកខោអាវខ្ញុំអស់ ហើយ
កំពុងចាស់រេចស្រាប់ផង! ម៉ោះអោយមកខ្ញុំវិញមក!

- មិនបានទេ ខ្ញុំពាក់មួយថ្ងៃហើយ មានក្លិនមិនល្អទេ ។

- តែខ្ញុំមិនប្រកាន់ទេ អោយមកខ្ញុំវិញមក ។

នារីជ្រួញចិញ្ចើម ហើយគ្រវីក្បាល រួចហើយក៏បោកហាលថ្ងៃ អោយនាយវិញយ៉ាងស្អាត ។
កូនមាន់ឃើញតាយាយចាស់ៗនៅតែ ពីរនាក់ ក៏ជួយពុសច្រៀកអុសហាល
និងជួយជញ្ជូនអុសជាច្រើន គរទុកក្នុងផ្ទះបាយជូនគាត់ ព្រមទាំងឆាយចំបើងទុកអោយគោស៊ី

CHANBOKEO.COM

ទៀតផង ។ ជ្រូកលីវនៅមានរបួសស្នាម មិនទាន់ជាស្រួលបួល មិន
អាចធ្វើអ្វីបានក៏ជួយបោសសំអាតផ្ទះមួយស្របក់ រួចហើយទៅកំនរ
តាចាស់នោះបិតឫស្សីធ្វើលប ។ ទំរាំខោរអាវស្ងួត ថ្ងៃរះត្រង់ល្មម ។
អ្នកទាំងពីរក៏លាតាយាយធ្វើដំណើរបន្តទៅទៀត ។

- ជំរាបលា តា! ជំរាបលាយាយ!
- អឺ! ទៅអោយបានសុខសប្បាយណាំចៅ!

តាយាយជូនពរអ្នកទាំងពីរ ដែលជំរាបលាគាត់ ដើម្បីធ្វើដំណើរ បន្តទៅទៀត ។

តាមផ្លូវ ជ្រូកលីវលួចគយគន់កូនមាន់មិនដាក់ភ្នែកទេ ។

- នែ៎! សម្លឹងមុខអីទៀតហើយ ? មានអ្វីចម្លែក មែនទេ ?
- អូហ៍! អត់អីទេ! តែព្រឹកមិញ ខ្ញុំឃើញកូនមាន់បំរើតាយាយ
ស្មានថា ចង់សុំគាត់ធ្វើជាឪពុកម្តាយធម៌ហើយតើហ៍!
- មកពីឃើញគាត់ចាស់ៗ ហើយគ្មានកូនចៅនៅជិតនឹងបំរើគាត់ ទើបខ្ញុំជួយដៃជើងម៉ាភ្លែតទៅ!
យ៉ាងម៉េចមិនដែលឃើញក្មេងបំរើ ចាស់ៗទេឬអី ទើបឆ្ងល់ច្រើនម្លេះ ?
- មែនហើយ! ព្រោះក្មេងខ្លះប្រហែលនឹកមិនឃើញនឹងមានចិត្ត ជួយដៃជើងញាតិសន្តាន
ដូចកូនមាន់ឯងនេះទេ ។
- នែ៎! ចង់បន្លំថាអោយខ្ញុំជាកូនក្មេងផងហ្នែ៎ស ?
- អូហ៍! ហើយកូនមាន់ឯងពេញក្រមុំហើយហ្នឹង ? ចរិតដូចកូន ក្មេងបេះដាក់ ចាម៉ាម៉ាត់ទៅ
តបងប់ម៉ាត់ម៉ៅ មិនអោយខ្វះសោះ តើអោយហៅពេញក្រមុំយ៉ាងម៉េចកើត ?
- តែផ្តាស! និយាយអោយដឹងវ័យបន្តិចមើល៍!
- អញ្ចឹង បើពេញវ័យមែន ជ្រូកលីវសុំស្រឡាញ់ធ្វើសង្សារបានទេ កូនមាន់ ?
- ពុទ្ធោ! ហេតុអ្វីស្រវឹងទឹកមាត់ទាំងព្រឹកហ្នឹង មិត្តជ្រូកអើយ ?
សង្ស័យហូបបាយកកស្ករផែនរបស់តាយាយព្រឹកមិញរួចហើយពុល ស្ករផែនទេដឹងនេះ ?
នារីណាទៅលង់ស្នេហ៍បុរសភ្នែកអ៊ីវ បើក ភ្នែក ឫបិទភ្នែក មើលមិនដឹងថា មួយណាយ៉ាងនេះ ?
- កុំក្អេងក្អាងពេក តិចលោចថាថ្ងៃមួយ កូនមាន់លួចស្រឡាញ់ជ្រូក ភ្នែកលិប
គេងយំបីខែហើមភ្នែកលិបមុខអស់ដូចជ្រូកដែរទៅ!
- ម៉េចក៏គង់គ្រាន់ជាងអ្នកមកតាមសុំស្នេហ៍គេ គេមិនស្រឡាញ់វិញ
នោះទើបយ៉ាប់មើលមិនបាន ។

CHANBOKEO.COM

- យី! នរណាគេសុំស្នេហ៍នរណា ?
- គឺមិត្តជ្រូកសុំស្រឡាញ់កូនមាន់នោះអី ?
- ហ្ហ៎ស ? ថាម៉េច ? នរណាគេយ៉ាប់ម្លេះទៅសុំស្នេហ៍កូនមាន់ ? មើលចុះមុខមើលមិនបាន
ភ្នែកធំក្រឡោត សក់ក្រញាស ខ្មៅក៏ខ្មៅ ពុទ្ធោអើយ!
មកផ្ទៀបនឹងសាច់សស្គុសរបស់ជ្រូកលីវម្តេចបាន ? គ្រាន់តែគេនិយាយលេងសោះ
អីក៏ស៊ីជោរលឿនម៉េះ ? ព្រះអើយ! ម៉េចក៏មិនចេះខ្មាស់ជ្រូកលីវសោះអញ្ចឹង ?

ផាច់! កូនមាន់ខ្ចាញ់ពេក ក៏ទះកំភ្លួនដៃបុរសយើង ហើយដើរ យ៉ាងលឿនហួសទៅមុន ។
- នែ៎ កុំដើរចោលគ្នាមើល៍! (ជ្រូកលីវស្រែកពីក្រោយ)

មាណវីឮដូច្នោះក៏បង្អង់ជើងវិញ ។
- ពេលនេះ យើងគិតទៅណា ? (កូនមាន់សួរ)
- ក្រែងថាយើងទៅសេរីសោភ័ណ មិនមែនទេ ?
- មែនហើយ! តែយើងទៅធ្វើអី ? រកនរណាគេទៅ ?
- គឺ... ខ្ញុំក៏គ្មានបងប្អូនដូចតែកូនមាន់ដែរហ្នឹង... ចេះតែដើរតាម យថាកម្មទៅ ។
- តែយើងត្រូវការអាហារបរិភោគ ដូច្នេះត្រូវធ្វើអ្វីដែលនាំអោយ
យើងរកសោហ៊ុយផាត់អង្ករប្រចាំថ្ងៃ ។
- អញ្ចឹងយើងទៅរត់ពន្ធទៅ (ជ្រូកលីវបបួល)
- អត់ដើម រត់ពន្ធនឹងអ្វីដែរ ?
- យើងមានកម្លាំងនោះអី! យើងរែកឥវ៉ាន់អោយគេយកសោហ៊ុយ លៀងក្រពះ ។
- តែជ្រូកលីវនៅមានដំបៅស្នាមនៅឡើយទេ ។
- ខ្ញុំអាចធ្វើការស្រាលៗបាន មិនអីទេ ។

អ្នកទាំងពីរដើរបណ្តើរជជែកគ្នាបណ្តើរ ។ តាមផ្លូវ គេបាន
ប្រទះសពមនុស្សមួយហ្វូងទៀតហើយ មើលទំនងដូចជាទើបនឹង ស្លាប់ថ្មីៗទៀតផង ។
កូនមាន់ដើរធ្មេចភ្នែកមិនហ៊ានមើលសាក សពរាយប៉ាយពេញថ្នល់ទាំងនោះទេ ។ រំពេចនោះ
ជ្រូកលីវក៏ស្ទុះ
ទៅបង្វិលសាកសពមួយឡើង ។
- នែ៎ មិត្តជ្រូក! ធ្វើអីហ្នឹង ? (កូនមាន់សួរ)
- គឺខ្ញុំចង់ដោះយកក្រមាពីសាកសពមកទុកប្រើ!

CHANBOKEO.COM

- កុំអី! ទុកអោយគេស្លាប់បិទភ្នែកជិតផងចុះ! ចាំយើងទៅរកស៊ី បាន ចាំទិញក្រមាប្រើខ្លួនយើងវិញ ។

ជ្រូកលីវឮដូច្នោះ ក៏ផ្តេកសាកសពនោះទៅវិញ ។ កូនមាន់ធ្វើ ទឹកមុខមិនសូវស្រួលសោះ ពេលឃើញសាកសពទាំងនោះ ។

- មានរឿងអ្វីរំខានចិត្តឬកូនមាន់ ?

កូនមាន់ក្រញាសឈ្លោកមុខដើរស្ទៀមស្ទាត់ មួយស្របក់មក ទើបដាច់ចិត្តឆ្លើយប្រាប់ថា ៖

- គំនរសាកសពរាយប៉ាយទាំងនោះ គឺជាទិដ្ឋភាពនាំអោយខ្ញុំនឹក ទៅដល់ឪពុកម្តាយខ្ញុំដែលត្រូវខ្មែរក្រហមសម្លាប់រាយប៉ាយ ពាសដី កាលពីបួនឆ្នាំមុន... ពិតជាពិបាកទប់មិនអារម្មណ៍ណាស់!

ជ្រូកលីវធ្វើមុខស្រងូតតាមដែរ ៖

- ការពិត ខ្ញុំក៏មានអារម្មណ៍មិនខុសពីកូនមាន់ដែរព្រោះឪពុកម្តាយ ខ្ញុំក៏ស្ថិតនៅក្នុងស្ថានការណ៍ស្រដៀងៗគ្នាហ្នឹង ។ សូម្បីតែខ្ញុំជាកូន ក៏ពុំមានសិទ្ធិទៅកាយដីកប់សពរបស់លោកទាំងពីរផង ។

ពោលដល់ត្រង់នេះ នរ:អួលដើមក ។ ចំណែកកូនមាន់ក៏មិន ខុសគ្នាប៉ុន្មានដែរ ។ គេឈរសម្រក់ទឹកភ្នែកដាក់គ្នាយ៉ាងយូរ ទំរាំ កូនមាន់លើកដៃជូតទឹកភ្នែក ហើយស្រដីថា ៖

- ណ្ហើយចុះ! យើងទាំងពីរត្រូវតែរៀនកាត់ចិត្តហើយ ។ ហោច ណាស់ យើងនៅសល់គ្នាពីរនាក់ដែរដែលមានប្រវត្តិស្រដៀងគ្នា! យើងត្រូវតាំងចិត្តរឹងមាំក្លាហាន តស៊ូនឹងជីវិតតទៅទៀត កុំចុះ ចាញ់ឥទ្ធិពលព្រហ្មលិខិតជាដាច់ខាត ។

ជ្រូកលីវក៏ប្រឹងលេបទឹកភ្នែកចូលពោះវិញ ហើយឆ្លើយថា ៖

- មែនហើយ កូនមាន់! យើងមិនគួរចុះចាញ់ជីវិតទេ! តោះយើង ធ្វើដំណើរទៅមុខទៀត!

អ្នកទាំងពីរជូតទឹកភ្នែកស្អាត ក៏នាំគ្នាដើរទៅមុខទៀត ។ ការ ពិត គេមិនទាន់ដឹងថា គេធ្វើដំណើរទៅណាទេ ចេះតែដើរៗទៅ ដើម្បីបន្លប់អារម្មណ៍សោកសៅ ដែលគេជាមនុស្សព្រាត់ម្តាយឪពុក និងក្រុមញាតិដូចគ្នា ។ តាមផ្លូវ គេរើសបានឆ្នាំងចាស់ដែលអ្នក ស្រុកគេវែងចោលបានមួយ និងបាវមួយ ។ ថ្វីបើអ្នកទាំងពីរទើប តែស្គាល់គ្នាក្តី ប៉ុន្តែប្រវត្តិជីវិតពីរបីថ្ងៃជាមួយគ្នានេះ បានធ្វើអោយ គេស្គាល់គ្នា កាន់តែជិតដិតនឹងគ្នាជាងមុន ទោះបីជាមានពេលខ្លះ គេចូលចិត្តប្រកែកប្រណាំងគ្នាយកឈ្នះចាញ់ខ្លះៗក៏ដោយ ។

CHANBOKEO.COM

សូរកាំភ្លើងធំគ្រឹមៗពីទិសខាងលិច លាន់សូរបន្តគ្នាឡើយៗ ។ យូរៗម្តង អ្នកទាំងពីរប្រទះរថយន្តកងទ័ពបរហុយដីទ្រលោម ។ ពួកគេក៏ប្រញាប់រត់គេចខ្លួនចុះទៅវាលស្រែ ធ្វើដំណើររបៀបអ្នក ស្រុកដើរបេះត្រកួន ។ ជួនកាលគេក៏ប្រទះអ្នកស្រុកដែលធ្វើដំណើរ ជាក្រុមៗ ជួនជាមនុស្សពេញវ័យទាំងអស់ ជួនកាលក៏ជាហ្វូងដែល មានលាយមនុស្សចាស់និងក្មេងតូចៗ ។ ប៉ុន្តែម្នាក់ៗមានមុខមាត់ ស្លេកស្លាំង មានសម្លៀកបំពាក់រយ៉ីរយ៉ៃពិបាកមើលណាស់ ។ មើលទៅពួកគេប្រហែលលជាជនភៀសខ្លួនដោយសង្គ្រាម ដូចតែជ្រូក លីវនិងកូនមាន់ ទើបចេះតែធ្វើដំណើរស្វែងរកកន្លែងរស់នៅសុខ សាន្ត ។

កាលនៅជំនាន់នោះ ខេត្របាត់ដំបងជាតំបន់សមរភូមិរងគ្រោះ ដោយសង្គ្រាមធ្ងន់ធ្ងរជាងគេ ។ អ្នកស្រុកជាច្រើនសែននាក់បានត្រូវក្រុមយោធាខ្មែរក្រហមបដិវត្តន៍ធ្វើឃាត យ៉ាងសាហាវព្រៃផ្សៃ ។ នៅសម័យបន្ទាប់មក ឆ្នាំ១៩៧៨-១៩៧៩ ក៏មានទ័ពបរទេសចូល មកលុកលុយក្នុងប្រទេសខ្មែរ ។ ពេលនោះ សង្គ្រាមរ៉ាំរ៉ៃរវាងកង ទ័ពខ្មែរក្រហម កងទ័ពសេរីការ និងកងទ័ពវៀតណាម បានបង្កភាពចលាចលនៅភាគខាងលិច និងខាងជើងនៃខេត្របាត់ដំបង ជាប់នឹងប្រទេសថៃ ។ ប្រជាពលរដ្ឋស្លូតត្រង់ក៏នាំគ្នារត់គេចខ្លួនរក កន្លែងសុខសាន្តជ្រកកោន ។ ក្នុងកាលសម័យនោះដែរ ខេត្របាត់ ដំបងមិនទាន់មានផ្សារលក់ឥវ៉ាន់ទេ មានតែការដោះដូរឥវ៉ាន់ដោយ មាស ហើយប្រព្រឹត្តទៅប្រញិបប្រញាប់ ក្នុងស្ថានការណ៍ភ្នែកនៅ កញ្ជឹងក ព្រោះគេមិនអាចដឹងថានឹងត្រូវចោរប្លន់ពេលណាវេលាទេ ដោយម្នាក់ៗត្រូវកាន់មាសទឹកដប់សុទ្ធ យកទៅដោះដូរឥវ៉ាន់គ្នា ។ អ្នកស្រុកខ្លះក៏ប្រថុយជីវិតទៅទិញឥវ៉ាន់ពីថៃ រួចហើយរែកកាត់ព្រៃ ភ្នំ លុយមីនត្រឡប់មកវិញ ដើម្បីយកដូរអង្ករ ដូរមាស ជាដើម ។ ភាគច្រើន គេរែកនាំរបស់រត់កាត់ព្រៃដូចជា ស្ករ អំបិល សារុង និងសៀង ព្រោះពេលនោះស្រុកទេសកំពុងមានទុរ្ភិក្សអត់បាយ អត់ ស្បៀងគ្រប់ទីកន្លែង ។ ខ្លះទៀតដែលក្រីក្រមានតែកម្លាំង ក៏រត់ទៅរែកអង្ករដែលអង្គការកាកបាទក្រហមអន្តរជាតិចែកចាយអោយ ជនភៀសខ្លួនខ្មែរតាមទល់ដែនត្រឡប់មកធ្វើប្រពន្ធកូន នៅមង្គល បុរីសេរីសោភ័ណ ឬតំបន់ជិតៗនោះ ។ ពួកគេទាំងនោះត្រូវដើរ ពុនលុនកាត់ព្រៃ ដែលប្រកបដោយគ្រោះថ្នាក់សព្វបែបយ៉ាង ។

.....................................

CHANBOKEO.COM

មកដល់ម្តុំទីប្រជុំជនសេរីសោភ័ណជស្ងាត់ជ្រងំមានតែអ្នកស្រុក ដើររពុយៗឆ្លងកាត់...

កូនមាន់និងជ្រូកលីវឈរមើលពពួកអ្នកស្រុករែកឥវ៉ាន់តាមផ្លូវ រាយៗមួយៗ ។ កូនមាន់ជាមនុស្សរួសរាយណាស់ ។ នាងតែងតែ សាកសួរគេតាមផ្លូវច្រើននាក់មិនដាច់ទេ ក្រោយមកនាងដឹងថាអ្នក ខ្លះគ្រាន់តែជាអ្នកស្រុកដែលរែកឥវ៉ាន់នូវអង្ករកៀនផ្ទះ តែខ្លះទៀត ជាអ្នកស្រុកដែលទៅរែកអីវ៉ាន់មកពីទល់ដែន ឬត្រឹមពាក់កណ្តាល ផ្លូវរួចត្រឡប់មកវិញ ។ ខ្លះទើបរត់រួចពីក្រញាំដៃខ្មែរក្រហម នាំគ្នា រែកពុនត្រឡប់ទៅស្រុកវិញ ។

នារីហៅជ្រូកលីវមកពិគ្រោះថា ៖

- ជីវិតយើងទាល់ច្រកណាស់ មានតែកម្លាំងជាដើមទុន មើលទៅ ប្រហែលជាត្រូវរកស៊ីរែកពុនដូចគេទាំងនេះហើយទើបរស់ ។

ជ្រូកលីវងក់ក្បាល ៖

- មែនហើយ! ប៉ុន្តែ តើកូនមាន់ហ៊ានប្រថុយប្រថានកាត់គ្រោះ ថ្នាក់ធ្វើដំណើរទៅទល់ដែនដែរទេហ៍ ?

- ទោះបីជាខ្លាច ក៏ត្រូវតែប្រថុយដែរ ព្រោះថាបើនៅសំកុកទីនេះ តើយើងបានអ្វីបរិភោគ ? ផ្ទះក៏គ្មាន បងប្អូនក៏គ្មាន មានតែផ្លូវតែ ម្យ៉ាងនេះគត់ ដែលយើងអាចរំដោះក្រពះបាន ។

ជ្រូកលីវញញឹមឡើង ៖

- បើអញ្ចឹង យើងតស៊ូជាមួយគ្នាចុះណា៎!

- ប៉ុន្តែមិត្តជ្រូកឯងមិនទាន់ជារបួសស្រួលបួលនៅឡើយទេ.. តើ អាចធ្វើការកើតដែរ ?

- កើត! មិនអីទេ! របួសសើស្បែកដូច្នេះ បួនដប់ថ្ងៃទៀតជាវិញ ហើយ ។ បើសិននៅដំអក់ តើយើងបានអ្វីបរិភោគ ?

- ខ្ញុំឃើញមិត្តជ្រូកមានទឹកមុខស្លេកៗមួយថ្ងៃហើយ គិតថាអោយ មិត្តសំរាកខ្លួនសិនចុះ!

មែនហើយ! ការពិតនោះ ជ្រូកលីវកំពុងគ្រុនខ្លាំងណាស់ព្រោះ ពីរថ្ងៃកន្លងមកនេះ គេមិនបានបរិភោគអាហារគ្រប់គ្រាន់ហើយគេង ហាលខ្យល់រងាអត់ខោអាវស្លៀកពាក់ត្រឹមត្រូវផង ។ ប៉ុន្តែ គេមិន ហ៊ានរអ៊ូចេញមកអោយនារីដឹងថា នាយមិនស្រួលខ្លួននោះទេ ត្បិត ចង់អោយនាងព្រួយ ណាខ្មាស់នារីយើងផង ខ្លាចនាងចំអន់ថាខ្លួនជា បុរសទន់ខ្សោយ ។

ដោយឃើញនរៈមានទឹកមុខស្លេកៗ នាងក៏សំរេចចិត្តថា ៖

CHANBOKEO.COM

- ល្អើយចុះ! ជ្រូកលីវស្នាក់នៅកន្លែងណាមួយសិនទៅ ចាំខ្ញុំទៅ ជួយរែកឥវ៉ាន់គេ
ដូរបាយពីរបីថ្ងៃសិន ទំរាំមិត្តជាស្រួលបួលឡើង វិញ ចាំយើងធ្វើដំណើរទៅទល់ដែនទាំងអស់គ្នា ។
ទោះបីជាចង់ប្រកែកក៏ទៅមិនរួចដែរ ព្រោះជ្រូកលីវមានទឹក មុខស្លេកស្លាំងណាស់ ។
បន្តិចមក កូនមាន់ក្រញាសក៏នាំជ្រូកលីវ ចូលស្នាក់នៅផ្ទះក្បឿងកំពុកកំបាក់កំបែកមួយ
ដែលមានពីងពាង ពទ្ធ័ជិត និងស្មៅដុះស៊ុបទ្រុបត្រឹមចង្កេះ គ្មានអ្នកស្រុកណាមកក្បែរ ទេ
ប្រហែលអ្នកស្រុកខ្លាចសភាពស្ងាត់ជ្រងំរបស់ផ្ទះនោះណាស់ ។
- មិត្តស្នាក់ទីនេះសិនហើយ! ខ្ញុំចេញទៅក្រៅសិន! កុំទៅណា អោយសោះ
ក្រែងខ្ញុំមកវិញរកមិនឃើញ ។
ជ្រូកលីវងក់ក្បាល ហើយដាក់ខ្លួនអង្គុយចុះនៅគល់ដូងមួយ
ដើមដែលដុះក្រៀមៗរកកលនឹងងាប់ទៅវិញ ។ កូនមាន់ក៏ស្ទុះទៅ
ប្រមូលធាងដូងនិងមែកឈើងាប់មកដុតបំពាក់ឡើង ៖
- អាំងភ្លើងនេះសិនទៅ កុំអោយរងា ។ បើមានភ្លៀង រត់ចូលទៅ
ស្នាក់នៅសំយាបផ្ទះធំនោះសិនទៅ ហើយកុំភ្លេចលើកដៃសំពះសុំ
ម្ចាស់ទឹកម្ចាស់ដីម្ចាស់ផ្ទះជកកោនផង ដើម្បីអោយលោកជួយរក្សា មិត្តជ្រូកបានសុខសប្បាយ ។
ថាហើយ នាងក៏ស្រវាមែកឈើវែងមួយលីចេញទៅ ។
- នាងយកមែកឈើទៅធ្វើអ្វីហ្នឹង ? (ជ្រូកលីវស្រែកសួរ)
- គឺទុកការពារខ្លួនផង ទុករែកឥវ៉ាន់ផង ។
កូនមាន់ឆ្លើយមកវិញពីចម្ងាយហើយក៏ដើរចេញទៅ ទុកអោយ
ជ្រូកលីវធ្មេចភ្នែកគេងដោយការអស់កម្លាំងខ្លាំងពេក ។
- សូមអោយនាងមានសុវត្ថិភាពណា៎ កូនមាន់!
ជ្រូកលីវគេងបន់ខ្សិបៗតែម្នាក់ឯង...រហូតលង់លក់ទៅ ។
.................................................
ចំណែកកូនមាន់ក្រញាសវិញ...
នារីយើងដើរតាមដានជើងមនុស្ស ដែលដើររពុយៗទៅមក តាមផ្លូវតែមួយគន្លង
ក្នុងកិរិយាភ្នែកនៅកញ្ជឹងក តម្រង់ទៅស្វាយ ចេកបន្ទាយឆ្មារ ។ ខ្លះរែកឥវ៉ាន់ ខ្លះពុន
ខ្លះដើរដៃទទេ... ខ្លះ ដឹកដៃកូនចៅរយោង... យូរៗឃើញអ្នកស្រុករត់ព្រូ ចូលពួនក្នុង
ព្រៃស្ងាត់ឈឹង...

CHANBOKEO.COM

ក្អុង! ក្អុង! អ៊ូយ!

សូរមីនផ្ទុះយ៉ាងសាហាវ និងសម្រែកអ្នកស្រុកលាន់ឡើងដោយ ក្ដីរន្ធត់តក់ស្លុត ។ កូនមាន់ស្ទុះក្រាបលើដីយ៉ាងរហ័ស តែគេចមិន ទាន់បំណែកមួយផ្ទាំងរត់កាត់ឆាល់ ដាច់កំភួនជើង រហែកសំពត់ ចាស់របស់នាង ។ សំណាងល្អ នាងគ្រាន់តែបានទទួលរបួសស្ទើ ស្បែកប៉ុណ្ណោះ កុំអីលែងមានជើងដើរហើយ ។ នៅខាងមុខនាង ប្រហែល២០ម៉ែត្រ អ្នកស្រុកមួយហ្វូងដួលទ្រេល ឈាមរហាច មានតាំងពីមនុស្សចាស់រហូតដល់ទារកតូចបីនឹងដៃ ។ មើលទៅ ពួកគេ ទំនងជាអ្នកស្រុកដែលក្រីក្រទុរគតបំផុត ។ ខ្លះដាច់ខ្លួន ដាច់ដៃដាច់ជើងកំណិតកំណាត់ ដោយសារកម្លាំងមីន ។ ខ្លះដេក ស្រោប ដោយឈាមពាសពេញរូបកាយ រកមើលពុំយល់...

កូនមាន់ក្រញាសភិតភ័យតក្កមា រកទឹកមាត់លេបគ្មានទេ ។ ឯ អ្នកស្រុកខ្លះទៀតរត់ប្រសាចទៅខាងៗ ហើយក៏ជាន់មីនដទៃដែល កប់ក្បែរៗនោះ បណ្ដាលឲ្យមានសូរគ្រាប់ផ្ទុះបន្តបន្ទាប់ថែមទៀត ។ នារីយើងគេងផ្កាប់មុខសណ្ដូកក្រោមគុម្ពោតព្រៃមួយ ប្រឹងរំលត់ ភាពញាប់ញ័រក្នុងទ្រូងដោយការភិតភ័យ ។ យូរបន្តិចមក ផ្លូវដើរក៏ មានមនុស្សដើរសាជាថ្មីឡើងវិញ ។ កូនមាន់ដើបចេញពីគុម្ពោតវារ ចេញមក ឃើញអ្នកស្រុកនាំគ្នាដើរកន្លងសពមនុស្ស និងជនរង គ្រោះខ្លះដែលនៅដកចង្កាមាន់នៅឡើយ ដើម្បីស្រូតដំណើរបន្ត ទៅទៀត ដោយគ្មាននរណាយកភ្នែកមើលនរណាទេ គិតតែរត់យក រស់តែរៀងៗខ្លួន ។

មាណវីកំពុងតែឈររន្ធត់អារម្មណ៍ នឹងទិដ្ឋភាពដ៏សែនទារុណ ស្រាប់តែមានបុរសម្នាក់ដើរបុកនារីម៉ាំង ធ្វើអោយនាងខ្ទាតទៅម្ខាង រួចហើយស្ដីអោយនាងថា ៖

- នៅឈរបន្ទឹសបន្ទើសស្អីហ្នឹង ? នឹងទេ បើចង់ស្លាប់ឆាប់ ប្រឹង ឈរកន្លែងហ្នឹងអោយយូរបន្តិចទៅ!

ថាហើយ បុរសនោះដើរចេញប្រញិបប្រញាប់ទៅបាត់ ។ កូន មាន់ឮសំដីពូម្នាក់នោះនិយាយហើយ ប៉ុន្តែស្ដាប់មិនយល់ទេ ថា គាត់ចង់មានប្រសាសន៍ថាម៉េច ។ ស្រាប់តែ...

ផាំង! ផាំង! អ៊ូយ!

សូរគ្រាប់កាំភ្លើងដែលលាន់ឡើង ព្រមទាំងសម្រែកយ៉ាងគ្រលួច កាត់ព្រៃ ។

- ជួយផង! ចោរប្លន់ៗ! ជួយ.... អ៊ូយ!

CHANBOKEO.COM

ផាំង! ផាំង! សូរកាំភ្លើងលាន់ឡើងថែមទៀត ។

កូនមាន់ភ័យពេករត់ចូលគុម្ពោធក្រោបវិញយ៉ាងរហ័ស ។ ពេល នេះទើបនាងយល់ច្បាស់នូវពាក្យសំដី ដែលពូអ្នកស្រុកនិយាយ អំបាញមិញ ។ នារីយើងភ័យសាបមាត់អស់រលីង មិននឹងជីវិតនាង ត្រូវចប់ត្រឹមនេះឬយ៉ាងណាទេ ។ នាងគេងស្តាប់សូរសម្រិបជើង អ្នកស្រុករត់ពាសព្រៃ និងសូរមីនផ្ទុះនាយអាយគ្រប់ទិស លាយឡំសូរគ្រាប់កាំភ្លើងចោរប្លន់ផុងផាំងៗ ម្តងឆ្វេងម្តងស្តាំ ។ បេះដូងនារី រណ្តំញ័រគគ្រឹករហូតរងាររណ្តំចង្កាលាន់កក្រឹកៗដោយក្តីតក់ស្លុត ។

មួយសន្ទុះធំក្រោយមក សភាពក្នុងព្រៃម្តុំនោះ ហាក់ដូចជាស្ងប់ ស្ងាត់វិញហើយ ។ កូនមាន់ក៏លូនចេញពីកន្លែងលាក់ខ្លួនមកវិញ ហើយដើរលបចេញមកស្រាប់តែប្រទះឃើញបុរសម្នាក់ត្រូវរបួស ឈាមស្រោចពេញខ្លួន កំពុងកម្រើកខ្ញៅៗ ៖

- នាង!.. ជួយផង! (ពូនោះហៅកូនមាន់ដោយសម្លេងខ្សាវៗ)

នារីងាកឆ្វេងស្តាំ មិនឃើញមាននរណាសោះ ក្រៅពីគំនរសាក សព និងមនុស្សរបួសដេករណ្តូករណែល មានធ្ងន់មានស្រាលតាម ដំណើរ ។ នាងក៏ស្ទុះទៅជិតបុរសនោះ ដែលកំពុងស្រវាលូកយក អ្វីម្យ៉ាងពីហៅប៉ៅចេញមកហុចអោយនាងទាំងដៃញ័រៗ... ហើយក៏ ស្រដីខ្សាវៗ ប៉ុន្តែ នារីយើងស្តាប់មិនបានទេ ។ នាងក៏ឈ្ងោកដាក់ ត្រចៀកដល់មាត់របស់គាត់ ដើម្បីស្តាប់ ប៉ុន្តែនៅស្តាប់មិនយល់ ដដែល ។ ទីបំផុត បុរសនោះក៏ដកចង្កាមាន់ដាច់ខ្យល់ស្លាប់ទៅ ។ កូនមាន់លាតដៃមើលរបស់ដែលបុរសនោះហុចមកអោយនាង ឃើញជាខ្សែកមាសបន្តោងប្រាក់កាក់ឆ្លាក់អក្សរចិនទម្ងន់ប្រហែល ជាបីបួនដម្លឹង ។ បន្ទាប់មក កូនមាន់ក៏លូកដៃបិទភ្នែកឲ្យបុរស នោះព្រមទាំងស្រដីខ្សឹបៗថា ៖

- សូមវិញ្ញាណក្ខន្ធរបស់ពូបានទៅសោយសុខនៅសុគតិភពផង!

រំពេចនោះ ស្រាប់តែ...

- នែ៎ មីនាង! ឯងទំនេរដៃទេ? បើទំនេរជួយមីងបន្តិចមោ៉!

កូនមាន់ងាកក្រោយយ៉ាងរហ័ស ឃើញមីងម្នាក់ក្នុងវ័យជាង៤០ឆ្នាំកំពុងប្រមូលឥវ៉ាន់តតេះតតះដាក់អម្រែក បំរុងរែកត្រឡប់ ថយក្រោយវិញ ។

- មីងទៅរែកឥវ៉ាន់មកពីណា អីក៏បានច្រើនម្ល៉េះ?

CHANBOKEO.COM

- គឺដើរប្រមូលពីក្នុងព្រៃហ្នឹងណា៎! ចោរវាប្រមូលយកទៅមិនអស់
ទើបនៅសល់រាយប៉ាយជាមួយសាកសពទាំងនេះ ។
- ហើយមីងហៅខ្ញុំមកជួយអីទៅ ?
- មកជួយរែកឥវ៉ាន់ទាំងនេះអោយមីងណា៎! ហើយចាំដល់ផ្ទះមីង ចាំមីងចែកឯងខ្លះនោះអី!
- អូហ៍! បើដូច្នោះមែន ចាំបាច់ខ្ញុំជួយរែកមីងធ្វើអី ? ទុកដៃរបស់ ខ្ញុំទំនេរ
ដើររើសរបស់ទាំងនេះរែកទៅផ្ទះវិញ មិនប្រសើរទេ ?
- យើស៍! គ្រាន់តែប្រាប់តម្រុយភ្លាម ចេះភ្លាម! ម៉េចចង់រកស៊ី កាត់មុខយើងផង មែនទេ ?
- មិនកាត់មុខទេ! ខ្ញុំទុកអោយមនុស្សចាស់រើសមុនចុះ ។ ចាំដល់ មីងរើសមិនអស់
ទើបខ្ញុំរើសតាមក្រោយ ។

ឮដូច្នោះ មីងម្នាក់នោះធ្វើមុខស្មឿកតែម្តង ព្រោះអម្រែករបស់ គាត់ធ្ងន់ដល់បន្ទុកទៅហើយ តើឲ្យគាត់ដាក់ថែមយ៉ាងម៉េចទៀត ? បន្តិចមក
កូនមាន់ក៏ដើររើសប្រមូលវត្ថុដែលជ្រុះរាយប៉ាយទាំងនោះ
យកតែរបស់ណាដែលស្រាលៗហើយមានប្រយោជន៍ ដាក់ចងនឹង ដងរែក
រែកត្រឡប់ទៅភូមិស្វាយដើម្បីទៅរកនាយជ្រូកលីវវិញ ។
- នែ៎! កុំដើរលឿនពេក! ចាំមីងផងវើយ! គ្រាន់នឹងបានជាគ្នា!
- បើដើរតាមខ្ញុំ មីងកុំស្ទូវមាត់ឮពេក ក្រែងពួកចោរវាឮសម្លេង របស់មីង
វាចេញមកប្លន់ម្តងទៀតទៅ ។

មីងនោះក៏ស្ងាត់មាត់ដូចគេចុកតែម្តង ហើយប្រឹងរែកឥវ៉ាន់ តាមក្រោយកូនមាន់ ឡើងហត់គយូរ ។ តាមផ្លូវ អ្នកទាំងពីរដើរ កន្លងសាកសពរាប់មិនអស់ ។ ចំណែកខ្យល់អាកាសវិញ ក៏ចោល ក្លិនអាសោចន៍ពិបាកនឹងដកដង្ហើមក្រៃលែង ព្រោះតែមានសាកសព តាមផ្លូវច្រើនពេក ។ ដែលពិបាកបំផុតនោះគឺ កូនមាន់ត្រូវបង្ខំចិត្ត បិទភ្នែកមិនហ៊ានសម្លឹងអ្នករបួសដែលដួលដេកតាមផ្លូវទេ ព្រោះ មិនដឹងថា ជួយមួយណាចោលមួយណាទេ បើច្រើនសន្ធឹកសន្ធាប់ យ៉ាងហ្នឹង...
មានតែយករួចខ្លួនមួយពេលសិនតែប៉ុណ្ណោះ ។

.........................................

ភ្លឺស្រាងៗ...

CHANBOKEO.COM

មកដល់ជិតភូមិស្វាយ ស្រាប់តែមីងម្នាក់នោះរេរកបំបែរទិស ចេញទៅផ្លូវផ្សេងបាត់ទៅ ។ កូនមាន់ក៏រែកឥវ៉ាន់ដើរត្រឡប់មក ដល់កន្លែងចាស់ដែលជ្រូកលីវស្នាក់នៅបណ្តោះអាសន្ន ។ ចៃដន្យ ទីនោះបែរជាស្ងាត់ជ្រងំ គ្មានស្រមោលជ្រូកលីវនៅទីនោះឡើយ ។

- យី! គេទៅណាអញ្ចេះ ?

កូនមាន់ដាក់អម្រែកចុះ ដើររកមើលម្តុំៗនោះ ឃើញតែភ្នក់ភ្លើងដែលនៅឆេះហុយៗនៅឡើយ ។ នារីក៏ដើរអើតចុះអើតឡើងម្តុំៗនោះទៅតែមិនឃើញមាណពដដែល ។ អស់ចិត្តហើយ នាងក៏ វិលមកកន្លែងចាស់ដាក់ខ្លួនអង្គុយចុះដោយការអស់កម្លាំងល្ហិតល្ហៃ ក្រៃលែងព្រោះអត់បាយមួយយប់មួយថ្ងៃមកហើយ ។ នាងក៏ ស្រវាទាញឆ្នាំងចាស់ដែលដាក់លាក់ចោលក្នុងស្មៅមុននឹងបែកពី ជ្រូកលីវទៅ រួចហើយស្រវាទែអង្ករដែលនាងរើសបានមកពីព្រៃ កាលពីយប់មិញ ដាក់ដណ្តាំបាយបរិភោគ ។

នារីស្រវាបាយចុកបណ្តើរនឹកទៅដល់ជ្រូកលីវបណ្តើរ ៖

- មិត្តជ្រូកអើយ! អ្នកទៅណាបានជាបាត់ស្រមោលអញ្ចឹង ? ឬក៏ អ្នកចេញទៅតាមខ្ញុំ ? តើអ្នកបារម្ភពីសុខទុក្ខរបស់ខ្ញុំដែរមែនទេ ? ឬក៏អ្នកបានជួបមិត្តភក្តិញាតិសន្តានហើយក៏ចាកចេញទៅ ?... ប៉ុន្តែ ទោះជាយ៉ាងណាខ្ញុំសូមអរគុណអ្នកដែលបានជួយជីវិតខ្ញុំនាគ្រាមួយនោះអោយផុតពីការបំពានព្រៃផ្សៃរបស់ពួកទមិឡ ។ សូមអោយអ្នកធ្វើដំណើរអោយបានសុខសប្បាយផងណា៎!

បន្តិចមក នាងក៏ដាក់ខ្លួនផ្ទេកនឹងគល់ឈូង សម្ងំគេងលង់លក់ទៅយ៉ាងស្កប់ស្កល់ដោយការអស់កម្លាំងពេកក្រៃ ។

oooooooooooooooo

ooooo

o

# វគ្គទី៥
## ចោរ

មិននឹងជាលង់លក់អស់ពេលយូរប៉ុនណាទេ ស្រាប់តែកូនមាន់ យើងមានអារម្មណ៍ថា មានអ្វីមកប៉ះថ្ពាល់នាងរសើបៗ ក៏លើកដៃ ទះយ៉ាងខ្លាំង ស្រាប់តែប៉ះនឹងមែកឈើមួយសំយុងដាក់ចំពីលើមុខ នាង ។ ធិតាបើកភ្នែកឡើងហើយស្ទុះក្រោកយ៉ាងរហ័ស ក៏ប្រទះ នឹងជ្រូកលីវអង្គុយក្បែរនោះ ធ្វើមុខទំនងអត់ងងុយអស់កម្លាំង ៖

- មិត្តជ្រូក ?
- បាទ!
- ទើបមកពីណាហ្នឹង ?
- គឺ... មកពីតាមរកកូនមាន់ហ្នឹងណា៎ ព្រោះឃើញបាត់យូរពេក តែ លុះដើរឆ្ងាយៗទៅ ក៏ខ្លាចឃ្លាងមិនជួបគ្នា ទើបខ្ញុំត្រឡប់មក វិញ ស្រាប់តែបានជួបកូនមាន់នៅទីនេះតែម្តងទៅ ។
- អញ្ចឹងតើ បានជាយកមែកឈើមកបបោសមុខខ្ញុំ ដើម្បីអោយ ខ្ញុំភ្ញាក់មែនទេ ?
- អត់ទេ! ខ្ញុំឃើញថ្ងៃចាំងចំមុខកូនមាន់ បានជាកាច់មែកឈើ អង្គុយបាំងអោយ ប៉ុន្តែអស់កម្លាំងពេក បានជាច្រឡំអង្គុយងក់ ម៉ាស្របក់ ទើបទន់ដៃធ្លាក់មែកឈើចំមុខកូនមាន់... សូមទោសណា៎ ដែលខ្ញុំធ្វើអោយកូនមាន់ភ្ញាក់ពីដំណេក!
- មិនអីទេ! ហើយចុះមិត្តជ្រូកហូបបាយហើយនៅ ?
- នៅទេ! ខ្ញុំអង្គុយអត់ម៉ាយប់ទើសភ្លឺហើយ!
- ហើយចុះបាយដែលខ្ញុំដាំទុកអោយនៅក្នុងឆ្នាំងនោះ ?

CHANBOKEO.COM

- ពុទ្ធោអើយ! ម៉េចខ្ញុំហ៊ានកាយដោយមិនបានសុំម្ចាស់នោះ ?
- ខ្លាចអីទៅ ?
- ខ្លាចក្រញាំមាន់ក្រញីដាច់មុខ!
- តែផ្ដាស! យ៉ាប់មែន មិត្តជ្រូកនេះ!

ថាហើយ កូនមាន់ក្រញាសក៏ស្ទុះទៅលើកឆ្នាំងមកហុច ៖
- ណេ៎ះ! មានតែបាយអត់ម្ហូបទេ កាយអកយករស់ម៉ាពេលសិន ទៅណា៎! មានកម្លាំងហើយចាំគិតទៀត ។

ជ្រូកលីវទទួលឆ្នាំងមកកាយយកបាយបរិភោគ ។ កូនមាន់ដាក់ ខ្លួនចុះផ្ទែកនឹងគល់ដូងដែលរួចស្រដីថា ៖
- មិត្តជ្រូកតាមរកខ្ញុំដល់ណាដែរ កាលពីយប់មិញ ?
- មិនដឹងដល់ណាទេ ចេះតែលបដើរតាមពួករត់ពន្ធ ឮគេថាទៅ ស្វាយចេកបន្ទាយឆ្មារ ប៉ុន្តែដោយឃើញមនុស្សស្លាប់ព្រោះជាន់ មីនផង ព្រោះចោរប្លន់ផង ត្រូវទាហានបាញ់ផង ណាមួយខ្ញុំខ្លាច កូនមាន់មករកខ្ញុំនៅទីនេះមិនជួបគ្នា ទើបគេចខ្លួនរត់ត្រឡប់មកវិញ នេះអី ។ សំណាងល្អ ខ្ញុំក៏បានជួបនាងនៅទីនេះវិញតែម្ដង ។
- អូហ៍ ខ្ញុំក៏ទៅផ្លូវហ្នឹងដែរ ប៉ុន្តែគ្រោះថ្នាក់គួរអោយតក់ស្លុតព្រឺ សម្បុរណាស់ ។ មើលទៅខ្ញុំលែងទៅតាមផ្លូវហ្នឹងទៀតហើយ ។
- ខ្ញុំក៏គិតអញ្ចឹងដែរ កូនមាន់! នេះសំណាងល្អហើយដែលយើង នៅសល់ជីវិតសល់ដៃជើងត្រឡប់មកវិញ ។

កូនមាន់ងក់ក្បាល ។ ពេលនោះ នាងក្រឡេកឃើញជ្រូកលីវ ធ្វើមុខស្លេកខ្លាំងពេក ក៏សួរថា ៖
- មើលទៅមិត្តជ្រូកឯងមិនស្រួលខ្លួនហើយ បានជាមុខខៀវចម្លែក ខុសធម្មតា!

ជ្រូកលីវងក់ក្បាល និយាយទម្លាក់សម្លេង ៖
- ប្រហែលជាខ្ញុំមានជម្ងឺគ្រុនចាញ់ទេដឹង ។
- ម៉េចក៏មិត្តជ្រូកដឹងកើត ?
- គឺខ្ញុំគ្រុនពេល អោយតែរសៀលគឺរោគគ្រុនធ្វើទុក្ខជានិច្ច ។

ស្រាប់តែមាណវីយើងនឹកឃើញរឿងមួយ ក៏ស្ទុះទៅស្រវាបង្វិចតវ៉ាន់ដែលនាងរើសពីក្នុងព្រៃមកកាលពីម្សិល ។
- កូនមាន់រកអីហ្នឹង ?

CHANBOKEO.COM

- តែកបង្វិចរកថ្នាំ ឬក៏អ្វីៗដែលអាចជួយឲ្យយើងរស់បាននោះអី

ជ្រូកលីវនៅស្ងៀម ឆ្មេចភ្នែកធ្វើអាការៈហាក់ដូចជាកំពុងរងា ខ្លាំង ។ ចៃដន្យក្នុងបង្វិចនោះមានតែសំពត់មនុស្សស្រីមួយ អង្ករ មួយកញ្ចប់ អំបិលមួយទូកដៃ និងខោអាវកូនក្មេងមួយសំរាប់ ។

- ជ្រូកលីវមិនស្រួលខ្លួនហើយ ។ យកសំពត់នេះដណ្តប់សិនទៅ ចាំខ្ញុំទៅបង្កាត់ភ្លើងថែមទៀត កំដៅកុំអោយមិត្តរងា!

ដោយមិនស្រួលខ្លួនខ្លាំង ជ្រូកក៏ផ្តេកខ្លួនទៅលើស្មៅ លូកដៃ ទទួលសំពតចាស់បំណាស់រុំជិតនោះមកដណ្តប់ ហើយក៏ឆ្មេចយក កម្លាំងទាំងញាក់ទទ្រើក គួរអោយបារម្ភ ។ លុះនារីយើងបង្កាត់ភ្លើង រួចហើយ នាងក៏ស្ទុះដើបឡើង ៖

- ជ្រូកលីវ នៅចាំទីនេះសិនហើយ ។ ខ្ញុំទៅដើរទៅរកផ្ទះអ្នកស្រុក ម្តុំនេះម៉ាភ្លែតសិន ។
- ទៅធ្វើអី ? (ជ្រូកលីវសួរ)
- ទៅរកសុំដូរថ្នាំគេ ក្រែងបានយកមកអោយជ្រូកលីវហូប ។
- អូហ៍ ? ហើយចុះបានអ្វីទៅដូរគេទៅ ?
- គឺ...

នារីយើងឈរអេះអុញ មួយភ្លែតក៏ឆ្លើយថា ៖

- ខ្ញុំខ្ចីមាសគេម្នាក់ប្រើសិន ចាំថ្ងៃក្រោយ ខ្ញុំមានឱកាស ខ្ញុំនឹងរក សងគាត់វិញ ។
- ខ្ចីមាស ? នរណាគេចិត្តល្អម្ល៉េះ អោយកូនមាន់ខ្ចីមាស ?
- គឺ... ម្ចាស់គេ... ម្ចាស់គេបានដោះអោយខ្ញុំកាលពីម្សិល ហើយផ្តាំ ខ្ញុំពីរបីម៉ាត់ តែខ្ញុំស្តាប់អត់បានទេ នៅសល់តែមាសរបស់គេដែល ផ្ញើអោយខ្ញុំទុកអោយ ។

ជ្រូកលីវជ្រួញចិញ្ចើម ទំនងមិនជឿថានាងនិយាយពិត ប៉ុន្តែ មាណវីយើងមិនខ្វល់ទេ គិតតែពីដើរយ៉ាងរហ័សចេញទៅ រកតែ ជ្រូកលីវឃាត់នាងមិនទាន់ផង ។

............................

ច្រើនម៉ោងកន្លងទៅហើយ ជ្រូកលីវមិនឃើញកូនមាន់ត្រឡប់ មកវិញសោះ ។ ព្រះអាទិត្យក៏ជ្រេរកអស្តង្គតដែរ ។ គេក៏ប្រវេ ប្រវាក្រោកដើរទាំងធីងធោងសំដៅផ្លូវធំ ។ តាមផ្លូវស្ងាត់ជ្រងំ គ្មាន មនុស្សដើរទេ ។ ពេលនេះ បុរសយើងមិនដឹងថា តើនាយត្រូវចេញទៅតាមទិសណាទេ ដើម្បីតាមរកកូនមាន់អោយឃើញ ។

CHIANBOKEO.COM

នរៈអង្គុយគប់ប្រមល់តែម្នាក់ឯងយ៉ាងយូរ... ក្នុងចិត្តអន្ទះសា ក្រៃលែងត្បិតមិនដឹងថាត្រូវធ្វើយ៉ាងណា ។ ដោយការបារម្ភខ្លាំង ពេក គេក៏បែកញើសរហូតស្វាងឆេងពីសភាពគ្រុនក្ដៅ ។ បន្តិច មក គេក៏សំរេចចិត្តប្រមូលឥវ៉ាន់របស់នាងលាក់ទុកក្នុងគុម្ពោធព្រៃ ខ្លះ ហើយចាក់យកពាក់កណ្ដាលទៅតាមខ្លួន ។ គេបំរុងគិតចេញ ទៅក្រៅ តាមរកកូនមាន់ ។ បើសិនគេរកនាងឃើញនោះ គេនឹង មានអង្ករខ្លះផ្ញើនាង ដើម្បីដណ្ដាំបរិភោគ ។ តែបើសិនគេបែរជា ឃ្លាងមិនបានជួបគ្នាវិញ ក៏នាងអាចមានអង្ករសល់ខ្លះដែលគេលាក់ នៅកន្លែងដើម ដើម្បី អោយកូនមាន់មានស្បៀងបន្តជីវិតបណ្ដោះ អាសន្នដែរ ។

ពេលនេះ យប់ទៅងងឹតឆ្ងាយចាប់រះព្រិចៗទៅហើយ... នាង កូនមាន់ក៏មិនឃើញវិលវិញដដែល ។ កាលពីយប់មិញ មាណព យើងគេងគប់ប្រមល់រង់ចាំនារីម្ដងហើយ រហូតទ្រាំមិនបាន ក៏ស្ទុះ រត់ចេញទៅតាមនាង ប៉ុន្តែ គេមិនដាច់ចិត្តដើរចោលទីណាត់ទេ ។ ទីបំផុត គេក៏ត្រឡប់មកវិញ ។ នេះជាលើកទីពីរហើយ ដែលគេ ត្រូវគេងចាំនារីយើងសាជាថ្មីម្ដងទៀត ។

- ហេតុអ្វីបានជាយើងក្លាយជាបុរសទន់ខ្សោយអោយនារីជួយយើង ទៅវិញអញ្ចឹង ? ហេតុអ្វីមិនប្រឹងដើបតស៊ូជួយខ្លួនឯងឡើង ?

គិតហើយ គេក៏ដើបដើរចេញវឹងទៅតាមរកកូនមាន់ភ្លាម ៖

- កូនមាន់អើយ! មិនថានាងនៅទីណាទេ... សូមអោយនាងសុខ សប្បាយផុតគ្រោះថ្នាក់ទាំងឡាយផង! ជ្រូកលីវ អរគុណនាង ណាស់ដែលនាងមានទឹកចិត្តចំពោះខ្ញុំយ៉ាងថ្លៃថ្លា...!

ភ្លាមនោះ ជ្រូកលីវបានឃើញស្រមោលមនុស្សមួយហ្វូងតោង ដៃគ្នាដើរសំដៅទៅកើតទាំងកណ្ដាលងងឹត តម្រង់ទៅសៀមរាប ។ មាណពនឹកពិភាល់ក្នុងចិត្តភ្លាម ៖

- ហេតុដូចម្ដេចបានជាគេធ្វើដំណើរទាំងយប់អាធ្រាតទៅសៀមរាប ទៅវិញ ? ព្រោះ...ការធ្វើដំណើរទៅសៀមរាប គ្មានការហាមឃាត់ ទេ កុំតែអ្នកស្រុកធ្វើដំណើរទៅលិច នោះទើបត្រូវគេចពីការដាក់ ទោសសព្វយ៉ាងពីអង្គការដែលកំពុងឡើងកាន់អំណាចថ្មី ។

ដោយការពិភាល់ គេក៏លួចធ្វើដំណើរតាមពីក្រោយ ។ ថែដន្យ គេមានរបួសលើស្មាមិនទាន់ជា ថែមទាំងមានជំងឺគ្រុនញាក់ពីរបី ថ្ងៃកន្លងមកទៀត ហើយក៏មិនបានបរិភោគឆ្អែតគ្រប់គ្រាន់តាម

CHANBOKEO.COM

គម្លាន ធ្វើឲ្យគេអស់កម្លាំងនឹងឆោងល្ហិតល្ហៃទៀតហើយ ។ គេទ្រាំ ដើរ
តាមហ្វូងអ្នកស្រុកនោះមិនបានប៉ុន្មានផង ក៏ដួលប្រូសទៅលើ វាលស្មៅនៅម្តុំណាមួយមិនដឹង
រួចហើយក៏បាត់ស្មារតីទៅ ។

មិនដឹងជាអស់ពេលយូរប៉ុន្មានទេ លុះគេភ្ញាក់ខ្លួនឡើង ឃើញថ្ងៃរះព្រឿងៗទៅហើយ ។
ជ្រូកលីវក៏ងើបអង្គុយ ទើបដឹង ថា គេនៅជាយភូមិមួយ ក្បែរមាត់ត្រពាំងទឹក មានសាកសពដេក
រកេតរហូត ហើមស្រកស្អុយចោលក្លិនមិនគួរនឹងដកដង្ហើមសោះ ឡើយ ។
គេស្រវារកបង្វិចអីវ៉ាន់ដែលគេខ្ចប់ផ្ញើកូនមាន់ ស្រាប់តែ បាត់អស់រលីង
ធ្វើអោយគេភ្ញាក់ស្មាងដំណោកឆិញតែម្តង ៖

- ពុទ្ធោអើយ! ពេលនេះ យើងបានអ្វីផ្ញើម្ចាស់គេ បើសិនយើង ជួបគេតាមផ្លូវ ?

គេអង្គុយខកចិត្តតែម្នាក់ឯង ណាអស់កម្លាំង ណាសោកស្តាយ ដែលបាត់ឥវ៉ាន់អស់រលីង
ណានឹកព្រួយទៅដល់សុខទុក្ខរបស់កូន មាន់... គេច្រាសច្រាល់ក្នុងចិត្តឥតឧបមា មិនដឹងថា
គេត្រូវធ្វើ យ៉ាងណាទៀតទេ ។ ការពិត នរៈមិនស្គាល់ច្រកផ្លូវទៅទល់ដែន ឡើយ ។
គេចេះតែដើរតាមតម្រុយដែលអ្នកស្រុកនាំគ្នាដើរប៉ុណ្ណោះ ទោះបីជាសួរគេ
ក៏គ្មាននរណាមួយហ៊ានឆ្លើយប្រាប់ដែរ ព្រោះអ្នក
ស្រុកម្នាក់ៗត្រូវរក្សាសុវត្ថិភាពរបស់គេមិនឲ្យអង្គការថ្មីចាប់បាន ។

គិតយូរៗទៅ ជ្រូកលីវក៏នឹកភ្នកចង់បែរត្រឡប់ក្រោយ ប៉ុន្តែ
ពេលនេះ គេនៅជាយភូមិម្តុំណាមិនដឹង តើអោយគេបែរក្រោយ ទៅទិសណាវិញ
ដើម្បីអោយទៅដល់កន្លែងដើម ? ពេលនោះ គេ វិលវល់ក្នុងចិត្តទៀតហើយ ។

- ហ៊ឺ! ហេតុអីទៅហ្ន៎ បានជាជីវិតរបស់យើងវិលក្បុងយ៉ាងនេះ ?

គេយកដៃអេះក្បាលស្ទើរតែជ្រុះសក់អស់តែម្តង ៖

- កូនមាន់អើយ! ខ្ញុំមិនដាច់ចិត្តទៅចោលនាងទេ ។ នាងមាន សន្តានចិត្តចំពោះខ្ញុំណាស់
មិនគួរខ្ញុំរត់ចោលនាងទេ ។ ណ្ហើយចុះ ខ្ញុំនឹងទៅរកនាងវិញនៅកន្លែងដើមដែលណាត់គ្នាចុះ ។

ទីបំផុត គេក៏សំរេចចិត្តដើរត្រឡប់ក្រោយ តាមស្នាមដានជើង លើផ្លូវតាមភ្លឺស្រែខ្លះ
តាមផ្លូវក្នុងភូមិខ្លះ រួចហើយក៏បានមកដល់ កន្លែងដែលគេហាក់ដូចជាចាំស្រពិចស្រពិលថា
នឹងអាចត្រឡប់ទៅ រកកន្លែងចាស់ដែលគេណាត់គ្នាជាមួយកូនមាន់ឃើញ ។ មិនដឹងជា
យ៉ាងម៉េចទេ ពេលនេះ អារម្មណ៍របស់គេផ្តោតជាប់ទៅលើសុខទុក្ខ របស់កូនមាន់ណាស់ ។

CHANBOKEO.COM

ក្នុងចិត្តរបស់គេ នាងជាញាតិមិត្តតែម្នាក់ គត់ ។ បើសិនគ្មានរូបនាងទេ បេះដូងរបស់មាណព ហាក់ដូចជា ហោងហោងកណ្ដោចកណ្ដែងយ៉ាងណាមិនដឹង ។

លុះដើរជិតមកដល់ផ្ទះដែលគេបោះបង់ចោលនោះ ស្រាប់តែ ជ្រូកលីវក្រឡេកឃើញបុរសម្នាក់កំពុងគ្រាហ៍នារីមួយរូប ដើរសំដៅ ទីនោះដែរ ។

- កូនមាន់ ? (ជ្រូកលីវឧទានឡើង)

មែនហើយ នារីនោះជាកូនមាន់ទាំងសាច់ទាំងឈាម ។ នរៈ ស្ទុះរឺងយ៉ាងលឿន ដោយភ្លេចគិតថា គេកំពុងមានជំងឺទន្រ្ទាន កាយហើយ ព្រោះអាល័យបារម្ភចំពោះសុខទុក្ខរបស់នាង ។

- កូនមាន់! កូនមាន់! នាងយ៉ាងម៉េចហ្នឹង ?

ជ្រូកលីវដើរផង កូកហៅមាណវីពីចម្ងាយផង ។ បុរសចម្លែក នោះក៏ផ្ដេកនាងទៅគល់ដូងមួយ ដែលមាណវីធ្លាប់គេងផ្អែកកាលពី ម្សិលមិញ ។

- នាងកើតអីហ្នឹង ល្បង ?

មាណពសួរទៅបុរសម្នាក់នោះ ។ គេក៏ឆ្លើយវិញថា ៖

- មិនដឹងទេ ប្អូនអើយ! សង្ស័យតែត្រូវចោរប្លន់ហើយ ។ ខ្ញុំដើរ ប្រទះឃើញរបួសដួលដេកតាមផ្លូវដោយថៃដន្យ រួចនាងក៏សូមខ្ញុំ អោយខ្ញុំជួយគ្រាហ៍នាងមកទីនេះតែម្ដង ។ អូហ៍នែ៎! តើប្អូនឯងហ្នឹង ជាប្ដីរបស់នាង មែនទេ ?

- បាទ! មិនមែនទេ គ្រាន់តែស្គាល់គ្នាតាមផ្លូវដោយថៃដន្យ ដូច តែល្បងអញ្ចឹង!

បុរសនោះងក់ក្បាលញាក់ស្មា ទំនងមិនសូវជឿ ។ ភ្លាមនោះ ជ្រូកលីវស្ទុះទៅជិតនារី សួរនាងថា ៖

- មានឧប្បត្តិហេតុអ្វីហ្នឹងកូនមាន់ បានជារបួសធ្ងន់ធ្ងរយ៉ាងនេះ ?

មាណពយើងឃើញឈាមហូររឹមៗពីបបូរមាត់នារី ថែមទាំង ឃើញស្នាមជាំលើខ្លួនរបស់នាងច្រើនកន្លែង ។ គេក៏ប្រញាប់រត់ទៅ វែកគុម្ពោតរករបស់ដែលគេលាក់ទុក ។ សំណាងល្អ របស់ទាំងនោះ នៅសល់កន្លែងដដែលមិនបាត់ទៅណាទេ ។ ជ្រូកលីវក៏ប្រញាប់ បង្កាត់ភ្លើងដាំទឹកយកមកជូតអោយមាណវី ។

បុរសម្នាក់ទៀត ក៏នៅអង្គុយក្បែរនោះស្ងៀមស្ងាត់ ក្បែរអ្នក ទាំងពីរមិនឃើញដើបទៅណាមកណាទេ ទំនងកំពុងតែទាល់ច្រក

CHANBOKEO.COM

គ្មានទិសដៅជីវិតដូចអ្នកទាំងពីរដែរ ។ បន្តិចមក បុរសនោះក៏ផ្ដេកខ្លួនលើស្មៅសំងំគេងលង់លក់ទៅ ។

បែរមកជ្រូកលីវវិញ...

ថ្វីបើគេអស់កម្លាំងញ័រដៃញ័រជើងតតះយ៉ាងណាក៏ដោយ ក៏គេប្រឹងស៊ូអង្គុយជូតឈាមអោយនារី រហូតដល់ស្អាតអស់ពីមុខមាត់ដៃ ជើង ថែមទាំងប្រឹងដើរចុះដើរឡើង ទៅរើសមែកឈើ ដងទឹកតាមប្រឡាយមកដាំអោយនារីយើងទៀតផង ។ ពេលនេះ កូនមាន់មានសភាពទ្រុឌទ្រោមមើលមិនយល់ទេ ខុសពីម្សិលមិញឆ្ងាយ ណាស់ ។ មាណពអង្គុយសម្លឹងមុខធិតា លួចនឹកអណោចអធម្មក្នុង ចិត្តតែម្នាក់ឯង ៖

- ហេតុតែនាងចង់ជួយយកអាសារខ្ញុំ ទើបនាងប្រទះគ្រោះថ្នាក់ បែបនេះ! គួរអោយស្ដាយណាស់! ខ្ញុំមិនគួរបណ្ដោយអោយនាង ដើរចេញទៅកាលពីម្សិលមិញនោះសោះ ។ ចាប់ពីពេលនេះទៅ ខ្ញុំ មិនបណ្ដោយអោយនាងដើរទៅណាតែម្នាក់ឯងអញ្ចឹងទៀតហើយ! យើងនឹងធ្វើដំណើរជាមួយគ្នា ស្លាប់រស់ជាមួយគ្នាចុះ ដើម្បីអោយបានការពារគ្នាទៅវិញទៅមកផង ។ ខ្ញុំពិតជាមានវិប្បដិសារីណាស់ ដែលពីរថ្ងៃកន្លងមកនេះ ខ្ញុំបានធ្វើខ្លួនជាបន្ទុកធ្ងន់ចំពោះនាង...!

ជ្រូកលីវអង្គុយសម្លឹងមុខនារីម៉ក់ៗ ប្រឹងជំនះនូវភាពអស់នឹងឆោងដែលមានសល់នៅក្នុងខ្លួននៅឡើយ ។

- ជ្រូកលីវ...!

កូនមាន់បើកភ្នែកហៅបុរសយើងខ្សាវៗ ។

- បាទ!

ជ្រូកលីវឆ្លើយហើយក៏ស្ទុះមកជិតនាង ព្រមទាំងស្រដីថា ៖

- នាងមិនស្រួលខ្លួន សម្ងំយកកម្លាំងសិនទៅ ចាំបន្តិចទៀត ចាំ យើងនិយាយគ្នា ។

ឮដូច្នោះ នារីញញឹមស្រាលៗបន្តិចនៅលើមុខ ដាក់ជ្រូកលីវ ហើយក៏បិទភ្នែកសម្ងំ ។ ជ្រូកលីវក៏ប្រញាប់ដងទឹកដាក់បបរ...

ថ្ងៃជិតត្រង់ទើបនារីយើងបើកភ្នែកមកវិញ សាជាថ្មីម្ដងទៀត ឃើញជ្រូកលីវអង្គុយធ្មេចផ្អែកកល់ដូងជិតនាងដែរ ។ កូនមាន់ក៏ សណ្ដូកជើងឡើង

CHANBOKEO.COM

ស្រាប់តែនាងឃើញកជើងរបស់នាងជាប់ខ្សែ សម្បារចេកមួយខ្សែ
ដែលបន្តជាប់ទៅនឹងកជើងរបស់នាយជ្រូក លីវ ។ នារីក៏លូកដៃកេះមាណព ៖
- នែ៎! មានរឿងអីហ្នឹង បានជាចងកជើងរបស់ខ្ញុំ ជាមួយមិត្តជ្រូក ឯងអញ្ចឹង ?
ជ្រូកលីវភ្ញាក់ព្រើត បើកភ្នែកឡើងយ៉ាងរហ័ស ៖
- ថាម៉េចហ្នឹង ?
- មើលហ្ន៎! ខ្ញុំសួរម៉េចបានជាយកសម្បារចេកមកចងជើងខ្ញុំ
ជាមួយជើងរបស់មិត្តជ្រូកឯងអញ្ចឹង ? (កូនមាន់ប៉ូញមាត់)
- អត់ទេ! ខ្ញុំមិនបានយកខ្សែចងកជើងរបស់កូនមាន់ឯណា!
- អញ្ចឹង នរណាគេជាអ្នកចងទៅ ?
ស្រាប់តែអ្នកទាំងពីរបែរមើលមុខគ្នា រួចហើយបែរមើលបុរស
ដែលជួយគ្រាហ៍នារីយើងមកកាលពីព្រឹកព្រហាម ស្រាប់តែបាត់រូប នាយម្នាក់នោះអោយឈឹង
ហើយក៏បាត់អស់ឆ្នាំងបាយព្រមទាំង បង្វិចអង្ករ
និងសម្បត្តិទ្រព្យកញ្ចេសកញ្ចាស់សំណេសសំណល់របស់ កូនមាន់អស់រលីងម៉ង្ហ ។
- ស្លាប់ហើយ! បុរសនោះក៏ជាចោរដែរហ៏ ? (ជ្រូកលីវលាន់មាត់)
- ហ៊ឺ! មិនគួរអោយជឿសោះហ្ន៎! (កូនមាត់ខទានបន្ទរ) មនុស្ស សម័យនេះ
ទុកចិត្តគ្នាមិនបានសោះ... ឃើញមានចិត្តជួយគ្នា ស្មាន ថាជាមនុស្សល្អ តាមពិត
គេចំណាយកម្លាំងដើម្បីតាមដានរកល្បិច លួចប្លន់យើងទេតើហ៏!
ជ្រូកលីវដកដង្ហើមធំ ៖
- ពេលនេះ យើងដាច់ស្បៀង ហើយមានជម្ងឺទៀត... តើត្រូវគិត យ៉ាងណាវិញទៅ ?
កូនមាន់ញញឹមស្ងួត ៖
- ទៅអស់សង្ឃឹមធ្វើអី ? អោយតែជីវិតនៅមាន យើងត្រូវតស៊ូ បន្តទៅទៀត
មិនត្រូវរួញរាទេ ។
- កូនមាន់ទៅរួចទេ ? មើលទៅនាងចុះ ទុរន់ទុរាដល់សួរហើយ!
- ជ្រូកលីវក៏មិនគ្រាន់អីជាងខ្ញុំប៉ុន្មានដែរ... យើងទ្រុឌទ្រោមដូចតែ គ្នាទេ ។
- តែពេលនេះ កូនមាន់ទ្រុឌទ្រោមច្រើនណាស់ ។ យើងគួរដើរ ទៅរកភូមិអ្នកស្រុក
សូមពឹងពាក់គេបន្តិចមើល៍ ក្រែងលោបានជួប សប្បុរសជនណាម្នាក់ជួយយើង ។
បើយើងសំកុកទីនេះ មានតែ ដាច់ពោះស្លាប់ឬឈឺស្លាប់តែប៉ុណ្ណោះ ។

CHIANBOKEO.COM

មាណវីងក់ក្បាល ៖

- តោះ! អញ្ជឹង យើងទៅទៀត...

នាងក៏ប្រវាប្រវាក្រោកឈឺទាំងតតេះតតះ ។ ឃើញដូច្នោះ នរៈ ក៏ស្ទុះទៅជួយគ្រាហ៍ ប៉ុន្តែគួរអោយអាសូរណាស់ ទាំងពីរនាក់កំពុង តែមានភាពទុរន់ទុរាដូចគ្នា មិននឹងថានរណាជួយទប់នរណាទេ ។ គេក៏នាំគ្នាដើរទ្រេតទ្រោតតតេះតតះ ចេញទៅ...

oooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៦

## សប្បុរសជន

នៅលើផ្លូវលំដីសែនស្ងាត់មួយ

ក្រោមដំណក់ភ្លៀងស្រិចៗ...

មានអ្នកស្រែចំណាស់ម្នាក់រទេះគោមួយបរងេតងីតៗ ស្រាប់តែ
ប្រទះឃើញវត្តមានកូនមាន់និងជ្រូកលីវ កំពុងគ្រាហ៍គ្នាដើរដួល តតេះតតះកណ្ដាលផ្លូវដើបមិនរួច
ធ្វើអោយទើសផ្លូវរទេះបរទៅ មក ។ បុរសនោះក៏ចុះពីរទេះមកមើល ៖

- ក្មួយទាំងពីរទៅណាមកណាដែរហ្នឹង ? មើលអាការៈដូចជាយ៉ាប់ យ៉ឺនណាស់
ទើបនឹងរត់មកពីតំបន់ខ្មែរក្រហមកាន់កាប់មែនទេ ?

ជ្រូកលីវងក់ក្បាល ៖

- បាទពូ ! សូមមេត្តាជួយយើងទាំងពីរផង !

ដោយចិត្តអាណិតអាសូរ ពូម្ចាស់រទេះក៏សណ្ដោសនាំអ្នកទាំងពីរ
ទៅផ្ទះរបស់គាត់ដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មាន ។

- អានាង ស្នាក់ទីនេះសិនទៅ ។ ប្រពន្ធពូគេនាំកូនៗទៅមើល
យាយដែលមានជម្ងឺនៅឯបន្ទាយនាងឯណោះ ពីរបីថ្ងៃទៀតទើប ត្រឡប់មកវិញ ។
ដូច្នេះក្មួយស្នាក់ទីនេះបណ្ដោះអាសន្នសិនទៅ ទំរាំមានកម្លាំង
ចាំធ្វើដំណើរបន្តទៅរកស្រុកភូមិរបស់ខ្លួនវិញ ។

CHANBOKEO.COM

មើលទៅពូអ្នកស្រែនោះមានសន្ដានចិត្តទូលាយណាស់ ថ្វីបើ គាត់គ្រាន់តែជាអ្នកស្រែក្រីក្រ ដែលមានត្រឹមតែផ្ទះខ្ទមកញ្ជាស់មួយ ខ្នង ប្រក់ស្លឹកត្នោតដ៏តូចចង្អៀត សង់កណ្ដាលដីភូមិតូចមួយ ក្បែរ មាត់ត្រពាំងទឹកដែលមានព្រលឹតផ្ការហង់ ក៏ដោយ ។

- នេះ ពូមានបាយកកបន្ដិចបន្តួច ហូបចំអែតពោះខ្លះៗសិនទៅ!

(ពូនោះថាហើយហុចបាយមួយចានមកផង) ពូក៏មិនមានអីដែរ ព្រោះទើបរត់ចេញមកពីបរវេលកាលពីខែមុន ជួបប្រពន្ធកូននៅទី នេះ ក៏ស្នាក់នៅទីនេះអញ្ចឹងទៅ ។

- បាទ! អរគុណពូ!

ជ្រូកលីវទទួលបាយហើយមិនបានបរិភោគទេ សុខចិត្តហុចឲ្យ ទៅកូនមាន់ដែលកំពុងតែដេកលើចំបើងក្នុងខ្ទមស្ងៀមស្ងាត់ ។

- កូនមាន់! ហូបបាយមួយម៉ាត់សិនទៅ ក្រែងមានកម្លាំងណា!

ថាហើយ គេក៏ជួយត្រកងលើកនាងឡើង អោយអង្គុយផ្អែក នឹងបង្គោលសសរឫស្សី រួចក៏ចាប់បាយបញ្ចុកនាង ។ អ្នកស្រែ សប្បុរសនោះ អង្គុយមើលអ្នកទាំងពីរភ្លៀកៗ រួចហើយក៏បន្លឺវាចា ដោយសម្លេងទន់ភ្លន់ ថា ៖

- ល្អហើយ ដែលក្មួយទាំងពីរចេះរក្សាគ្នាទៅវិញទៅមក មិនរត់ ចោលគ្នា ។ ពូជួបគូស្រករក្មេងៗដែលចាប់ដៃជាគូស្រករ ក្នុង សម័យអង្គការបដិវត្តន៍ខ្មែរក្រហមជាច្រើនគូហើយ ។ គេមិនសូវ រក្សាគ្នាទេ បន្ទាប់ពីអង្គការត្រូវរលំរលាយទៅ ព្រោះគេទាំងនោះជា គូស្រករដែលទទួលការបង្ខិតបង្ខំពីអង្គការ អោយរៀបការនឹងគ្នា ។ ប៉ុន្ដែ ចំពោះក្មួយឯងទាំងពីរ មើលទៅ ដូចជាស្រឡាញ់នឹងទុក្ខ ធុរៈគ្នាណាស់ ខុសប្លែកគូស្រករក្មេងៗដទៃទៀត ។ សម័យឥឡូវ នេះ មនុស្សប្រែក្លាយជាអាត្មានិយមអស់ហើយ ចូលចិត្តបញ្ឈរភ្នែក មើលបំណាំគ្នា មិនសូវស្គាល់ទុក្ខធុរៈគ្នាទៅវិញទៅមកទេ ។ ម្នាក់ៗ គិតយកតែរស់រៀងៗខ្លួន ។ ភាពយង់ឃ្នងរបស់របបកុម្មុយនិស្ដ ភាពក្រខ្សត់ ភាពទាល់ច្រកក្នុងជីវិត និង ការព្រាត់ប្រាសបុគ្គល ជាទីស្រឡាញ់ក្នុងគ្រួសារ បាននាំអោយចិត្តមនុស្សជក់ជាប់នូវការ ឈឺចាប់និងកំហឹងយ៉ាងខ្លាំងក្លា ពិបាករំសាយ... ធ្វើអោយប្រទេស ខ្មែរក្លាយពីកោះសន្តិភាព ទៅជាកោះអសន្តិសុខប្រទុស្តរាយ ប្រកប ដោយកំហឹងគុំគួននិងភាពស្អប់ខ្ពើមចំពោះគ្នា គួរអោយសង្វេគ...

មានប្រសាសន៍មកដល់ត្រង់នេះ ពូម្ចាស់ខ្ទមដកដង្ហើមធំយូ យ៉ាងវែងទើបស្រដីបន្តទៀតថា ៖

- ប៉ុន្តែ ទោះបីជាយ៉ាងណា ពូសូមជូនពរអោយអ្នកទាំងពីររក្សាគ្នា លុះចាស់ព្រឹទ្ធចាស់ព្រេងណា៎! កុំបែកបាក់គ្នាឲ្យសោះ ។ សូម អោយស្រឡាញ់គ្នា រក្សាគ្នាយ៉ាងល្អបែបនេះរៀងរហូតទៅ..!

ជ្រូកលីវអង្គុយស្តាប់ពូម្ចាស់ខ្ទមមានប្រសាសន៍ លុះចប់ចុងចប់ ដើម ដោយឥតមានស្រដីអ្វីមួយម៉ាត់ទេ ។ គេគ្រាន់តែលួចចោល កន្ទុយភ្នែកសម្លឹងកូនមាន់ភ្លៀកៗ ចង់ដឹងអារម្មណ៍នារី ពេលបុរស ចំណាស់យល់ច្រឡំថាគេនិងកូនមាន់ជាគូស្វាមីភរិយានឹងគ្នា ។ រីឯ មាណវីរបស់យើងវិញ កំពុងតែមានអាការៈឈឺចាប់ធ្ងន់ធ្ងរ មិនមាន កម្លាំងនឹងនឹកគិតអំពីរឿងអ្វីទេ ។ នាងទទួលបាយដែលជ្រូកលីវ បញ្ចុករួចហើយក៏ឆ្មេចសម្រាកយកកម្លាំង សម្រន់ការឈឺចាប់ពីមុខ របួសជាំពេញខ្លួនទាំងនោះ យ៉ាងស្ងៀមស្ងាត់តែម្នាក់ឯង ។

នៅក្នុងជំរៅចិត្តរបស់នាយជ្រូកលីវ គេបែរជាមានអារម្មណ៍ រំភើបប្លែកយ៉ាងណាមិនដឹងទេ ដែលសុខៗបុរសចំណាស់មកជូន ពររូបគេនឹងកូនមាន់យ៉ាងពិរោះដូច្នេះ ។ គេលួចចោលភ្នែកមើល កូនមាន់ជាញឹកញាប់ ។ ថ្វីបើពេលនេះ គេកំពុងដឹងថា ខ្លួនគេកំពុង តែអស់កម្លាំងល្វើយយ៉ាងណាក៏ដោយ ក៏មានអារម្មណ៍ថា ខ្លួនគេ កំពុងមានសេចក្តីសុខក្នុងចិត្តឥតឧបមា ដែលគេមានឱកាសបាន មកនៅក្បែរនារីមួយរូបនេះវិញម្តងទៀត ។

ឃើញអ្នកទាំងពីរមានអាការៈយ៉ាប់យ៉ឺនពេក បុរសចំណាស់ក៏ មានប្រសាសន៍ថា ៖

- បើមិនទាន់ស្រួលខ្លួនស្រួលបួលទេ ក្មួយនៅស្នាក់ទីនេះពីរបីថ្ងៃ សិនក៏បានដែរ ទំរាំមានកម្លាំងធ្វើដំណើរបន្តទៅទៀត ។ ផ្ទះពូក្រ ណាស់ មិនមានអ្វីជួយផ្គត់ផ្គង់ក្មួយទេ មានតែអង្ករប៉ុន្មានកំប៉ុង ដែលនៅសល់ក្នុងពាងនិងបន្លែបង្កាក្បែរផ្ទះនេះ ។ ពេលនេះ ពូធ្វើ ស្រែនៅជិតៗនេះ សល់ពេលសំរាក ចាប់ក្តាមចាប់ខ្យងចាប់ត្រីយក ដូរអង្ករខ្លះៗ ដើម្បីរស់សិនទៅ ។ ទម្រាំដល់រដូវច្រូត ពូនឹងមាន ស្រូវហូបបរិបូណ៌វិញហើយ ។

ជ្រូកលីវញញឹម ហើយលើកដៃសំពះ ៖

- សន្តានចិត្តសប្បុរសរបស់ពូចំពោះក្មួយទាំងពីរនាក់ នៅពេលនេះ មានទំហំធំធេងវាស់មិនបានទេ ។ ក្មួយសូមអរគុណចំពោះទឹកចិត្តដ៏ ថ្លៃថ្លារបស់ពូណាស់ ដែលអនុញ្ញាត្តិអោយក្មួយស្នាក់នៅដោយមិន មានការទើសទាល់ក្នុងចិត្ត ។

អ្នកស្រែនោះញញឹម ហើយស្រដីថា ៖

CHANBOKEO.COM

- មិនអីទេ! គិតថាយើងជាញាតិសន្តាននឹងគ្នាទៅចុះ ។ សម័យ ខ្មែរក្រហម
បងប្អូនរបស់យើងបានត្រូវអង្គការបដិវត្តន៍សម្លាប់ស្ទើរ ផុតពូជគ្រប់គ្រួសារអស់ទៅហើយ
សល់តែពួកយើងដែលនៅរស់ រាយប៉ាយទាំងនេះ ។ បើសិនជាយើងរាប់គ្នាជាញាតិនឹងគ្នា នោះ
ប្រហែលជានាំអោយចិត្តយើងម្នាក់ៗ មានការកក់ក្តៅខ្លះៗឡើងវិញ
មិនកំព្រាងាកណ្តោចកណ្តែងតទៅទៀតឡើយ... ។

ជ្រូកលីវមានអំណររំភើបក្នុងចិត្តជាអតិបរមា ដែលគេបានមក
ប្រទះមនុស្សដែលមានចិត្តសប្បុរសទូលំទូលាយ ដូចពូអ្នកស្រែមួយ រូបនេះ ។
មើលទៅជីវភាពរបស់គាត់ មិនសមបើគាត់ជាមនុស្សល្អ ដល់ថ្នាក់ហ្នឹងឡើយ
ព្រោះគាត់ក្រីក្រអត្តខាត់ណាស់ ។ បែរសម្លឹង មើលមុខមាត់គិតវិញ
គឺមិនគួរអោយទុកចិត្តបន្តិចសោះឡើយព្រោះ ថា គាត់មានសម្បុរខ្មៅក៏ខ្មៅ មុខខ្មួត សក់កន្ទ្រើង
ខោអាវរខេក រខោកមើលមិនយល់ រកតែបិទខ្លួនស្ទើរមិនជិត មិនខុសប៉ុន្មានពី
កូនមាន់និងជ្រូកលីវដ៏រយីករយាកនោះឡើយ ។ ចៃដន្យ រូបសម្បត្តិ
មិនបានឆ្លុះបញ្ចាំងអោយឃើញតម្លៃពិតរបស់មនុស្សទេ ។ ពូអ្នក ស្រែម្នាក់នេះ
បែរជាមានសំដីសំដៅគួរអោយរាប់អាន មានសន្តាន ចិត្តចំពោះញាតិ យ៉ាងទូលំទូលាយក្រៃលែង
ខុសពីរូបសំបករបស់ គាត់ដូចមេឃនឹងដី ។

រាត្រីនោះ...

ពូអ្នកស្រែដើរចូលមកក្នុងខ្ទមសម្លឹងមុខកូនមាន់និងជ្រូកលីវ ៖
- អានាងឯងនិងប្រពន្ធដេកនៅក្នុងខ្ទមចុះ ព្រោះប្រពន្ធកូន របស់ពូមិននៅ ។
ចំណែកពូវិញចេញទៅចងមុងដេកនៅខាងក្រៅ ផ្ទះយាមគោនិងរទេះវិញចុះ
ក្រែងមានអ្នកណាចិត្តមិនល្អ ចូលមក
លួចអស់ ខានប្រើ ។

មានប្រសាសន៍ហើយ ពូនោះក៏បោះមុងមួយមកអោយជ្រូកលីវ
ហើយក៏ដើរចេញទៅចងមុងសំរាន្តលើរទេះ យាមគោមួយនឹមដែល
ជាសម្បត្តិដ៏ថ្លៃថ្លារបស់គ្រួសារគាត់ ទុកឲ្យនាយជ្រូកលីវនិងកូនមាន់
ទទួលទានដំណេកនៅលើគ្រែមួយ ដែលគ្រាន់តែយកមែកឈើលះ តូចៗ
មកតម្រៀបជារនាបដាក់ក្រាលចំបើង រួចហើយក្រាលកន្ទេល ស្លឹកត្នោតពីលើសំរាប់គេង ។
ចំណែកមុងដែលពូអ្នកស្រែប្រគល់ អោយមកនោះ ក៏ជាមុងកណ្តាចតូចចង្អៀតមួយ

CHANBOKEO.COM

ដែលមានបំណះ ប៉ះពាវច្រើនកន្លែង មិនដឹងថា អោយគេងប្រជ្រៀតគ្នាយ៉ាងណា ។ ចំណែកកន្លែងគេងវិញក៏ជាកន្លែងតែមួយគត់ក្នុងខ្ទម ដែលអ្នកទាំងពីរអាចផ្ដេកកាយសំរាកយកកម្លាំងបាន ព្រោះត្បិតទីដទៃទៀតក្នុងខ្ទមសុទ្ធតែជាដីសើមៗទាំងអស់គ្រប់កន្លែង ។ ពេលនេះ ជារដូវ វស្សាភ្លៀងធ្លាក់ជាញឹកញាប់ស៊ឹងរាល់ថ្ងៃ សមនឹងខ្ទមដាចលិចសឹង គ្រប់កន្លែងផង សមនឹងភាពទុរគតក្នុងផ្ទះផង មើលទៅវេទនា ភ្នែកណាស់ ។ ប៉ុន្តែពូអ្នកស្រែបែរជាសុខចិត្តទៅចងមុងសំរាន្ត នៅក្រោមដំបូលរទេះកណ្ដាចនោះ ដើម្បីទុកកន្លែងអោយអ្នកទាំង ពីរបានសំរាកស្នាក់នៅ ឃើញថាគាត់ជាមនុស្សមានចិត្តសទ្ធាជ្រះថ្លាក្រៃលែង ដែលមិនមើលបំណាំមនុស្សទុរគតដាច់សង្វែងដូចកូន មាន់ និងជ្រូកលីវ ។

បែរមើលទៅអាការៈកូនមាន់វិញ ថ្ងៃនេះ នាងមានអាការៈ យ៉ាប់យ៉ឺនហួសការស្មានមិនឮមានសំដីអ្វីមួយម៉ាត់ទេ តាំងពីមក ដល់ផ្ទះពូអ្នកស្រែមក ។ ឃើញនាងសម្ងំបិទភ្នែកយកកម្លាំង នាយ ជ្រូកលីវក៏ស្ទុះយកដៃស្ទាបថ្ងាសរបស់នាងឃើញមាណវីកំពុងគ្រុន ក្ដៅគគុក ។ ពេលនោះ រូបនាយក៏កំពុងគ្រុនផីងឆោងមិនស្រួលខ្លួនដូចគ្នាដែរ ប៉ុន្តែដោយក្ដីបារម្ភចំពោះកូនមាន់ គេសុខចិត្តប្រឹងដើប ចងមុងអោយនាងគេងហើយសុខចិត្តគេងអោបដៃនៅក្រៅមុងតែ ម្នាក់ឯង ត្បិតមិនហ៊ានចូលមុងគេងក្បែរនារី ។

រាត្រីនេះ មាណពគេងរសាប់រសល់ទាល់ភ្លឺ... យូរៗ គេដើប លបមើលអាការៈកូនមាន់ក្រែងនាងមិនស្រួល ប៉ុន្តែ នារីមួយរូប នេះប៉ិនអត់ធ្មត់ណាស់ ។ ពេញមួយយប់ហើយជ្រូកលីវមិនឮនាង ថ្ងូរអ្វីមួយម៉ាត់ទេ ថ្វីបើគេឃើញនាងរសាប់រសល់ប្រែខ្លួនចុះឡើងច្រើនដងក៏ដោយ ។ បុរសយើងគេងកើយដៃស្ដាប់មូសយំដេរៗកំដរ ត្រចៀកភ្នែកសម្លឹងកូនមាន់តាមចន្លោះស្បៃមុងកណ្ដាច រហូតទន់ ត្របកភ្នែកលង់លក់ទៅ...

..................................

ព្រហាមស្អែកថ្មីក៏ចូលមកដល់...

- អានាង! ក្រោកហើយហ្អែស ?

ពូអ្នកស្រែសួរជ្រូកលីវដែលកំពុងដើរចេញពីខ្ទមទាំងផីងឆោង ទ្រេតទ្រោត ។ ឃើញដូច្នោះ គាត់ក៏មានវាចាថែមទៀតថា ៖

- បើឯងមិនទាន់មានកម្លាំងស្រួលបួលទេ ទៅដេកវិញសិនទៅ! ពូទៅស្រែសិនហើយ ។ នៅក្នុងពាងមានសល់អង្ករខ្លះ ហើយនិង អំបិលនៅក្នុងក្រឡ បបរហូបកំដរពោះទៅ ។

CHANBOKEO.COM

ចាំពូទៅស្ទោះសំបក ឈើមកដាំទឹកអោយឯងផឹក ក្រែងលោមានកម្លាំងជាគ្រុន និងជម្ងឺឈឺថ្កាត់ផ្សេងៗ ។ ល្ងាចបន្តិច ពូមកវិញហើយ!

ការពិត ជ្រូកលីវកំពុងអស់កម្លាំងមែនហើយ ប៉ុន្តែ គេខ្លាចចិត្តពូអ្នកស្រែទើបមិនហ៊ានដេកទ្រមក់ ។ លុះពូគាត់មានប្រសាសន៍ យ៉ាងដូច្នោះ គេក៏វិលទៅប្រះខ្លួនគេងលើគ្រែចំបើងវិញសាជាថ្មី ។ បន្តិចមក ពូអ្នកស្រែក៏ទឹមរទេះចេញទៅស្រែបាត់ទៅ ។

ប្រហែលជាមួយម៉ោងក្រោយមក...

កូនមាន់ភ្ញាក់នឹងខ្លួន ប្រឹងងើបឡើង ឃើញជ្រូកលីវគេងអោប ដៃក្រញុនខាងក្រៅមុង ។ នាងហាក់ដូចជានឹកអាណិតបុរសនេះនៅ ក្នុងចិត្តគ្រលួច ដែលគេហាក់ដូចជាតស៊ូតតេះតតះជាមួយនាង មិន ព្រមបែកទៅណាមកណាសោះ ថ្វីបើគេទើបតែស្គាល់នាវីពីរបីថ្ងៃ នេះ ក៏ដោយ ។

ធីតាងើបឡើង ដើរចេញទៅបង្កាត់ភ្លើងដាំបបរ ។ កំពុងតែ ឈ្ងោកមុខផ្លុំភ្លើងទាំងអស់កម្លាំងផង វិលមុខផង ស្រាប់តែឃើញ ដៃមួយមកចាប់លើកនាងឡើង ។ កូនមាន់ងាកបែរមើលឃើញជ្រូក លីវឈ្ងោកមុខហើយស្រដីមករកនាងថា ៖

- កូនមាន់មិនទាន់ស្រួលខ្លួនទេ! មិត្តទៅគេងវិញសិនទៅ! ចាំខ្ញុំបង្កាត់ភ្លើងដាំបបរអោយនាងចុះ ។

- ខ្ញុំមិនអីទេ! (កូនមាន់ឆ្លើយ) ថ្ងៃនេះ ខ្ញុំមានអារម្មណ៍គ្រាន់បើ ជាងមុនបន្តិច គ្រាន់តែនៅឈឺខ្លួនបន្តិចបន្តួចប៉ុណ្ណោះ ។

ជ្រូកលីវសម្លឹងមើលស្នាមជាំលើមុខនិងដៃជើងរបស់នាង ៖

- នាងមានរបួសជាំខ្លួនដល់ម្លឹងទៅហើយ នៅថាមិនអីម៉េចកើត ? នែ៎! ទៅគេងសិនទៅ! ខ្ញុំមិនលួចហូបបបរចោលនាងទេ កុំភ័យ ពេកមើល៍!

- យី! នរណាថាមិនភ័យនោះ ? កំពុងតែហេវផង បើសិនអត់ អាហារមួយថ្ងៃនេះទៀត ខ្ញុំច្បាស់ជាលាមិត្តជ្រូកឯងរហូតហើយ ។

- និយាយតែផ្តាស! កូនមាន់ឯងស្បែកស្វិតយ៉ាងនេះ គ្មាននរណាគេអោយទៅណាមកណាងាយៗទេ ជាពិសេស បើអត់កូនមាន់ទៅ ជ្រូកលីវច្បាស់ជាកណ្តោចកណ្តែងស្លាប់ហើយ...

ឮសំដីនេះ កូនមាន់ក៏រពឹសមាត់ឆ្លើយថា ៖

- ទោះកូនមាន់ស្លាប់ជាខ្មោច ក៏តាមលងមិត្តជ្រូកឯងមិនអោយដេក លក់ស្រួលដែរ ព្រោះយប់មិញស្រមុកតម្លង់ខ្ញុំទល់ភ្លឺឯណោះ មិនទាន់ជម្រះបញ្ជីគ្នានៅឡើយទេណា៎!

ជ្រូកលីវសើចខឹកៗ បាត់ឈឺ បាត់អស់កម្លាំងរលីងតែម្តង ៖

- ហើយបញ្ជីហ្នឹងជម្រះយ៉ាងម៉េច ប្រាប់ខ្ញុំផងមើល៍ ?

- គង់តែដឹងទេ!

- តែខ្ញុំចង់ដឹងឥឡូវ !

- យី! កុំលេងបង្ខំអញ្ជឹងមើល៍ តិចជម្រះមែនឥឡូវ !

- ជម្រះសាកមើលទៅ ក្រែងជ្រះមែន!

ជ្រូកលីវនិយាយលលេងកូនមាន់យ៉ាងរីករាយ ។ ពេលនេះ គេ គិតថា កូនមាន់មានកម្លាំងបន្តិចហើយ ព្រោះនាងអាចដើបអង្គុយ ជជែកលេងជាមួយនាយបាន មិនដូចពីម្សិលទេ ដែលនៅដេក រង្វៀមពេញមួយថ្ងៃ មិនមាត់មិនក ។

- អញ្ជឹង ដាំបបរទៅ! ខ្ញុំទៅសម្ងំគេងវិញហើយ ។

កូនមាន់ស្រដីប្រាប់ជ្រូកលីវ ហើយក៏លូនទៅគេងវិញធ្វើមិន ដឹង ។ មាណពយើងសម្លឹងតាមនាងបណ្តើរ ស្រវាក្តាប់អង្ករដាក់ ឆ្នាំងបណ្តើរ រួចហើយស្រដីសួរថា ៖

- កូនមាន់! ប្រាប់ខ្ញុំបានទេ ថាកាលពីពីរថ្ងៃមុន នាងមានរឿងអ្វី ទើបទទួលរងគ្រោះផ្លូវកាយធ្ងន់ធ្ងរដល់ម្លឹង ?

កូនមាន់កំរើកខ្លួនបែរមកវិញ ឆ្លើយតបយ៉ាងល្ហើយថា ៖

- គឺខ្ញុំយកមាសទៅដូរប៉ះពួកចោរពីរនាក់វាប្លន់... ថៃដន្យមានអ្នកស្រុកដើរកាត់ធ្វើអន្តរាគមន៍ទាន់ទើបខ្ញុំផុតគ្រោះថ្នាក់... បានត្រឹមតែ របួសបែកមុខបែកមាត់ដៃជើង...

ជ្រូកលីវសំលឹងនាងដោយក្តីអាណិតអាសូរ ៖

- ខ្ញុំមិនគួរបណ្តោយអោយកូនមាន់ទៅលំបាកសោះ... តែមិនអីទេ ពេលនេះកូនមាន់រួចផុតគ្រោះថ្នាក់ហើយ ខ្ញុំមិនឲ្យមិត្តទៅយ៉ាប់យ៉ឺន អីចឹងម្នាក់ឯងទៀតទេ ។ អស់ចុះមាស កុំអោយតែអស់ជីវិត យើងនៅអាចរកវាបានមកវិញ ។

កូនមាន់ញញឹមតិចៗ ហើយឆ្លើយថា ៖

- អ្នកណាថាខ្ញុំអស់មាស ? ពួកចោរគ្មានសំណាងដល់ម្លឹងទេ ។

ជ្រូកលីវបើកភ្នែកធំៗ ៖

- មែនហ្អែស ? ហើយកូនមាន់ទុកយ៉ាងណាបានវាប្លន់មិនបាន ?

- កុំចង់ដឹងអី! គ្រាន់តែដឹងថា ខ្ញុំមិនបានបាត់បង់អ្វីទេ ក្រៅពីត្រូវ ពួកវាចោមវាយ...

CHANBOKFO.COM

- អញ្ចឹងធូរទ្រូងបន្តិច... មិត្តសំងំគេងសិនទៅ ចាំបាយឆ្អិន ចាំខ្ញុំ ដាស់ ឮនៅ ?

កូនមាន់ឮហើយក៏បិទភ្នែកគេងវិញទាំងល្ងិតល្ងៃ ។

.........................

ពីរបីថ្ងៃកន្លងទៅ....

- ជ្រូកលីវ !

- បាទ !

- ពីរថ្ងៃហើយណា៎ ដែលពូអ្នកស្រែនោះមិនទាន់ត្រលប់មកផ្ទះ មានរឿងអ្វីទេដឹង ?

ខ្ញុំដូចជាពិភាល់ក្នុងចិត្តណាស់ ។ ម្យ៉ាងខ្ញុំដូច ជាធូរស្រាលក្នុងខ្លួនបន្តិចហើយ ចង់ធ្វើដំណើរបន្តទៀត...

- ខ្ញុំក៏ព្រួយក្នុងចិត្តដូចតែកូនមាន់ដែរហ្នឹង មិនដឹងហេតុអ្វីបានពូ គាត់មិនត្រលប់មកផ្ទះ...

- ហើយបើចេញដំណើរទៅដោយមិនបានប្រាប់ម្ចាស់ខ្ទមដូចជាមិន សម តែបើរង់ចាំ... មិនដឹងពេលណាគាត់នឹងមក ហើយយើងក៏ បរិភោគអង្ករបស់គាត់អស់រលីងដែរ...

ជ្រូកលីវដើរចុះដើរឡើងមួយស្របក់ ក៏ស្រដីថា ៖

- ណ្ហើយចុះ ! អត់សុជីវធម៌បន្តិចក៏អត់ទៅ ! យើងមិនអាចទ្រាំ នៅដាច់ពោះទីនេះបានឡើយ ។

ថាហើយគេក៏អូសដៃនារីចេញទៅក្រៅ យកខ្សែចងទ្វារហើយ ក៏និយាយដាក់ទ្វារថា ៖

- បើមាននិស្ស័យ ក្មួយនឹងមកសងគុណពូវិញមិនខាន ។

គេក៏ឱនកេសាលើកដៃសំពះទ្វារខ្ទម ។ កូនមាន់ក្រញាស់ឃើញ ដូច្នេះក៏លើកដៃប្រណម្យសំពះតាមពីក្រោយ ។

- ជ្រូកលីវដឹងភូមិសាស្ត្រដំបន់នេះខ្លះទេ ? តើយើងគួរធ្វើដំណើរ ទៅខាងណា ? (កូនមាន់សួរ)

- មិនដឹងទេ តែបើតាមខ្ញុំសង្កេតដើងការណ៍ដំណើរអ្នកស្រុក គេ មិនដើរតម្រង់ទៅលិចតែម្ដងទេ ត្បិតមានគ្រោះថ្នាក់ពេក ប្រហែល ជាគេដើរវាងចេញទៅកើតខាងព្រៃមាន់ហើយឡើងទៅតាមភ្នំស្រុក សរសៀរទៅខាងជើងរួចហើយទើបចេញទៅខាងលិចវិញ ដើម្បី វាងអន្ទាក់ ។ ខ្ញុំគិតថាផ្លូវនេះប្រហែលមានសុវត្ថិភាពជាជាង ។

កូនមាន់ឈ្ងោកមុខគិត បន្តិចក៏ងើយមុខឡើងស្រដីថា ៖

- នៅពេលនេះ យើងគ្មានអ្វីសល់ទេ ក្រៅពីជីវិត ។ នៅក៏អត់ បាយស្លាប់ ទៅក៏ប្រទះនឹងគ្រោះដល់ស្លាប់... ដូច្នេះ គ្មានអ្វីដែលគួរ អោយភ័យខ្លាចតទៅទៀតទេ ។ គួរតែប្រថុយទៅចុះ ក្រែងជួប រស្មីជីវិតថ្មីទៀត...

CHANBOKEO.COM

ជ្រូកលីវឮសំដីនូច្នេះក៏ញញឹមឡើង ៖

- កូនមាន់ក្លាហានមែន! តោះយើង! ទៅ!

០០០០០០០០០០០០០០

០០០០០០

០

CHANBOKEO . COM

# វគ្គទី៧
# អាសន្នថ្មី

ជាច្រើនម៉ោងក្រោយមក...

ក្រោមស្បៃមេឃដ៏ស្រអាប់មានភ្លៀងធ្លាក់ស្រិចៗ...

- កូនមាន់ទៅរួចទេ ? មើលទៅមិត្តដូចជារងារណ្ដំថ្កាមខ្លាំងណាស់

- ខ្ញុំមិនអីទេ... គិតតែពីដើរទៅមុខទៀតទៅ... បើអង្គុយសំរាក ស្ងៀមវិញ វារិតតែធ្វើអោយរងាឡើងណា នឹងទេ ?

ស្រាប់តែជ្រូកលីវលាន់មាត់ឡើង ៖

- កូនមាន់! មើលសាកសពមួយនោះហ្ន៎!

កូនមាន់ក្រញាសងាកបែរតាមចង្អុលដៃរបស់ជ្រូកលីវ ឃើញ សពមួយផ្កាប់មុខនៅក្បែរភ្លឺស្រែដែលពួកគេកំពុងដើរ ៖

- គឺ... ពូអ្នកស្រែតើហ៎! ជ្រូកលីវ! (កូនមាន់លាន់មាត់)

ទាំងពីរនាក់ស្ទុះទៅជិតសពហើយលើកបំបែរឡើង ។

- តើនរណាចិត្តសាហាវធ្វើបាបពូដល់ថ្នាក់នេះ ? (កូនមាន់និយាយ ទាំងទឹកភ្នែករលីងរលោង)

- គ្មានអ្វីទេ ក្រៅពីចោរសម្លាប់ដើម្បីប្លន់យកគោយករទេះរបស់ គាត់ហ្នឹងឯង (ជ្រូកលីវស្រដីដោយទឹកមុខសង្វេគ) មើលទៅគាត់ ប្រហែលជាត្រូវគេសម្លាប់តាំងពីពីរថ្ងៃមុនម្ល៉េះ ។

ជ្រូកលីវបែរមើលជុំវិញខ្លួន ៖

CHANBOKEO.COM

- ម៉្តំនេះដាច់ស្រយាលពន់ពេក... ពួកយើងគ្មានមធ្យោបាយនឹងកប់ សពរបស់ពូទេ... គួរអោយអណោចអធម្មណាស់...

ជ្រូកលីវធ្វើមុខស្រងូត ។ បន្ទាប់មកគេក៏កាច់មែកឈើមកគ្រប សពរបស់ពូអ្នកស្រែ ហើយក៏ទាញដៃកូនមាន់មកលុតជង្គង់ថ្វាយ បង្គំ ៖

- សូមអោយវិញ្ញានក្ខន្ធ័របស់ពូបានដល់សុគតិភពផង! ក្មួយសូម លាសិនហើយ ។

ទាំងពីរនាក់បន្ទន់សិរសាជាចុងក្រោយ ហើយក៏នាំគ្នាបន្តដំណើរ តទៅទៀត ។

- គិតទៅខាងណាវិញទៅ ជ្រូកលីវ ?

- ចេះតែដើរស្មានៗទៅណាកូនមាន់ ក្រែងជួបងានអ្នកស្រុក

- ដើរព្រាវៗយ៉ាងនេះ មិនវង្វេងពេញព្រៃទៅហើយទេឬ ?

- ផ្សងសំណាងទៅណា... ការពិត ខ្ញុំធ្លាប់រៀនអំពីភូមិសាស្ត្រដីខ្មែរ ដែរ កាលពីនៅមធ្យមសិក្សា សង្ឃឹមថាអាចប្រើការបាន ។ ម៉ោះ! តាមខ្ញុំមក!

ពន្ធូច្នោះ កូនមាន់ក៏ឈ្ងោកមុខដើរតត្រុកពីក្រោយជ្រូកលីវ...

ច្រើនម៉ោងក្រោយមកទៀត គេក៏បានប្រទះនឹងហ្វូងអ្នកស្រុក ពីរបីគ្រួសារមានចាស់ មានក្មេង មានទាំងទារកតូចមួយផង ។ ឃើញអ្នកទាំងពីរមានសភាពរខេករខោក ពួកគេក៏នឹងថា ជ្រូកលីវ និងកូនមាន់ជាអ្នកស្រុកសាមញ្ញដូចគ្នា ម្ល៉ោះហើយពួកគេក៏ហៅឲ្យ ចូលរួមធ្វើដំណើរជាមួយដោយមិនខ្លាចរអា ។ នៅគ្រានោះកម្រមាន នរណាទុកចិត្តគ្នាណាស់ ត្បិតមនុស្សម្នាក់ៗខ្លាចម្នាក់ទៀត ជាបក្ស ពួកខាងសត្រូវរបស់ប្រទេសខ្លួន ឬខ្លាចថាជាចោរព្រៃ ។

ផាំង! ផាំង! ផាំង!

គ្រាប់កាំភ្លើងលាន់ឡើងយ៉ាងខ្ទ័រខ្ទារ ។ អ្នកស្រុកស្រែកខ្សៀវខ្សា ឡើងរត់គេចប្រសេចប្រសាច ស្រាប់តែមានសម្លេងគំរាមថា ៖

- នៅស្ងៀមម៉ាកន្លែង! ពុំនោះសោត យើងបាញ់ស្លាប់!

កូនមាន់រត់ភ្លែតពួនក្រោយខ្នងជ្រូកលីវ ឃើញបុរសមួយហ្វូង ក្នុងឯកសណ្ឋានពណ៌ខ្មៅប្រដាប់អាវុធគ្រប់ដៃ ក៏លាន់មាត់ខ្សឹបៗ ដាក់ជ្រូកលីវថា ៖

- ទីវរហើយ! ពួកនេះជាកងទ័ពខ្មែរក្រហម... យើងត្រូវគេកៀរ ចូលព្រៃមិនខាន ហើយបើមិនធ្វើតាមគេ យើងនឹងស្លាប់...

ជ្រូកលីវងក់ក្បាល ហើយខ្សឹបវិញថា ៖

- មែនហើយ យើងបណ្ដែតខ្លួនតាមទឹកហូរសិនទៅ...

CHANBOKEO.COM

ភ្លាមនោះ ទារកយំវ៉ាឡើង ។

- វើ៉យថ្លង់ណាស់! នែ៎ មិត្តឯងមើលកូនកុំអោយយំមើល៍! ហើយ ទាំងអស់គ្នាដើរតាមយើងទៅភ្នំឆត្រ!

អ្នកស្រុកទាំងនោះមានទឹកមុខតក់ស្លុតណាស់ ខ្លាចចុងកាំភ្លើង មិនប្រណី ។ ពួកគេក៏នាំគ្នាឈ្ងោកមុខដើរស្ងៀមស្ងាត់ តាមពីក្រោយ បុរសអាវខ្មៅបីបួនរូបដែលនាំមុខទុកអោយមួយហ្វូងទៀត កាន់ កាំភ្លើងភ្ជង់ពីក្រោយ ។ មកដល់ដីព្រៃមួយដុំមានសភាពរៀងក្រាស់បន្តិច អ្នកស្រុកពីរនាក់ស្ទុះគេចយ៉ាងរហ័សពីហ្វូងកំណៀរ រត់ប្រូច ចូលព្រៃប្រោក ។

ផាំង! ផាំង! ផាំង! ស្នូរកាំភ្លើងផ្ទុះឡើងប្រសាច ។ មើលទៅអ្នកស្រុកពីរនាក់នោះគ្មានថ្ងៃវិលត្រលប់ទេ កាលបើពួកទ័ពអាវខ្មៅបាញ់ពីក្រោយពួកគេឡើងសុសព្រៃយ៉ាងនេះ ។

ឃើញហេតុការណ៍នេះហើយ កូនមាន់ស្ងួតទឹកមាត់អស់រលីងថ្វីបើជ្រូកលីវលួចកាន់ដៃផ្តល់កម្លាំងចិត្ត មិនអោយនាងភិតភ័យក៏ ដោយ ។ កូនមាន់ក៏រណ្តំចង្កាក្រឹកៗទប់លែងជាប់តែម្តង ។

ច្រើនម៉ោងក្រោយមក ពួកគេបានមកដល់ទីតាំងនៅចង្កេះភ្នំមួយដែលមានមនុស្សពាក់អាវខ្មៅច្រើនឡើងងងឹតព្រៃ ។

- នែ៎ មិត្តឯងពីរនាក់ជាប្តីប្រពន្ធនឹងគ្នាមែនទេ ?

ជ្រូកលីវភ្ញាក់ព្រើត ពីការលង់អារម្មណ៍ក្នុងការសង្កេតស្ថានភាព ទិសដំបន់ ហើយបែរមើលកូនមាន់ដែលធ្វើមុខស្លេកមិននិយាយស្តី រួចហើយបែរមើលម្ចាស់សម្លេង ឃើញយោធាប្រដាប់អាវុធមួយរូប កំពុងសួរដោយសំដីខែងរ៉ែង ។

- បាទ! មែនហើយ! មិត្តនារីនេះជាគ្រួសារខ្ញុំ!

- អញ្ចឹងមិត្តឯងទាំងពីរទៅចូលរួមក្រុមខាងនោះ ។

យោធានោះក៏ចង្អុលអោយជ្រូកលីវនាំកូនមាន់ដើរទៅម្ខាងទៀត មិនទាន់ដល់កន្លែងស្រួលបួលផង ស្រាប់តែមានយោធាផ្សេងទៀតបោះខោអាវខ្មៅចែកម្នាក់មួយប្រដាប់ ហើយប្រាប់ថា ៖

- ដល់ស្លៀកពាក់ហើយ ប្រញាប់មកតម្រង់ជួរនៅជើងភ្នំជួយសែងគ្រាប់អោយកងទ័ពចេញច្បាំងដេញខ្មាំងចេញពីទឹកដីយើង ។

CHANBOKEO.COM

ជ្រូកលីវឮហើយនាំកូនមាន់ដើរស្ងៀមស្ងាត់ធ្វើតាមពាក្យបញ្ជា ។ ពេលមកដល់ជើងភ្នំ ជ្រូកលីប្រទះឃើញអ្នកស្រុកជាច្រើនរយទៀត ដែលត្រូវពួកទ័ពខ្មែរក្រហមកៀរយកមក ដើម្បីជួយជាកម្លាំងតដៃ ទាហានវៀតណាមដែលចូលមកទន្ទ្រានដីកម្ពុជា ។

- ខ្ញុំសែងមិនរួចទេ ធ្ងន់ណាស់ (កូនមាន់ស្រដីប្រាប់យោធាមួយរូប ដែលកំពុងបញ្ជានាងអោយសែងកែសគ្រាប់រំសេងពីរនាក់នឹងនាយ ជ្រូកលីវ ។

- តមាត់ផង! តិចងាប់!

យោធានោះគំហកតបវិញ ថែមទាំងយកត្រាកាំភ្លើងទះខ្នងនារី ផាំង ធ្វើអោយកូនមាន់ដួលខ្ពោកទៅដីព្រូស ។ ជ្រូកលីវឃើញ ដូច្នេះ ក៏ពោលកម្លាអន្តរាគមន៍យ៉ាងរហ័ស ៖

- ប្រពន្ធខ្ញុំមានផ្ទៃពោះ ទើបមិនអាចសែងធ្ងន់បាន តែមិនអីទេ ចាំ ខ្ញុំជួយទទួលភារៈនេះចុះ មិនអីទេណា៎ មិត្តបង កុំបារម្ភអី ។

យោធានោះឮហើយបែរចេញធ្វើព្រងើយថែមទាំងគំហកថា ៖

- អញ្ចឹង ធ្វើការទៅ! មាយាទំរន់បែបហ្នឹង កាលណាទើបរំដោះ ប្រទេសជាតិបានទៅរើយ ?

ជ្រូកលីវប្រញាប់ប្រញាល់ ស្ទុះទៅគ្រាហ៍កូនមាន់អោយងើប ឡើង ហើយរំលែកគ្រាប់ដើម្បីរែកម្នាក់ឯង ទុកតែមួយចំនួនតូច អោយកូនមាន់ពុនលើស្មា ។

- ទៅរួចទេ កូនមាន់ ? (ជ្រូកលីវខ្សិបសួរ)

នារីងក់ក្បាល ៖

- ប៉ុនហ្នឹងមិនអីទេ ខ្ញុំពុនបាន តែមើលទៅជ្រូកលីវវិញហ្ន៎! តើ អាចរែកបានប៉ុន្មានម៉ែត្រទៅ ?

- ប្រឹងតាមដំណើរទៅ កុំប្រកែក ប្រយ័ត្ន "ធ្លុសឹង"

- ចា៎ស! ខ្ញុំដឹងហើយ!!

ទាំងពីរនាក់តតេះតតះនាំគ្នាពុកផងរែកផង ដើរតាមពីក្រោយ ហ្វូងមនុស្សជាច្រើនរយទៀតដែលដើរជាខ្សែៗកាត់ព្រៃ មើលទៅ មិនខុសពីហ្វូងស្រមោចដញ្ជូនស្បៀងបន្តិចណាឡើយ ។

ផាំង! គ្រាប់កាំភ្លើងហើរច្រៀសក្បាលកូនមាន់ ធ្វើអោយនារី លោះព្រលឹងស្ទើរបាត់ស្មារតី ។

- នែ៎ ឈរសំកុកធ្វើអីកណ្តាលផ្លូវ ឃើញគេឯងកំពុងធ្វើការទេហ៍ ?

យោធាមួយរូបបាញ់សម្លុតមាណវីពេលនាងហេវហត់ឈរសំរាក តាមផ្លូវ ។ ធិតាមិនហ៊ានឆ្លើយទេ ខំតែឈ្ងោកមុខពុនស្នោងគ្រាប់ ដើរទៅមុខទៀតទាំងអាការៈរវើយអស់កម្លាំង ។ មែនហើយ! ការ ពិត នាងនិងជ្រូកលីវមិនទាន់មានអាហារចូលពោះទេ មួយថ្ងៃមក ហើយ... ពេលនេះ យប់ជ្រៅបន្តិចហើយ...ក្រពះក៏រមួយស្ទើរទ្រាំ មិនបាន ស្នោងគ្រាប់ក៏ធ្ងន់... ជ្រូកលីវឃើញធិតាយើងហេវហត់ ពេកក៏លួចឱ្យបកម្លាចិត្តរហូតតាមផ្លូវ ។ មើលទៅនាយក៏មិនជាមាន អាការៈអ្វីប្រសើរជាងកូនមាន់ប៉ុន្មានដែរ ។ គេហេវហត់ណាស់តែ គេមិនហ៊ានរអ៊ូចេញមកទេ ណាខ្លួនជាបុរស ណារអារនឹងចុង កាំភ្លើង ណាអាណិតអាសូរកូនមាន់ពេញបេះដូង គេក៏ខំខាំមាត់ប្រឹង រែកគ្រាប់រំសេវទាំងទុរន់ទុរា...

.............................

ក្អូងៗ...គ្រឹម! គ្រឹម!

ស្នូរគ្រាប់កាំភ្លើងធំតូចចម្រុះគ្នានៅទិសខាងលិចឆៀងខាងត្បូង ជ្រូកលីវសម្លឹងទៅលំហមេឃតាមចន្លោះមែករុក្ខព្រឹកធំៗ ឃើញ ពន្លឺគ្រាប់ផ្លោងហោះឆ្វែលឆ្វាត់ទៅមក...

- ឱ! ខ្មែរអើយ! ថ្ងៃណាទើបស្គាល់សុខសន្តិភាព ?

ជ្រូកលីវស្រដីខ្សិបៗបន្ទូរទ្រូង ។ ភ្លាមនោះមានមិត្តម្នាក់ដែល សែងគ្រាប់ជាមួយគ្នាលួចកេះជ្រូកលីវហើយស្រដីខ្សិបៗថា ៖

- ខ្ញុំមានបាយក្តាំងមកជាប់ខ្លួនខ្លះ ។ មើលទៅមិត្តដូចជាហេវខ្លាំង ណាស់ ។ នែះ! យកបរិភោគខ្លះទៅកុំអោយខ្យល់គស្លាប់! ហើយ កាច់ចែកប្រពន្ធខ្លួនផងទៅ ។

ជ្រូកលីវភ្ញាក់ព្រើត ចំពោះទឹកចិត្តសប្បុរសរបស់បុរសមួយរូប នោះ ។ គេមិននឹកស្មានថា នៅក្នុងគ្រាអាសន្នអន់ក្រយ៉ាងនេះ នៅ មានសល់មនុស្សដែលមានទឹកចិត្តសប្បុរសដូច្នេះសោះ ។ មាណព លួចគន់មើលមុខបុរសនោះ តែក៏មើលមិនច្បាស់ ព្រោះរស្មីខែមួយ ចំណិត មិនអាចជួយអ្វីដល់ជ្រូកលីវបាននឹងឡើយ ថាគេមានវ័យ ចំណាស់ណា ។ ប៉ុន្តែទឹកចិត្តរបស់បុរសមួយរូបនោះ បានធ្វើអោយ ជ្រូកលីវមានកម្លាំងប្រឹស ហាក់បីដូចជាថ្នាំសក្តិសិទ្ធិតែម្តង ។

- អរគុណ បាទ!

ជ្រូកលីវទទួលក្តាប់យកបាយក្តាំងពីបុរសនោះទាំងទឹកចិត្តសែន រំភើបរកគ្មាន ។ រួចហើយមាណពក៏ហុចចែកអោយកូនមាន់ពាក់ កណ្តាល ។ គេអកគ្រាប់បាយក្តាំងបណ្តើរ រៃកបណ្តើរមិនហ៊ានឈប់ ទេ ព្រោះកងយោធាទាំងនោះនឹងបាញ់សំដៅនរណាដែលមិនដើរទៅមុខ ។ ភ្លាមនោះ បុរសដែលអោយបាយក្តាំងជ្រូកលីវក៏បែរក្រោយខ្សិបដាក់ត្រចៀកនាយយើងថា ៖

- ខ្ញុំត្រូវពួកខ្មៅកៀរមកធ្វើការទីនេះជាងម៉ាអាទិត្យហើយ ហើយសង្កេតឃើញថានៅម្តុំៗនេះមិនមានយោធាយាមច្រើនប៉ុន្មានទេ...
- ហើយមិត្តកំពុងគិតអីមែនទេ ? (ជ្រូកលីវខ្សិបសួរវិញ)
- មែន! បើយើងព្រួតដៃគ្នា ខ្ញុំគិតថាយើងអាចដណ្តើមអាវុធពីពួក វាហើយវាយលុករកច្រកចេញបានយ៉ាងជោគជ័យ ។
- ដូចជាប្រថុយប្រថានពេកដឹង ? មិត្តស្គាល់ស្ថានភាពនិងទីកន្លែង សំរាប់គេចខ្លួនហើយនៅ ?
- ខ្ញុំប្រុងជើងការពីរថ្ងៃហើយណ៎! នៅខាងមុខនេះ មានគ្នីគ្នាខ្ញុំពីរ បីនាក់ដែលមានចិត្តដូចគ្នាដូច្នេះបើយើងព្រួតដៃគ្នាពេលនេះ គឺពិត ជាជោគជ័យ ។
- អញ្ចឹងខ្ញុំតាមមិត្តដែរចុះ ។

មិនទាន់ផុតសំដីខ្សិបផង ស្រាប់តែអ្នកស្រុកប៉ុន្មានរូបទម្លាក់ អម្រែកគ្រាប់រំសេវចោល ហើយហក់យ៉ាងរហ័ស ស្ទុះសំរុកចូល ដណ្តើមអាវុធពីដៃយោធាប៉ុន្មាននាក់ដែលដើរយាមភ្លេចខ្លួនអមអ្នក ស្រុករែកគ្រាប់តាមផ្លូវ ។ ភាពច្របូកច្របល់ក៏កើតមានឡើងមួយ រំពេច ។ ចៃដន្យគ្រានោះ មានការប្រយុទ្ធតតាំងកាន់តែខ្លាំងនៅមិន ឆ្ងាយពីទីនោះប៉ុន្មានឡើយ ម្ល៉ោះហើយអ្វីៗក៏ក្លាយជាចលាចល យ៉ាងតក្កហល មិនដឹង មិនយល់ មិនស្គាល់ថានរណាជានរណាទេ ។ ស្នូរគ្រាប់កាំភ្លើងក៏ស្ទុះឡើងផ្ទុងផាំងយ៉ាងខ្ទ័រខ្ទារ...

ជ្រូកលីវទម្លាក់គ្រាប់ចោលស្ទុះរឹងទៅជួយអ្នកស្រុក វាយពួកយោធាខ្មែរក្រហមដណ្តើមបានកាំភ្លើងវែងមួយដើម ហើយក៏ស្ទុះចាប់ដៃកូនមាន់រត់កាត់ព្រៃប្រសេចប្រសាចតាមគេតាមឯង ។ មួយ ស្របក់ក្រោយមក កាំភ្លើងនៅដៃរបស់គេក៏អស់គ្រាប់ ។ នាយក៏ គ្រវែងចោលទៅក្នុងព្រៃ ហើយប្រឹងតែចាប់ដៃនារីសម្លឹងរកទិស គេចខ្លួន ដើម្បីសុវត្ថិភាព ។

......................

ថ្ងៃរះឡើងហើយ...

CHANBOKEO.COM

គ្រាប់កាំភ្លើងក៏ស្ងប់ស្ងាត់ទៅវិញ ជ្រូកលីវលូនចេញមកពីគុម្ព ព្រៃគុម្ពោតមួយ សម្លឹងឆ្វេងស្តាំហើយក៏បែរក្រោយខ្សឹបហៅ ៖

- កូនមាន់ចេញមក! យើងធ្វើដំណើរបន្តទៀត ។

និតាយើងក៏លូនចេញមកទាំងមុខមាត់ស្រមេកស្រមកមើលមិន យល់ ។ លុះក្រលេកមើលជុំវិញខ្លួន កូនមាន់ប្រទះឃើញសាកសព ដេករណ្ដូករណោលពាសពេញព្រៃ មានខ្លះក៏របួសធ្ងន់ធ្ងរស្រែកថ្ងូរ ពេញព្រៃ តែក៏គ្មាននរណាអាចជួយនរណា ក្រៅពីស្រវារករស់រៀង ខ្លួន ។ អ្នកទាំងពីរត្រូវបង្ខំចិត្តធ្មេចភ្នែកដើររំលងសាកសពនិងអ្នករបួសទាំងឡាយ រហូតមកដល់ទីព្រៃស្រោងមួយ...

- យើងគិតទៅណាទៀត ជ្រូកលីវ ? ខ្ញុំស្បើយកម្លាំងហើយណា៎.. ដើរលែងចង់ទៅមុខរួចហើយពេលនេះ...

ជ្រូកលីវឃើញសភាពទ្រុឌទ្រោមរបស់នារី ក៏ទុចដំណើរ ៖

- អញ្ចឹង យើងសំរាកទីនេះទៀតសិនក៏បាន ។

គេក៏នាំគ្នាដាក់ខ្លួនចុះផ្អែកនឹងគល់ឈើ ធ្មេចភ្នែកទំរេតខ្លួនយក កម្លាំង ។

- អូយ៎!
- កើតអីហ្នឹងកូនមាន់ ?

ជ្រូកលីវបើកភ្នែកបែរមើលនារី ។

- គឺមានសត្វអីនេះ រាងដូចឈ្លើង ខាំឈឺណាស់

មាណវិឆ្លើយវិញ ថែមទាំងយកដៃបេះចេញផង ។

- អូហ៍ គេហៅថាទៀក មិនមែនឈ្លើងទេ ។ រដូវនេះភ្លៀងច្រើន ដីសើម សំបូរសត្វហ្នឹងណាស់ ។
- អ៊ូយ! ខាំទៀតហើយ! មើលហ្ន៎ក ច្រើនណាស់ ។

ឃើញកូនមាន់យកដៃបេះអោយញាប់ស្ទាញ់ដូច្នេះ បុរសក៏ទាញ ដៃនាងអោយក្រោកឡើង ៖

- ម៉ោះ! ទៅរកកន្លែងផ្សេងសំរាកវិញ ក្រែងមានសុវត្ថិភាពជាង នេះបន្តិច ។

គេនាំគ្នាដើរមួយស្របក់ នៅតែមិនប្រទះកន្លែងអ្វីប្រសើរជាង ហ្នឹងសោះ ។

- មើលទៅ យើងត្រូវគេងលើប្រកៀបឈើ សំរាកខ្លួនហើយ ។
- នែ៎ជ្រូកលីវ! គេងលើប្រកៀបឈើយ៉ាងម៉េចទៅ មិនខ្លាចធ្លាក់បាក់កស្លាប់ទេឬអីហ្នឹង ?

CHANBOKEO.COM

- តើយើងមានជំរើសអីទៅ បើគេងផ្ទាល់ដី ទៀតវាខាំ មានតែទំ លើមែកឈើដូចសត្វហើយ ។

ដោយទាល់ច្រក នារីក៏សំរេចចិត្តទទួលសំណូមពរជ្រូកលីវ តោងដៃនាយឡើងលើដើមឈើ ទំលើប្រគៀបមែកមួយម្នាក់ ។ ជ្រូកលីវលួចសម្លឹងកូនមាន់ ឃើញនាងលូកដៃជូតទឹកភ្នែកជាញឹកញាប់ ដឹងថានាងកំពុងស្រក់ទឹកភ្នែកអាណិតខ្លួន ក៏ស្រដីកម្លាថា ៖

- កូនមាន់អើយ! យើងមិនកំសត់បែបហ្នឹងយូរទៀតទេ... ខ្ញុំគិតថា ស្អែកៗជីវិតយើងនឹងជួបភាពភ្លឺស្វាងមិនខាន អោយតែយើងមាន ការព្យាយាមពិតប្រាកដ... ហោចណាស់ គឺយើងមិនបោះបង់ចោល គ្នា នឹងហើយឬនៅ ?

កូនមាន់ឮសំដីនេះក៏លើកដៃជូតទឹកភ្នែក ៖

- សូមទោសដែលខ្ញុំភ្លេចខ្លួនអំបាញមិញ ។ ខ្ញុំមិនគួរស្រក់ទឹកភ្នែក អោយជ្រូកលីវអស់កម្លាំងចិត្តទេ...

- មិនអីទេ កូនមាន់! បើទឹកភ្នែកអាចជួយសំរាលការតានតឹងក្នុង ដួងចិត្តបាន មិត្តយំចុះណា៎! មនុស្សយើងដែលអាចយំបានគឺពិតជា សំណាងណាស់ ត្បិតយើងនឹងថា យើងនៅមានជីវិត ស្គាល់យល់ ដឹងពីការឈឺចាប់និងភាពខ្លោចផ្សាក្នុងអារម្មណ៍ ។ អ្នកដែលមិន ស្គាល់ទឹកភ្នែកទេតើដែលមិនយល់ថា តើអារម្មណ៍ឈឺចាប់នោះ មាន រសជាតិយ៉ាងម៉េច... ? ដូចជាឥឡូវនេះអីចឹង គូបដិបក្សប្រយុទ្ធគ្នា ក្នុងក្ដាំងរាល់ថ្ងៃ... គេមិនស្គាល់ទឹកភ្នែករបស់អ្នកស្រុកស្លូតត្រង់ទេ គេស្គាល់តែអំណាចវាតទីដណ្ដប់ដីនិងជីវិតអ្នកដទៃតែប៉ុណ្ណោះ ។

កូនមាន់បែរមើលទៅជ្រូកលីវ ស្រដីតបវិញថា ៖

- សង្ឃឹមថា យើងអាចស្គាល់ពន្លឺថ្ងៃស្អែកបាន ដោយមិនបាច់ស្រក់ ទឹកភ្នែកតទៅទៀត ។

ជ្រូកលីវញញឹម ។ បន្តិចមកគេក៏នាំគ្នាបិទភ្នែកសំងំ ។ ស្រាប់ តែកូនមាន់ស្រែកវ៉ាសយ៉ាងខ្លាំង ។

- មានរឿងអ្វីទៀតហើយ កូនមាន់ ? (ជ្រូកលីវបើកភ្នែកសួរ)

ធិតាយើងមិនតបទេ តែបែរជាធ្វើភ្នែករិលជាសញ្ញាឲ្យនាយ សម្លឹងទៅចុងជើងរបស់នាង ។ នរៈភ្ញាក់ព្រើតបើកភ្នែកធំៗ ៖

- ពុទ្ធោ! ពស់រុំជើងនាង កូនមាន់! តើធ្វើម៉េចទៅ ?

CHANBOKEO.COM

ទាំងពីរនាក់ធ្វើភ្នែកស្លន់ស្លោ តែមិនហ៊ានកំរើកទេ ខ្លាចពស់នោះភ្ញាក់ស្ទុះខាំកូនមាន់នាំតែមានគ្រោះថ្នាក់ ។

- នាងសម្ងំស្ងៀមអញ្ជឹងហើយ (ជ្រូកលីវខ្សិប) ដើម្បីអោយពស់ ច្រឡំថាខ្លួននាងជាមែកឈើ...

កូនមាន់ភ័យឡើងមុខស្វាយល្អក ប្រឹងសំងំឡើងបែកញើស សស្រាក់ ។ សំណាងល្អពស់មួយនោះក៏វារចេញទៅបាត់យ៉ាងស្ងប់ ស្ងៀម ។

កូនមាន់ធូរទ្រូងខ្សាកយកដៃអោបខ្លួនរបស់នាង ៖

- ព្រះអង្គអើយ! អរគុណណាស់ ដែលមិនយាយីជីវិតខ្ញុំ!

ជ្រូកលីវឮដូច្នោះក៏សើចកក្អឹកឡើង ៖

- អីយ៉ា! លើកឋានៈល្បងពស់រហូតជាព្រះហើយហ្អែស ?

- បើមិនជាព្រះក៏ជាអ្នកតាថែរក្សាព្រឹក្សព្រៃទីនេះដែរណា ជ្រូកលីវហើយបើយើងមានការគោរពម្ចាស់ទឹកម្ចាស់ដីខ្លះ យើងប្រាកដជា នឹងបានសុខសប្បាយរហូតដឹងហើយនៅ ?

- ចុះខ្ញុំមានទៅថាអីឯណា ?

រំពេចនោះ អ្នកទាំងពីរក៏ឮសន្ធឹកជើងមនុស្សដើរក្នុងព្រៃរសិប មកទៀតហើយ ។ គេក៏លើកដៃអោយសញ្ញាគ្នា រួចហក់ចុះពីលើ មែកឈើរកកន្លែងពួនលាក់ខ្លួន ។ ភ្លាមនោះមានក្រុមមនុស្សមួយ ហ្វូងមានគ្នាប្រាំនាក់ដើរមកដល់ ខ្លះដូចជាមានរបួសតិចៗផង ។ ក្នុងចំណោមនោះមានបុរសបីនាក់ ស្ត្រីមួយរូប និងក្មេងប្រុសតូច ប្រហែល១២ឆ្នាំម្នាក់ទៀត ។

- អូហ៍! គេជាមិត្តរបស់ខ្ញុំតើហ៍!

ជ្រូកលីវខ្សិបដាក់ត្រចៀកកូនមាន់ រួចហើយក៏ដើបឡើងកូកហៅមិត្តរបស់គេដែលនៅក្នុងចំណោមអ្នកដំណើរបួនដប់នាក់នោះ៖

- ខេង! ឆាល់!

ឮសម្លេងហៅ ពួកគេក៏បែរមើល ៖

- នាយលីវ ? គឺឯងតើហ៍

ខេងនិងឆាល់ស្ទុះរត់មកដល់ ។

- ឯណាត្រោកនិងសង្សារគេនោះ ? (ជ្រូកលីវសួរ)

CHANBOKEO.COM

- យើងបែកផ្លូវគ្នាតាំងពីនៅសេរីសោភ័ណម្លេះ ។ ហើយបីនាក់ទៀតនេះជាអ្នកស្រុកដែលនាំគ្នារត់ទៅទល់ដែនជាមួយយើង... ជួប គ្នាហើយក៏ធ្វើដំណើររួមគ្នាមកអោយបានកក់ក្ដៅ ។

- ល្អណាស់អញ្ចឹង! ខ្ញុំនឹងមិត្តនារីខាងនេះសូមរួមដំណើរផង ។

ជ្រូកលីវថាផង បួញមាត់ចង្អុលទៅកូនមាន់ផង ។ បុរសទាំងពីរបែរមកមើលនាងហើយក៏ញញឹមស្វាគមន៍ ។

- តោះយើង ប្រញាប់ចេញទៅ! (នាយខេងស្រដីឡើង)

......................................

ច្រើនម៉ោងក្រោយមក...

ខេងដាក់អម្រែកឥវ៉ាន់ចុះ លូកយកបាយកាតាកហុចអោយជ្រូក លីវ ម៉ាក្ដាប់ ៖

- នេះ! អកកំដរក្រពះសិនទៅ

រួចហើយនាយក៏ចាប់មួយក្ដាប់ទៀត ហុចអោយកូនមាន់ ៖

- ខ្ញុំមានតែប៉ុណ្ណឹងទេ! យ៉ាងម៉េចយ៉ាងម៉ាចាំគិតតទៅទៀត ។

កូនមាន់លើកដៃទទួលយកបាយកាតាកពីនាយខេង ៖

- អរគុណមិត្តណាស់ចំពោះចិត្តថ្លើមដ៏ល្អនេះ ។

ខេងគ្រវីក្បាល ៖

- មិនបាច់អរគុណអ្វីទេ មិត្តនារី! ពាក្យចាស់ពោលថា នៅផ្ទះម្ដាយ ទីទៃ នៅព្រៃម្ដាយជាមួយ ស្គាល់ក្នុងគ្រាក្រសម្បុរល្អនៅខែកក្ដឹក មិត្តនារីស្គាល់ពាក្យស្លោកនេះទេ ។ ខ្ញុំតែងចងចាំក្នុងចិត្តរហូតមក ហើយមិត្តខ្ញុំខ្លះ ក៏រៀនចេះដែរ គ្រាន់តែមិនព្រមអនុវត្តន៍ ។

នាយខេងស្រដីផង លួចចោលកន្ទុយភ្នែកទៅនាយឆាល់ ដែលអង្គុយនៅឆ្ងាយពីអ្នកទាំងបីបន្តិច ហើយបរិភោគពំនូតបាយតែម្នាក់ឯងមិនខ្វល់នឹងនរណាជុំវិញខ្លួន ។ ចំណែកប្ដីប្រពន្ធនិងកូនបីនាក់ នោះវិញក៏អង្គុយប្រឈមមុខគ្នាបរិភោគអាហារដែលគេខ្ចប់យកមកដោយស្ងៀមស្ងាត់មិនឃើញគួរសមហៅនរណាចូលរួមឡើយ ។

កូនមាន់យល់ស្ថានការណ៍ភ្លាមថា នាយខេងនិយាយចង់មាន ន័យយ៉ាងណានោះ ។ នាងញញឹមតបវិញ ហើយក៏ដាក់បាយក្នុង មាត់ទំពារមួយៗ ។ មែនហើយ! ថ្វីបើបាយនោះត្រឹមតែជាបាយ ហាលក្រៀមៗ គ្មានអាហារអ្វីកំដរ ប៉ុន្តែបាយនោះមានមានរសជាតិ

CHANBOKEO.COM

មិនខុសពីថ្នាំទិព្វ មកប្រោសជីវិតរបស់គេឡើយ ។ នារីយើងទំពារ បាយផង រំភើបចិត្តផង ដែលនាងបានប្រទះមនុស្សល្អ ក្នុងជីវិត ជាពិសេសក្នុងពេលគ្រោះថ្នាក់ប្រផិតប្រផើយយ៉ាងនេះ ។

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៨
# ទឹកចូលច្រមុះ

- នែ៎ ក្រោកឡើង! ដើប!

ផាំង! សម្លេងគ្រាប់កាំភ្លើងលាយគ្នានឹងសម្លេងគំហកខ្ជុំខ្ជារ ។ កូនមាន់បើកភ្នែក ដើយមើលឃើញមនុស្សប្រុសមុខមាត់ស្រមឹម ស្រមូម ស្លៀកពាក់ស៊ីកាឃូ បួនប្រាំនាក់កំពុតកាន់កាំភ្លើងគ្រប់ដៃ ចេញពីគុម្ពោធព្រៃជិតនោះ ភ្ជង់ចុងកាណុងមកលើកូនមាន់ជ្រូកលីវនិងគ្នីគ្នាទាំងអស់ ។

- ដើបឡើង! ដោះខោដោះអាវ ហើយទុកឥវ៉ាន់នៅទីនេះទាំង អស់ បើចង់រក្សាជីវិត!

ទាំងអស់គ្នាភ្ញាក់ស្រឡាំងកាំងបើកភ្នែកធំៗ ។

- ឮហើយនៅ ? ដើបឡើង ថយក្រោយចេញពីសំពាយឥវ៉ាន់ រួចហើយស្រាតខោស្រាតអាវទុកអោយយើងទីនេះភ្លាម!

ទាំងអស់គ្នាដើបឈរស្រេ ធ្វើកិរិយាអេះអុញមិនព្រមដោះខោ ដោះអាវថ្វីបើពួកគេដើរគេចថយពីសំពាយអីវ៉ាន់របស់គេបីបួន ជំហានហើយក៏ដោយ ។ ជ្រូកលីវលួចមើលមុខកូនមាន់ឃើញនាង ភ្ញាក់ផ្អើលមុខឡើងស្លេកគ្មានឈាម ។

ផាំង! គ្រាប់កាំភ្លើងហើរជៀសក្បាលនាយឆាល់ឡើងរហើយ សក់ ។

- ថាអោយស្រាតខោអាវ ឮហើយនៅ ?

ឃើញភាពយង់ឃ្នង បង្ហាញនៅលើផ្ទៃមុខចោរព្រៃទាំងនោះគ្រប់គ្នាក៏ប្រឡេះឡេវអាវយ៉ាងលឿន ។ ជ្រូកលីវក៏ស្រដីឡើងទៅ ហ្វូងចោរថា ៖

- បងប្រុស! មានស្រីភេទពីរនាក់ក្នុងចំណោមពួកយើង សុំលើក លែងផងបានទេ ?

CHANBOKEO.COM

- ស្រីអីប្រុសអី ? យើងមិនស្គាល់ ! (ចោរស្រែកតំហកតបវិញ) ដោះតែអាវទុកអោយយើងមក
ហើយឆាប់ទៅងាប់ឯណាក៏ទៅទៅ..

ចោរនោះពោលផងដើរទៅជិតកូនមាន់ដែលនៅឈរក្បែរជ្រូក លីវ
រួចហើយយកចុងកាណុងកេះអាវនាង កន្ត្រាក់សើយបំបើកអាវ នាងឡើង ថែមទាំងស្រែកថា ៖

- ដោះអាវ ! លឿនឡើងមើស៍ !

ជ្រូកលីវឃើញដូច្នោះ ទ្រាំមិនបាន ក៏ហក់វឹងចាប់អូសកាណុង ចេញ
ដើម្បីឃាត់មិនអោយចោរធ្វើដូច្នោះលើនាង ៖

- កុំ.... !

ផាំង ! ចោរគាស់កៃមិនប្រណី ។ គ្រាប់កាំភ្លើងហោះភ្លែតទម្លុះ កំភួនជើងរបស់ជ្រូកលីវ
បាញ់ឈាមព្រល...

- ជ្រូកលីវ ! (កូនមាន់ស្រែកឡើងយ៉ាងគ្រលួច)

អ្នកដទៃទៀតឃើញហេតុការណ៍ដូច្នោះ ក៏ខំមាត់ផ្ដាច់ឡេវអាវ ទាំងស្មារតីតក់ស្លុត
គ្មានពាក្យអ្វីនឹងថ្លែងអោយសមស្មើបានឡើយ ។

ទីបំផុត... អ្នកទាំងអស់គ្នាត្រូវនាំគ្នាដើរទាំងអាក្រាតកាត់ព្រៃ ។ ថ្វីបើចោរប៉ុន្មាននាក់នោះ
មិនបានសម្លាប់ជីវិតរបស់គេមែន តែ ពេលនេះ
ជនរងគ្រោះទាំងប៉ុន្មាននាក់នោះមានអារម្មណ៍ថាវិញ្ញាណ
របស់គេបានស្លាប់ក្នុងព្រៃជ្រៅដោយស្នាដៃចោរទាំងនោះ អស់បាត់ ទៅហើយ ។

- កុំយំអីកូនមាន់... ជីវិតយើងមានតម្លៃណាស់... កុំបណ្ដោយអោយ ភាពយង់ឃ្នងទាំងនេះ
វាគម្រាមកម្លាំងចិត្តយើងបានអោយសោះ ។

ជ្រូកលីវខំពោលលួងលោមកូនមាន់ដែលកំពុងរណ្ដំចង្កាដោយក្ដី ខ្មាស់អៀន
និងភាពតក់ស្លុតក្នុងចិត្តជាអតិបរិមា ។ បន្តិចមក នាងលើកដៃជូតទឹកភ្នែក
ហើយស្រដីសួរជ្រូកលីវ ថា ៖

- របួសរបស់មិត្តយ៉ាងណាហើយ ? ដើររួចទេ ? នែ៎ះ ! ពួកគេ
ចេញដំណើរទៅចោលយើងអស់ហើយ មែនទេ ?

- មែន ! គេចេញទៅអស់ហើយ ! សល់តែកូនមាន់និងខ្ញុំទេ ។

កូនមាន់ខំកាត់ចិត្តអាមាសនឹងភាពអាក្រាត លូកដៃជួយលើក គ្រាហ៍ជ្រូកលីវឡើង
ដើម្បីបន្តដំណើរទៅមុខទៀត ។ ស្រាប់តែ មានមនុស្សម្នាក់ហុចមែកឈើមួយបាច់យ៉ាងក្រាស់

CHIANBOKEO.COM

មកអោយកូន មាន់ ។ នារីងើបមុខឡើងសម្លឹងមើល ឃើញនាយខេងហុចមែក ឈើមកអោយនាង ថែមទាំងស្រដីថា ៖

- មិត្តនារីយកមែកឈើព្រៃរុំបាំងខ្លួនសិនទៅ ។ ខ្ញុំបានពិនិត្យរួច ហើយថាស្លឹកឈើនោះមិនធ្វើអោយស្បែករមាស់ទេ ។ ចំណែកនាយ លីវវិញ ទុកអោយខ្ញុំអៀវគេចុះណា៎ ។

កូនមាន់ឃើញសមានចិត្តល្អរបស់នាយខេង ក៏លូកដៃទទួល យកមែកឈើទាំងរលីងរលោងទឹកភ្នែក ៖

- អរគុណណាស់...! អរគុណ!

បន្តិចមក គេក៏នាំគ្នាចេញដំណើរទៅមុខទៀត ។

..................................

មួយយប់ក្រោយមក...

អ្នកទាំងបីកំពុងឆ្មេចភ្នែកសម្រាកនៅតំបន់មួយ មានថ្មផ្ទាំងៗ បន្តុបលើគ្នាទំនងដូចជាប្រាសាទបុរាណដែលបាក់បែកយូរឆ្នាំហើយ

- មិត្តនារីមិនអីទេហ៏ ?

នាយខេងសួរទៅកូនមាន់ដែលឈ្ងោកត្របោមជង្គង់តែម្នាក់ឯង បាំងនឹងផ្ទាំងសិលាបាក់បែកសំដែងកិរិយាទំនងរងា ។ មែនហើយ! នាងកំពុងរងាមែន... រងាទាំងកាយ រងាទាំងចិត្ត រងាទាំងវិញ្ញាណ.. គិតៗទៅសង្គ្រាមដណ្តើមអំណាច ដណ្តើមទឹកដី ពិតជាធ្វើឲ្យជីវិត អ្នករងគ្រោះខ្លោចផ្សាយ៉ាងនេះឯង ។ សំណាងនេះដែលពីរថ្ងៃមក នេះ មិនមានការបាញ់ប្រហារគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ព វៀតណាម កុំអីមិនដឹងថាជីវិតអ្នកទាំងបីត្រូវប្រទះអ្វីខ្លះទៀតទេ ។ កូនមាន់លើកដៃផ្ចិតទាំងភ្នែក រួចហើយតបវិញថា ៖

- ខ្ញុំមិនអីទេ! កុំបារម្ភអី ប៉ុន្តែ ចុះជ្រូកលីវនោះ យ៉ាងណាហើយ!

ឮនារីសួរសុខទុក្ខរបស់ខ្លួនមុនសួរសុខទុក្ខនាយខេង ជ្រូកលីវ នឹករំភើបចិត្តតែម្តងហើយស្រដីតបវិញខ្សាវៗថា ៖

- អោយតែដឹងថាកូនមាន់សុខសប្បាយ ខ្ញុំពិតជាឆាប់ជាសះស្បើយ មិនខាន ។

ភ្លាមនោះស្រាប់តែឮសូរសម្លេងមាត់មនុស្សស្រែកសួរ ៖

- អ្នកណាហ្នឹង នៅក្នុងព្រៃ ?

CHANBOKEO .COM

អ្នកទាំងបីភ្ញាក់ព្រើត បែរសម្លឹងមុខគ្នា ។ មិនទាន់បានឆ្លើយ យ៉ាងណាផង មនុស្សប្រុសបីនាក់បានមកដល់ ក្នុងសម្លៀកទាហាន ប៉ាវ៉ា ប៉ុន្តែគ្មានប្រដាប់អាវុធទេ ។

- ព្រះអើយ! អ្នកទាំងបីទើបតែត្រូវចោរប្លន់មែនទេ?

បុរសម្នាក់ចំណាស់ប្រហែលសែបួាយលាន់មាត់ឡើង ។ ចំណែក ពីរនាក់ទៀត ចំណាស់ប្រហែលជាង២០ឆ្នាំ ។ បុរសចំណាស់ក៏ស្រវា ដោះកន្សែងពីក បោះអោយទៅជ្រូកលីវ ៖

- នេះ យក៏រុំខ្លួនសិនទៅ អានាង ។

រួចហើយក៏បែរមកក្តីគ្នាគាត់ម្នាក់ទៀតដែលរាងល្អិតទាបជាងគេ ហើយស្រដីថា ៖

- នែ៎ នាយដុំដី! ដោះខោអាវឯងអោយស្រីៗខ្ញីប្រើសិនទៅ ព្រោះខ្លាតឯងតូច ប្រហែលជានាងស្លៀកត្រូវ ។

- ស្លាប់ហើយពូតាលឹងទឹង! ហើយចុះខ្ញុំមានអីស្លៀក?

- ស្លៀកខោស្នាប់ផន់ឯងហ្នឹងសិនទៅ ទំរាំទៅដល់ជំរំវិញ

- ពុទ្ធោ! ខ្ញុំឯណាដែលមានខោស្នាប់ស្លៀកនោះ?

- យី! ឯងនេះ អត់មាយាទដល់ម្លឹងផង?

- មិនអត់មាយាទទេ តែអត់លុយទិញស្នាប់ស្លៀកហ្នឹងណាពូ!

- អួយ៎ យ៉ាប់មែន! អញ្ចឹង ខ្ញីក្រមានាយម៉ាប់រុំខ្លួនទៅ ហើយឯង ស្រាតខោអាវមក ។ ពូខ្ញីអោយមីនាងនោះវាស្លៀកសិន ។

នាយដុំដីធ្វើឫកអេះអុញមួយស្របក់ ទំរាំដាច់ស្រាតខោគប់ឲ្យទៅកូនមាន់ដែលនៅអង្គុយយកមែកឈើបាំងខ្លួន ។ ចំណែកឯពូតាលឹងទឹងវិញក៏ស្រាតខោរបស់គាត់ហុចអោយនាយខេង ។

- នេះ ស្លៀកសិនទៅ បើចង្អេះវាធំ ឯងដើរកាន់សិនទៅ ចាំពូនាំ ឯងចូលជំរំ ។

ខេងក៏ទទួលខោពីបុរសចំណាស់យកមកស្លៀក ហើយក៏សួរទៅ គាត់វិញថា ៖

- ហើយពូជាទាហានទល់ដែននេះមែនទេ?

- អ្នកណាថា? (ពូតាលឹងទឹងឆ្លើយវិញ)

- គឺ...ខ្ញុំឃើញពូស្លៀកពាក់ខោអាវដូចពួកទាហានប៉ាវ៉ា..ទើប...

- ហាហ៉ា!ហាហ៉ា! (ពូយើងសើចក្អាក្អាយ) មិនមែនទេ គឺពូដោះខោអាវហ្នឹងពីខ្មោចទាហាននៅក្នុងព្រៃយកមកបោកប្រើទេហ៎ មិន ដែលបានធ្វើទាហានអីឯណា ។

ពូយើងសើចធ្វើព្រងើយ ។

CHANBOKEO.COM

- អញ្ចឹង ពូមកពីជំរំទល់ដែនមែនទេ ?

- មែនហើយ! ឯងមកដល់ជាយដីជំរំហើយ ។ សំណាងហើយ ឯងបានមកជួបពូ... ការពិតម៉្លឹះនេះ សំបូរពួកចោរវាប្លន់ណាស់ ។ វាមិនសម្លាប់មនុស្សទេ តែវាសំរាតយកអីវ៉ាន់អស់ ព្រោះវានឹងថាទាំងស្រីទាំងប្រុសដែលរត់ចេញពីស្រុកខ្មែរមក ច្រើនលួចដេរមាស លាក់ក្នុងថ្នេរអាវខោ ជាពីសេសខោទ្រនាប់ អាវទ្រនាប់ហ្នឹងឯង ។

- រួចពូមានក្រុមគ្រួសារនៅជំរុំនេះដែរមែនទេ ?

- អត់មានទេ ប្រពន្ធនិងកូនពីរនាក់ព្រាត់គ្នាតាំងពីឆ្នាំ១៩៧៥ម្ល៉េះ ហើយអាលូវនេះ ចិញ្ចឹមអាពីរនាក់នេះ ជាកូនជំនួសសម្តង ឃើញវា កំព្រីកំព្រាមិនមានសាច់ញាតិ ។

- ហើយថ្ងៃនេះហេតុអ្វីបានពូមកដល់ទីនេះដែរ ? ស៊ើបដើងការណ៍ អោយក្រុមទាហានទល់ដែនហីអីពូ ?

- វើយ! កុំចេះតែស្មានផ្តាស! ពូគិតថាចង់ធ្វើដំណើរទៅស្រុកវិញ រកប្រពន្ធកូន តែខ្លាចជាន់មីនងាប់តាមផ្លូវ ក៏ដើរបកក្រោយ ហើយ ក៏បានជួបពួកឯងដោយចៃដន្យហ្នឹងតែម្តងទៅ ។

- ចុះនៅជំរំ ពូរកស៊ីធ្វើការអីដែរទៅ ?

- អត់មានធ្វើអីទេ ជួនកាលអង្គការកាកបាទក្រហមអន្តរជាតិគេ យកអង្ករ យកថ្នាំ មកចែក ។ ជួនកាលពូទៅជួយរែកឥវ៉ាន់អោយ អ្នករត់ពន្ធ បានប្រាក់កម្រៃតិចតួចគ្រាន់លៀងក្រពះ ជួនកាលក៏ទៅ ធ្វើអាចារ្យពេលាអោយគេ ហើយក៏បានបាយហូបម៉ាឆ្អែតៗទៅ ។

បន្តិចមក ពូតាលឹងទឹង ដេញអោយនាយម៉ាប់និងនាយដុំដីជួយ គ្រាហ៍ជ្រូកលីវដើរតម្រង់ទៅជំរំ ។ នាយខេងនិងពូតាលឹងទឹងត្រូវ មាត់ត្រូវកគ្នាណាស់ ឃើញជជែកគ្នាអោយរអឹកតាមផ្លូវ ។ មានតែ កូនមាន់ទេ ដែលដើរស្ងៀមស្ងាត់ ទាំងចិត្តនឹកអាមាសចំពោះហេតុ ការណ៍ដែលកើតឡើងចំពោះនាង ។ ប៉ុន្តែ អោយនាងធ្វើម្តេចទៅ ? ពេលនេះ ធិតាស្ថិតនៅក្នុងស្ថានភាពទាល់ច្រក មិនអាចជួយខ្លួនឯងបានឡើយ... នាងដើរពីក្រោយជ្រូកលីវបណ្តើរ ដកដង្ហើមបន្ទូរក្តី តានតឹងក្នុងចិត្តបណ្តើរ ។

ចំណែកជ្រូកលីវវិញ ក៏ដូច្នោះដែរ ។ ថ្វីបើខ្លួនគេរបួសខ្សោះ ឈាមពីខ្លួនក៏ដោយ ក៏គេហាក់មិនខ្វល់ចំពោះរបួសនោះស្មើនឹងការ បារម្ភចំពោះកូនមាន់ឡើយ ។ គេលួចចោលកន្ទុយភ្នែកសង្កេតសុខ ទុក្ខរបស់នាងមិនដាច់មួយវេលាណាឡើយ ។

CHANBOKEO . COM

ពូតាលឹងទឹងនាំអ្នកទាំងអស់ ដើរតាមផ្លូវក្រវិកក្រវក់យ៉ាងយូរ ទើបមកដល់ជំរំ ដែលមានខ្ទមស្បូវតូចៗ សង់ទីងណាត់ទីងណែង រកេតរកូតពេញព្រៃ និងមនុស្សរស់នៅណែនណាន់ខ្ពាន់ខ្ពាប់យ៉ាង អាណាធិបតេយ្យ គ្មានរបៀបអ្វីបន្តិចឡើយ ។

- ម្តុំនេះគេហៅថា ជំរុំណងចាន់ ។

- ពុទ្ធោ! ជំរំនេះធំដល់ម្លឹងផង ? (នាយខេងលាន់មាត់)

- អូហ៍ ជំរុំម្តុំនេះមិនធំប៉ុន្មានទេ មានម៉ាកន្លែងពីរទៀត ធំៗជាង ហ្នឹង ។ មនុស្សរត់ប្រសេចប្រសាចមកដល់រាល់តែថ្ងៃ មានទាំងអ្នក របួស មានទាំងអ្នកជា ។ ហើយអង្គការគេមកចែកទឹកចែកអាហារ និងថ្នាំឲ្យយើងតែពេលមានថ្ងៃៗទេ ។ លុះពេលព្រលប់ ពួកគេនាំ គ្នាត្រលប់ទៅវិញអស់ហើយ ត្បិតខ្លាចអសន្តិសុខ (ពូយើងឆ្លើយ)

នៅថ្ងៃនោះ ជ្រូកលីវ កូនមាន់ និងនាយខេងបានទទួលការរាប់អានយ៉ាងកក់ក្តៅពីពូតាលឹងទឹង ។ គាត់បានដាំបបរអោយអ្នកទាំង បីឆីម្នាក់ៗឡើងហាល់ ថែមទាំងអូសកន្ទេលរបស់គាត់មកក្រាលចែក ពួកគេដេកប្រជ្រៀតជាមួយគាត់ទៀតផង ។ មិនតែប៉ុណ្ណោះគាត់ក៏ បាននាំជ្រូកលីវទៅសុំថ្នាំព្យាបាលពីមណ្ឌលសង្គ្រោះនៅក្នុងជំរំ ជួនប៉ះចំពេលគេមិនធ្វើការ ។ ចៃដន្យពេលនោះ មានអ្នកជិតខាងម្នាក់ ចិត្តល្អហុចថ្នាំបុកមួយកំប៉ុងឲ្យជ្រូកលីវយកទៅរុំរបួស ទំរាំអង្គការ វិលមកធ្វើការវិញនៅថ្ងៃស្អែក ។

ពាក់អាធ្រាតហើយ...

ជ្រូកលីវប្រែខ្លួនឡើង ឃើញកូនមាន់អង្គុយផ្អែកបង្គោលឫស្សី ជញ្ជាំងខ្ទមតែម្នាក់ឯងស្ងៀមស្ងាត់ ។ ក្រោមពន្លឺព្រះចន្ទដ៏ស្រទន់ ដែលជះតាមជញ្ជាំងរខេករខោក នារីធ្វើមុខស្ងួតស្ងប់ ចងចញ្ចើម ទំនងមានកង្វល់ក្នុងចិត្តស្រាយមិនចេញ ។

- កូនមាន់! នាងមិនទាន់គេងទេហ៍ ? (គេខ្សិបសួរនាងតិចៗ)

ធិតាភ្ញាក់ក្រញាង កាលបើឮនាយសួរដូច្នោះ ។ នាងក៏ឆ្លើយ ខ្សិបៗវិញ ៖

- ជ្រូកលីវគេងទៅ! ខ្ញុំមិនអីទេ... គ្រាន់តែខ្ញុំភ្ញាក់ផ្អើលបន្តិចដែល មកគេងកន្ទេលមួយជាមួយបុរសដល់ទៅប្រាំនាក់...

- តែមិត្តមិនបានគេងក្បែរពួកគេឯណា ? នាងគេងនៅខាងក្បែរ ជញ្ជាំង មានតែខ្ញុំទេដែលនៅជិតខ្លួននាង តើខ្លាចអីហ្នឹង ?

- មិនខ្លាចទេ... តែស្ថានការណ៍ពីរបីថ្ងៃនេះ ធ្វើអោយខ្ញុំទប់ស្មារតី ថា មិនតក់ស្លុតមិនបានសោះ ។

CHANBOKEO.COM

- មិត្តកុំគិតច្រើនអី... ស្រុកទេសជ្រួលច្របល់ ជីវិតរបស់យើងតែ
ប៉ុនហ្នឹងឯង មិនថាប្រុសមិនថាស្រីទេ... គឺវេទនាដូចគ្នា...
- យល់ហើយ គ្រាន់តែខ្ញុំពិបាកទ្រាំទ្រក្នុងចិត្ត...

កូនមាន់ស្រដីទាំងខ្សឹកខ្សួល ។ ជ្រូកលីវក្រោកឡើងលូកដៃជូត ទឹកភ្នែកអោយនិតា ៖

- មិនអីទេ! មិនអីទេ! ឥលូវយើងមកដល់កន្លែងសុខហើយ! ឈប់ភ័យឈប់បារម្ភទៀតទៅ ។
ម៉ោះ! គេងមកណា! កុំអោយ អត់ងងុយ ក្រែងធ្លាក់ខ្លួនឈឺថ្កាត់...

ឃើញជ្រូកលីវមានសន្តានចិត្តឈឺឆ្អាលចំពោះសុខទុក្ខរបស់នាង
កូនមាន់ក៏ដាច់ចិត្តផ្ដេកខ្លួនគេងក្បែរខាងបុរសយើង ទាំងទើសទាល់ ក្នុងចិត្ត ។

- ខំសម្ងំគេងទៅ! អ្វីកន្លងផុតអស់ហើយណា៎! សូមនាងគេងលក់ អោយបានស្ងប់ក្នុងចិត្ត!
សង្ឃឹមថាយប់នេះ យើងសុខសប្បាយ...

ឮសំដីដ៏ស្រទន់របស់ជ្រូកលីវ និតាហាក់ដូចជារំភើបចិត្តយ៉ាង ណាំមិនដឹងទេ រកថាមិនត្រូវ
ប៉ុន្តែក៏មិនមានស្តីអ្វីតបនាយវិញដែរ ក្រៅពីខំបឹងធ្មេចភ្នែក
ពន្លត់អារម្មណ៍ច្របូកច្របល់ទាំងឡាយដែល រំខានជីវិតនាងប៉ុន្មានថ្ងៃកន្លងមក ។
ណាមួយនារីយើងមិនចង់ឲ្យ ជ្រូកលីវអត់ងងុយ ដោយសារភាពខ្វល់ខ្វាយចំពោះសុខទុក្ខរបស់
នាងផង ព្រោះនាយកំពុងមានរបួសមិនទាន់បានទទួលការព្យាបាល អ្វីនៅឡើយទេ
ក្រៅពីទំពារគ្រួយស្លឹកឈើបិទមុខរបួសនោះ ។ មិន ដឹងថាពេលនេះ
គេកំពុងឈឺចាប់ក្នុងកាយប៉ុនណាឡើយ ។

*oooooooooooooooo*

*ooooooooo*

CHANBOKEO.COM

# វគ្គទី៩
# ពន្លឺជីវិត

ព្រហាមឡើង...

ទាំងអស់គ្នាជួយនាំជ្រូកលីវដល់រោងព្យាបាលប្រចាំជំរុំរួចហើយ ពួកគេក៏នាំគ្នាចេញទៅតាមពូតាលឹងទឹង រកមើលផ្លូវរកស៊ីរត់ពន្ធ ឥវ៉ាន់ឆ្លងមកពីប្រទេសថៃ ទុកអោយកូនមាន់នៅកំដរជ្រូកលីវតែ ម្នាក់ឯង ។ អ្នកទាំងពីរនៅតម្រង់ជួររង់ចាំឡើងថ្ងៃជិតត្រង់ ទើប ឃើញក្រុមពេទ្យបរទេសបើករថយន្តពេទ្យមកដល់ ។

- របួសគាត់មិនធ្ងន់ប៉ុន្មានទេ ។ នេះថ្នាំសំរាប់លេប៣ថ្ងៃ ។

អ្នកបកប្រែឆ្លើយប្រាប់មកជ្រូកលីវ ។

កូនមាន់ប្រែទឹកមុខភ្លាម កាលបើឮដូច្នោះ ហើយស្រដីថា ៖

- បងស្រីបកប្រែខុសហើយ ។ ខ្ញុំឮលោកគ្រូពេទ្យជាតិអាគាំងនោះ ថាអោយថ្នាំសំរាប់៧ថ្ងៃ មិនមែន៣ថ្ងៃទេ ។

ស្រាប់តែស្ត្រីអ្នកបកប្រែនោះខឹងឆេវតែម្តង ៖

- នែ៎! កុំចេះជាងគេអ្នកធ្វើការ! ថាបីថ្ងៃគឺបីថ្ងៃហើយ!

- មិនមែនទេ! បងស្រីបកប្រែបន្លំលាក់ថ្នាំទុកបួនថ្ងៃ ។

អ្នកទាំងពីរក៏ប្រកែកតវ៉ាគ្នាទៅវិញទៅមក មិនព្រមចាញ់រៀង ខ្លួន ។ ជ្រូកលីវទាញដៃកូនមាន់អោយអង្គុយចុះ ថែមទាំងនិយាយ ថា ៖

CHANBOKEO.COM

- គេអោយរបស់យើងមិនគិតកម្រៃហើយ កុំករឿងគេអីណា៎មិត្ត!

តែកូនមាន់មិនព្រមទេ ។ នាងស្ទុះក្រោកក្លែតស្រដីថា ៖

- វាជាអំណោយរបស់អន្តរជាតិដោយមិនគិតកម្រៃមែន តែមិន មែនបានន័យថាយើងបណ្តោយអោយគេកេងប្រវ័ញ្ចលើខ្លួង យ៉ាង ផ្ទែមអញ្ចឹងនោះទេ ។

ឮសំដីចេចចាចរបស់កូនមាន់ ពេទ្យបរទេសម្នាក់នោះក៏ដើរមក សួរនាងជាភាសាអង់គ្លេសថា ៖

- មានរឿងអ្វីហ្នឹង បានជាមាត់ឮខ្លាំងម្ល៉េះ ?

អ្នកបកប្រែឆ្លើយទៅពេទ្យបរទេសនោះ ថា ៖

- អ្នកជំងឺម្នាក់នេះមានសតិមិនល្អ ទើបមានរឿងរំខានតិចតួច

កូនមាន់ឮហើយអត់មិនបាន ក៏ឆ្លើយរឹងជាភាសាអង់គ្លេសវិញ យ៉ាងរហ័ស ៖

- អ្នកបកប្រែរបស់លោកធ្វើការមិនល្អ លួចកាត់បន្ថយថ្នាំពី៧ថ្ងៃ មកបីថ្ងៃ មិនដឹងថា គាត់ហ្នឹងចេះអង់គ្លេសមិនគ្រប់គ្រាន់ ស្តាប់ ភាសាមិនបាន ឬក៏គាត់មានបំណងកេងប្រវ័ញ្ចថ្នាំពីអ្នកជំងឺ ?

ឮភ្លាម ពេទ្យបរទេសនោះឈរសម្លឹងមុខកូនមាន់ធ្វើភាំង រួច ហើយទើបលាន់មាត់ថា ៖

- នាងចេះភាសាអង់គ្លេសត្រឹមត្រូវគួរសរសើរមែន!

បន្ទាប់មក ពេទ្យនោះក៏បែរទៅអ្នកបកប្រែហើយស្រដីថា ៖

- ការពិត អ្នកជំងឺនេះពិតជាត្រូវការថ្នាំ៧ថ្ងៃមែន ។ លើកក្រោយ បើស្តាប់មិនទាន់ ឬស្តាប់មិនយល់ ត្រូវសាកសួរបញ្ជាក់ម្តងទៀត មិនត្រូវបកប្រែទាំងខុសទេ ។ បើបកប្រែមិនត្រូវ អ្នកជំងឺមិនបាន ទទួលថ្នាំត្រឹមត្រូវតាមវេជ្ជបញ្ជា ហើយក៏មិនអាចជាសះស្បើយបាន តាមកំណត់ឡើយ ។ រីឯអ្នកស្រុកនឹងគិតថា ពេទ្យខ្ញុំនេះមានស្នាដៃ អន់ឬក៏ថ្នាំដែលយើងយកមកចែកចាយឲ្យប្រើជាថ្នាំដែលគ្មានប្រសិទ្ធិ ភាពគ្រប់គ្រាន់ ។ ធ្វើយ៉ាងនេះ អ្នកស្រុកនឹងអស់សេចក្តីទុកចិត្ត ចំពោះពួកយើង ហើយក៏ធ្វើឲ្យខូចកេរ្តិ៍ឈ្មោះរបស់ពួកយើង ដែល ខំសិក្សា ខំធ្វើការរាប់ឆ្នាំមកហើយនោះអស់រលីងផង ។ ម្យ៉ាងទៀត បើនាងមានគំនិតលួចកេងប្រវ័ញ្ចវិញនោះ នាងជ្រើសរើសកន្លែង ធ្វើការខុសហើយ សង្ឃឹមថានាងនឹងផ្លាស់ប្តូរគំនិត ហើយឈប់មាន សំដីក្អេងក្អាងដាក់អ្នកស្រុកដូចថ្ងៃនេះទៀត ។

CHANBOKEO.COM

នេះសំណាងល្អដែរ ដែលម្នាក់ខាងនេះចេះភាសាអង់គ្លេសល្អ អាចយល់នូវអ្វីដែលខ្ញុំចង់ និយាយ កុំអីខ្ញុំមិនបាននឹងរឿងដែលនាងធ្វើការភ្លាត់នេះឡើយ ។

មានប្រសាសន៍ចប់ លោកគ្រូពេទ្យនោះក៏ដើរចេញទៅ ទុកឲ្យ អ្នកបកប្រែនោះឈរសម្លក់ដាក់កូនមាន់ទាំងឃ្នាន់ខ្នាញ់ ព្រោះត្រូវ នាងជាន់កែងឡើងស្ពឹកមុខទាំងថ្ងៃ ។

កំពុងអង្គុយចាំបើកថ្នាំ ជ្រូកលីវខ្សិបសួរកូនមាន់ថា ៖

- មើលទៅ កូនមាន់រៀនសូត្របានខ្ពស់ណាស់ ទើបចេះភាសា អង់គ្លេសស្ទាត់ជំនាញយ៉ាងនេះ ?

មាណវីញញឹមឡើង ៖

- ចុះជ្រូកលីវគិតថា ខ្ញុំមានការសិក្សាដល់ណាដែរ ?

ជ្រូកលីវសម្លឹងមុខនាងមួយស្របក់ទើបឆ្លើយថា ៖

- ថ្នាក់មហាវិទ្យាល័យ ហោចណាស់ក៏ឆ្នាំទីមួយទីពីរដែរ

ឮដូច្នោះ កូនមាន់សើចគ្រហាញឡើង ៖

- យី! ប៉ិនទាយមែន! ហើយចុះជ្រូកលីវវិញនោះ ?

- ខ្ញុំក៏រៀនបានកំរិតប្រហាក់ប្រហែលហ្នឹងដូចគ្នាដែរ ទទួលស្រុក ទេសធ្លាក់ចូលមហន្តរាយសម័យខ្មែរក្រហមទៅ ខ្ញុំក៏ខកខានដូចតែ កូនមាន់អញ្ចឹង ។

ភ្លាមនោះ មានក្មេងជំទង់ម្នាក់រត់មកហៅ ៖

- បងស្រីៗ លោកគ្រូពេទ្យបរទេសម្នាក់នោះមានប្រសាសន៍អោយ បងស្រីទៅជួប ។

កូនមាន់ភ្ញាក់ព្រើតកាលបើឮដូច្នោះ រួចសួរវិញថា ៖

- គាត់មានអ្វីទៅប្អូន ?

- ខ្ញុំអត់ដឹងទេបង បងទៅជួបគាត់ទៅ

ថាហើយក្មេងក៏គេចចេញទៅវិញ ។

- ប្រហែលជាគេហៅទៅយកថ្នាំដោយផ្ទាល់ហើយ (កូនមាន់ស្រដី)

- ខ្ញុំថា មិនមែនទេ! មើលទៅទំនងជាគេពេញចិត្តនឹងចំណេះវិជ្ជា ផ្នែកភាសារបស់កូនមាន់ជាជាង (ជ្រូកលីវនិយាយកាត់) ខ្ញុំគិតថា លោកគ្រូពេទ្យហ្នឹងច្បាស់ជាបបួលកូនមាន់ អោយធ្វើការនៅរោង ព្យាបាលនេះមិនខាន ។

- ចេះតែថាហើយ ជ្រូកលីវនេះ ។ គេមិនស្គាល់ខ្ញុំច្បាស់ផង ម៉េច នឹងគេហ៊ានជ្រើសរើសយកខ្ញុំធ្វើការទៅ ?

CHANBOKEO.COM

មាណវីស្រដីហើយ ក៏ក្រោកដើរទៅរកលោកគ្រូពេទ្យមួយរូប នោះយ៉ាងរហ័ស ។ មែនហើយ លោកគ្រូពេទ្យម្នាក់នោះពិតជាមាន ចំណង ហៅកូនមាន់អោយចូលធ្វើការ ជាអ្នកបកប្រែក្នុងរោងព្យាបាលនោះមែន ។ លោកមានឈ្មោះ ថម ជាវេជ្ជបណ្ឌិតហ្វឹកហ្វឺន

មកពីសហរដ្ឋអាមេរិក ។

- លោកគ្រូពេទ្យពិតជាទទួលខ្ញុំធ្វើការទីនេះមែនទេ ?

កូនមាន់សួរបញ្ជាក់ ។

- បាទ! (លោកថមងក់ក្បាល) ខ្ញុំឃើញនាងចេះភាសាអង់គ្លេស ច្បាស់លាស់ល្អមទុកចិត្តបាន ទើបចង់បាននាងមកធ្វើការនៅទីនេះ ប៉ុន្តែយើងគ្មានកម្រៃសំរាប់ផ្តល់អោយជាប្រាក់បៀវត្សទេ មានតែ បាយពីរពេលក្នុងមួយថ្ងៃ និងបណ្ណ័បើកអាហារប្រចាំអាទិត្យ សំរាប់

ពេលអង្គការយកស្បៀងមកចែកដល់អ្នកស្រុកភៀសខ្លួន ។

កូនមាន់អរហើបជើងពីដី តែខំសួរបញ្ជាក់ម្តងទៀត ៖

- លោកទុកចិត្តហើយឬថាខ្ញុំអាចធ្វើការមានប្រសិទ្ធភាព ។

លោកថម ញញឹមហើយឆ្លើយថា ៖

- នាងសាកមើលទៅ ។ ខ្ញុំជឿថា នាងមិនធ្វើអោយក្រុមព្យាបាល របស់យើងខកចិត្តទេ ។

កូនមាន់មានអារម្មណ៍ថា ហាក់ដូចជាបានចាប់កំណើតម្តងទៀត ពេលដឹងច្បាស់ថា លោកគ្រូពេទ្យថមទទួលនាងធ្វើការ ។

- អញ្ចឹង តើពេលណាខ្ញុំអាចចូលធ្វើការបាន លោកគ្រូពេទ្យ ?

- ពេលនេះតែម្តង យ៉ាងម៉េចដែរ ?

- អឺ.... អោយខ្ញុំសុំអនុញ្ញាត្តិយកបងប្អូនទៅផ្ទះវិញសិន បានទេ ?

ព្រោះគាត់នៅអង្គុយចាំខាងក្រៅយូរហើយ ហើយចាំខ្ញុំត្រឡប់មក ធ្វើការជូនលោកវិញ ។

- បាទ!

ធិតាយើងអរណាស់ ក៏ប្រញាប់ប្រញាល់នាំជ្រូកលីវត្រលប់ទៅ

សំរាកនៅខ្ទមពូតាលឹងទឹងវិញ ។

តាមផ្លូវ....

- ធ្វើមុខដូរម្ល៉េះ ជ្រូកលីវ ? មិនសប្បាយចិត្តទេហ៏ដែលខ្ញុំមានការ ធ្វើ មានបាយបរិភោគ ? ជាពិសេសបានធ្វើការជាមួយជនជាតិ បរទេស ធ្វើអោយយើងអាចដុះខាត់ការចេះដឹង មិនអោយច្រេះ ចាប់ផង ។

CHANBOKEO.COM

ជ្រូកលីវគ្រវីក្បាល ៖

- ខ្ញុំថាគេកំពុងចាប់អារម្មណ៍លើរូបសម្បត្តិរបស់កូនមាន់ជាជាង ។

កូនមាន់ភ្ញាក់ក្រញាង បើកភ្នែកមូលក្រឡង់ឡើង ៖

- ចេះគិតផ្ដេសផ្ដាសអញ្ចឹងកើតដែរ យ៉ាប់មែន!

- មិនបានគិតផ្ដេសផ្ដាសទេ គឺខ្ញុំសង្កេតឃើញគេដូចជាចោលភ្នែក លើកូនមាន់ចម្លែកយ៉ាងណាមិនដឹងទេ ។

- នែ៎! កុំគិតច្រើនមើល៍! ខោមិនខោអាវមិនអាវ ពភ្លិកពភ្លក់ ដូចខ្ញុំនេះ មានសោភ័ណអ្វីត្រង់ណាទៅ ?

- មនុស្សភ្នែកមុត គេមិនសម្លឹងសំបកហ្នឹងទេ

- ពុទ្ធោអើយ! និយាយធ្វើមើល៍តែជាប្ដីកំពុងប្រចណ្ឌប្រពន្ធអញ្ចឹង

- ហើយចុះបើខ្ញុំមានអារម្មណ៍អញ្ចឹងមែន កូនមាន់ថាម៉េចដែរ ?

- យី! ថាម៉េចហ្នឹង ? កុំនិយាយលេងមើល៍!

- មិនបាននិយាយលេងទេ គឺខ្ញុំនិយាយលេងមែន ។

- ហ៊ឺយ! និយាយស្ដាប់គ្នាមិនបានសោះ ជ្រូកលីវនេះ តិចឈប់ គ្រាហ៍ទៅផ្ទះវិញអាលូវ!

ឮដូច្នោះ ជ្រូកលីវក៏នៅស្ងៀម ទុកបណ្ដោយអោយធិតាយើង ជួយទប់ខ្លួននាយដើរត្រិបៗ សំដៅវិមានស្បូវរបស់ពូតាលឹងទឹង នៅក្នុងចិត្ត គេនៅគិតពិភាល់ចង់ដឹងថានារីមានអារម្មណ៍យ៉ាងណា..

ព្រលប់ថ្ងៃនដែល...

- នែ៎ជ្រូកលីវ! ឯងតតេះតតះបំរុងទៅណាហ្នឹង ?

- ខ្ញុំទៅតាមកូនមាន់ណា៎ខេង! ព្រលប់ជិតងងិតហើយនៅមិនទាន់ ឃើញមកផ្ទះ ។

- បន្តិចទៀតគេមកដល់ហើយ កុំបារម្ភអី! មើលទៅឯងទុរន់ទុរា យ៉ាងហ្នឹង នៅរក្សាខ្លួនអោយល្អវិញ ប្រសើរជាង ។

ជ្រូកលីវដាក់ខ្លួនអង្គុយចុះវិញ ។ ពូតាលឹងទឹងដួចបបរមួយ ចានហុចអោយនាយ ៖

- នេះអ្នកជំងឺ! ដាក់ម៉ាចានអោយឆ្អែតសិនទៅ ដើម្បីឆាប់ជា នឹង អាលបានជូនដំណើរកូនមាន់ទៅមក មិនចាំបាច់អង្គុយចាំកន្ទុះរា បែបនេះតទៅទៀត ។ ហក់! នេ៎ះ! យកទៅ ។

ជ្រូកលីវគ្រវីក្បាល ៖

- ពូពិសាមុនចុះ បាទ! ខ្ញុំមិនទាន់ឃ្លានទេ!

ការពិត ជ្រូកលីវឃ្លានស្ទើរដាច់ពោះទៅហើយ ប៉ុន្តែក្នុងចិត្ត កំពុងបារម្ភពីកូនមាន់ណាខ្លាចចិត្តពូតាលឹងទឹង គេក៏ប្រកែកយកគួរ សម ថ្វីបើទឹកមាត់កំពុងហូរច្រោកៗ ស្ទើរតែហៀរមកក្រៅម្តងៗ ទៅហើយក៏ដោយ ។

- អឺ ស្រេចតែចិត្តឯងចុះ ។ ចាំពូទុកម៉ាចានអោយ ។

បន្ទាប់មក ពូតាលឹងទឹងក៏បបួលកូនក្មួយនិងនាយខេង វាតវង់ បរិភោគ ។

- ម៉េចពូពិសាបាយចោលខ្ញុំអញ្ចឹងពូ ? នេះនែ៎ ខ្ញុំបានម្ហូបមកពី កន្លែងធ្វើការ យកមកផ្ញើផង ។

ទាំងអស់គ្នាភ្ញាក់ព្រើតបែរមើលម្ចាស់សម្លេង ក៏ប្រទះឃើញកូនមាន់ដើរចូលមកក្នុងសម្លៀកជាអ្នកធ្វើការក្នុងពេទ្យ ។ ទាំងអស់គ្នាក៏ញញឹមគ្រហាញទទួលនាងភ្លាម ។ ចម្លែកអី តែជ្រូកលីវម្នាក់ឃើញកូនមាន់ហើយបែរជាមុខក្រញូវទៅវិញ ។

- អូហូហ៍ ក្មួយស្រី! បែកតែម៉ាថ្ងៃសោះ ចេះប្រែក្រឡាខ្លួនស្រស់ ម្ល៉េះហ្នឹង ? ពូវីះតែមើលមិនស្គាល់ទៅហើយ ។

កូនមាន់ញញឹមឡើង ៖

- កន្លែងធ្វើការគេបើកអោយប្រើទេពូ ព្រោះខោអាវខ្ញុំវាយ៉ាប់មើល ពេក ។ ចាំស្អែក ចាំខ្ញុំបោកខោអាវសងបងដុំដីវិញអោយស្អាតណា៎

នាយដុំដីលើកដៃរា ៖

- មិនអីទេ! បើត្រូវការ មិត្តប្អូនទុកពាក់សិនចុះ ព្រោះខ្ញុំនៅមាន អាចាស់ៗម៉ាបម្លាស់ពីរល្មមប្រើបានដែរ ។

នាយដុំដីនិយាយផង ស្រវាកញ្ចប់អាហារពីដៃរបស់កូនមាន់មក ចាក់ដាក់ចានចែកគ្នាបរិភោគផង ។ រំពេចនោះ នាយខេងក៏ស្រវា ទាញកញ្ចប់មួយ ចេញមក ៖

- ខ្ញុំទៅជួយរែកអីវ៉ាន់រត់ពន្ធអោយគេពេញម៉ាថ្ងៃ បានទទួលកម្រៃ ចិតសិបបាត ហើយក៏ទិញសារុងមួយមកផ្ញើកូនមាន់ ។ នេះយកទុក ប្រើទៅ!

កូនមាន់ភ្ញាក់ព្រើតមិននឹកស្មានថា នាយខេងផ្តល់នូវការចាប់ អារម្មណ៍ចំពោះនាងដល់ម្លឹងទេ ។ ឃើញនារីអង្គុយអេះអុញៗ ខេង ក៏លូកស្រវាចាប់ដៃកូនមាន់អោយលាតឡើង រួចហើយក៏ដាក់របស់ ទម្លាក់ទៅក្នុងដៃនាង ៖

CHANBOKEO.COM

- ខ្ញុំអោយមិត្តពិតមែនណា! កុំថាអីថាវាន់!

កូនមាន់ទទួលយកដោយក្តីរំភើប ចំពោះទឹកចិត្តនាយខេង ។ នៅក្បែរនោះ ជ្រូកលីវផ្អែកខ្លួនកើយបង្គោលឫស្សីសសរខ្ទម ធ្វើ មុខស្មឿក ។

- ម៉េចបានធ្វើមុខដូចជាមិនរីករាយជាមួយកូនមាន់ដែលបានការធ្វើ នៅជំរំនេះអញ្ចឹង នាយលីវ ?

ខេងយកដៃទះស្មាជ្រូកលីវ ។ គេក៏បង្ខំចិត្តធ្វើពើជាញញឹមទាំង ស្ងួតស្ងប់ ហើយឆ្លើយដោះសារថា ៖

- មកពីខ្ញុំមិនសូវស្រួលខ្លួន ទើបមុខជ្រួញៗមិនស្អាតដូចគេណា៎!

ស្រាប់តែពូតាលីងទីងសើចវ៉ាសឡើង ៖

- ឯងស្អាតឯណាស្មើនឹងនាយម៉ាប់ នាយដុំដី ? ពុទ្ធោអើយ! មើល៍ ទៅមុខអាពីរនាក់នេះចុះ សមនឹងទឹកក្នុងជំរំក៏មិនសូវសំបូរ ហើយ មារយាទវាវិញក៏កំជិលផេះ ម៉ាខែបានដូតទឹកម្តង មើលនែ៎ ស្រែង កមរមាស់វារាលដាលពេញខ្លួន... អេះព្រឹកល្ងាចចេញក្រមរអោយ រឃីង ទុកណាក៏ឯងនៅគ្រាន់បើជាងពួកវាបន្តិចដែរ អានាងអើយ

ភាពកំប្លែងរបស់ពូតាលីងទីង បានធ្វើអោយអ្នកទាំងអស់គ្នា សើចហោរគិលឡើងព្រមគ្នាយ៉ាងរីករាយ ។ នាយដុំដីយកដៃអេះ ក្បាលយ៉ាងញាប់ ស្រដីបន្តថា ៖

- ពុទ្ធោអើយពូខ្ញុំ! បែកកេរ្តិ៍ខ្ញុំចែកក្រមុំៗនឹងអស់អាលីងអញ្ចឹង តើអោយខ្ញុំរកប្រពន្ធម៉េចបាននឹងគេទៅពូ ?

- មុខឯងហ្នឹងគ្មាននរណាគេយកធ្វើប្តីទេ នឹងហើយនៅនាយដុំដី ?

- ហើយចុះគេទុកអោយធ្វើអីវិញពូ ?

- គេទុកអោយនៅយាមកុដិលោក

- ហ្ហ៎ក! សម័យនេះ ពួកខ្មែរក្រហមបំផ្លាញអស់វត្តអស់ព្រះសង្ឃ រលីងយ៉ាងនេះ បានអីយាមទៅ ?

- គឺឯងត្រូវយាមចង្ក្រានបាយពូ កុំអោយចោរវាលួចឆ្នាំង ក្រែងថ្ងៃ ស្អែកអត់អីដាំបាយទៅ ។ នឹងទេ ថានៅជំរំនេះ មនុស្សគ្រប់គ្នា ដែលឯងជួប សុទ្ធជាចោរទាំងអស់ ឲ្យតែឃ្លានហើយ ស្អីក៏វាលួច ដែរ ។

- ហើយចុះពូតាលីងទីងហ្នឹងជាចោរនឹងគេដែរទេ ?

- ចឹក៏មិនចោរ... លួចដោះអាវខ្មោចងាប់យកមកពាក់ហើយ នៅ ធ្វើឫកគ្រាន់បើស្អីទៀត ? ចោរអាទាំងអស់ហ្នឹង ។

CHANBOKEO.COM

ទាំងអស់គ្នាក៏សើចហ៊ោរឡើងសាជាថ្មី ។

................................

យប់នោះ ជ្រូកលីវហាក់ដូចជារសាប់រសល់ក្នុងចិត្តចម្លែកខុស ធម្មតា ។ គេមិនដែលមានអារម្មណ៍បែបនេះទេពីមុនមក ។ ពេល នេះ ខ្លួនគេហាក់ដូចកំពុងគេងនៅលើភ្នក់ភ្លើងដ៏ក្តៅមួយ ៖

- យី! ខ្ញុំនេះយ៉ាងម៉េចហ្នឹង ? ហេតុអ្វី ខ្ញុំមានអារម្មណ៍ម៉ូម៉ៅបែប នេះផង ?

ជ្រូកលីវលួចគិតក្នុងចិត្ត ។ យូរៗម្តង នាយក្រោកលួចមើល កូនមាន់ក្រញាស់ ឃើញនាងគេងអោបដៃកំប្រោនៗ ហាក់ដូចជា រងា ។ គេក៏ទាញក្រមាយកទៅដណ្តប់អោយនាង ហើយគិតក្នុងចិត្ត បន្តទៀតថា ៖

- កូនមាន់! សូមអោយនាងបានសុខសប្បាយរហូតទៅណ៎! កុំបី មានអ្វីមកបៀតបៀនជីវិតនាងបានអោយសោះ ។

ជ្រូកលីវគេងសម្លឹងភ្លិះៗ មើលនារីដែលគេងបែរខ្នងមករក នាយ... រហូតដល់វេលាដែលនាងនិទ្រាទេពីសណ្តំត្របកភ្នែកយ៉ាង ធ្ងន់ទ្រាំលែងបាន ។

ទ្រីន! ទ្រីន!

ស្នូរសន្ធឹករថយន្តបរមកឈប់នៅមុខខ្ទមកំព្រុករបស់ពូតាលឹង ទឹង ។ ជ្រូកលីវបើកភ្នែកឡើង ឃើញកូនមាន់រៀបចំខ្លួនហើយ ស្រេច ងាកមកញញឹមដាក់ទាំងអស់គ្នា ហើយស្រដីថា ៖

- គ្រូពេទ្យមកទទួលខ្ញុំទៅធ្វើការហើយ! សូមលាទាំងអស់គ្នា! ពេលល្ងាចពិសាបាយ ចាំខ្ញុំផងណ៎ា ខ្ញុំនឹងយកអាហារមកចូលរួម ។

ថាហើយនាងក៏អោនដើរចេញពីខ្ទម សំដៅរថយន្តហ្ស៊ីបដែល កំពុងបញ្ឆេះចាំនៅក្រៅផ្ទះ ។

- អីយ៉ូយ! ទើបតែមកដល់ជំរំបានពីរថ្ងៃ សុទ្ធតែមានចៅហ្វាយ ជាតិបរទេសមកទទួលទៅធ្វើការដល់ផ្ទះ ពិតជាមិនធម្មតាមែន!

នាយម៉ាប់លាន់មាត់ ។

- មិត្តឯងនិយាយបែបនេះ ចង់មានន័យថាម៉េច ?

ជ្រូកលីវសួរ ហាក់មិនសប្បាយចិត្តចំពោះពាក្យសំដីនោះ ។

- ខ្ញុំមានថាអីណា គឺខ្ញុំគិតថានាងមានរាសីខ្ពស់ទេតើហ៎ មិនដូចពួក យើងដែលមានរាសីរហេមរហាមនោះទេ ហើយខ្ញុំក៏មិនបានគិតអ្វី ផ្តេសផ្តាសដែរ មិត្តកម្លោះអើយ ។

ថាហើយ នាយម៉ាប់ក៏ក្រោកដើរគេចចេញទៅ ទំនងហាក់ដូច
ជាយល់ជំរៅចិត្តរបស់ជ្រូកលីវ ។ ខេងឃើញមិត្តរបស់ខ្លួនធ្វើមុខ ក្រញូវ គេក៏កេះខ្សិបថា ៖
- នែ៎សម្លាញ់! រៀនរក្សារាសីអោយគ្នីគ្នាផង់យើងផង ។ គេទើប បានការធ្វើ
ហើយធ្វើនៅកន្លែងល្អទៀត ឯងមិនជួយត្រេកអរ បែរ ជាក្រញាំក្រញូវទៅវិញ ។ ឯងនេះ
យ៉ាប់មែនទែនហើយ ។

ជ្រូកលីវឮហើយយកដៃច្រាននាយខេង ៖
- អឺ! អញ្ចឹងឯងប្រញាប់ទៅយកចិត្តគេ... យកមុខយកមាត់ថែម បន្តិចទៀតទៅ!
ធ្វើម៉េចគ្នាកំបាក់កំបែកជួយអ្វីគេមិនកើត ។
- ម៉េច ? ចង់ប្រណាំងប្រជែងគ្នាមែនទេ ? អញ្ចឹងក៏បាន ម៉ោះ! យើងប្រកួតគ្នាបែបអ្នកកីឡា
អ្នកណាមានគុណសម្បត្តិប្រសើរយក ឈ្នះចិត្តកូនមាន់បានគឺអ្នកហ្នឹងហើយ! ម៉េចសុខចិត្តទេ ?

នាយខេងថាហើយក៏លូកដៃហុចមក រួចស្រដីថែមថា ៖
- ម៉ោះ! ចាប់ដៃគ្នាសន្យា! យ៉ាងម៉េចដែរ ?

ម្តងនេះ ជ្រូកលីវធ្វើអាការៈអេះអុញតែម្តង ។ តែដើម្បីកុំឲ្យ បាត់បង់កិត្តិយសកូនប្រុស
គេក៏ខាំមាត់លូកចាប់ដៃនាយខេងវិញ ហើយពោលថា ៖
- យល់ព្រម! យើងប្រកួតគ្នាដោយគុណធម៌និងសីលធម៌ ។

ខេងក៏ញញឹមឡើង ។ ពូតាលឹងទឹងនិងនាយដុំដីដែលអង្គុយ
មើលពីរនាក់ជជែកគ្នាក្បែរនោះយូរហើយ ក៏ទះដៃហ៊ោរគ្រេវឡើង ព្រមគ្នា ៖
- អស្ចារ្យ! នេះបានហៅចិត្តអ្នកកីឡាមែន ។

ខេងយកដៃទះស្មាជ្រូកលីវហើយ ក៏បបួលម្ចាស់ខ្ទមចេញទៅ
ក្រៅរកប្រកបរបរចិញ្ចឹមជីវិតតទៅទៀត ទុកអោយនាយជ្រូកលីវ
នៅតែឯងចាំខ្ទមយ៉ាងស្ងៀមស្ងាត់កណ្តោចកណ្តែង ៖
- កូនមាន់អើយ! ពេលនេះ នាងដឹងទេ ថាខ្ញុំកំពុងតែនឹកនាង មិនដាច់នាទីណា ?

មាណពយើងអង្គុយរវើរវាយហៅឈ្មោះកូនមាន់តែម្នាក់ឯង ក្នុងខ្ទម ដដែលជាងដែល
ហាក់ដូចជាមិនចេះធុញទ្រាន់ទាល់តែសោះ...

oooooooooooooooooo

oooooo

CHANBOKEO.COM

0

CHANBOKEO.COM

# វគ្គទី១០
# ហេតុការណ៍ថ្មី

ជាងមួយអាទិត្យកន្លងទៅ...

ថ្ងៃនេះ កូនមាន់មកដល់ផ្ទះពីថ្ងៃខុសធម្មតា ។

- ការងារអត់រវល់ទេហ៍ ទើបឆាប់មកដល់ផ្ទះម្លេះ ?

ជ្រូកលីវសួរ ។

- គឺមកពីគ្រូពេទ្យបរទេសទាំងនោះមានការប្រជុំនៅអារញ្ញទើបបិទ រោងព្យាបាលតាំងពីថ្ងៃត្រង់ ។

កូនមាន់តបវិញទាំងញញឹម ។ តែជ្រូកលីវបែរជាជ្រួញចិញ្ចើម ទៅវិញ ៖

- លោកគ្រូពេទ្យថម តែងតែឆៀងចូលមកដឹកកូនមាន់ យកទៅរោងព្យាបាលរៀងរាល់ព្រឹកមិនដែលខានទេ ។ មើលទៅគាត់ដូចជាពេញចិត្តពេញថ្លើមនឹងកូនមាន់ណាស់ ។
- មកពីគាត់ឃើញខ្ញុំធ្វើការល្អនោះអី ។
- មិនមែនទេ គឺគាត់កំពុងសម្លឹងរូបសម្បត្តិរបស់កូនមាន់ហើយ ។
- នែ៎ កុំប៉ាន់ស្មានតែផ្តាសអញ្ចឹង ។ គឺគេមានទឹកចិត្តសប្បុរសធម៌ លើយើងទេ កុំប្រមាថសន្តានចិត្តគេបែបនេះ វាបាបណា៎ ។

ជ្រូកលីវនៅស្ងៀម ។ រំពេចនោះ គេដាក់ភ្នែកទៅឃើញសំណុំក្រដាសមួយរមូរក្នុងថង់ដែលកូនមាន់យួរមកពីកន្លែងធ្វើការ ៖

- ក្រដាសអ្វីហ្នឹង កូនមាន់ ?

CHANBOKEO.COM

- អូហ៍ជាក្រដាសធានាគំរូរបស់អ្នកជំងឺខ្លះៗ ខ្ញុំចម្លងយកមកទុក អានលេង ចង់នឹងថា
គេធានាចេញក្រៅប្រទេសហ្នឹងវាយ៉ាងម៉េច ខ្លះ ?
- មានន័យថា កូនមាន់មានបងប្អូននៅក្រៅប្រទេសមែនទេ ?
- អត់មានទេ! (កូនមាន់គ្រវីក្បាល) តែខ្ញុំចង់ស្វែងរកមធ្យោបាយ
ជួយខ្លួនឯងអោយបានចេញទៅបរទេសនឹងគេ ព្រោះខ្ញុំចង់រៀន បន្តណាស់
ខាតពេលវេលាបួនឆ្នាំក្នុងសម័យខ្មែរក្រហម ខ្ញុំភ្លេច ចំណេះដែលបានរៀនជិតអស់រលីងហើយ ។
- ហើយ កូនមាន់មានសួរគេទេហ៍ ថាបើមានអ្នកធានាយើង យើង អាចចេញពីទីនេះបាន ?
- សួរហើយ គឺសួរជនបរទេស ដែលធ្វើការនៅកាកបាទក្រហម អន្តរជាតិ ។ គេប្រាប់ថា
ជំរំនេះស្ថិតក្នុងដីខ្មែរ ដូច្នេះគេមិនហៅថា ជាជំរំជនភៀសខ្លួនទេ
លុះណាតែជំរំនោះស្ថិតនៅក្រៅប្រទេសខ្មែរ ទើបយើងក្លាយជាជនភៀសខ្លួន
ហើយមានសិទ្ធដាក់ពាក្យសុំជ្រក កោននៅប្រទេសដទៃបណ្តោះអាសន្នបាន
ទំរាំស្រុកទេសទទួលភាព សាន្តត្រាណឡើងវិញ ។
- អញ្ចឹង បើមានសំបុត្រធានាហើយ ក៏មិនមែនបានន័យថា អាច
មានឱកាសចេញក្រៅប្រទេសនោះដែរ មែនទេ ?
- មែនហើយ! កាលបើយើងរស់នៅក្នុងទឹកដីប្រទេសរបស់ខ្លួន
ឯង យើងមិនមែនជាជនភៀសខ្លួនទេ ។
- តើយើងធ្វើម៉េចទៅ នឹងអាចមានឱកាសដាក់ពាក្យសុំទៅរៀន នៅប្រទេសទីបីបានទៅហ្ន៎ ?
- ជ្រូកលីវកុំភ័យអី! ខ្ញុំខំប្រឹងធ្វើការជាមួយជនបរទេសអោយគេ
ជឿទុកចិត្តនូវសមត្ថភាពរបស់យើង ដើម្បីអោយគេមានទឹកចិត្ត ធានាយើងយកចេញ
ដោយទេពកោសល្យការងារ ។
- ធានាយើង ? មានន័យថា...ខ្ញុំនិងកូនមាន់ មែនទេ ?
- ចា៎ស! គឺយើងទាំងពីរ មានន័យថា ខ្ញុំមិនទៅចោលជ្រូកលីវទេ សូមមេត្តាកុំភ័យពេកអី ។
យើងទៅណាទៅទាំងអស់គ្នា មិនចោល គ្នាឡើយ ។ នៅគ្រាកំសត់កម្រ យើងមិនចោលគ្នាផង
ចុះទំរាំគ្រា សុខសាន្តដូច្នេះ តើអោយយើងភ្លេចគ្នាយ៉ាងម៉េចកើតទៅហ្ន៎ ?

កូនមាន់ញញឹមដាក់ជ្រូកលីវយ៉ាងរីករាយ ធ្វើអោយនាយយើង
រំភើបរីករាយយ៉ាងចម្លែកតែម្តង ។

រំពេចនោះ ស្រាប់តែពួកគេឃើញមនុស្សរត់ប្រសេចប្រសាច កូកហៅគ្នាលាន់ពេញជំរំ ។

CHANBOKEO .COM

- មានរឿងអ្វីហ្នឹង ? (ជ្រូកលីវលាន់មាត់ឡើង)
- មិនដឹងទេ! មិត្តនៅក្នុងខ្ទមហ្នឹងហើយ ចាំខ្ញុំទៅសាកសួរគេសិន បន្តិចខ្ញុំមកវិញ ។

ថាហើយ កូនមាន់ក៏បោះជំហានចេញទៅយ៉ាងរហ័សរកតែជ្រូក លីវឃាត់មិនទាន់ ។ មួយស្របក់មក នារីក៏ត្រលប់មកវិញទាំងស្លន់ ស្លោ ។

- មានការអ្វីចម្លែកមែនទេ ?
- ចា៎ស! ឃើញមានរថយន្តធំៗមកពីប្រទេសថៃ ហើយមានគេ ប្រកាសអោយជនភៀសខ្លួនឡើងរថយន្ត ដើម្បីដឹកទៅនៅកន្លែង ផ្សេងទៀត ។
- បើអញ្ចឹងមែន ហេតុអ្វីមានអ្នកខ្លះអរ អ្នកខ្លះភ័យ ?
- ខ្លះគិតថា គេដឹកទៅជំរំជនភៀសខ្លួនក្នុងដីថៃ ។ ខ្លះទៀតថា គេ ដឹកយកទៅចាក់ចោលនៅតំបន់ខ្មែរក្រហមកាន់កាប់...
- អញ្ចឹងយើងគិតយ៉ាងណាទៅ ?
- ខ្ញុំគិតថាមិនទៅទេ ព្រោះខ្ញុំមិនដឹងគោលដៅពិតប្រាកដ ។ ណា មួយ ខ្ញុំមិនទុកចិត្តសកម្មភាពរបស់រដ្ឋាភិបាលថៃអ្វីបន្តិចឡើយ មិន ដឹងថាគេចិត្តល្អជាមួយយើងដើម្បីក្រេបជំនួយអន្តរជាតិ ឬក៏គេស្អប់ យើង ដែលរត់ឈ្លានពានទន្ទ្រានចូលក្នុងទឹកដីគេ ទាំងម៉ឺន ទាំង ពាន់យ៉ាងនេះ ?

ជ្រូកលីវយកដៃឈ្លីថ្ងាស ៖

- យើងគួរតែនៅស្ងៀមមើលស្ថានការណ៍សិនទៅចុះ យ៉ាងណាៗ ចាំឡើងឡានក្រោយគេក៏បាន ។

រំពេចនោះ ស្រាប់តែអ្នកទាំងពីរឮមាត់ស្រែកកូកហៅ ។ គេក៏ អើតទៅក្រៅ ឃើញបុរសស្លៀកពាក់ជាឯកសណ្ឋានដើរកូកហៅអ្នក ស្រុកឡើងរថយន្តដែលកំពុងបញ្ឆេះចាំមនុស្ស ។

- ឃើញទេ ? ខ្ញុំពិភាល់ក្នុងចិត្តណាស់ គិតមិនអស់មិនហើយ ថា នេះជាចេតនាល្អរបស់អង្គការអន្តរជាតិសង្គ្រោះជនភៀសខ្លួន ឬក៏ ជាកលល្បិចរបស់រដ្ឋាភិបាលថៃ ។ ហេតុអ្វីបានពួកដែលដើរកោះ ហៅអ្នកស្រុកនេះនិយាយខ្មែរប៉ែឡាំ ? ហេតុអ្វីក៏ចិត្តល្អដើរប្រមូល មនុស្សយ៉ាងសស្រាក់សស្រាំផង ?

CHANBOKEO.COM

កូនមាន់ពិចារណាហេតុផលជាមួយជ្រូកលីវតែពីរនាក់ ។ ភ្លាម នោះ នាយខេងរត់មកដល់ស្រែកវ៉ាសពីចម្ងាយមកថា ៖

- នែ៎អ្នកទាំងពីរ មិនប្រញាប់ទៅឡើងឡាននឹងគេទេហ្អី ? ហ្នឹ៎ គេកំពុងចាំដឹកអ្នកស្រុកចូលដីថៃណា៎ ។

- មិនទេ! (កូនមាន់គ្រវីក្បាល) មិត្តខេងមិនឆ្ងល់ទេហ៏ ថាសុខៗហេតុអ្វីគេមកចិត្តល្អហ្នឹងយើងអញ្ចឹង កាលបើគេប្រើចុងកាំភ្លើងបាញ់រះសម្លាប់ពួកអ្នកស្រុករាល់ថ្ងៃ ពេលពួកគេរត់ឆ្លងចូលដីថៃ ?

ខេងឮហើយទុចដឹក់ ទំនងពិចារណា រួចហើយក៏បែរមើលជ្រូក លីវឃើញនាយហាក់ដូចជាយល់ស្របនឹងកូនមាន់ដែរ ។

- អញ្ចឹងក៏បាន! អ្នកទាំងពីរសំរេចចិត្តមិនទៅ ខ្ញុំក៏មិនទៅណាដែរ តែពូតាលឹងមឹងនិងកូនចិញ្ចឹមពីរនាក់នោះឡើងរថយន្តទៅមុនបាត់ ទៅហើយ ។

- អរគុណណាស់សម្លាញ់ដែលឯងមិនរត់ចោលគ្នីគ្នា ។

ជ្រូកលីវយកដៃទះស្មានាយខេងដោយក្ដីសរសើរ ។

យប់នោះ មនុស្សម្នាចាកចេញឡើងស្ងាត់ជំរំទាំងមូល នៅសល់ តែមនុស្សរពុយមួយៗដែលមិនព្រមឡើងរថយន្តទៅតាមគេ មិន ដឹងថាគេគិតយ៉ាងណាមានគម្រោងជីវិតយ៉ាងណាឡើយ ។ ទាំងបី នាក់ កូនមាន់ ជ្រូកលីវ និងខេងក៏គេងអោបដៃមើលមុខគ្នាម៉ក់ៗ នឹកក្នុងចិត្តមិនអស់មិនហើយអំពីស្ថានការណ៍ចម្លែកថ្ងៃនេះ ។

- មិនដឹងថ្ងៃស្អែក ខ្ញុំមានការធ្វើទៀតដែរឬទេហ្ន៎ ?

កូនមាន់និយាយខ្សិបៗដាក់ជ្រូកលីវ ។ នាយក៏ស្រដីតបថា ៖

- សង្ស័យណាស់ថាអត់... ព្រោះមនុស្សចេញពីជំរំអស់ហើយ

ស្រាប់តែខេងលាន់មាត់ឡើងថា ៖

- មិនទៀងទេ... បើអ្វីៗកើតឡើងយប់នេះ ជាកលល្បិចរបស់ជាតិ ថៃ ស្អែកនេះពួកអង្គការអន្តរជាតិនិងត្រលប់មកវិញដូចធម្មតាហើយគេនឹងភ្ញាក់ផ្អើលចំពោះហេតុការណ៍នេះមិនខានឡើយ ។

- តែបើជាគំរោងរបស់អង្គការអន្តរជាតិវិញ (ជ្រូកលីវឆ្លើយ) ពួកគេហ្នឹងដើរហើរតាមប្រភពជនភៀសខ្លួនហើយ ហើយគេក៏លែង ត្រឡប់មកទីនេះទៀត ។

CHANBOKEO.COM

- ទុកណាក៏គេនៅគិតខ្លះដែរ ថាមានមនុស្សខ្លះមិនចង់ផ្លាស់ប្តូរទី តាំង ដូចជាពួកយើងនេះជាដើម ដូច្នេះគេនៅតែត្រឡប់មកវិញមក រកពួកយើង ។

ជជែកគ្នាទៅជជែកគ្នាមក មេឃក៏ភ្លឺល្មម ។

ទាំងបីនាក់ក៏នាំគ្នាដើរមកដល់ដើមផ្លូវចូលពីប្រទេសថៃមកជំរំ ដើម្បីរង់ចាំមើលស្ថានការណ៍ ។ នៅទីនោះ គេបានឃើញអ្នកស្រុក ដប់ម្ភៃនាក់មកដល់ដែរ ។ មិនយូរប៉ុន្មាន រថយន្តអន្តរជាតិក៏បាន មកដល់... មែនហើយ! ពួកគេមានការភ្ញាក់ផ្អើលមិនខុសពីអ្នកស្រុកប៉ុន្មានដែរ ចំពោះស្ថានការណ៍ពីយប់មិញ ។ ភាគច្រើនធ្វើមុខ មឹងមាំងមិនដឹងខ្យល់អ្វីបន្តិច ខ្លះទៀតធ្វើមុខស្រងូត ហើយក៏ចាប់ ផ្តើមការងារដូចធម្មតា ។ ពេលនេះ ជំរំស្ងាត់ជ្រងំណាស់ មិនអ៊ូអរ ខ្ញៀវខ្ញាដូចសព្វដងទេ ។

នៅក្នុងរោងព្យាបាល...

- នាងចង់ទៅរស់នៅប្រទេសទីបីទេ ?

លោកគ្រូពេទ្យថម សួរទៅកូនមាន់ជាភាសាអង់គ្លេស ។

- បើសិនមានឱកាស ខ្ញុំពិតជាចង់ទៅរៀនណាស់... តើមានមធ្យោបាយណាអាចអោយខ្ញុំដាក់ពាក្យសុំជ្រកកោនបានទេ ?
- មាន... តែនាងត្រូវតែជាជនភៀសខ្លួននៅជំរំក្នុងដីថៃ... ហ៊ឺ! នាងកុំចង់ទៅអី...នៅជំរំខ្លះសំបូរទៅដោយពួកទាហានខ្មែរក្រហម ដែលរត់ចេញពីស្រុកខ្មែរមក ។ ខ្ញុំថានាងគ្មានសុវត្ថិភាពទេ ។
- បើអញ្ចឹងស្រេចហើយ...
- តែនៅមានមធ្យោបាយមួយទៀត
- មែនឬលោកគ្រូពេទ្យ ? តើជាមធ្យោបាយអ្វីទៅ ?

កូនមាន់សួររន្ថើន ។

- គឺនាងទៅជាមួយខ្ញុំ ។
- ជាអ្នកបកប្រែជូនលោកមែនទេ ?
- ខុសហើយ!
- អញ្ចឹងជាអ្វីវិញទៅ ?
- គឺ... ជាប្រពន្ធរបស់ខ្ញុំ
- ចាស ? ថាម៉េច ?

CHANBOKEO.COM

កូនមាន់បើកភ្នែកធំៗ បែរក្រោយមើលទៅនាយខេងនិងជ្រូក លីវដែលអង្គុយពីក្រោយ រួចហើយក៏បែរមកវិញ ហើយក៏ឆ្លើយ យ៉ាងរហ័សថា ៖

- បើអញ្ជឹង មិនបាច់ក៏បានដែរ! អរគុណចំពោះបំណងល្អរបស់ លោកគ្រូពេទ្យ ។

នារីខកណាស់ ដែលឃើញលោកគ្រូពេទ្យថម ស្រដីលែបខាយ លលេងរូបនាងដូច្នោះ ។ នាងដើបចេញពីកៅអីបំរុងនឹងដើរចេញ ទៅ ស្រាប់តែលោកគ្រូពេទ្យថមស្រដីបន្តថា ៖

- អីក៏ប្រញាប់ច្រឡោតម្ល៉េះ ? ខ្ញុំគ្រាន់តែគិតរកមធ្យោបាយជួយ នាងទេ មិនមានចិត្តគិតប្រមាថលើនាងឡើយ ។

- តែមធ្យោបាយនេះ ខ្ញុំមិនចូលចិត្ត ។

- ដឹងហើយ... មើលហ្ន៎! នាងដូចជាខឹងខ្លាំងណាស់! សូមទោស ណា៎ ដែលខ្ញុំនិយាយត្រង់ៗពេក ។ ណ្ហើយចុះ! ខ្ញុំឃើញនាងឆ្លាត មានការចេះដឹងច្រើន ហើយឧស្សាហ៍ធ្វើការ ទើបចង់ជួយ ។ ពេល នេះ.. ខ្ញុំលែងដឹងហើយថាជួយនាងយ៉ាងណាកើត ។

- គ្រាន់តែការមានសន្តានចិត្តល្អចំពោះរូបខ្ញុំនោះ លោកបានបំពេញ នាទីយ៉ាងខ្ពង់ខ្ពស់គួរអោយខ្ញុំកោតគោរពណាស់ទៅហើយ ។ លោក មិនបាច់ជួយអ្វីទៀតទេ ។

នៅខាងក្រោយខ្នង ជ្រូកលីវនិងខេងអង្គុយស្តាប់យ៉ាងស្ងាត់ ស្ងៀម មិនមានស្រដី ។ ខេងលួចជៀងភ្នែកមើលជ្រូកលីវ ឃើញ គេលួចញញឹមតែម្នាក់ឯងយ៉ាងក្រឡួចមាត់ ថ្វីបើនាយធ្វើពើជាហីៗ ក៏ដោយ ។

ថ្ងៃបន្តិច ពួកអង្គការអន្តរជាតិក៏ឡើងរថយន្តត្រឡប់ទៅវិញ ។ ទាំងបីនាក់អង្គុយមើលមុខគ្នា ។

- តើយើងគិតយ៉ាងណាទៅពេលនេះ ? យើងមិនគួរនៅរង់ចាំតែ ទទួលជំនួយមនុស្សធម៌អន្តរជាតិ ដើម្បីរស់យ៉ាងនេះទេ (ជ្រូកលីវ ស្រដី)

- មែនហើយ! យើងមានដៃមានជើងម ានប្រាជ្ញ យើងគួរធ្វើអ្វីឲ្យ មានប្រយោជន៍សំរាប់ជីវិតរបស់យើងវិញ (នាយខេងបន្ទរ)

- តែយើងគ្មានដើមទុន តើយើងរកស៊ីធ្វើអ្វីកើត ក្រៅពីប្រើកម្លាំង រែកពុននោះ ?

ជ្រូកលីវពោលទាំងមុខស្លូត ។

- អ្នកណាថាអត់ ? (កូនមាន់ឆ្លើយកាត់)

បុរសទាំងពីរភ្ញាក់ក្រញាង កាលបើឮកូនមាន់ពោលដូច្នោះ ។

CHANBOKEO.COM

- មិត្តនារីមានដើមទុនពីណាមក កូនមាន់ ? (ជ្រូកលីវសួរ)
យើងជាមនុស្សកណ្តាច់កណ្តោចមកជាមួយគ្នាយូរហើយ ម៉េចក៏មិត្ត
មានដើមទុនកើត ។

កូនមាន់ញញឹមហើយស្រដីថា ៖

- អញ្ចឹង ជ្រូកលីវដាក់ដៃមក ខ្ញុំមានវត្ថុប្រគល់ជាដើមទុនរកស៊ីរស់ ទាំងអស់គ្នា ។

ជ្រូកលីវនិងខេងសម្លឹងមុខគ្នាទំនងមិនសូវជឿ ។ បន្ទាប់មក
ជ្រូកលីវក៏ហុចដៃទៅមុខទំនងចង់ទទួល ។ នារីយើងក៏ក្តាប់វត្ថុមួយ
យកមកដាក់បាតដៃរបស់ជ្រូកលីវ ។ នាយយើងទាញយកមើល ស្រាប់តែលាន់មាត់ឡើង ៖

- ខ្សែកមាស ? ពុទ្ធោ! នាងបានពីណាមកហ្នឹង ? នេះទម្ងន់យ៉ាង ហោចណាស់ក៏បីតម្លឹងដែរ ។
- គឺខ្ញុំលាក់ទុករហូតមកតាំងពីនៅសេរីសោភ័ណម្ល៉េះ ។
- ហើយនាងលាក់យ៉ាងណា កាលបើពួកចោរ.... ?

កូនមាន់ញោចទឹកមុខ កាលបើជ្រូកលីវរំលឹកដល់រឿងនេះ ។ បន្តិចមក
នាងប្រឹងលេបទឹកភ្នែកចូលវិញ ហើយស្រដីថា ៖

- គឺខ្ញុំបានលាក់ទុករបស់នេះនៅក្នុងគំនួចចំណងសក់របស់ខ្ញុំនោះអី ពួកចោរវាមានដឹងឯណា ។

ទាំងជ្រូកលីវ ទាំងខេង នៅស្ងៀមយ៉ាងយូរ មិនហ៊ានស្តីអ្វី ឡើយ
ខ្លាចប៉ះពាល់ដល់អារម្មណ៍នារីយើង អោយនាងខ្មាសអៀន ។

បន្តិចមក ជ្រូកលីវក៏ពោលឡើង ៖

- អរគុណកូនមាន់ណាស់ដែលមានគំនិតលាក់ទុករបស់នេះ កុំអី...

គេនិយាយផង អោនឈ្ងោកមើលរបស់ផង ស្រាប់តែគេភ្ញាក់ ព្រើត
ពេលឃើញអក្សរចិនដែលដាំនៅលើបន្តោង រួចហើយក៏បែរ ទៅកូនមាន់សួរយ៉ាងរហ័សថា ៖

- តើនាងស្គាល់ម្ចាស់បន្តោងនេះទេ ? ហើយហេតុអ្វីបាននាងមាន របស់នេះជាប់នឹងខ្លួន ?
- គឺ... ខ្ញុំមិនស្គាល់ម្ចាស់ទេ! គាត់ត្រូវរបួសធ្ងន់នៅក្នុងព្រៃ ហើយ បានដោះខ្សែកនេះអោយខ្ញុំ
ផ្តាំអោយទៅសាច់ញាតិ តែគាត់មិនទាន់ ប្រាប់ឈ្មោះអ្វីផងក៏ដាច់ដង្ហើមទៅ ។
ខ្ញុំក៏រក្សាទុកជាប់នឹងខ្លួនរហូត
មក ។ មិត្តអានអក្សរចិននេះដាច់មែនទេ ?

ជ្រូកលីវងក់ក្បាល ៖

CHANBOKEO.COM

- មែនហើយ គឺជាឈ្មោះបងប្រុសខ្ញុំ! យើងមានខ្សែកម្នាក់មួយ ដូចគ្នាអញ្ចឹង ខុសតែឈ្មោះទេ ។

ជ្រូកលីវនិយាយទាំងអួលដើមក ។ ខេងក៏យកដៃអង្អែលខ្នង នាយ ហើយលួងលោមថា ៖

- អីលូវ គាត់ចែកស្ថានហើយ ។ ទុកខ្សែកនេះជាកេរ្តិ៍ចុះ មិនបាច់ ចំណាយវាទេ ។ យើងរកមធ្យោបាយផ្សេងទៀតចុះ ។

ជ្រូកលីវយកដៃឈ្លីថ្ងាសយ៉ាងយូរ ទំរាំងើបមុខឡើងនិយាយ សាថ្មី ថា ៖

- ណ្ហើយចុះ! យើងគិតតទៅមុខទៀត! បើអាល័យតែបែរក្រោយ មើលអតីតកាលហើយសោកសង្រេង យើងគ្មានថ្ងៃនឹងឈានទៅមុខ ដើម្បីយល់ពន្លឺរស្មីក្នុងជីវិតទេ ។ អតីតកាលកន្លងទៅហើយ មិន ត្រឡប់មកវិញឡើយ ហើយក៏យើងមិនអាចកែកុនអ្វីបានដែរ ។ មានតែអនាគតប៉ុណ្ណោះដែលយើងអាចក្ដាប់ក្នុងកណ្ដាប់ដៃយើងបាន រួចមានតែបច្ចុប្បន្ននេះឯង ជាទ្វារ ជាហេតុ ជាបច្ច័យនាំយើងឆ្ពោះ ទៅអនាគត ។ បើយើងដើរលើមាគ៌ាប្រពៃក្នុងជីវិត នោះយើងមិន លិចលង់ស្លាប់យ៉ាងអាសារឡើយ ។

ឃើញជ្រូកលីវតាំងស្មារតីយ៉ាងរឹងប៉ឹងដូច្នោះ អ្នកទាំងអស់គ្នាក៏ ញញឹមឡើងផ្ដល់កម្លាំងចិត្តអោយនាយយ៉ាងស្រស់បំព្រង ។

oooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី១១
# អកព្រាត់គ្នា

ជាងមួយអាទិត្យក្រោយមក...

ហ្វូងមនុស្សភៀសខ្លួនថ្មីៗមកពីក្នុងស្រុក បានមកដល់យ៉ាងកក កុញក្នុងជំរំសាជាថ្មី...

រាល់ថ្ងៃ កូនមាន់តែងតែទៅស្កាត់ចាំជួយធ្វើការពួកអង្គការកាក បាទក្រហមជានិច្ច មិនថាជាគេធ្វើដំណើរមកជំរំឬមិនមកទេ ។ រីឯ របួសនាយជ្រូកលីវក៏បានគ្រាន់បើដែរហើយ ។ គេអាចដើរបានមក វិញត្រឹមៗ តែមានទាន់មាំទាំនៅឡើយទេ ។ ចំណែកនាយខេងបាន យកខ្សែកមាសរបស់បងប្រុសជ្រូកលីវ ទៅធ្វើជាដើមទុនទិញដូរ ឥវ៉ាន់ជាមួយអ្នកស្រុកជាតិថៃ ហើយវិលត្រលប់ទៅបោះអោយម៉ូយ ជាតិខ្មែរនៅក្នុងព្រៃ ដើម្បីអោយពួកគេយកទៅជួញដូរនៅស្រុក ខ្មែរ ហើយក៏បានប្រាក់ចំណូលតិចតួចគ្រាន់នឹងទិញបាយអង្ករ ។

ព្រលប់នេះ ខេងដើរមកដល់ផ្ទះវិញ ស្រាប់តែប្រទះនឹងនាយ ដុំដីដែលទើបធ្វើដំណើរមកពីណាមិនដឹង ធ្វើមុខស្លេកៗដូចតក់ស្លុត នឹងហេតុការណ៍អ្វីម្យ៉ាង ។ គ្រាន់តែនាំដុំដីមកដល់ខ្ទមជួបជ្រូកលីវ និងកូនមាន់ភ្លាម នាយយើងក៏ឆ្លាយសំដីវ៉ាយមកថា ៖

- ពូតាលឹងទឹងនឹងនាយម៉ាប់ ស្លាប់បាត់បង់ជីវិតទៅហើយ ។
- ហ៊្វាស ! ថាម៉េច ?

ទាំងបីនាក់លាន់មាត់ព្រមៗគ្នា ។ នាយដុំដីលេបទឹកមាត់ផ្សើម បំពងកបន្តិច រួចក៏បន្តទៀតថា ៖

CHANBOKEO.COM

- គឺពួកយើងចាញ់បោកពួកទាហានថៃ ត្រូវគេដឹកយកទៅចាក់
ចោលនៅភ្នំខៀវដែលជាសំបុកទីតាំងរបស់ខ្មែរក្រហម ។ អ្នកស្រុក ខ្លះក៏ត្រូវគេកៀរចូលព្រៃ ។
ខ្លះក៏រត់ប្រសេចប្រសាចនាំកូនចៅគេច ខ្លួនជាន់មីនផ្ទុះស្លាប់ពេញព្រៃ
ខ្លះក៏ស្លាប់ដោយអត់ទឹកអត់អាហារ ។ ខ្លះក៏ត្រូវខ្មែរក្រហមបាញ់ ថៃបាញ់សម្លាប់ ។
ពូតាលឹងទឹងនិងនាយ ម៉ាប់មានរាសីមិនល្អ ទើប...

មកដល់ត្រង់នេះ នាយយើងក៏អួលដើមក ស្រដីលែងរួច ។

- ណ្ហើយចុះ ដុំដី! ពេលនេះ មិត្តរត់រួចបានមកជួបពួកយើងវិញ
យ៉ាងណាក៏យើងមិនចោលមិត្តដែរ (កូនមាន់ស្រដី)

- មែនហើយ! ថ្វីបើយើងមិនមែនជាសាច់ឈាមនឹងគ្នាមែន តែ
យើងអាចភ្ជាប់ចំណងជាបងប្អូននឹងគ្នា ហើយរស់នៅកក់ក្ដៅ ដូច គេដូចឯងបានតើហ៍!
(នាយខេងបន្ថែម)

ឮដូច្នោះ នាយដុំដីក៏ញញឹមឡើង ហាក់ដូចជារសាយនូវភាព
កង្វល់ស្មុគស្មាញមុននេះអស់រលីងពីក្នុងអារម្មណ៍ ។

រាត្រីនោះ គេបរិភោគបាយជុំគ្នាយ៉ាងឆ្ងាញ់ពិសារ ។

នៅលើកន្ទេលធំមួយ ដែលមានមនុស្សបួននាក់ចែកគ្នាគេង...

- ថ្លង់សម្លេងស្រមុករបស់នាយខេងនិងដុំដីឬកូនមាន់ បានជាប្រែ ទៅ ប្រែមក៍ មិនព្រមគេង ?

ជ្រូកលីវឱ្យបសួរកូនមាន់ ដែលនៅត្រេះត្រុះមិនព្រមដាក់ខ្លួន ចូលនិទ្រា ។

- ថាអញ្ចឹងក៏បាន... តែពេលនេះ ខ្ញុំហាក់ដូចជាមានប្រផ្នូលក្នុងចិត្ត យ៉ាងណាមិនដឹងទេ...
គឺជាអារម្មណ៍ចម្លែកណាស់...

- ចម្លែកយ៉ាងណាទៅ រហូតដល់គេងមិនលក់ដូច្នេះ ?

- គឺចម្លែកមែនណា... គឺ...ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងតែព្រាត់ចេញ ពីអ្នករាល់គ្នាអញ្ចឹង...

- ពុទ្ធោ! ប្រហែលមកពីកូនមាន់តក់ស្លុតនឹងរឿងពូតាលឹងទឹងនិង នាយម៉ាប់ទេដឹង ?

- មិនមែនទេ...ខ្ញុំថា... ជាប្រផ្នូលចម្លែកជាងហ្នឹង...

- កុំគិតអ្វីផ្ដេសផ្ដាសណា៎កូនមាន់... យើងមិនបែកគ្នាទៅណាទេ ។ ខ្ញុំបានតាំងចិត្តហើយ
ថាមិនទៅណាចោលកូនមាន់ឡើយ...ឮហើយ នៅ ? មិនថាស្ថានការណ៍បែបណាទេ
ខ្ញុំនឹងនៅក្បែរកូនមាន់ជានិច្ច
ម៉ោះ! ឆាប់គេងមក៍! កុំគិតអីច្រើនពេក ប្រយត្ន័មិនស្រួលខ្លួនទៅ

CHANBOKEO.COM

ជ្រុវលីវក៏ស្រវាទាញដៃកូនមាន់ក្រញាស អោយផ្អែកខ្លួនលើ ខ្នើយក្បែរនោះ ដើម្បីសំងំគេង ។
- ស្តាយណាស់ដែលខ្ញុំមិនចេះច្រៀង កុំអីខ្ញុំច្រៀងបំពេរកូនមាន់ អោយគេងមិនខាន
(ជ្រូកលីវពោលខ្សិបៗ)
កូនមាន់ព្រួងឮដូច្នោះក៏បែរមុខរកនាយហើយសើចខឹកៗ ៖
- មិនបាច់ច្រៀងក៏បានដែរ ។ គ្រាន់តែពាក្យលើកកម្លាំងចិត្តប៉ុន្មាន ម៉ាត់អំបាញមិញនេះ
ក៏មានរសជាតិទឹកដមមិនខុសពីសម្លេងចំរៀង បំពេរដួងចិត្តឡើយ គឺ... ផ្អែមណាស់ណា៎
មុតដល់បេះដូងឯណោះ
- មែនហ្អែស ?
- មែន!
- ហើយចង់ស្តាប់ថែមទៀតទេ ?
- អ្នកណាថាមិនចង់ ?
- ស្តាប់មួយជីវិតយកទេហ៏ ?
- យក! ហើយជ្រូកលីវសុខចិត្តកំដរខ្ញុំមួយជីវិតមែនហ្អែស ?
- ដោយសេចក្តីពេញចិត្តបំផុត បើកូនមាន់អនុញ្ញាត្ត ។
- អញ្ចឹងសុំគេងគិតមើលបន្តិចសិនណា ។
- បាទ! តែកុំអោយយូរពេកអី
- ម៉េច ? ចាំយូរបន្តិចមិនបានទេ ?
- គឺ ខ្ញុំខ្លាចស្អកស្រូវអស់ ខ្លាច...មិនបាន....
- នែ៎ ឈប់និយាយផ្តាសទៅ! ខ្ញុំងុយគេងហើយ
ថាហើយ នារីក៏ប្រែខ្លួនបែរខ្នងអោយមាណពយើង ។ ជ្រូកលីវ លួចញញឹមក្រប្ូច
មើលតាមនារី ត្បិតដឹងថា នាងកំពុងអៀន មិន
ហ៊ានសន្ទនាតទៅទៀតខ្លាចធ្លាក់ចូលដល់រឿងដែលមាណវីត្រូវលាត
ត្រដាងដួងចិត្តប្រាប់បុរសយើង ។ ពេលនេះ មាណពមានអារម្មណ៍ រំភើបអ្វីម្ល៉េះទេ
រកពាក្យអ្វីមកប្រៀបធៀបក៏មិនសមស្មើឡើយ ។ ថ្វី បើនារីមិនបានស្រដីត្រង់ៗ
ថានាងកំពុងពេញចិត្តបុរសយើង តែ ភាសាសន្ទនា
ហាក់ដូចជាឆ្លើយប្រាប់នរៈនូវជំរៅដួងចិត្តរបស់នាង អស់ហើយអីចឹង ។
គេគេងញញឹមតែម្នាក់ឯងមិនអស់មិនហើយ ។

CHANBOKEO.COM

ជិតភ្លឺហើយ...

- កំពុងធ្វើអីហ្នឹង កូនមាន់ ?
- គឺបង្កាត់ភ្លើងដាំបបរអោយអ្នករាល់គ្នាបរិភោគហ្នឹងណាជ្រូកលីវ !
- អញ្ចឹងម៉េចក៏ប្រញាប់ក្រោកម្ល៉េះ មេឃមិនទាន់ភ្លឺនៅឡើយទេ
- គេងមិនលក់ មិនដឹងធ្វើអ្វី ក៏ក្រោកដាំបបរចំណីទៅ

ជ្រូកលីវក្រោកឡើងដើរចេញពីខ្ទមមកជួយកូនមាន់ ទុកអោយខេងនិងនាយម៉ាប់ដេកស្រមុកប្រណាំងគ្នាលើកន្ទេលតែពីរនាក់ ។

- ហេតុអ្វីក៏សម្លឹងមុខខ្ញុំម្ល៉េះជ្រូកលីវ ? មានអ្វីខុសធម្មតាហ្មែស ?
- អឺ... អត់ទេ... តែខ្ញុំគ្រាន់តែចម្លែកចិត្ត...
- ចម្លែកចិត្ត ?... ចម្លែករឿងអ្វី ?
- គឺ... គឺ.... ហ៊ឺ! ខ្ញុំមិនដឹងនិយាយយ៉ាងណាទេហ្ន៎!
- បើពិបាកនិយាយមិនបាច់និយាយទេ ។ នែះ! ជួយហាន់ឆៃពៅហើយច្របាច់លាយខ្ទឹមសនិងក្រូចឆ្មារ ទុកគ្រាន់ញាំបបរ កុំឲ្យខ្លួន ទំនេរឥតប្រយោជន៍ ។

ជ្រូកលីវទាញកាំបិតហាន់ឆៃពៅបណ្តើរ លួចមើលទឹកមុខកូន មាន់បណ្តើរ ឃើញនាងហាក់ដូចជាមានកិរិយាត្រេះត្រុះ ៖

- កូនមាន់! គឺ... ខ្ញុំពិភាល់ក្នុងចិត្តមែនណា
- រឿងអ្វីទៅ ជ្រូកលីវ ? (កូនមាន់សួរ)
- ហេតុអ្វីមិត្តនារីដូចមានកិរិយាចម្លែកម្ល៉េះ ថ្ងៃនេះ ?
- ចម្លែក ? គ្មានអ្វីចម្លែកទេ គ្រាន់តែយល់សប្តិមិនល្អ ម៉្លោះហើយខ្ញុំមានាការរំខានក្នុងអារម្មណ៍បន្តិចបន្តួច
- នាងនៅតែគិតថាជាប្រផ្នូលអាក្រក់ដដែល មែនទេ ?
- មែនហើយ (កូនមាន់ងក់ក្បាល) វាធ្វើអោយខ្ញុំគិតមិនអស់មិន ហើយទេ ពេញម៉ាយប់ហើយ
- ពីរឿងដែលថា ខ្លាចពួកយើងត្រូវបែកព្រាត់ពីគ្នាហ្នឹងហ្មែស ?
- ចា៎ស! ស្ថានភាពស្រុកទេសមើលមិនឃើញ... តើយើងនៅជួប ជុំគ្នាយ៉ាងនេះ បានយូរប៉ុនណាក៏មិនដឹង ?

- ពិតមែនហើយដែលយើងមើលមិនឃើញអនាគត ថានឹងក្លាយជា យ៉ាងណា តែយើងមិនគួរណាចាយពេលគិតពីអនាគតច្រើនពេក រហូតដល់ភ្លេចទទួលភាពកក់ក្ដៅនៅក្នុងបច្ចុប្បន្ននេះឡើយ...

កូនមាន់ឮដូច្នេះក៏បែរមុខសម្លឹងជ្រូកលីវ ទំនងយល់ដំរៅចិត្ត របស់មាណព ។ បុរសក៏បន្តទៀតថា ៖

- កាលបើយើងកំពុងនៅជួបជុំគ្នា ម៉េចក៏មិនឆ្លៀតទទួលនូវភាព កក់ក្ដៅក្នុងចិត្ត ហើយប្រគល់ចិត្តស្រលាញ់ចំពោះគ្នាទៅវិញទៅមក នោះទៅ ចាំបាច់អី ទៅគិតអនាគតអោយរំខានវេលាល្អៗបែបនេះ ធ្វើអ្វី ?...

កូនមាន់ឈ្ងោកមុខមួយស្របក់ ក៏ឆ្លើយថា ៖

- ព្រោះមនុស្សយើងមានចិត្តលោភលន់នោះអី! កាលបើបាន ទទួលនូវភាពកក់ក្ដៅនោះហើយ តែងតែចង់បានទៀត រហូតតទៅ មិនចង់អោយស្រកស្រុត មិនចង់អោយឃ្លាតចាកភាពកក់ក្ដៅនោះ ទៅវិញ ម្ល៉ោះហើយក៏កើតមានការបារម្ភ មានការភ័យខ្លាច មានការ គិត ព្រួយខ្វល់ខ្វាយផ្សេងៗ ខ្លាចអ្វីៗប្រែមិនដូចចិត្តប្រាថ្នា...

- មានន័យថា កូនមាន់ទទួលស្គាល់នូវភាពកក់ក្ដៅនៅក្នុងដំរៅចិត្ត របស់នាង នៅពេលនេះដែរ មែនទេ ?

កូនមាន់នៅស្ងៀមមិនហ៊ានស្រដីតបឡើយ ។ ជ្រូកលីវសម្លឹង មុខនាងមួយស្របក់ ក៏ពោលបន្តថា ៖

- ពិតមែនតែយើងទាំងពីរបានឆ្លងកាត់ស្ថានភាពសាហាវយង់ឃ្នង ជាច្រើនកន្លងមក... តែក៏យើងមិនបាក់កម្លាំងចិត្ត មិនរត់ចោលគ្នា មិនមើលបំណាំ នោះគឺមកពីភាពកក់ក្ដៅក្នុងចិត្ត ដែលយើងបាន ទទួលពីគ្នាទៅវិញទៅមក ដោយការមានសមានចិត្ត ជួយឈឺឆ្អាល និងរក្សាសុវត្ថិភាពចំពោះគ្នា...

កូនមាន់ងក់ក្បាល ៖

- ជ្រូកលីវនិយាយត្រូវហើយ ហើយខ្ញុំចង់ទទួលភាពកក់ក្ដៅបែប នេះរហូតតទៅផង ។

- ជ្រូកលីវមិនទៅណាចោលកូនមាន់ទេ ដឹងហើយនៅ ? មិនថា ស្ថានការណ៍ស្រុកទេសផ្លាស់ប្ដូរបែបណាទៀតទេ ខ្ញុំនឹងនៅជាគ្នា ក្បែរនាងជានិច្ច...

- ជាពាក្យសន្យាមែនទេ ?

- មិនមែនទេ! ជាទឹកចិត្តស្រលាញ់ស្មោះស្មគ្រ័ចំពោះគ្នាជាជាង

កូនមាន់ងើបមុខឡើងសម្លឹងក្រសែភ្នែករបស់ជ្រូកលីវ ក្រោម ពន្លឺក្រហមពីភ្នក់ភ្លើងដណ្ដាំបបរ ឃើញគេសម្លឹងមករកនាងដោយ ក្រសែភ្នែកយ៉ាងស្រទន់ ហាក់ដូចជាចង់បង្ហាញនូវសេចក្ដីអាណិត អាសូរចំពោះនាង និងអ្វីៗកន្លងមក ដែលអ្នកទាំងពីរបានឆ្លងកាត់ រួមគ្នា ។

- ហើយស្មោះប៉ុនណាដែរទៅ ? (កូនមាន់សួរបន្ត)
- មួយជីវិត យកទេហ៎ ? (ជ្រូកលីវឆ្លើយ)
- គិតច្បាស់ហើយ ?
- ច្បាស់ប្រាកដណាស់ !
- កុំអោយមានពាក្យថា ស្ដាយក្រោយណ៎ា !
- គ្មានទេ ! ខ្ញុំដឹងថា ខ្ញុំសម្រេចចិត្តមិនខុសឡើយ ។
- ជឿជាក់ដល់ម្លឹង ?
- មែន ! ហើយខ្ញុំក៏សុខចិត្តប្ដូរជាជីវិតដែលនៅសល់ ដើម្បីយើង ទាំងពីរនាក់ ។

កូនមាន់ឈ្ងោកមុខ និយាយខ្សិបៗតបវិញ ៖

- ជ្រូកលីវ មិនគិតថា ឆាប់រហ័សពេកទេ ?
- មិនទេ ព្រោះពេលវេលាដែលយើងឆ្លងកាត់ជាមួយគ្នា វាអត្ថន័យ ធំធេងសំរាប់យើងណាស់ ប៉ុន្តែ ចុះចំពោះកូនមាន់វិញ... នាងគិត ដូចខ្ញុំដែរទេ ?

កូនមាន់មិនទាន់ឆ្លើយផង ស្រាប់តែ...

ក្ទុង ! ក្ទាំង ! ផាំង ! ផាំង !

សូរគ្រាប់ផ្លោងធ្លាក់ផ្ទុះផ្ទួនៗគ្រប់ទីកន្លែងក្នុងជំរំ ឆេះខ្ទមស្បូវ ទាំងឡាយនៅក្នុងជំរំអនាធិបតេយ្យមួយនោះ យ៉ាងសន្ធោសន្ធៅ ឡើង ។ ភាពចលាចលយ៉ាងតក្កមាលក៏ផ្ទុះឡើងដែរ ។ មនុស្សម្នា រត់គេចគ្រាប់ប្រសេចប្រសាច ពេញទឹកពេញដី ។ ឯគ្រាប់ផ្លោងក៏ ហោះជាបន្តៗ មិនដឹងជាមកពីទិសខាងណាទេ ស្រាប់តែមកធ្លាក់ ផ្ទុះពាសពេញជំរំតែម្ដង ។ ឯស្នូរកាំភ្លើងដៃ ក៏លាន់ឡើងរំភូសផស យ៉ាងរន្ថើនបន្ថែមទៀត គួរអោយព្រឺខ្លាចបំផុត ។

ជ្រូកលីវស្ទុះក្រោកឡើងយ៉ាងប្រញាប់ កញ្ឆក់ដៃកូនមាន់រត់ សំដៅទីទាប ដើម្បីគេចខ្លួនពីសំណាចគ្រាប់កាំភ្លើង ដែលកំពុង ហោះប្រសាចដូចគ្រាប់ភ្លៀង ។ ដោយក្ដីភិតភ័យតក់ស្លុតខ្លាំងពេក នារីយើងក៏រត់ដួលៗ ជាច្រើនដង ។

CHANBOKEO.COM

- ទៅរួចទេ កូនមាន់ ? អោយខ្ញុំអៀវកនាងទេ ?

ជ្រូកលីវសួរ ។

- មិនអីទេ! មិត្តមិនទាន់ជារបួសជើងស្រួលបួលផង អៀវខ្ញុំម្តេច រួចទៅ ?
- តែក៏គ្រាន់ជាងបណ្តោយអោយនាងរត់ដួល អញ្ចឹងដែរ ។

ស្រាប់តែមានសំដីមួយឆ្លើយពីក្រោយខ្នងអ្នកទាំងពីរ

- បើជ្រូកលីវអៀវមិនរួច ចាំខ្ញុំជួយក៏បាន ។

ជ្រូកលីវឮហើយបែរក្រោយ ឃើញខេងនិងនាយឌុំឌីរត់តាមពី ក្រោយមកដែរ ។ កាលបើឮសំដីរបស់ខេងកាលណា ធីតានឹកខ្មាស ក្នុងចិត្ត ក៏ខំខាំមាត់រត់បន្តទៅទៀត ។

ក្តាំង! ផាំង! អូ៎យ!

នាយឌុំឌីដួលត្មោល ប៉ុន្តែអ្នកទាំងបីមិនអាចជួយអ្វីបានទេពេល នោះ ត្បិតគ្រាប់រត់ប្រសាចច្រើនពេក ។ គេក៏ប្រឹងតែពីឆ្មេចរត់យក ព្រះអាយ៉ុសតែប៉ុណ្ណោះ ។ រំពេចនោះ ស្រាប់តែ...

- អូ៎យ!

កូនមាន់ស្រែកឡើង ហើយក៏ដួលប្រូសទៅដី បាត់មាត់ឈឹង!

- កូនមាន់! កូនមាន់! កូនមាន់!

ជ្រូកលីវរន្ធត់ក្នុងចិត្តណាស់ ក៏ស្ទុះត្រកងបីកាយនារីឡើង រួច ហើយខាំមាត់ប្រឹងរត់កាត់សំណាចគ្រាប់កាំភ្លើង ។ ភ្លាមនោះ បុរស យើងក៏អារម្មណ៍ថា មានអ្វីមួយមករត់កាត់ខ្នងខាងស្តាំ រួចសរសៀរ ប្រឆាកចេញមកខាងពោះ ។ តែនាយមិនខ្វល់ទេ គិតតែពីបីកូន មាន់រត់ត្របាញ់រកទីជ្រកពួនតែម្យ៉ាងប៉ុណ្ណោះ ។ គួរឲ្យស្តាយ គេរត់ មិនបានឆ្ងាយប៉ុន្មានផងក៏ហេវហត់ងងឹតមុខឈឹង រួចស្លុតជង្គង់ដួល ទៅដីប្រូស ធ្លាក់កូនមាន់ពីដៃ បាត់ស្មារតីលែងដឹងខ្លួនទៅ ។

..............................

មិនដឹងជាអស់ពេលយូរប៉ុនណាទេ....

ជ្រូកលីវភ្ញាក់ស្មារតីឡើង ក្រោកមើលនាយអាយជុំវិញខ្លួន ក៏ចាប់ភ្លឹកថា ខ្លួននាយត្រូវរបួសនៅពោះខាងស្តាំ តែមិនឃើញកូន មាន់ឬនាយខេងទេ ។ គេក៏ចាំបានដែរថា នាយឌុំឌីត្រូវបំណែក គ្រាប់ផ្លោងក្រេបយកជីវិតបាត់ទៅហើយ ។ ហើយកូនមាន់ក៏ត្រូវ របួស... ប៉ុន្តែ ចុះពេលនេះ នាងនៅឯណា ?

CHANBOKEO.COM

ជ្រូវលីវរន្ធត់ក្នុងចិត្តពេកក្រៃ បែរមើលជុំវិញខ្លួនឡើងសព្វទិស ហើយ
នៅតែមិនឃើញសាកសពមួយណាដែលមានរាងរៅដូចជា កូនមាន់សោះ ៖

- ឬក៏នាយខេងជួយយកអាសាជីវិតរបស់នាង ?

គិតដល់ត្រង់នេះ បុរសយើងហាក់ដូចជាមានសង្ឃឹមបន្តិចមក វិញ ។ គេក៏ក្រោកឡើងយកដៃអោបរបួសនៅលើពោះ ខំប្រឹងដើរ តតេះតតះ កាត់គំនរសាកសពអ្នកស្រុកទាំងឡាយ សំដៅទៅរក ថ្នល់ធំ ដែលរថយន្តមនុស្សធម៌អន្តរជាតិតែងបរចូលមក ចែក ជំនួយដល់អ្នកស្រុក ។

រំពេចនោះ ស្រាប់តែគេឃើញនាយខេងធ្វើដំណើរមកដល់ទាំង ហត់គយូរ ទំនងអស់កម្លាំងដោយការមានរបួស ។

- ខេង ! មកពីណាហ្នឹង ? ឯណាកូនមាន់ ?
- ជ្រូកលីវ....

ខេងដកដង្ហើមទាំងដង្ហក់មួយស្របក់ទើបលើកដៃចង្អុលទៅផ្លូវ ធំ ហើយស្រដីទាំងសំដីផិតផើយ បន្ថែមទៀត ថា ៖

- គឺ ខ្ញុំបាន... បីកូនមាន់... យកទៅដាក់រថយន្ត... កាកបាទក្រហម ហើយ...ទើប...ខ្ញុំត្រលប់មក...យកឯង...ដើម្បីចេញ...ទៅដែរ...
- អរគុណខេង... ដែលត្រលប់មករកខ្ញុំវិញ ។ ឯងជាមិត្តដ៏ល្អរបស់ ខ្ញុំយ៉ាងពិតប្រាកដមែន...
- តោះ... យើង ប្រញាប់ទៅ...!

អ្នកទាំងពីរក៏តោងស្មាគ្នាទៅវិញទៅមក ខំប្រឹងដើរតតេះតតះ ទៅរកកូនមាន់ ។ មិនយូរប៉ុន្មានគេក៏បានមកដល់កន្លែងដែលខេង ប្រាប់ ។ ចៃដន្យ អ្នកទាំងពីរមិនបានជួបរថយន្តសង្គ្រោះនោះទេ ។ អ្នកស្រុកដែលមានរបួស អង្គុយចាំទីនោះប្រាប់ថា រថយន្តផ្ទុកជន រងគ្រោះពេញអស់ទៅហើយមុននឹងចេញដំណើរទៅ តែគេប្រាប់ថា រថយន្តទាំងនោះនឹងវិលមកវិញជើងក្រោយទៀត ដើម្បីមកទទួល អ្នករបួសដែលនៅសល់ទាំងប៉ុន្មាននោះ ។ ឮដូច្នោះ ជ្រូកលីវទន់ ជើងទន់ដៃរសេះរសោះ អស់កម្លាំងចិត្តពីខ្លួនរលីង គ្មានសល់បន្តិច ណាឡើយ ។ ទឹកភ្នែកពីរតំណក់ក៏អណ្តែតចេញមក ប្រលែងកែវ ភ្នែកទាំងគូរបស់បុរសយើង ៖

- កូនមាន់អើយ ! ហេតុអ្វីបានជាយើងត្រូវព្រាត់គ្នាដូច្នេះផង ? កូនមាន់ សូមនាងបានចាកផុតពីគ្រោះថ្នាក់ផងណា !

CHANBOKEO.COM

មិនថាតែជ្រូកលីវទេដែលសង្វេគចិត្ត សូម្បីតែនាយខេងក៏ខក ចិត្តមិនតិចដែរ ដែលត្រឡប់មកវិញមិនទាន់ដំណើររថយន្ត ។ ទាំងពីរនាក់ដាក់ខ្លួនអង្គុយចុះធ្វើមុខស្រងូតស្រងាត់ ។

- ណ្ហើយចុះ លីវអើយ! បើមាននិស្ស័យនឹងគ្នាពិតមែន យើងគង់ តែនឹងជួបនាងវិញមិនខាន ។ កុំអស់សង្ឃឹមអី!

ខេងស្រដីកម្លាចិត្តខ្លួនឯងផង កម្លាចិត្តមិត្តរបស់ខ្លួនផង ។

សំណាងមិនល្អ... អ្នកទាំងពីរអង្គុយចាំមើលផ្លូវរថយន្តសង្គ្រោះ រហូតថ្ងៃលិចទៅហើយ រថយន្តក៏មិនដែលត្រឡប់មកវិញដូចដែល គេបានសន្យាប្រាប់អ្នកស្រុកនោះឡើយ ។

oooooooooooooooooo

oooooo

o

CHANBOKEO . COM

# វគ្គទី១១
# វង្វេង

- លីវ ! មិត្តមិនស្តាយវាទេ ?
- ខ្ញុំមិនស្តាយទេ ខេង ។ យើងបានកាត់ខ្សែវាធ្វើដើមទុនរកស៊ីរួច ហើយ ។ នៅសល់តែបន្តោងនេះ ខ្ញុំក៏មិនដឹងទុកធ្វើអ្វីដែរ ។ មិត្ត យកវាទៅលក់អោយអ្នកស្រុកថៃ ហើយទិញថ្នាំគេមកព្យាបាលខ្លួន យើងវិញប្រសើរជាង ជីវិតយើងសំខាន់ជាងមាសមួយដុំនេះណា៎ ដឹងទេ ?
- តែវាជាកេរ្តិ៍មរតករបស់បងប្រុសលីវឯង ដឹងហើយនៅ ?
- បើសិនជា... ខ្ញុំត្រូវអស់ជីវិតនៅពេលនេះ កេរ្តិ៍មរតកមួយនេះក៏ នឹងក្លាយជាវត្ថុឥតន័យសម្រាប់រូបខ្ញុំដែរ ដូច្នេះ តើខ្ញុំគួរទុកវាអោយ នៅស្ងៀមធ្វើអ្វី ? យកកេរ្តិ៍មរតកដូរជាថ្នាំ ដើម្បីរក្សាជីវិតរបស់ខ្លួន វិញនោះ មិនប្រសើរវិសេសវិសាលជាងទេហ្អី សម្លាញ់ ? ហើយ ខ្ញុំក៏នៅចងចាំបងប្រុសខ្ញុំមួយជីវិត មិនសាបសូន្យដដែល...

ខេងញញឹមឡើងកាលបើបានឮសំដីរបស់ជ្រូកលីវដូច្នេះ ៖

- ឯងពិតជាមានគំនិតខ្ពង់ខ្ពស់ណាស់ ដែលមិនស្រឡាញ់ទ្រព្យជា ជាងជីវិតនិងសុវត្ថិភាពរបស់ខ្លួនឯង ។

ជ្រូកលីវញញឹមតបវិញ ឆ្លើយថា ៖

- ហើយក៏មិនស្រឡាញ់ទ្រព្យ ជាជាងសុវត្ថិភាពរបស់មិត្តសម្លាញ់ ដែរ ឮទេ ?

ពេលនេះ ខេងសើចពព្រាយតែម្តង ។ ជ្រូកលីវតឿន ៖

CHANBOKEO.COM

- តោះយើង! ប្រញាប់ទៅលក់មាសសិន... យកលុយទិញថ្នាំ អោយខេងឯងលាបរបួស ។

- លីវឯងក៏ដូចគ្នាដែរ មើលទៅរបួសលើពោះហ្នឹ ហាក់ដូចជាធ្ងន់ ធ្ងរណាស់ ។

- គ្រាន់តែសើស្បែកទេ ខ្ញុំមិនអីទេណា៎ ។

ជ្រូកលីវនិយាយកម្លាចិត្តខ្លួនឯង ។

- អញ្ចឹង លីវនៅចាំខ្ញុំទីនេះហើយ ចាំខ្ញុំយកមាសទៅលក់ ដើម្បី ទិញថ្នាំ ។ បន្តិចទៀត ខ្ញុំមកវិញ!

ចាហើយ ខេងក៏ប្រញាប់ចេញដំណើរទៅ ។ មែនហើយ គេពុំ មានរបួសអ្វីធ្ងន់ធ្ងរ គ្រាន់តែសើៗស្បែកប៉ុណ្ណោះ តែជ្រូកលីវដូចជា វាសីដាក់បន្តិច ឃើញតែជួបគ្រោះមិនអស់មិនហើយ ថ្វីបើមិនដល់ ថ្នាក់អស់ជីវិតក៏ដោយ ក៏ទុរន់ទុរាយ៉ាប់យ៉ឺន រកពាក្យថ្លែងអោយស្មើ មិនបានឡើយ ។

ដោយអស់កម្លាំងល្ហិតល្ហៃពេក ជ្រូកលីវក៏ផ្អែកខ្លួននឹងគល់ឈើ ធ្មេចភ្នែកយកកម្លាំង...

មិនដឹងអស់ពេលយូរប៉ុនណាទេ ពេលបុរសយើងភ្ញាក់ឡើង ក៏ ឃើញខេងក៏ត្រឡប់មកវិញបានថ្នាំបីបួនបន្ទះនិងអង្ករមកខ្លះផង ។

គេក៏នាំគ្នាដណ្តាំបាយបរិភោគស្ងៀមស្ងាត់ ស្រាប់តែឮសម្លេង ក្មេងយំនៅមិនឆ្ងាយពីកន្លែងដែលអ្នកទាំងពីរកំពុងអង្គុយប៉ុន្មាន ។ ជ្រូកលីវក្រឡេកភ្នែកទៅឃើញក្មេងតូចម្នាក់កំពុងយកដៃចង្អុលមក អ្នកទាំងពីរ ទំនងឃ្លានបាយ តែត្រូវស្រីក្មេងម្នាក់ដែលអង្គុយក្បែរ ឃាត់មិនអោយសុំ ។ ឃើញដូច្នេះ ជ្រូកលីវក៏រំលែកបាយមួយដុំ ហុចអោយទៅមាណវីមួយរូបនោះ ៖

- នេះបាយ! មិត្តនារីយកអោយប្អូនញ៉ាំទៅ កុំអោយគេយំ ។

- ចាស! អរគុណណាស់មិនអីទេ ប្អូនខ្ញុំវាខូចតែអញ្ចឹងឯង ញ៉ាំរួច ហើយក៏ទាររកទៀតដែរ ។ មិត្តបងទុកពិសាចុះ ។

អីយ៉ា! នាងមានសំដីសំដៅពិរោះពិសាផង ។ ជ្រូកក៏ញញឹម ហើយឆ្លើយថា ៖

- ខ្ញុំមានបាយល្មមអាចចែករំលែកបាន កុំខ្លាចចិត្តអី! យកទៅណា៎ អោយក្មេងញ៉ាំកុំអោយវាយំ ព្រោះគេនៅក្មេង ពេលឃ្លានមិនចេះ ទ្រាំអត់ដូចមនុស្សចាស់បានទេ ។

ឮសំដីទន់ភ្លន់របស់ជ្រូកលីវ មាណវីក៏លូកដៃទទួលយកបាយពី បុរសយើង ៖

- អរគុណ មិត្តបង!

CHANBOKEO . COM

រំពេចនោះ ស្រាប់តែមានបុរសស្ត្រីផ្សេងៗ ដែលមានរបួសអត់ បាយក្រហាយទឹក អង្គុយក្បែរម្តុំៗនោះ ក៏ងើបឡើង មកក្បែរជ្រូក លីវលើកដៃសំពះ ៖

- កូនខ្ញុំក៏អត់បាយដែរ អោយខ្ញុំសុំម៉ាំពំនូតបានទេហ៎ ?

ជ្រូកលីវនិងខេង មើលមុខគ្នាធ្វើឡឹងឡង់... ទីបំផុត គេមិន បានបរិភោគឆ្អែតមាត់ខ្លួនទេ ព្រោះអាល័យតែអាណិតជនរងគ្រោះ ដូចគ្នា ជាពិសេសគឺក្មេងតូចៗតែម្តង ។ បាយពេញមួយឆ្នាំងដែល
នោះ គេក៏បារចែកអ្នកស្រុកអស់ ។ រីឯខ្លួនគេវិញ បានទទួលត្រឹម ពីរបីម៉ាត់ប៉ុណ្ណោះ ។

........................................

មេឃភ្លឺ ថ្ងៃរះម្តងទៀតហើយ...

- មិត្តបងត្រូវការអោយខ្ញុំជួយបោកខោអាវអោយទេ ?

ជ្រូកលីវបែរមើលម្ចាស់សំនួរ ឃើញនារីដែលគេហុចបាយពំនូត ពីម្សិលនោះកំពុងដើរតម្រង់មក ។ បុរសយើងមិនទាន់ស្រដីអ្វីផង នាងក៏ពោលបន្តថា ៖

- ម្សិលមិញមិត្តបងអោយពំនូតបាយពួកយើងបរិភោគ ចៃដន្យខ្ញុំ នៅមានដៃជើងជាអាចធ្វើការបាន ខ្ញុំគិតថាសុំជួយមិត្តបងវិញ ចាត់ ជាការជួយដោះស្រាយធុរៈគ្នាទៅវិញទៅមក ។

ជ្រូកលីវនឹកចម្លែកក្នុងចិត្ត គិតតែម្នាក់ឯងថា ៖

- យី! នៅក្មេងសោះ តែមានទឹកចិត្តថ្លៃថ្លាគួរអោយកោតសរសើរ ក្រៃលែងតែម្តង ។

តែមិត្តយើងក៏មិនប្រកែកអ្វីដែរ ព្រោះខោអាវរបស់នាយកំពុង មានក្លិនឆ្អេះឆ្អាបដោយឈាមរបួស ។ គេក៏ដោះអាវហុចអោយទៅ នារី ។

- ហើយចុះមិត្តបងម្នាក់ទៀតទៅណាហើយ ? (នារីសួរ)

- គេចេញទៅក្រៅរកស៊ីលៀងជីវិតហើយ ល្ងាចទើបមកវិញ ។ អូហ៍ ហើយចុះមិត្តនារីឈ្មោះអ្វីដែរ ?

នាងញញឹមឡើង ហើយឆ្លើយថា ៖

- ចាស! ឈ្មោះធា!

- ចុះឪពុកម្តាយមិត្តនារីវិញ ?

- បែកគ្នាប៉ុន្មានឆ្នាំហើយ តាំងពីគេចាប់ខ្ញុំបញ្ជូនអោយធ្វើការជាកង ចល័តនារីនៅសម័យខ្មែរក្រហមមក ។

CHANBOKEO.COM

- អូហ៍! ហើយចុះប្អូនតូចនោះ... ?

នាងធាញញឹមហើយឆ្លើយថា ៖

- ខ្ញុំមិនស្គាល់គេទេ ទើបតែរើសបានពីម្សិល ព្រោះគ្នារត់វង្វេងម៉ែ តែម្នាក់ឯង ហើយខ្ញុំក៏ជួយយកអាសារទៅ ។

ថាហើយនាងក៏កាន់ខោអាវរបស់ជ្រូកលីវយកទៅបោកបាត់ទៅ ទុកអោយនៅសំកុកធ្វើភ្នែកភ្លិះៗតែម្នាក់ឯង ។ ក្នុងអារម្មណ៍របស់ នាយ មានតែស្រមោលកូនមាន់ទេ ដែលចេញមករំខានមិនអស់មិន ហើយ ៖

- កូនមាន់អើយ! សូមអោយយើងបានជួបគ្នាឆាប់ៗវិញផងណ៎! ខ្ញុំនឹកហើយបារម្ភពីនាងណាស់ ។ តើខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីឲ្យ ដឹងថានាងនៅឯណា ? នោះខ្ញុំនឹងទៅរកនាងភ្លាម...

ជ្រូកលីវគិតក្នុងចិត្តតែម្នាក់ឯង...

មិនយូរប៉ុន្មាន ស្រាប់តែនាងធារត់ត្រលប់មកវិញយកខោអាវ សើមមកហុចអោយនាយ ថៃមទាំងពោលថា ៖

- មិត្តបង! យើងគ្មានពេលហាលខោអាវអោយស្ងួតទេ ។ ពេល នេះ រថយន្តកាកបាទក្រហម បានមកដល់ជំរំយើងទៀតហើយ ។ មិត្តបងប្រញាប់ធ្វើដំណើរអោយលឿនទៅ ក្រែងទាន់ជើងរថយន្ត សង្គ្រោះជីវិត ។ ខ្ញុំសូមលាទៅមុនសិនហើយណ៎ មិត្តបង!

ថាហើយ នាងក៏អូសដៃក្មេងប្រុសតូចម្នាក់នោះរត់យ៉ាងលឿន សំដៅទីចំណតរថយន្ត ។

ជ្រូកលីវងើបឡើង គិតថានឹងរត់ទៅ តាមពីក្រោយនារី តែក៏ទុចដំក់ទៅវិញ ត្បិតមិនដាច់ចិត្តទៅចោល នាយខេង ដែលនៅកន្លែងណាមិនដឹងក្នុងខណៈនេះ ។ គិតចុះគិត ឡើងមួយស្របក់ គេក៏ដាច់ចិត្តដើរទៅតាមនាងធា ម្យ៉ាងដោយសារ នឹកគិតចង់ទៅស្វែងរកកូនមាន់ផង ។

លុះដើរតតេះតតះមកដល់កន្លែងរថយន្តអង្គការអន្តរជាតិចតចាំ ជ្រូកលីវប្តូរចិត្តគិតជាថ្មីមួយសាទៀតហើយ ៖

- តើអោយខ្ញុំគិតយ៉ាងម៉េច ? បើឡើងឡានតាមគេទៅ តើយើង សង្ឃឹមថានឹងបានជួបកូនមាន់ទេ នៅឯទីតាំងថ្មី ? ចុះបើមិនជួប នាងវិញ ? នាយខេងក៏បាន កូនមានក៏ខក តើអោយយើងគិត ធ្វើម្តេចទៀតទៅ ?... ណ្ហើយចុះ! មកពីយើងមិនដឹងជាក់ ថាកូន មាន់នៅទីណាពិតប្រាកដ យើងមិនទៅទេ... សុខចិត្តនៅទីនេះ ចាំ នាយខេងចុះ ។

CHANBOKEO.COM

ទីបំផុត គេក៏ដាច់ចិត្តដើរទៅរកនាងធា រួចស្រដីថា ៖
- ឲ្យខ្ញុំសុំពឹងមិត្តនារីរឿងមួយបានទេ ?
- ចាស ! មិត្តបង !

ភ្លាមនោះ ជ្រុកលីវក៏ឱនខ្សិបដាក់ត្រចៀករបស់នាងធា រួច ហើយនាងក៏ងក់ក្បាល បន្ទាប់មក នាងក៏ដឹកដៃប្អូនប្រុសតូចនោះ ឡើងរថយន្តចេញទៅ ។

ជ្រុកលីវក៏ពោលខ្សិបៗពីក្រោយខ្នង ៖
- អរគុណណាស់ មិត្តនារី !

មិនយូរប៉ុន្មានរថយន្តក៏ចេញដំណើរទៅ ទុកបន្សល់នូវអ្នកស្រុក ជាច្រើនទៀត ដែលរង់ចាំជំនួយជាបន្តៗ ទំរាំឡែរថយន្តត្រឡប់ មកវិញសាជាថ្មី ។ ជ្រុកលីវសម្លឹងមើលតាមរថយន្តរហូតផុតកន្ទុយ ភ្នែក ទើបបែរវិលមកក្រោយ តាមរកមើលដាននាយខេង ។

ពេលវេលាកន្លងទៅយ៉ាងយឺតបំផុត សំរាប់ជ្រុកលីវដែលនៅ អង្គុយរង់ចាំមិត្តអោយត្រលប់មកវិញ... មួយយប់ហើយ មួយយប់ ទៀត.. ពីរបីយប់កន្លងទៅ នាយខេងក៏បាត់ស្រមោលឈឹងសូន្យ គ្មានដំណឹងអ្វីបន្តិច ធ្វើអោយបុរសយើងរិតតែហ្មងសៅក្នុងចិត្តថែម ទៀត ។ ឯរថយន្តសង្គ្រោះមនុស្សក៏មិនឃើញវិលវិញមកទៀតដូច គ្នា ។ ពេលនេះ ត្រីរស់ក៏រួចទន្សាយក៏រួចដដែល ។

ជ្រុកលីវអង្គុយកើយគល់ឈើ គិតសាំញ៉ាំតែម្នាក់ឯង មិនបាន ចាប់អារម្មណ៍ទេថា ក្នុងជំរំមនុស្សជ្រួលច្របល់ប៉ុនណា អត់បាយប៉ុន ណា ក្តៅក្រហាយវង្វេងបាត់ប្តីកូនប្រពន្ធយ៉ាងណាទេ... គេអង្គុយ គិតតែម្យ៉ាងគត់ គឺ... តើគេត្រូវរកមធ្យោបាយអ្វីនឹងទៅរកកូនមាន់ អោយឃើញ ? បេះដូងរបស់គេរណ្តំដោយក្តីទុក្ខព្រួយសែនធ្ងន់ពន់ ប្រមាណ...
- កូនមាន់អើយ... មួយខែដែលយើងបានជួបគ្នា បានឆ្លងកាត់ជីវិត ស្លាប់រស់ជាមួយគ្នា... ជាអនុស្សាវរីយ៍ដែលផ្តិតជាប់បេះដូងរបស់ខ្ញុំ គ្មានថ្ងៃនឹងរលប់ទេ... ពេលនេះ ខ្ញុំនឹកនាងណាស់... នឹកណាស់ នឹករកពាក្យអ្វីមកថ្លែងមិនបានទេ... ខ្ញុំពិតជាចង់ទៅរកនាង... ខ្ញុំ នឹងទៅរកនាង... រកអោយឃើញ... តើពេលនេះនាងនៅឯណា ? ហើយមានដឹងទេថាខ្ញុំកំពុងតែនឹករូបនាង ?

CHANBOKEO.COM

*នឹក! នឹកក្រៃលែង! ខ្ញុំសច្ចាថា ពេលបានជួបនាងជាថ្មី ខ្ញុំមិននាងបែកឃ្លាតពីខ្ញុំទៀត ឡើយ... ខ្ញុំនឹងនៅថែរក្សានាងមួយជីវិត...!!!*

*ooooooooooooooo*

*ooooooo*

*o*

CHANBOKEO . COM

# វគ្គទី១៣
# ជំរំដីថៃ

CHANBOKEO . COM

- នេះ.... ខ្ញុំ... ខ្ញុំនៅឯណាហ្នឹង ?
- នាងនៅក្នុងរោងព្យាបាលជំរំខៅអ៊ីដាង
- ខៅអ៊ីដាង ?
- មែនហើយ... ជំរំខៅអ៊ីដាង ក្នុងដែនដីថៃណា៎នាង ។
- ហើយចុះឯណាគ្នីគ្នារបស់ខ្ញុំនោះ ?
- ពេទ្យយើងមិនទាន់ស្គាល់ឈ្មោះនាងផងទេ តើនាងឈ្មោះអ្វីដែរ នឹងអាលពួកយើងជួយផ្សាយដំណឹងរកបងប្អូន ព្រោះអីនាងក៏មាន របួសត្រូវពួកអង្គការមនុស្សធម៌ដឹកមកទីនេះ កាលពីម្សិល ហើយ ទើបនឹងដឹងស្មារតីវិញអីលូវនេះឯង...
- គឺ.... ខ្ញុំ... ឈ្មោះ... កូនមាន់ក្រញាស
- ពុទ្ធោ! ឈ្មោះអ្វីចម្លែកម្ល៉េះ ? នេះ នាងមិនវង្វេងស្មារតីទេណា៎ នាង ?
- អត់ទេមីង! គឺជាឈ្មោះរបស់ខ្ញុំពិតមែន ។ មីងជាគ្រូពេទ្យទីនេះ មែនទេ ?
- អត់ទេ! មីងទំនេរៗចេះតែមកជួយធ្វើការទីនេះទៅ មិនជាចេះ ភាសាបរទេសអីទេ ចេះតែសរសេរអក្សរខ្មែរ តែមីងអាណិតជនរង គ្រោះដែលបែកព្រាត់បងប្អូនក្រុមគ្រួសារ ទើបមានទឹកចិត្តមកជួយ កត់ឈ្មោះប្រកាសរកបងប្អូនអោយអ្នកជំងឺហ្នឹងណា៎! ព្រោះនៅព្រៃ

ខាងលិចឯណោះ គេដឹកអ្នកស្រុកមកទម្លាក់ពាក់ពពូន មិនដឹង នរណាជានរណាទេ ។ មីងគិតថាគួរប្រកាសផ្សងព្រេងសំណាងទៅ ក្រែងរកគ្នីគ្នាសាច់ញាតិឃើញវិញ ។

កូនមាន់ញញឹមឡើង រួចលើកដៃសំពះ ៖

- មីងមានចិត្តថ្លើមល្អយ៉ាងនេះ សូមទេវតាតាមថែរក្សាមីងអោយ សុខសប្បាយរហូត ។

មីងនោះសើចកខឹក ហើយឆ្លើយថា ៖

- យី! នៅក្មេងសោះ ចេះធ្វើអាចារ្យជូនពរហើយប្អូស ? នែ! នាងខំរក្សាខ្លួនបន្តិចទៅណា នឹងអាលឆាប់ជា មកជួយធ្វើការមីង ។ ដៃជើងឯងល្អៗយ៉ាងនេះ មុខជាអាចធ្វើការបានប្រយោជន៍ជូនជាតិ យើង ចំរើនវិញមិនខាន ។

មើលទៅស្ត្រីម្នាក់នេះ ដូចជារឹងប៉ឹងក្លាហានណាស់ ខុសពីស្រី ខ្មែរសាមញ្ញធម្មតា ។ កូនមាន់ក៏សួរគាត់វិញថា ៖

- មីងជាជនភៀសខ្លួនដូចពួកយើងដែរ មែនទេ ?

គាត់ងក់ក្បាល ៖

- មែនហើយ មីងជាប់ក្នុងសម័យកុម្មុយនីស្តពីរឆ្នាំ លួចរត់ចេញ មកតាមឧត្តរមានជ័យទៅសុរិន្ទ ហើយក៏បានស្ម័គ្រជួយធ្វើការអោយ អង្គការមនុស្សធម៌ រំពឹងក្រែងរកសាច់ញាតិឃើញខ្លះ ព្រោះប្តីមីង និងកូនបែកគ្នាទាំងអស់ មិនដឹងស្លាប់មិនដឹងរស់ទេ នាងអើយ ។ មីងចេះតែគិតសង្ឃឹមថា នឹងរកគេឃើញនៅពេលណាមួយ...

- ខ្ញុំជួយបន់ស្រន់សូមអោយមីងឆាប់បានជួបក្រុមគ្រួសាររបស់មីង វិញឆាប់ៗនេះ ។

មីងងក់ក្បាល រួចហើយក៏ឈ្វេកកត់ឈ្មោះនាងចូលបញ្ជីយ៉ាង រហ័សរហួន ។ រំពេចនោះ ស្រាប់តែមានគ្រូពេទ្យម្នាក់ចូលមកដល់ ក្បែរអ្នកទាំងពីរ ។ កូនមាន់ក្រឡេកឃើញភ្លាមក៏លាន់មាត់ឡើង ៖

- លោកថម ?

មែនហើយ! នោះគឺលោកគ្រូពេទ្យឈ្មោះថមពិតមែន ។ គ្រាន់ តែឮនាងហៅចំឈ្មោះ លោកគ្រូពេទ្យក៏ញញឹមឡើង សួរវិញជា ភាសាអង់គ្លេសថា ៖

- នាងបានធូរស្រាលខ្លះហើយឬនៅ ?

កូនមាន់ងក់ក្បាល រួចហើយក៏សួរត្រឡប់វិញ ៖

- ម៉េចលោកដឹងថា ខ្ញុំនៅទីនេះ ?

លោកគ្រូពេទ្យញញឹម រួចតបថា ៖

CHANBOKEO.COM

- គឺមិត្តរបស់នាងបានបីនាងមកដល់រថយន្តសង្គ្រោះ ទទួលខ្ញុំនៅទី នោះស្រាប់ក៏ជូននាងរហូតមកដល់ខៅអ៊ីដាងនេះតែម្តង ។

- ហើយចុះពួកគេនៅឯណាដែរ ?

លោកគ្រូពេទ្យគ្រវីក្បាល ៖

- ខ្ញុំមិនដឹងទេ! នៅក្នុងជំរំពេលនោះចលាចលណាស់ មិត្តរបស់ នាងប្រាប់ថា គេទៅទទួលមិត្តប្រុសរបស់នាងអោយមកឡើងឡាន ជាមួយគ្នា... តែពួកយើងមិនអាចចាំគេបាន ព្រោះយើងត្រូវការដឹក អ្នករបួសធ្ងន់ៗមកព្យាបាលជាបន្ទាន់ ទើបចេញដំណើរចោលពួកគេ យ៉ាងប្រញាប់ប្រញ៉ា មិនអាចចាំពួកគេបាន ។

ឮដូច្នេះ កូនមាន់នឹកដល់ជ្រូកលីវភ្លាមហើយក៏រលីងរលោងទឹក ភ្នែកមួយរំពេច ។ បន្តិចមក នាងក៏យកដៃផ្ជិតទឹកភ្នែកចេញពីរង្វង់ មុខ រួចសួរបន្តថា ៖

- តើពួកគេអាចមានឱកាសឡើងឡានមកទីនេះដូចខ្ញុំដែរទេ ?

លោកគ្រូពេទ្យងក់ក្បាល ៖

- បើសិនជាគេមិនរត់គេចទៅជំរំផ្សេង វង្វេងដើងដំណើររថយន្ត មនុស្សធម៌ទេ គេនឹងមានឱកាសឡើងរថយន្តមកទីនេះមិនខាន ។

កូនមាន់ក្តាប់ដៃខាំមាត់សង្កត់ចិត្ត មិនអោយពុះកញ្ជ្រោលដោយ ក្តីបារម្ភចំពោះជ្រូកលីវ... តែក៏ទប់មិនបាន... នាងក៏ទ្រោបមុខយំហ៊ូ លើស្មាស្ត្រីចំណាស់នោះ ។ លោកគ្រូពេទ្យចមយើញដូច្នោះក៏ស្រដី លួងលោមនាងពីរបីម៉ាត់ ហើយក៏ដើរត្រឡប់ទៅវិញ ។

- កាត់ចិត្តទៅមីអូនអើយ! គិតវិញទៅថា បើមាននិស្ស័យ នោះ នាងនឹងបានជួបសាច់ញាតិ និងមនុស្សជាទីស្រលាញ់របស់នាងគ្រប់ គ្នាវិញមិនខាន ។

មីងម្នាក់នៅមានវាចាពិរោះណាស់ ។ ពាក្យពេចន៍លួងលោម របស់គាត់បានធ្វើអោយបានធូរស្រាលអារម្មណ៍ក្រៃលែង ។

..............................

ច្រើនថ្ងៃក្រោយមក...

- កំពុងសរសេរអ្វីហ្នឹង កូនមាន់ ?

- អូហ៍មីងសឿន! សុខសប្បាយទេមីង ? ខ្ញុំកំពុងគូររូប...

- នាងគូរអ្នកណាគេដែរ ? សង្សារមែនទេ ?

CHANBOKEO .COM

កូនមាន់ញញឹម ដាក់ក្រដាសនិងខ្មៅដៃចុះ ។ នាងមិនតបនឹង សំនួររបស់គាត់ទេ បែរជាសួរវិញថា ៖

- ពេទ្យគេអោយខ្ញុំចេញថ្ងៃនេះឬមីង ?
- មែនហើយនាង!
- អញ្ចឹងខ្ញុំត្រូវត្រលប់ទៅណាងចាន់វិញឬយ៉ាងណាមីង ?
- អត់ទេ! នរណាគេអោយឯងទៅណាងចាន់វិញនោះ ? ម៉ោះ! រៀបចំខ្លួនមក់! មីងជូនឯងទៅ ។
- ទៅណាវិញមីង ?
- ទៅចុះឈ្មោះរកកន្លែងស្នាក់នៅ ។

កូនមាន់ក៏ដើបឡើងដើរតាមពីក្រោយមីងសឿន ។

- ជំរំនេះថ្មីជាងគេ ក្នុងចំណោមជំរំជនភៀសខ្លួនខ្មែរទាំងឡាយក្នុង ដីថៃ (មីងសឿនរៀបរាប់) ។ ការពិត ជំរំនេះ គ្រាន់តែជាដីព្រៃ មានតែស្មៅភ្លាំងបន្លាព្រេចតែម្យ៉ាងប៉ុណ្ណោះ គ្មានខ្ទម គ្មានផ្ទះទេ ។ នាងមើលហ្ន៎! ឃើញទេ ? ខ្ទមរកេតរកូតទាំងនោះ មិនមានរបៀប រៀបចំអ្វីស្រួលបួលនៅឡើយទេ ។

កូនមាន់សម្លឹងតាមចង្អុលដៃរបស់ស្ត្រីចំណាស់ ឃើញដំបូលខ្ទម ទាំងឡាយមានពណ៌ខៀវៗ តម្រៀបគ្នា ពេញព្រៃគុម្ពោធ ។ មីង សឿនក៏នាំនារីទៅឈរតម្រង់ជួរជាមួយជនភៀសខ្លួន ដែលទើប មកដល់ថ្មីៗទៀតដើម្បីចុះឈ្មោះយកបណ្ណ័បើកអាហារ ។ ពេលនោះ កូនមាន់បានត្រូវ បូករួមបញ្ចូលជាមួយអ្នកស្រុកភៀសខ្លួន១៩នាក់ ទៀត ដើម្បីទទួលឬស្សី២០ដើម និងផ្ទាំងសំពត់កៅស៊ូខៀវសំរាប់ ប្រក់ដំបូល ។
រីឯជនភៀសខ្លួនម្នាក់ៗវិញក៏បានទទួលផ្តិលជ័រមួយ សំរាប់ធ្វើជាចានបាយ ស្លាបព្រាមួយ និងឆ្នាំង៤សំរាប់មនុស្ស២០ នាក់ ស្លដាំរួមគ្នា ។ រួចកិច្ចការរបស់គាត់ហើយ មីងសឿនក៏ត្រលប់ ទៅវិញ ។ កូនមាន់ក៏នៅឈរធ្វើអេះអុញៗ ជាមួយអ្នកស្រុកមួយ ហ្វូងនោះត្បិតពួកគេសុទ្ធតែជាមនុស្សមិនដែលស្គាល់គ្នាពីមុនមក ។ ឯ១៩នាក់នោះទៀតសោត សុទ្ធតែជាស្ត្រីនិងកូនក្មេង មានបុរស ចាស់ៗតែពីរនាក់ប៉ុណ្ណោះ ក្នុងចំណោមពួកគេ ។

កូនមាន់ក៏ត្រដេរត្រដរទាំងអស់កម្លាំងល្ងិតល្ងៃ ជួយពូៗពីរនាក់ នោះរើសឬស្សី២០ដើមនិងផ្ទាំងសំពត់កៅស៊ូពណ៌ខៀវដែលអង្គការ មនុស្សធម៌ចែកឲ្យ

CHANBOKEO.COM

ដើម្បីសង់ជាខ្ទមឡើង ។ មានមីងៗខ្លះទៀត ក៏មានទឹកចិត្តមកជួយធ្វើការ ។ ខ្លះទៀតក៏ទំរន់ទំរេត មិនព្រមជួយ អ្វីទេ មិនដឹងថាគាត់មានជំងឺ មានរបួសអស់កម្លាំង ឬក៏ខ្ជិលអ្វីឡើយ ឃើញតែរ៉េរ៉ៃគេងលើស្មៅរង់ចាំអោយគេប្រក់ខ្ទមអោយហើយ ។

- យើងកុំយកផ្ទាំងក្រណាត់កៅស៊ូប្រក់ធ្វើអ្វីណ៎ាពូ! គួរតែច្រូតស្បូវ ប្រក់ដំបូលវិញប្រសើរជាង ។

កូនមាន់ផ្តល់យោបល់ទៅពូពីរនាក់នោះ ។

- ម៉េចអញ្ជឹង មីនាង ? ប្រក់សំពត់នេះទៅលឿនផង ឆាប់ពេញ ដំបូល នឹងអាលបានជ្រកយប់នេះ (ពូម្នាក់ពោលកាត់)

កូនមាន់ញញឹមហើយឆ្លើយថា ៖

- គឺខ្ញុំយល់ថា បើយើងច្រូតស្បូវមកប្រក់ដំបូល យើងហត់បន្តិច ម្យ៉ាងត្រូវចាយពេលបីបួនថ្ងៃទើបប្រក់ខ្ទមរួចរាល់ តែដំបូលស្បូវវា មានម្លប់ត្រជាក់ រស់នៅដកដង្ហើមស្រួល រួចហើយយើងសល់សំពត់ កៅស៊ូសំរាប់ត្រងទឹកភ្លៀងស្តុកទុកសំរាប់បរិភោគទៀតផង ។
- យី សំពត់បន្ទះបែបនេះ ផ្ទុកទឹកភ្លៀងយ៉ាងណាទៅមីនាង ?
- គឺយើងជីករណ្តៅជាជំរៅប្រហែលមួយម៉ែត្រ ហើយកាត់សំពត់ កៅស៊ូទម្លាក់ចូលទៅ ទើបបង្ហូរទឹកចូលបំពេញ ។ ធ្វើយ៉ាងនេះមិន ខុសពីមានពាងទឹកឬអាងទឹកទេណាពូ ព្រោះខ្ញុំឃើញនៅតំបន់នេះ គ្មានស្រះ គ្មានអូរ គ្មានបឹងបួរទេ ។ យើងរង់ចាំតែទឹកដែលអង្គការ ដឹកយកមកចែកពិតជាមិនគ្រប់គ្រាន់នឹងប្រើឡើយ ។ ម្យ៉ាងទៀត បើយើងអាចជីកអណ្តូងចេញទឹកបាន នោះរិតតែប្រសើរ!

អ្នកស្រុកប៉ុន្មាននាក់នោះក៏សើចកក្អឹកនឹងគំនិតល្អនេះ ។

ពូម្នាក់លាន់មាត់ឡើងថា ៖

- យីអើ! មើលឃើញរាងល្អិត មុខស្លេកអញ្ជឹង ចេះមានប្រាជ្ញាអី សំបើមម្ល៉េះទី! ថាអញទៅវាឆ្លាតទៅហើយ ម៉េចក៏មកមានឯក្មេង ស្រីស្អីនេះ មកឆ្លាតជាងអញទៅទៀត... អើហ៎ អើហ៎! គំនិតល្អ! តោះ ពួកយើង!ទៅច្រូតស្បូវ ។ អ្នកណាចាំខ្ទម កុំភ្លេចដាំបាយផង ហើយ ប្រយ័ត្នណា កុំលួចគែអង្គការចែក ប្រយ័ត្នមានកូនខ្វាក់ភ្នែក ទើយ! ព្រះជួយមិនរួចទេ ។

បន្តិចមក អ្នកស្រុកក៏ចេញប្រសាចទៅច្រូតស្បូវ ហើយគំនិត នេះក៏លាន់ឮខ្ទរខ្ទាយទៅក្រុមផ្សេងៗទៀត ធ្វើអោយមនុស្សនាំគ្នា ចេញទៅច្រូតស្បូវយកមកប្រក់ដំបូល កាន់តែច្រើនឡើង ។ មិន យូរប៉ុន្មាន

CHANBOKEO.COM

ទីវាលស្បូវភ្លាំងក្បែរជើងភ្នំខាវអ៊ីដាង បានក្លាយជាដី
ភូមិដែលមានខ្ទមប្រក់ស្បូវយ៉ាងស្កេកស្កះទៅវិញ ។

.........................................

ពីរបីថ្ងៃកន្លងទៅ...

ដោយសាមគ្គីភាព ផ្ទះស្បូវមួយខ្នងក៏និម្មិតឡើងល្មមអាចឲ្យ
អ្នកស្រុក២០នាក់សណ្ដូកជើងពេលយប់ ផុតទឹកភ្លៀងផុតក្ដៅរងា បានមួយដំណើរ ។

- មីអូនអើយ! ទៅអង្គុយសំកុកអីហាលសន្សើមអញ្ចឹង ? ប្រយ័ត្ន
ផ្ដាសាយណាស់រើយ! យប់ហើយ ម៉េចមិនចូលដេកហ្ន៎ស ?

កូនមាន់ងាកបែរមើលឃើញមីងម្នាក់ឈ្មោះផា ដែលនៅផ្ទះជា មួយគ្នា បក់ដៃហៅនាង ។

- បន្តិចទៀតខ្ញុំចូលគេងហើយមីង ។ មីងសំរាន្តមុនចុះ ។

មីងផាឮហើយក៏វិលចូលទៅក្នុងផ្ទះស្បូវវិញ ។

ការពិត កូនមាន់កំពុងសំកុកនឹកគិតទៅដល់ជ្រូកលីវ...

- មិននឹងជាហេតុអ្វីហ្ន៎បានជាខ្ញុំជំពាក់ចិត្ត ជំពាក់អារម្មណ៍លើបុរស ម្នាក់នេះម្ល៉េះ ?
(កូនមាន់សួរខ្លួនឯង) ហើយអ្វីរូបគេមានអនុភាព មកលើចិត្តខ្ញុំយ៉ាងហ្នឹង ?
ថ្ងៃណាក៏ខ្ញុំនឹកគេ...មិនមានលោះវេលាទេ តើគេមាននឹកខ្ញុំដែរឬអ្វី ?
ហ៊ឺ!...តើហេតុអ្វីយើងត្រូវបែកគ្នាផង ? ជាតិនេះ... យើងមាននិស្ស័យនឹងជួបគ្នាវិញដែរឬទេហ្ន៎ ?

កូនមាន់ក្រញាសអង្គុយញ័រចង្កាចំប្រប់ ពេលនឹកទៅដល់ពេល វេលាប្រហែលមួយខែកន្លងមក
ដែលនាងបានឆ្លងកាត់ពីរនាក់តត្ត ជាមួយជ្រូកលីវ ស្ទើរស្លាប់ស្ទើររស់
ទំរាំមកដល់ជាយដែនខ្មែរថៃ ។

- បើសំណាងវាសនានៅមាន... សូមអោយពួកយើងបានជួបគ្នា វិញឆាប់ៗនេះផង...

កូនមាន់ងើយសម្លឹងផ្កាយរះព្រិចៗលើមេឃ លួចបន់ស្រន់ក្នុង ចិត្តតែម្នាក់ឯង...
យប់ជ្រៅបន្តិចហើយ ខ្យល់ក៏កាន់តែរងា ប៉ុន្តែ ធាតុអាកាសនេះមិនបានរំខានដល់កូនមាន់ទេ
ព្រោះអារម្មណ៍របស់ នាង ចិត្តរបស់នាងបានហើរបាត់ពីខ្លួនត្រលប់ទៅណាងចាន់វិញបាត់
ទៅហើយ....

..........................

ថ្ងៃបន្តបន្ទាប់មកទៀត....

- រៀបចំខ្លួនទៅណាទាំងព្រឹកហ្នឹងមីនាង ?

CHANBOKEO .COM

មីងផាសួរកូនមាន់ ។
- ខ្ញុំទៅរកការងារធ្វើណា៎មីង ក្រែងលោបានកម្រៃជាអាហារ ចែក គ្នាទទួលទាន ។
- អឺ អញ្ចឹងហ្អែស ? មីងឮអ្នកជិតខាងគេនាំគ្នាទៅធ្វើការឲ្យពួក អ្នកស្រុកជាតិថៃ
ម៉ាថ្ងៃបានកម្រៃ១០បាតដែរ ។
- តែខ្ញុំមិនទៅធ្វើការអោយពួកថៃទេ មីង!
- អញ្ចឹងឯងទៅធ្វើការអីវិញ ?
- គឺការងារនៅក្នុងជំរំនេះឯង ។ ខ្ញុំមិនហ៊ានដើរចេញពីបរិវេណ ជំរំទេ ខ្លាចគ្មានសុវត្ថិភាព ។
- អឺ! អញ្ចឹងក៏បានដែរ ខ្លួនជាស្រី ត្រូវមានការប្រយ័ត្នប្រយែង អញ្ចឹងទើបប្រសើរ ។

កូនមាន់ញញឹមហើយដើរចេញទៅ ។ ការពិត នាងមិនទៅណា ឆ្ងាយក្រៅពីទៅជួបមីងសឿន ព្រោះនាងចង់ធ្វើការក្នុងមន្ទីរពេទ្យ ក្រែងលោអាចស៊ើបដំណឹងពីជំរំណាងចាន់ តាមរយៈជនភៀសខ្លួន ដែលទើបមកដល់ថ្មីៗ ។

តាមពិតទៅ មន្ទីរព្យាបាលអ្នកជម្ងឺនិងអ្នករបួសនោះគ្រាន់តែជា រោងធំវែងប្រក់ដំបូលក្រណាត់ ដូចតែនៅជំរំណាងចាន់អញ្ចឹងដែរ ហើយក៏គ្មានជញ្ជាំងដូចគ្នា ។
គេដាក់អ្នកជំងឺលើប៉ាវអ៊ីតូចៗតម្រៀប ជួរដង្ហែដូចតម្រៀបត្រីងៀតហាលដូច្នេះឯង ។

............................

នៅក្នុងរោងព្យាបាល...
- មែនហើយ! កូនមាន់ចេះនិយាយអង់គ្លេស ចេះបារាំងយ៉ាងនេះ អាចធ្វើការក្នុងពេទ្យនេះក៏បាន
(មីងសឿននិយាយ) ប៉ុន្តែមីងឮគេ ប្រាប់ថា
គេត្រូវការអ្នកបកប្រែពីរបីនាក់នៅការិយាល័យយូអិនខាង មុខជំរំឯណោះ
ដើម្បីជួយរៀបបញ្ជីគ្រួសារជនភៀសខ្លួន និងការ ផ្សាយដំណឹងរកសាច់ញាតិ ។
- មែនឬមីង! បើដូច្នេះខ្ញុំទៅរកការធ្វើទីនោះក៏បានដែរ ។
- កុំគិតថាមីងដេញឯងមិនអោយធ្វើការនៅរោងព្យាបាលនេះអីណា៎ ការពិត
មីងចង់អោយឯងបានការធ្វើនៅទីនេះស្រួលនឹងទាក់ទងជា មួយអង្គការប្រទេសក្រៅ
ដើម្បីសុំសិទ្ធិជ្រកកោននៅស្រុកគេ នឹង ហើយនៅ ? នៅវ័យក្មេង
គំនិតស្មារតីឆ្លៀវឆ្លាតដូចក្មួយឯងនេះ គឺ គួរតែទៅបន្តការសិក្សាថែមទៀត
ក្រែងថ្ងៃណាមួយបានមកជួយ ស្រុកទេសយើងវិញ ព្រោះអ្នកប្រាជ្ញស្រុកយើងត្រូវខ្មែរក្រហមអារ
កសម្លាប់អស់ហើយ... ហ៊ឺ! ប្ដីមីងក៏ប្រហែលជា... មិនសល់ជីវិតដែរ មើលទៅ!

CHANBOKEO.COM

ពោលដល់ត្រង់នេះ មីងសឿនធ្លាក់ទឹកមុខស្រងូតតែម្ដង ។

- ខ្ញុំអរគុណណាស់មីង ចំពោះសន្ដានចិត្តដ៏ល្អនេះ ។

រំពេចនោះ រថយន្តដឹកជនភៀសខ្លួនមកដល់ទៀតហើយ មានទាំងមនុស្សជាមនុស្សឈឺមនុស្សរបួសសព្វយ៉ាង ។ កូនមាន់ងាកទៅឃើញបុរសម្នាក់ចុះពីររថយន្តដើរធីងធោង ក៏ភ្ញាក់ព្រើតស្រែក ហៅយ៉ាងលឿន ៖

- មិត្តខេង ?

បុរសនោះក៏បែរមកយ៉ាងរហ័ស ៖

- កូនមាន់ ?

- ចា៎សគឺខ្ញុំ!

ខេងក៏ញញឹមឡើង ហើយដើរយ៉ាងលឿនសំដៅមករកនារី ។

- ខ្ញុំរំភើបចិត្តណាស់ កាលបើឃើញកូនមាន់សុខសប្បាយ ។

- ចា៎ស ខ្ញុំទើបបានស្រួលបួលប៉ុន្មានថ្ងៃនេះឯង ។ ហើយចុះឯណា ជ្រូកលីវ ?

គ្រាន់តែឮសំនួរនេះភ្លាម គេក៏ទម្លាក់ទឹកមុខស្រងូតតែម្ដង ។ មាណវីយើងឃើញដូច្នោះ នឹករន្ធត់ក្នុងចិត្តណាស់ ក៏ដេញសួរនាយ យ៉ាងរន្ថើនថែមទៀត ៖

- ជ្រូកលីវយ៉ាងម៉េចហើយ ? ប្រាប់ខ្ញុំផងបានទេ ?

- គឺ... ខ្ញុំនឹងគេវង្វេងគ្នា... ពេលនេះ មិនដឹងថាគេនៅឯណាទេ...

កូនមាន់អួលដើមកទឹកភ្នែករលីងរលោង ៖

- មិត្តមិនបានភូតខ្ញុំទេ មែនទេ ?

- មិនទេ... គឺយើងវង្វេងគ្នាមែន...

ទ្រាំមិនបាន កូនមាន់ក៏ឈ្ងោកមុខចុះ សម្រក់ទឹកភ្នែក យំខ្សឹក ខ្សួលតែម្ដង...

ខេងឈរសំកុកស្ងៀមស្ងាត់សម្លឹងកូនមាន់យ៉ាងយូរ ទើបស្រដី លួងលោមថា ៖

- គេប្រហែលជាមិនអីទេ! នេះគ្រាន់តែវង្វេងគ្នាមួយពេលទេតើហ៎ កូនមាន់កុំបារម្ភអី... មិនយូរមិនឆាប់ យើងគង់ជួបគេមិនខានទេ...

រំពេចនោះ ស្រាប់តែ...

- ខេង! គឺឯងមែនទេ ?

អ្នកទាំងពីរបែរមើលឃើញស្ត្រីចំណាស់ប្រហែលសែបឬយ ដើរ ចូលមក ។

- អ្នកមីងខែ ?

CHANBOKEO.COM

- អឺ គឺមីងហើយ... នេះឯងនៅចាំម្ដាយមីងរបស់ខ្លួនដែរតើហ៎
- ជំរាបសួរមីង! ខ្ញុំត្រេកអរណាស់ដែលបានជួបមីង ហើយនឹងថា មីងសុខសប្បាយ ។ មីងស្នាក់នៅជំរំនេះដែរមែនទេ ?
- ហ្នឹងហើយ! មីងមកដល់ទីនេះជិតកន្លះខែហើយ ថ្ងៃនេះ មីង មកពេទ្យសុំថ្នាំគ្រុនចាញ់ ទើបបានមកប្រទះឯងហ្នឹងតែម្ដង ។
- ពិតជាសំណាងរបស់ខ្ញុំណាស់ដែលបានជួបមីងថ្ងៃនេះ ។

រួចហើយខេងក៏ងាកមកកូនមាន់ ប្រាប់ថា ៖

- កូនមាន់! ខ្ញុំបានជួបម្ដាយមីងខ្ញុំហើយ ខ្ញុំសុំឱកាសទៅជួបគាត់ សិន ហើយថ្ងៃក្រោយ ចាំយើងនិយាយគ្នាទៀតណា៎
- ចា៎ស!

បន្ទាប់ពីខេងដើរចេញទៅជាមួយម្ដាយមីង ។ ឯមាណវីយើងក៏ បោះជំហានសំដៅការិយាល័យយូអិនប្រចាំជំរំខៅអ៊ីដាងដាក់ពាក្យសុំ ធ្វើការ រួចហើយទើបត្រលប់មកខ្ទមសំណាក់វិញ ។

- ឯងធ្វើមុខស្ងួតផង រីករាយផងយ៉ាងនេះ មានរឿងអ្វីកើតឡើង មែនទេ ក្មួយ ?

មីងផានងទឹកពីរណ្ដៅកៀនផ្ទះ ស្រោចកូនជីរបណ្ដើរ ជជីក សួរទៅកូនមាន់ ដែលកំពុងអង្គុយត្របោមជង្គង់ផ្ទែកជញ្ជាំងនោះ បណ្ដើរ ។ ឮសំនួរមីងផាភ្លាម នារីយើងភ្ញាក់ព្រើត ឆ្លើយភ្លាមថា ៖

- គឺ... ខ្ញុំនឹកបងប្អូនសាច់ញាតិរបស់ខ្ញុំណាមីង... ហើយម្យ៉ាងទៀត ការិយាល័យយូអិន ទទួលអោយខ្ញុំចូលទៅជួយធ្វើការ ជាអ្នកបក ប្រែចាប់ផ្ដើមពីថ្ងៃស្អែកនេះហើយ... ខ្ញុំចង់តែគិតផ្ដួចៗ បែបន់សុំ អោយខ្ញុំមានឱកាសរកឃើញញាតិសន្ដានរបស់ខ្ញុំវិញ ។
- អឺ! មីងជួយអរឯងផង ហើយកុំភ្លេចជួយកត់ឈ្មោះប្ដីមីងនិងកូន មីងពីរបីនាក់ទៀតចុះបញ្ជីផង ក្រែងអង្គការអាចជួយរកពួកគេទាំង នោះឃើញវិញ ។

កូនមាន់ញញឹម ៖

- ចា៎សមីង! ខ្ញុំនឹងកត់ឈ្មោះគ្រួសារមីងមុនគេ នៅព្រឹកស្អែកនេះ ពេលខ្ញុំចូលធ្វើការ ។

រំពេចនោះស្រាប់តែពួមីងពីរបីនាក់ទៀតដែលនៅផ្ទះជាមួយគ្នា នោះ កូកប្រជែងគ្នាមករកនាងព្រមៗគ្នា ថា ៖

- អឺ! មីងដែរ!

CHANBOKEO.COM

- ចំណែកពូវិញ ក៏ចុះឈ្មោះដែរ! ជួយរកកូន ប្រពន្ធផង...

កូនមាន់អត់មិនបាន ក៏សើចកខឹកៗ ឆ្លើយកាត់វិញថា ៖

- ចា៎ស!ៗៗ មីងពូទាំងអស់ ចាំស្អែកចាំខ្ញុំយកក្រដាសចុះឈ្មោះ គ្រប់ៗគ្នាមិនខានទេ ។ ជឿក្នុយចុះ ។

ទាំងអស់គ្នាក៏ផ្ទុះសំណើចឡើងយ៉ាងកក្អឹក ដោយព្រោះគេមាន កម្លាំងចិត្តយ៉ាងធំធេង ត្បិតសង្ឃឹមថា នឹងអាចស្វែងរកសាច់ញាតិ របស់ខ្លួនឃើញវិញតាមរយៈអង្គការមនុស្សធម៌ ។

ការពិត នៅក្នុងជំរំនេះ នរណាៗក៏បែកព្រាត់សាច់ញាតិដែរ ។ គេរត់ចេញពីស្រុកខ្មែរដោយមូលហេតុ និងបំណងផ្សេងៗគ្នា តែអ្វី ដែលដូចគ្នានោះ គឺពួកគេត្រូវចាកចេញពីទឹកដីរបស់ខ្លួនក្នុងស្ថាន ភាពគ្រោះថ្នាក់តក្កហាលដល់ជីវិត ។ ម្ល៉ោះហើយ គ្មាននរណាម្នាក់ ដែលបានមកដល់ជំរំជុំគ្នាទាំងគ្រួសារឡើយ ។

សំណាងល្អ ក្រសួងមនុស្សធម៌អន្តរជាតិបានបង្កើតកម្មវិធីស្វែង រកសាច់ញាតិ ម្ល៉ោះហើយម្នាក់ៗអាចនៅមានទឹកចិត្តសង្ឃឹមខ្លះៗថា នឹងមានឱកាសជួបជុំមនុស្សជាទីស្រឡាញ់របស់គេវិញ នៅថ្ងៃណា មួយមិនខាន ។

*oooooooooooooooooo*

*oooooooo*

*o*

CHANBOKEO .COM

# វគ្គទី១៨
## គិតយ៉ាងណា ?

ពេលវេលាចេះតែកន្លងទៅ...

កូនមាន់រៀបចំក្រដាសស្នាមទុកដាក់ត្រឹមត្រូវហើយក៏ដើរចេញពីក្រោយជនបរទេសដែលជាបុគ្គលិកយូអិន ដើម្បីត្រឡប់ទៅផ្ទះ វិញ ស្រាប់តែប្រទះឃើញបុរសមួយរូបឈរអោរវង់ចាំនាងនៅក្បែរ ក្លោងទ្វារ ។ នាងក៏ញញឹមឡើង ៖

- ម៉េចដឹងថាខ្ញុំធ្វើការនៅទីនេះ មិត្តខេង ?
- គឺខ្ញុំទៅរកនាងនៅរោងព្យាបាលហើយមីងម្នាក់នោះប្រាប់ថា កូន មាន់មកធ្វើការនៅទីនេះ ។
- ចា៎ស ! ហើយខេងមករកខ្ញុំមានការអ្វីដែរហ្នឹង ?
- គឺ... ខ្ញុំចង់មកប្រាប់...

ខេងក៏សើចញញឹមឡើង ។

- មានអ្វីរីករាយមែនទេ បានសើចគ្រហាញស្អាតម្ល៉េះ ?
- ខ្ញុំមានអ្វីចង់អោយកូនមាន់មើលបន្តិច

ភ្លាមនោះ កូនមាន់សង្កេតឃើញមាណពកាន់អ្វីលាក់ក្រោយខ្នង ទំនងជាស្រោមសំបុត្រ ។

- មានដំណឹងល្អមកពីក្រៅមែនទេ ? (កូនមាន់សួរ)
- មែនហើយ... យី ! ម៉េចក៏កូនមាន់ដឹង ?
- ខ្ញុំមិនដឹងទេ គ្រាន់តែស្មានទេតើហ៍ ហើយវាជាក្រដាសអ្វីហ្នឹង ?
- ជា... ក្រដាសធានាចេញទៅប្រទេសក្រៅណា៎ !

CHANBOKEO.COM

- អូហ៍ មែនហ្អេស៎ ? អញ្ចឹង ខ្ញុំសុំជួយត្រេកអរផងដែលខេងមាន ឱកាសល្អ
មានបងប្អូនជួយធានាចេញទៅ ។ ចំណែកខ្ញុំវិញ គ្មាន សាច់ញាតិនៅប្រទេសក្រៅម្នាក់សោះ...

ពោលដល់ត្រឹមនេះ កូនមាន់ដាក់មុខជ្រប់ លែងសប្បាយ ។

- មើល៍! កុំធ្វើមុខអញ្ចឹងមើល៍ ខ្ញុំនិយាយមិនទាន់ចប់ឯណា!

កូនមាន់ងើបមុខសាជាថ្មីមើលនាយខេង ហើយសួរថា ៖

- នៅមានរឿងអ្វីទៀតដែលចង់ប្រាប់មែនទេ ?
- បាទ! មែនហើយ! គឺខ្ញុំបានសុំបងប្អូនរបស់ខ្ញុំអោយបន្ថែម
ឈ្មោះកូនមាន់ម្នាក់ទៀតលើក្រដាសធានា ហើយគេក៏យល់ព្រមទើប
ខ្ញុំមកសុំឈ្មោះពិតប្រាកដរបស់កូនមាន់ ដើម្បីសរសេរក្រដាសស្នាម ធានាអោយបានត្រឹមត្រូវ ។

កូនមាន់ឮហើយញោចចិញ្ចើមទំនងគិត រួចហើយក៏ស្រដីថា ៖

- តើអោយខ្ញុំចុះឈ្មោះជាសាច់ញាតិយ៉ាងម៉េច ជាមួយនឹងខេង ដើម្បីអោយគេធានាបាន ?
- គឺអ្នកធានានោះជាបងប្រុសរបស់ខ្ញុំដែលទើបចេញពីជំរំទៅដល់ អាមេរិកប៉ុន្មានខែមុន ។
ហើយកូនមាន់ដាក់ឈ្មោះធ្វើជាគូដណ្តឹងខ្ញុំ ទៅ នឹងអាលបានទៅជុំគ្នាផង ។

កូនមាន់ភ្ញាក់ក្រញាងកាលបើឮដូច្នោះ ៖

- ខ្ញុំគិតថាមិនសមរម្យទេដឹង ព្រោះការពិត ខ្ញុំមិនមែនជាគូដណ្តឹង របស់ខេងឯណា!
- តើយើងក៏អាចក្លាយជាគូដណ្តឹងបានដែរ មិនថាអញ្ចឹង ? ខ្ញុំមាន
ម្តាយមីងនៅក្នុងជំរំនេះស្រាប់ហើយ ។ គាត់អាចធ្វើចាស់ទុំចូលស្តី កូនមាន់សមរម្យតាមប្រពៃណី
មិនអោយអាក្រក់មើលដូចការចាប់ ប្រជល់គ្នា ជំនាន់អង្គការខ្មែរក្រហមទេ ។

កូនមាន់នៅស្ងៀមមួយស្របក់ ក៏ស្រដីថា ៖

- ទុកអោយខ្ញុំគិតមើលសិនណ៎! ពេលនេះ ខ្ញុំមិនមានអារម្មណ៍ថា
ចង់ចេញទៅរស់នៅប្រទេសទីបីនៅឡើយទេ ។

ខេងទម្លាក់ទឹកមុខភ្លាម កាលបើឮនាងឆ្លើយដូច្នោះ ៖

- កូនមាន់នៅចាំជ្រួកលីវមែនទេ ?

នារីងើបមុខភ្លែតសម្លឹងខេងដោយក្រសែភ្នែកភ្លឺថ្លាផ្លេកៗ ៖

- ចុះបើមែន មិត្តគិតយ៉ាងណាដែរ ?

ខេងបែរមុខចេញ និយាយថា ៖

- នាងមិនទុកឱកាសអោយខ្ញុំផងដែរទេហ៏ ?

CHANBOKEO.COM

- គឺ... ខ្ញុំកំពុងរង់ចាំដំណឹងពីជ្រូកលីវ... មិនអាចសំរេចចិត្តអ្វីពេល នេះបានទេ... អោយខ្ញុំសូមទោសផងណា៎...

ថាហើយ កូនមាន់ក៏បោះជំហានចេញទៅ ទុកអោយនាយខេង ឈរធ្វើមុខស្រងូតតែម្នាក់ឯង ។

តាមផ្លូវ កូនមាន់ដើរបណ្តើរគិតបណ្តើរ ៖

- ខ្ញុំបានបែកពីជ្រូកលីវច្រើនអាទិត្យហើយ ម្តេចមិនឮដំណឹងគេ សោះអញ្ចឹង ? តើគេមានគ្រោះថ្នាក់ ឬក៏គេបំភ្លេចរូបខ្ញុំ ហើយក៏ធ្វើ ដំណើរតាមវិថីជីវិតរបស់គេបន្តទៅទៀត ? តើខ្ញុំគួរនៅរង់ចាំគេ រហូតអញ្ចឹងទៅ ឬយ៉ាងណា ? បែរទៅខេង... គេក៏ជាមនុស្សមាន សន្តានចិត្តល្អមិនចាញ់ជ្រូកលីវទេ ហើយគេក៏ជិតបានទៅរស់នៅ អាមេរិកដែលជាប្រទេសមហាអំណាច ប្រហែលជាគេនឹងមានជីវិត ចំរុងចំរើន ។ តើខ្ញុំគួរលះបង់ឱកាសនេះទេ ? តើអនាគតរបស់ខ្ញុំ ស្ថិតនៅលើជ្រូកលីវ.. ឬក៏ផ្អែកទៅលើមិត្តខេង ? ខ្ញុំពិតជាចង់បាន អនាគតល្អ ចង់រៀនបន្ត ចង់រស់នៅមានសុខសុវត្ថិភាព... តើខ្ញុំ គួរគិតយ៉ាងណាដើម្បីខ្លួនឯង ? ទេហ៍! ខ្ញុំពិតជាមិនដាច់ចិត្ត ចាក ចោលជ្រូកលីវទេ... គេបានប្តូរជីវិតដើម្បីខ្ញុំជាច្រើនដង... ខ្ញុំភ្លេច គេមិនបានទេ...ភ្លេចមិនបានទេ...

កូនមាន់ដើរបណ្តើរ ស្រក់ទឹកភ្នែកបណ្តើររហូតដល់លំនៅ ។

.......................................

CHANBOKEO.COM

- ឯងពិបាកចិត្តធ្វើអ្វី មីអូនអើយ !

មីងផានិយាយលួងលោមកូនមាន់ ពេលគាត់ឃើញនារីអង្គុយយំ ខ្សឹកខ្សួលមិនបរិភោគបាយ ។ តាមពិត មីងផារាប់អានស្រឡាញ់ កូនមាន់ស្និទ្ធស្នាលណាស់ ហើយយល់ស្គាល់ទុក្ខធុរៈដូចជាសាច់ញាតិ មួយរូបដូច្នោះឯង ។ ក្រោយពីបានដឹងរឿងដ៏កំសត់របស់កូនមាន់ ហើយ គាត់ក៏ដកដង្ហើមធំ និយាយកម្លាចិត្តកូនមាន់ថា ៖

- មីងគិតថា ឯងគួរសម្លឹងទៅមុខ មិនគួរសម្លឹងបកក្រោយអោយ ទុក្ខគ្រាំគ្រាពារក្នុងទ្រូងឯងអញ្ចឹងទេណា៎! ឱកាសល្អមិនដែលមាន ច្រើនដងទេ ហើយជាពិសេស មនុស្សល្អក៏ពិបាករកណាស់នៅ សម័យអីលូវនេះ ។ បើមីអូនឯងបានប្រទះនឹងមនុស្សល្អហើយ ក៏ គួរគិតគូរទៅ កុំនៅរង់ចាំអ្វីដែលវាមិនទៀងអី ព្រោះឯងមិនដឹងថា អារអន្ទិតជ្រូកលីវនោះវាស្លាប់ឬរស់យ៉ាងណាផងនោះ ។

កូនមាន់នៅតែឈ្ងោកមុខអង្គុយស្ងៀមស្ងាត់មិនស្រដី ។ បន្តិចមក មីងផាក៏ពោលបន្ថែមថា ៖

- មីងបានត្រឹមតែនិយាយប៉ប៉ោចឥតន័យទេ ឯងកុំគិតច្រើនអី ។ ជួនកាលរឿងផ្លូវចិត្តវាពិបាកនឹងស្រាយចំណងណាស់... មីងក៏ធ្លាប់ ហែលឆ្លងអារម្មណ៍បែបនោះរួចមកហើយដោយការរង់ចាំអោយប្តី មីងត្រឡប់មកវិញ ហើយមិនព្រមរៀបគូស្រករថ្មី... ដូច្នេះមីងក៏មិនចង់ឃើញឯងរស់នៅរីងរៃក្នុងចិត្តដូចមីងសព្វថ្ងៃអញ្ចឹងទេ...

កាលបើឮសំដីដ៏សែនអួលអាក់របស់មីងផា ស្រាប់តែកូនមាន់ ងើបមុខឡើង ស្រដីថា ៖

- ប៉ុន្តែ..ខ្ញុំមិនចង់អោយបុរសម្នាក់នោះគិតថា ខ្ញុំទទួលយករូបគេជាប្តីដោយសារចង់ទៅអាមេរិកទេមីង ។ ម្យ៉ាងទៀត ខ្ញុំនេះក៏មិនបាន ស្រឡាញ់គេផង តើអោយរស់នៅជាមួយគ្នាយ៉ាងណា ?

- ហ៊ឺ! មីងមិនមានយោបល់អីទៀតទេក្មួយអើយ! ពេលនេះជីវិតអនាគតស្ថិតនៅក្នុងកណ្តាប់ខ្លួនឯងហើយ ។ ចូរឯងគិតមើលអោយ បានល្អទៅណ៎!

- ចា៎សមីង!

បន្តិចមក ធិតាយើងក៏ផ្តេកក្បាលកើយដៃធ្មេចភ្នែកសំងំគេង ។

.........................

ពេលរំលងអាធ្រាត ស្រាប់តែឮអ្នកស្រុកក្បែរៗនៅស្រែកខ្ទៀវ ខ្ទាឡើង ហើយនាំគ្នាគោះចបគោះធុងទឹកក្នុងក្តាំងទ្រហឹងអឺងកង៖

- ចោរ! ៗៗៗ ចោរចូលភូមិ!! ចាប់!!

ភ្លាមនោះ កូនមាន់បើកភ្នែកឡើងមើលទៅក្រៅ ក៏ឃើញស្រមោលមនុស្សរត់ពីរនាក់បែកខ្ញែកផ្លូវគ្នា ហើយមានម្នាក់រត់ចូល មកក្នុងខ្ទមរបស់នាង ។ មីងផាភ្ញាក់ស្រែកវាស ស្រាប់តែជននោះ លូនមកខ្សិបដាក់គាត់ថា ៖

- ខ្ញុំមនុស្សល្អទេ! ខ្ញុំទើបរត់កាត់ព្រៃចូលមកទីនេះ ហើយក៏ជាន់ដានចោរដែលចេញលួចពេលយប់... មីងកុំស្រែកអី... ខ្ញុំមិនធ្វើអ្វី មីងនិងកូនចៅទេ ។ មីងសំរាន្តវិញចុះ ខ្ញុំសុំអនុញ្ញាត្តិជ្រកចុងជើង ម៉ាយប់ទៅចុះណ៎បាទ ។

មីងផានិងកូនទាំងពីរឮហើយក៏នាំគ្នាធ្មេចភ្នែកចូលដំណេកវិញ ទៅ ។ ចំណែកឯកូនមានក៏បានឮសំដីជននោះដែរ តែមិនដឹង ត្រូវធ្វើយ៉ាងម៉េចក៏ទាញក្រមាយកមកទទូពួនកំប្រុន  កៀនជញ្ជាំង គេងគិតតែម្នាក់ឯង ។ ម្យ៉ាងទៀត

CHANBOKEO.COM

មនុស្សម្នាក់នោះហាក់ដូចជាគ្មាន កិរិយាសាហាវយង់ឃ្នងផង ។ តែទោះបីយ៉ាងណា នាងក៏មិនទាន់ ទុកចិត្តអ្វីដែរ ម៉្លោះហើយ ក៏លួចតាមសង្កេតមើលកិរិយាជនមួយរូបនោះទាល់ភ្លឺតែម្តង ។

នៅខាងក្រៅ សម្លេងអ្នកស្រុកគោះធុងទឹក គោះផ្លែចប ក៏បាត់ ស្ងាត់ទៅវិញ បន្សល់នូវសភាពស្ងាត់ជ្រងំដល់ជំរំសាជាថ្មី....

.........................

ថ្ងៃរះហើយ...

កូនមាន់ភ្ញាក់ឡើងក្រឡេកមើលទៅមនុស្សដែលរត់ចូលជ្រកក្នុង ខ្ទមរបស់នាងយប់មិញ ឃើញគេជាយុវជនជំទង់មួយរូប អាយុ ប្រមាណ ១៨ឆ្នាំ ។

- ហេតុអ្វីក៏អានាងឯងចាំបាច់ប្តូរជីវិត រត់កាត់ព្រៃចូលមកជំរំនេះ អោយគ្រោះថ្នាក់ឈឺខ្លួនធ្វើអី ? ម៉េចក៏មិនឡើងជិះរថយន្តអង្គការ សង្គ្រោះជនភៀសខ្លួនអញ្ចឹង ?

មីងផាសួរទៅក្មេងប្រុសនោះ ។

- គឺ... ពេលខ្ញុំមកដល់ជំរុំគោកធ្លុង ពួអ្នកស្រុកគេប្រាប់ថារថយន្ត ទាំងនោះ មកទទួលដឹកជនភៀសខ្លួន តែវេលាណាមានការបាញ់ ប្រហារគ្នានៅតាមទល់ដែនទេ ពុំនោះសោតគេមិនចូលមកឡើយ

អញ្ចឹងហើយបានជាខ្ញុំបបួលគ្នីគ្នាបួនប្រាំនាក់ប្រថុយរត់ចូលមកដីថៃ ធ្លាយដល់ជំរំខៅអ៊ីដាងនេះដោយខ្លួនឯង...

- ហ៊ឺ! អានាងអើយ! ឯងសំណាងហើយដែលមិនត្រូវទាហានថៃ បាញ់ស្លាប់ ពេលឯងរត់តាមព្រៃចូលដីគេ ។ ហើយចុះគ្នីគ្នារបស់ ឯងនោះ ?

- គឺមានមានប្រសាសន៍ត្រូវហើយ មិត្តរបស់ខ្ញុំពីរនាក់ត្រូវទាហាន ថៃបាញ់សម្លាប់នៅជាយព្រៃមុនមកដល់បរិវេណជំរំនេះ ។ អ្នករួម ដំណើរជាមួយខ្ញុំម្នាក់ទៀត បានមកដល់ជំរំហើយ តែត្រូវបែកគ្នា ពេលអ្នកស្រុកច្រឡំថា ពួកយើងជាចោរចេញលួចពេលយប់ ។

- អឺ... ពេលនេះ ឯងឈប់ភ័យទៀតទៅ នៅកន្លែងនេះឯងបាន សុខហើយ ។ នេះមីនាងខាងនេះ ធ្វើការនៅក្រសួងអង្គការយូអិន ចាំសុំគេអោយនាំឯងទៅចុះឈ្មោះបើកអាហារនិងគេ ។

- បាទ មីង!

ក្មេងនោះក៏បែរមករកកូនមាន់ហើយញញឹមដាក់នាង ស្រាប់តែ មីងផាពោលកាត់ថា ៖
- ហើយឯងឈ្មោះអីដែរ ?
- បាទ! ខ្ញុំឈ្មោះធី ។
- ហើយឯងមានបងប្អូនរត់មកនៅជំរំនេះឬអី បានជារត់ចូលមក ?
- បាទ! អត់មានទេ មីង តែមិត្តរបស់ខ្ញុំពីរនាក់ដែលត្រូវទាហាន ថៃបាញ់ស្លាប់នៅជាយព្រៃនោះ មានម្តាយនិងប្អូននៅក្នុងជំរំនេះ ។ ឮថា ឪពុករបស់គេនៅបរទេស ។
- ហ៊ឺ! គួរអាណិតដល់ហើយ ដែលគេមានគ្រោះថ្នាក់មុននឹងដល់ គោលដៅ... មិនដឹងជាម្តាយឪពុករបស់គេនៅទន្ទឹងមើលផ្លូវកូន របស់គាត់យ៉ាងណាទេ...

បន្តិចមក កូនមាន់ក៏នាំនាយធីដើរសំដៅការិយាល័យយូអិន ។ តាមដងផ្លូវ អ្នកទាំងពីរជជែកគ្នា ៖
- ប្អូនកុំភ័យអី! បងក៏ជាមនុស្សទោល គ្មានសាច់ញាតិដូចគ្នាដែរ បើប្អូនមានការលំបាកអ្វី ប្អូនអាចពិគ្រោះជាមួយបងបាន ។ យើង រាប់គ្នាជាបងប្អូនចុះណា៎
- បាទបង!

.......................

នៅក្នុងការិយាល័យយូអិនប្រចាំជំរំ...
- គេជាក្មេងក្រោមអាយុ ត្រូវបញ្ជូនទៅរស់ក្នុងមណ្ឌលកុមារកំព្រា តាមសង្កាត់និមួយៗ ។

បុរសម្នាក់ដែលជាបុគ្គលិកយូអិន ក៏ណែនាំអោយកូនមាន់នាំខ្លួន នាយធីទៅកន្លែងដែលត្រូវស្នាក់នៅ ។ ឃើញក្មេងប្រុសនោះមាន ទឹកមុខស្ងួតស្ងប់ បុគ្គលិកនោះក៏និយាយកម្លាចិត្តអោយយុវជនធូរ ស្រាលអារម្មណ៍ ៖
- ក្មួយកុំភ័យអី! នៅក្នុងមណ្ឌលកុមារកំព្រានោះ ឯងច្បាស់ជានឹង មានសុវត្ថិភាពមិនខាន ហើយអង្គការមនុស្សធម៌និងផ្តត់ផ្គង់របូត ឯងតាមរកក្រុមគ្រួសារសាច់ញាតិឃើញវិញ ។ ទីនេះ ជាតំបន់ មនុស្សធម៌កាន់កាប់ គឺហោចណាស់ក៏មានសន្តិសុខជាងកន្លែងណា ទាំងអស់នៅក្នុងដីខ្មែរ ថ្វីបើឯងមិនអាចដើរចេញពីរង្វង់បរិវេណដី ជំរំនេះបានក៏ដោយ ។

នាយធីញញឹមឡើងវិញ កាលបើបានឮសំដីរបស់បុគ្គលិកជាតិ បរទេសមួយរូបនោះ ។ គេចេះនិយាយខ្មែរយ៉ាងស្ទាត់ជំនាញ ធ្វើឲ្យ នាយធីនឹកស្ញើចតែក្នុងចិត្ត ។ បន្ទាប់មក កូនមាន់ក៏នាំខ្លួននាយធី

CHANBOKEO . COM

ទៅស្នាក់នៅមណ្ឌលកុមារកំព្រាមួយក្នុងជំរំ ។

នៅទីនោះ នាយធីឃើញក្មេងៗជាច្រើន មុខមាត់ប្លែកៗ សុទ្ធតែជាក្មេងវង្វេងព្រាត់ម្តាយឪពុកសាច់ញាតិរបស់ខ្លួន តាំងពីទារក តូចៗរហូតដល់ក្មេងជំទង់អាយុ ១៦-១៧ឆ្នាំ ហើយមានអ្នកធ្វើការដែលជាជនភៀសខ្លួនដូចគ្នាមកស្ម័គ្រចិត្តជួយមើលការខុសត្រូវទាំង ឡាយក្នុងមណ្ឌល ។ កូនមាន់ក៏ប្រញាប់នាំនាយធីដើរចូលទៅក្នុង ការិយាល័យដើម្បីចុះឈ្មោះ ។

រំពេចនោះ នាយធីប្រទះឃើញនារីម្នាក់ដើរចូលមកដល់ទីនោះ ដែរ ។ នាយភ្ញាក់ព្រើតស្រែកហៅ ៖

- បងធា!

នារីនោះភ្ញាក់ក្រញាង ងាកមករកនាយ ហើយក៏លាន់មាត់ថា ៖

- ធី ?

- បាទ គឺខ្ញុំ!

ស្រាប់តែអ្នកទាំងពីរហក់រឹង ស្រវាអោបគ្នាទ្រហោរយំគគ្រូក តែម្តង ធ្វើអោយកូនមាន់និងអ្នកទាំងឡាយនៅទីនេះ ភ្ញាក់ផ្អើល ដោយសេចក្តីត្រេកអររំភើបជំនួសអ្នកទាំងពីរ ។

- បងសប្បាយចិត្តណាស់ដែលបានជួបប្អូនវិញ!

- ខ្ញុំក៏ដូច្នោះដែរបង!...

បន្តិចមក អ្នកទាំងពីរក៏ជូតទឹកភ្នែករៀងខ្លួន ។

- ហើយប្អូនមានដឹងដំណឹងអ្វីពីប៉ាម៉ាក់យើងទេ ធី ?

- អត់សោះតែម្តងហើយបង (ធីគ្រវីក្បាល)

- ហ៊ឹ! ល្អើយចុះ ហោចណាស់ យើងនៅសល់គ្នាពីរនាក់ដែរ ។ ហើយចុះមិត្តបងខាងណោះជាអ្នកណា ?

នាងធាស្រដីសួរប្អូនដោយចោលភ្នែកទៅរកកូនមាន់ ។ នាយធី ក៏ឆ្លើយវិញថា ៖

- គឺ ខ្ញុំត្រូវពួកទាហានថៃដេញបាញ់ ពេលរត់កាត់ព្រៃចូលមកក្នុង ជំរំនេះយប់មិញ ទទួលបានបងស្រីនិងក្រុមញាតិគាត់សង្គ្រោះ ទើប លាក់ខ្លួនមានសុវត្ថិភាព ផុតគ្រោះថ្នាក់ ។ ហើយព្រឹកនេះ គាត់បាន នាំទៅចុះឈ្មោះនៅយូអិនហើយគេក៏បញ្ជូនខ្ញុំមកទីនេះតែម្តងទៅ...

CHANBOKEO.COM

- អូហ៍ អីចឹងទេ ? បងយល់ហើយ ។

  នាងធាក៏ងាកបែរមករកកូនមាន់លើកដៃសំពះ ៖

- ខ្ញុំអរគុណបងស្រីណាស់ដែលជួយសង្គ្រោះជីវិតប្អូនប្រុសខ្ញុំ ។ ខ្ញុំមិនភ្លេចគុណបំណាច់របស់បងនិងក្រុមគ្រួសាទេ ។

  កូនមាន់ញញឹមហើយគ្រវីក្បាល ៖

- មិនអីទេ ប្អូន! ការពិត ខ្ញុំមិនបានធ្វើអ្វីផង ពេលគេមកចូលសុំ ជ្រក ក៏អាណិតអោយជ្រកទៅ ព្រោះខ្លាចទាហានថៃចាប់បានយក ទៅចងវាយធ្វើបាប ដូចគេធ្លាប់ធ្វើលើជនភៀសខ្លួនខ្មែរយើងខ្លះៗ កន្លងមក ។ ខ្លះទទួលការធ្វើបាបរហូតដល់អស់ជីវិតក៏មាន ។ រីឯ ក្រុមគ្រួសារដែលស្នាក់នៅជុំគ្នាជាមួយខ្ញុំនោះ មិនមែនជាសាច់ញាតិ របស់ខ្ញុំទេ តែជាគ្រួសារខ្មែរភៀសខ្លួនទីងណាត់ទីងណោងដូចពួក យើងអញ្ចឹងដែរ ហើយយើងក៏រាប់អានគ្នាជាបងប្អូន ។

  នាងធាឮហើយងក់ក្បាល ៖

- ចាស! អញ្ចឹង ប្អូនសូមផ្តាំផ្ញើតាមបងស្រីទៅជំរាបពួកគាត់ផង ថាខ្ញុំអរគុណណាស់ដែលជួយយកអាសារប្អូនធីនៅក្នុងគ្រាអាសន្ន ។

- មិនមានគុណស្រ័យអ្វីទេ យើងជាខ្មែរដូចគ្នា មានទុក្ខមានលំបាក យើងមិនគួរមើលបំណាំទេ ។

  រំពេចនោះ នាយធីសួរទៅបងស្រីខ្លួនថា ៖

- ហើយចុះបងមកទីនេះធ្វើអ្វីដែរ ?

  នាងធាក៏ឆ្លើយវិញថា ៖

- គឺបងបានមកស្ម័គ្រធ្វើការដោយឥតកម្រៃ នៅមណ្ឌលកុមារកំព្រា នេះ ។ ម្យ៉ាងមកពីបងរើសបានក្មេងកំព្រាមួយរូប កាលពីនៅទួល ដែនហើយបានយកគេមកផ្ញើនៅទីនេះ ទើបគិតថា បើបងធ្វើការទី នេះ បងអាចនៅជិតជួយមើលគេបានល្អផង ។

- ហើយបងធ្វើការនេះ បានទទួលប្រាក់កម្រៃដែរទេ ?

- អត់ទេ! បងជាបុគ្គលិកឥតកម្រៃ

- អញ្ចឹង ម៉េចបងមិនធ្វើការអ្វីដែលបានកម្រៃវិញ គ្រាន់នឹងបាន សម្រាលជីវភាពប្រចាំថ្ងៃផង ?

  នាងធាញញឹមហើយងើបមុខចោលភ្នែកទៅកូនមាន់ រួចហើយ ក៏ឆ្លើយវិញថា ៖

- បុគ្គលិកដែលធ្វើការក្នុងជំរំបំរើកិច្ចការជនភៀសខ្លួនសុទ្ធសឹងតែ ជាបុគ្គលិកការងារឥតកម្រៃគ្រប់គ្នា ។ គេធ្វើការនេះ ដើម្បីបម្រើ

CHANBOKEO.COM

ប្រយោជន៍មនុស្សធម៌ទាំងអស់ ។ ម្យ៉ាងទៀត ថ្វីបើការងារនេះអាច ដូរបានត្រឹមតែបាយមួយឆ្នែត
ដែលអង្គការមនុស្សធម៌ចែកអោយក៏ ដោយ
ក៏គ្រប់គ្នាអាចមានឱកាសធ្វើអំពើល្អទៅលើមនុស្សដែលខ្វះ ខាត ឬដែលមានជីវិតផិតផើយ ។
មិនតែប៉ុណ្ណោះ យើងបានហ្វឹក ហ្វឺនការងារនិងការពិសោធន៍ ផ្នែកបំរើកិច្ចការមនុស្សធម៌ មិនទុក
ខ្លួនអោយទំនេរឥតប្រយោជន៍ ដើម្បីរង់ចាំតែអាហារគេដឹកយកមក
ចែកអោយបរិភោគរាល់អាទិត្យនោះទេ ។

- មានន័យថា គេបំរើមនុស្សអ្នកខ្វះខាត ដោយទឹកចិត្តមនុស្សធម៌ មែនទេ បងធា ?
- ត្រូវហើយប្អូនធី ។ នៅវេលានេះ ក៏ជាវេលាដែលពពួកអន្តរជាតិ អាចដឹងបានថា
នរណាជាមនុស្សឧស្សាហ៍ មិនបំបង់បាយ នរណា មានវិជ្ជា មានការចេះដឹង
និងអ្នកមានសម្បទាសំរាប់ស្វែងរកជោគ ជ័យនៅនាអនាគត ។
- មានន័យយ៉ាងម៉េចទៅបង ?
- មានន័យថា មិនចាំតែមានកម្រៃទើបយើងធ្វើការនោះទេ ។ ការ ងារអ្វីក៏មានតម្លៃទាំងអស់
ជាពិសេសការងារមនុស្សធម៌ ។ ថ្វីបើ
យើងមិនបានទទួលកម្រៃជាប្រាក់បំប៉នសេចក្តីត្រូវការបស់ខ្លួន តែ
យើងបានបំប៉នកង្វះខាតដល់ជនដែលកំពុងទុក្ខវេទនា ។ ហើយគេ
ក៏នឹងឃើញគុណសម្បត្តិដ៏ល្អទាំងនេះ ។
- ឃើញហើយ មានប្រយោជន៍អ្វីទៅ ? បានត្រឹមតែធ្វើការហត់អត់ ប្រយោជន៍ហ្នឹង!
- មិនមែនទេអូន! ការពិត ចំពោះជនភៀសខ្លួនដែលចង់បាន
ឱកាសអាចចេញទៅរស់នៅជ្រកកោនក្នុងប្រទេសទីបីបាន ទាល់តែ
គេមានសាច់ញាតិធានាពីខាងក្រៅមក ។ តែចំណែកអ្នកដែលគ្មាន សាច់ញាតិវិញ
គឺគ្មានស្ពានដើរឆ្លងឡើយ ក្រៅពីនាំគ្នាខំប្រឹងប្រែង ធ្វើការបង្ហាញនូវប្រាជ្ញា ទេពកោសល្យ
ទឹកចិត្តតស៊ូព្យាយាម ទឹក ចិត្តមនុស្សធម៌និងសីលធម៌ ជាពិសេសគឺ បង្ហាញនូវសម្បទាផ្ទាល់
របស់ខ្លួនយើង... ក្រែងលោគេសំគាល់ឃើញកម្លាំងសមត្ថភាពផ្នែក ការងាររបស់យើងហើយ
គេនឹងផ្តល់ឱកាសអោយយើងបានទៅរស់ នៅឯប្រទេសទីបី ដើម្បីសេរីភាព សន្តិសុខ
ហើយបានបន្តការ រៀនសូត្រខ្ពង់ខ្ពស់តទៅមុខទៀតផង ។
- ហើយចុះបងមានសង្ឃឹមទេ ?

នាងធាសើចខឹកៗ ហើយឆ្លើយតបថា ៖

- ប្អូនមានចាំបានទេនូវពាក្យស្លោកខ្មែរ ដែលថែងថា "រពីសដៃផ្ទៃ ឆ្អែត" និង "អ្នកជួយខ្លួនអ្នកទើបទេវតាជួយអ្នក" ដូច្នេះ យើងខំ តែប្រឹងធ្វើការ និងប្រព្រឹត្តអំពើល្អទៅ ថ្ងៃណាមួយជីវិតយើងនឹង បានភ្លឺស្វាងមិនខានទេ ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាយ៉ាងស្រស់បំព្រងឡើង ។ កូនមាន់ នៅអង្គុយស្មៀមក្បែរនោះយូរហើយ ក៏ពោលឡើងថា ៖

- ប្អូនស្រីមានប្រាជ្ញវៀងវៃ ហើយជាមនុស្សមានសន្តានចិត្តប្រពៃ គួរអោយសរសើរណាស់ ។ បងសូមជួយត្រេកអរផងដែលប្អូនទាំង ពីរបានជួបគ្នាវិញ ។

- ចាំសអរគុណបង!

- អញ្ជឹង បងគិតលាប្អូនទាំងពីរត្រលប់ទៅធ្វើការវិញហើយណាំ

- ចាំស!

- បាទ!

នាយធីនិងបងស្រីឆ្លើយឡើងព្រមគ្នា ។ លុះកូនមាន់ឈានបោះ ជំហានចេញក្រៅមិនទាន់បានប៉ុន្មានជំហានផង ស្រាប់តែនាងធា ស្រែកសួរពីក្រោយមកថា ៖

- អូហ៍ ឈប់សិនបងស្រី! ខ្ញុំមិនទាន់បានស្គាល់ឈ្មោះបងស្រីទេ តើបងឈ្មោះអីដែរ?

មាណវីយើងទុចដឹក់ បែរក្រោយហើយញញឹមដាក់អ្នកទាំងពីរ រួចក៏ឆ្លើយវិញថា ៖

- ឈ្មោះបងអាក្រក់ស្តាប់ណាស់! ប្អូនកុំចង់ដឹងអី!

នាងធាសើចកខឹកហើយស្រដីមកវិញថា ៖

- ឈ្មោះមិនពិរោះ ក៏មិនអីដែរណាំបង អោយតែបងមានសន្តាន ចិត្តល្អ នោះគ្រប់គ្រាន់ហើយ ហើយនេះ បងមិនប្រាប់ប្អូនៗទេ ថា បងឈ្មោះអី គ្រាន់នឹងយើងបានស្គាល់គ្នាជិតដិតផង ។

មាណវីសើចក្រហាញតបវិញ ៖

- មនុស្សសំដីពិរោះដូចប្អូនស្រីឯងនេះ នរណាទៅដាច់ចិត្តថាមិន ប្រាប់នោះ... គឺ.. បងមានឈ្មោះថា កូនមាន់ ។

ភ្លាមនោះ ស្រាប់តែនាងធាបើកភ្នែកមូលក្រឡង់ឡើង ហើយ លាន់មាត់ថា ៖

- បងឈ្មោះកូនមាន់? អញ្ជឹងបងជាប្រពន្ធរបស់មិត្តបងម្នាក់នោះ ឈ្មោះជ្រូកលីវមែនទេ?

កូនមាន់ភ្ញាក់ក្រញាង ៖

- ប្អូននិយាយថាម៉េច? ប្អូនស្គាល់ជ្រូកលីវដែរហ៍?

- គឺ បងប្រុសឈ្មោះជ្រូកលីវ បានផ្តាំខ្ញុំអោយជួយរកប្រពន្ធគាត់

CHANBOKEO.COM

ផង ។ គាត់ប្រាប់ថា ប្រពន្ធរបស់គាត់ឈ្មោះកូនមាន់ក្រញាស ។

ភ្លាមនោះ ធិតាយើងមានអារម្មណ៍ថា បេះដូងរបស់នាងលោត កញ្ជ្រោលយ៉ាងខ្លាំងស្ទើរធ្លាយទ្រូងមកក្រៅ ។ នាងស្ទុះហក់ទៅជិត នាងឆាសួរយ៉ាងរន្ថើនវិញថា ៖

- ហើយ ប្អូនស្រីបានជួបគាត់នៅឯណា ? ពីអង្កាល់ ?

- គឺ ខ្ញុំជួបនៅទល់ដែន មុននឹងឡើងរថយន្តមនុស្សធម៌មកជំរំ ខៅអ៊ីដាង កាលពីជាងមួយខែមុននេះ ។ គាត់ផ្តាំថា គាត់រស់នៅ សុខសប្បាយជាទេ ហើយគាត់នឹងរកមធ្យោបាយមកតាមរកបងស្រី នៅជំរំក្នុងដីថៃ ព្រោះអីពេលនោះ គាត់អាល័យនៅតាមរកមិត្ត របស់គាត់ម្នាក់ដែលបាត់ខ្លួន ឈ្មោះខេង ។

កូនមាន់ឮសំដីនេះភ្លាម ក៏រងាឡើងរណ្តំចង្កា ដោយការព្រួយ បារម្ភដល់ជ្រូកលីវឥតឧបមា ។ ពេលនោះ ធិតានិយាយអ្វីក៏លែង ចេញដែរ ក្រៅពីឈរទ្រឹងបណ្តោយអោយទឹកភ្នែកស្រក់ចុះមក ជំនួសសំដីទាំងឡាយ ដែលមាននៅក្នុងចិត្ត ។

មួយស្របក់ក្រោយមក មាណវីក៏យកដៃផ្ជិតទឹកភ្នែក ហើយក៏ បែរញញឹម ដាក់នាងឆា រួចស្រដីថា ៖

- អរគុណប្អូនស្រីណាស់ ដែលផ្តល់ដំណឹងអោយបងដឹង ។ បងក៏ កំពុងរង់ចាំដំណឹងពីគាត់រាល់ថ្ងៃដូចគ្នា ។

នាងឆាដើរមកជិត ចាប់ដៃកូនមាន់ក្តាប់យ៉ាងណែន ៖

- ទប់ស្មារតីណាបង! ខ្ញុំសង្ឃឹមថា គាត់សុខសប្បាយ ហើយនឹង មានឱកាសបានមកជួបបងនៅទីនេះឆាប់ៗ!

កូនមាន់ងក់ក្បាល ៖

- អរគុណដែលប្អូនជួយលើកកម្លាំងចិត្តបង! បងទៅធ្វើការវិញ សិនហើយ ។ ថ្ងៃក្រោយយើងជួបគ្នាទៀត ។

- ចាស៎បង!

កូនមាន់ក៏ដើរត្រឡប់មកធ្វើការវិញទាំងដួងចិត្តច្របូកច្របល់ ។ តាមផ្លូវ នាងនឹកគិតពីជ្រូកលីវមិនអស់មិនហើយ ៖

- ជាងមួយខែហើយ ដែលខ្ញុំបែកពីជ្រូកលីវ... តើអ្នកសុខទុក្ខយ៉ាង ណាដែរហើយ ? នៅរស់ ឬក៏.... ? ហ៊ឺ... ខ្ញុំមិនចង់គិតផ្តេសផ្តាស ទេ ប៉ុន្តែកាលបើបាត់ដំណឹងនាយយូរពេក

ចិត្តខ្ញុំអន្ទះសាតក្កហាល ណាស់ ។ តើកាលណាយើងជួបគ្នាវិញ ? កាលណា ? នេ៎ះ នាយខេងបានមកដល់ជំរំខៅអ៊ីដាងតាំងពីយូរហើយ ហើយម្ដេចក៏បាត់ រូបជ្រូកលីវដូច្នោះ ? ហើយពេលខ្ញុំបានជួបនាយខេង ម្ដេចក៏គេមិន ដែលនឹកនានិយាយអំពីជ្រូកលីវសោះ ។ តើមានរឿងហេតុអ្វីទៅ ?

oooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី១៥
# វាសនាពីព្រេង

ថ្ងៃដដែល...

នៅក្នុងការិយាល័យយូអិន...

- កំពុងរើឯកសារ រកអ្វីហ្នឹង កូនមាន់ ?

បុគ្គលិកបរទេសម្នាក់ចូលមកដល់និយាយអង់គ្លេសសួរកូនមាន់ ដែលកំពុងរើសំណៅអាន ។ ធិតាងើបមុខឡើង ស្រដីថា ៖

- ខ្ញុំមានមិត្តម្នាក់ឈ្មោះខេង រស់នៅជំរំនេះ ។ ខ្ញុំចង់រកលេខខ្ទង់ និងលេខសង្កាត់ដែលគេរស់នៅ ព្រោះខ្ញុំមានការ ចង់សាកសួរ ដំណឹងអំពីសាច់ញាតិរបស់ខ្ញុំម្នាក់ ។

- ហើយនាងមានស្គាល់នាមត្រកូលគេទេ ?

កូនមាន់គ្រវីក្បាល ៖

- អត់ស្គាល់ទេ ។

- អញ្ចឹង រកយ៉ាងណាឃើញទៅ ?

- រកឈ្មោះខេងដែលអាយុស្រករៗខ្ញុំ ភេទប្រុស... ខ្ញុំជឿថាមិន មានមនុស្សច្រើននាក់ទេ ដែលមានឈ្មោះខេង ភេទប្រុសអាយុ ស្រករគ្នាហ្នឹងនោះ ថ្វីបើនាមត្រកូលខុសគ្នាក៏ដោយ ។

- រួចនាងឃើញឈ្មោះខ្លះហើយឬនៅ ?

- បានពីរបីនាក់ហើយ តែខ្ញុំនឹងខំរកតទៅទៀត

- អញ្ចឹងខ្ញុំឈប់រំខាននាងហើយ សង្ឃឹមថា នាងអាចរកឃើញបង ប្អូនឆាប់ៗ ។

CHANBOKEO.COM

- ចាស អរគុណ!

បុគ្គលិកបរទេសនោះក៏ដើរចេញទៅ ទុកអោយកូនមានកកាយបញ្ជីឈ្មោះជនភៀសខ្លួនក្នុងជំរំតែម្នាក់ឯង ដើម្បីរកទីស្នាក់របស់ នាយខេង ។

........................

នៅមន្ទីរព្យាបាលអ្នកជំងឺ...

- មីងសឿន! ខ្ញុំសុំខ្ចីកង់មីងម៉ាភ្លែតបានទេ?
- ហើយ កូនមាន់ឯងយកវាជិះទៅណា?
- ទៅតាមរកមិត្តភក្តិម្នាក់នៅក្នុងជំរំ
- អ្នកណាគេ?
- គេឈ្មោះខេង
- អូហ៍ គឺអាអន្ទិតដែលមកសាកសួររកឯងនៅទីនេះ ពីថ្ងៃមុននោះ មែនទេ?
- ចាស មែនហើយ មីង!
- អឺ អញ្ចឹងល្អហើយ! ព្រឹកមិញ គេមករកឯងទីនេះ ហើយប្រាប់ មីងថា គេបានទៅរកកូនមាន់នៅការិល័យយូអិន តែមិនជួប ។
- អូហ៍ អញ្ចឹងគេមករកខ្ញុំទីនេះ មានការអ្វីដែរ?
- គេប្រាប់ថា គេទៅរកឯងនៅកន្លែងធ្វើការតែមិនបានជួប ហើយ គេក៏មករកមីង យកក្រដាសស្នាមមួយសំណៅមកផ្ញើទុកនៅនឹងមីង នេះផង ដើម្បីអោយឯង ពេលណាឯងមកលេងមីងទីនេះ ។
- ក្រដាសស្នាម.. ក្រដាសស្នាមអ្វីទៅមីង? (កូនមាន់ជ្រួញចិញ្ចើម សួរមីងសឿនទាំងងឿងឆ្ងល់)
- មីងមិនដឹងទេ គ្រាន់តែទទួលក្បាលសំណៅហើយក៏យកទៅទុក ទៅ មិនបានពិនិត្យផង ព្រោះព្រឹកមិញមានអ្នកជំងឺច្រើនពេក មីង រវល់ជាប់ដៃ ទើបមិនបានសួរដេញដោលដឹងរឿង ។ នែ៎! ចាំមីង នៅហ្នឹងសិនហើយ មីងទៅយកក្រដាសមកអោយឥលូវហ្នឹង!

មានប្រសាសន៍ចប់ មីងសឿនដើរតាំងៗយ៉ាងលឿនទៅក្នុង រោងព្យាបាលមួយស្របក់ក៏ត្រឡប់មកវិញ ដោយមានកាន់មកជា មួយនូវសំណៅឯកសារមួយបាច់ យកមកហុចអោយកូនមាន់ ៖

- នេះនែ៎ហ៍! មានទាំងកូនសំបុត្រតូចមួយច្បាប់ភ្ជាប់មកជាមួយ ផង! ប្រហែលជាគេមានការសំខាន់អ្វីចង់ប្រាប់ឯងហើយ ។

CHANBOKEO COM

- ចា៎ស! អរគុណមីង! អញ្ចឹង ខ្ញុំជំរាបលាមីងសិនហើយ!
- អឺ! អឺ! ទៅចុះ! សុខសប្បាយណា៎នាង!
- ចា៎ស!

.............................

នៅក្នុងខ្ទមស្បូវ ដែលកូនមាន់ជ្រកជាមួយជនភៀសខ្លួន១៨ នាក់ទៀត...

- កូនមាន់! ក្មួយកាន់ឯកសារស្អីហ្នឹង ? ហើយយកទៅណាដែរ ?

មីងផាសួរ ។

- ចា៎សមីង! គឺជាសំបុត្រដែលមិត្តខ្ញុំផ្ញើមកអោយ ។
- សង្ស័យថាជាក្រដាសធានាចេញទៅប្រទេសទីបីទេ ។
- យី! ម៉េចក៏មីងជ្រាប កាលបើខ្ញុំមិនទាន់មានឱកាសបើកយកមក អានផង ។
- មីងទាយលេងទៅណា ក្រែងវាមែន ។
- អញ្ចឹងមីងជួយអានខ្ញុំទេ ?
- យី! មីនាងឯងនេះ!មីងអានតែឈ្មោះខ្លួនឯងមិនដាច់ផង អោយអានអ្វីដាច់ទៅហ្ន៎ស ?
- អញ្ចឹង ចាំខ្ញុំអានចប់ ចាំខ្ញុំជំរាបមីង ។

ថាហើយ មាណវីដាក់ខ្លួនអង្គុយចុះ ផ្អែកជញ្ជាំង រួចហើយក៏ហែកស្រោមសំបុត្រតូចមួយច្បាប់ដែលមានភ្ជាប់មកជាមួយសំណៅឯកសារសរសេរជាភាសាអង់គ្លេសនោះ ។ បន្ទាប់មកនាងក៏ហូត យកកូនសំបុត្រមួយចេញមកអាន មានសេចក្ដីថា ៖

- កូនមាន់! ខ្ញុំដឹងថា នាងបានប្រកែកមិនទទួលសំណូមពររបស់ខ្ញុំ ថ្ងៃមុនម្ដងហើយ អំពីរឿងដែលខ្ញុំសុំនាងជាគូដណ្ដឹង ដើម្បីអោយបងប្រុសខ្ញុំធានាយើងទាំងពីរចេញទៅអាមេរិកជុំគ្នា ។ តែខ្ញុំនៅតែ នឹកខ្វល់មិនអស់មិនហើយ ។ ខ្ញុំក៏ដឹងដែរថា នាងកំពុងរង់ចាំការ វិលត្រឡប់របស់ជ្រូកលីវ តែខ្ញុំហាមចិត្តខ្លួនឯងថាមិនឲ្យគិតព្រួយ បារម្ភចំពោះនាង មិនបានសោះ ។ ខ្ញុំឃើញកូនមាន់រស់នៅតែលតោលម្នាក់ឯងយ៉ាងកំសត់ក្នុងជំរំ... រីឯការរង់ចាំចំពោះជ្រូកលីវក៏មិនដឹងថានឹងមានចម្លើយយ៉ាងណា រួចខ្ញុំមិនចង់ផ្ញើដំណើរចេញទៅដោយទុកនាងចោលអោយអណ្ដែងវង្វេងតែឯង ក្នុងវាសនាកម្មដែរ ចៃដន្យខ្ញុំក៏គ្មានសិទ្ធិបង្ខំចិត្តកូនមាន់ដូចគ្នា ។ ខ្ញុំក៏បានគេងគិតតែ ម្នាក់ឯងពិចារណាមិនអស់មិនហើយ

ទីបំផុត ខ្ញុំសំរេចចិត្តថែម ឈ្មោះម្នាក់ទៀតជាភេទស្រី ត្រូវជាប្រពន្ធរបស់ខ្ញុំ ដើម្បីអោយបងប្រុសខ្ញុំធានាទៅអាមេរិក ដោយប្រតិស្ឋនាមអោយថា ផល សុធា! នេះគ្រាន់តែជាឈ្មោះបណ្តោះអាសន្នតែប៉ុណ្ណោះ ព្រោះខ្ញុំមិនស្គាល់ឈ្មោះនិងនាមត្រកូលពិតរបស់កូនមាន់ ។ ខ្ញុំបានសរសេរជំរាបបង ប្រុសនៅអាមេរិកអោយប្តឹងទៅស្ថានទូតអាមេរិកហើយ ថាខ្ញុំនិង ភរិយារស់នៅជំរំខៅអ៊ីដាងនេះ រង់ចាំក្រសួងអន្តោប្រវេសន៍ហៅ សម្ភាសន៍ ។ រីឯឯកសារដែលភ្ជាប់មកនេះ មានប្រវត្តិខ្ញុំ និងក្រុម គ្រួសារ រូបថតរបស់បងប្រុស និងសំបុត្រដែលបងប្រុសខ្ញុំដាក់ ពាក្យធានា ។ កូនមាន់យកទៅពិនិត្យ ហើយគិតមើលចុះ! បើនាង សំរេចចិត្តយ៉ាងណាៗនោះ សូមផ្តល់ដំណឹងអោយខ្ញុំដឹងផង តាម រយៈអាស័យដ្ឋានដូចការលើខ្នងសំបុត្រនេះ ។ ខ្ញុំរង់ចាំចម្លើយពី នាងជានិច្ច មិនថាយូរប៉ុនណាទេ.... ខេង ។

កូនមាន់អានសំបុត្រផង រំជួលចិត្តផង អន្ទះសាក្នុងចិត្តមិនដឹង គិតយ៉ាងណា ។ មីងផាឃើញមិត្តនារីយើងអានសំបុត្រធ្វើទឹកមុខ ស្ងួតស្ងប់មិនរីករាយ ក៏លែងហ៊ានមាត់កសួរអ្វីតទៅទៀត ហើយក៏ នាំកូនរបស់គាត់គេចទៅដាំដំណាំបាត់ទៅ ។

ឯកូនមាន់វិញ នៅតែអង្គុយកាន់ក្រដាសធានា អានចុះ អាន ឡើងជាច្រើនសាហាក់ដូចមិនដាច់ស្រេច... ទីបំផុត នាងក៏បត់ ក្រដាសសំណៅនោះញាត់ក្នុងស្រោមវាវិញ ហើយក៏យកទៅដាក់ពី ក្រោមខ្នើយ ទំនងហាក់ដូចជាមិនចង់គិតនឹកនារំពីវាតទៅទៀត ។

.............................

ថ្ងៃស្អែកឡើង....

នៅសង្កាត់មួយ ក្នុងជំរំខៅអ៊ីដាង...

ស្ត្រីចំណាស់ម្នាក់កំពុងអង្គុយងូតទឹកក្បែរខ្ទមរបស់គាត់ ស្រាប់តែប្រទះឃើញនារីម្នាក់ដើរចូលមកដល់ ៖

- ជំរាបសួរមីង! ខ្ញុំឈ្មោះកូនមាន់ជាមិត្តរបស់ខេង ។
- អូហ៍ លើកដៃថ្វាយព្រះ នាង! ម៉ោះចូលអង្គុយលេងចាំមីងម៉ា ភ្លែតសិនទៅ មីងផ្លាស់ខោអាវសិន ។
- ចា៎ស មីង!

ស្ត្រីចំណាស់ក៏ប្រញាប់រៀបចំខ្លួនហើយ ក៏ដើរមកជួបកូនមាន់ ដែលអង្គុយចាំនៅក្នុងខ្ទម ។

- ខេងមិននៅផ្ទះទេហ៍ មីង ?

- គេនៅផ្ទះរាល់ថ្ងៃ តែព្រឹកនេះ គេថាយកសំបុត្រទៅដាក់ផ្ញើនៅ ប្រអប់សំបុត្រកាកបាទក្រហម ដើម្បីទាក់ទងទៅបងប្រុសគេនៅ អាមេរិក ។ បន្តិចទៀត ប្រហែលជាគេមកវិញហើយ ។ នាងមាន ការអ្វីសំខាន់ ចង់សួរវាឬ ?

- ចាស! គឺខ្ញុំចង់សាកសួរដំណឹងមួយពីគាត់ ។

- រឿងនាយជ្រូកលីវស្ទីគេនោះ មែនទេនាង ?

- ចាស មែនហើយមីង! ម៉េចក៏មីងជ្រាបរឿងនេះ ?

- ព្រោះមីងឃើញវាអន្ទះសា តាមរកពួកម៉ាកវាមួយនេះយូរហើយ តែមិនបានដំណឹងអ្វីទេ ហើយក៏មិនដឹងថាហេតុអ្វីវាអន្ទះសា បែប ហ្នឹងផង មើលឫកពាវាបារម្ភចំពោះជ្រូកលីវ មីងចេះតែភ័យ គិត ថាវាជាខ្មើយស្រឡាញ់ប្រុសដូចគ្នាហើយតើហ៎!

កូនមាន់ព្នដូច្នោះក៏ញញឹមឡើងបំរុងនឹងឆ្លើយទៅហើយ ស្រាប់តែមានសម្លេងមកឆ្លើយកាត់មុនយ៉ាងលឿនថា ៖

- ចេះតែថាហើយមីង! ខ្ញុំឯណាជាខ្មើយនោះ ?

ទាំងពីរនាក់ងាកក្រោយ ឃើញនាយខេងដើរចូលមកទាំងទឹក មុខញញឹម ព្រមទាំងនិយាយបន្តថា ៖

- ថ្ងៃនេះ ផ្ទះខ្ញុំមានរាសីណាស់ បានកូនមាន់មកលេងដល់ផ្ទះ ។

កូនមាន់ញញឹម រួចហើយតបថា ៖

- មកពីខ្ញុំមានការចង់សួរខេងហ្នឹងណា ។

- រឿងជ្រូកលីវហ្នឹងហ្ន៎ស ? គឺ... ខ្ញុំតាមស៊ើបដំណឹងពីគេតាំងពី យើងបែកគ្នាម្ល៉េះ រហូតមកទល់នឹងថ្ងៃនេះ ខ្ញុំមិនទាន់ព្នដំណឹងអ្វីពី គេនៅឡើយទេ ។ ខ្ញុំព្រួយបារម្ភណាស់ ហើយបន់ព្រះរាល់ថ្ងៃឲ្យគេ បានសុខសប្បាយ ។

កូនមាន់ងក់ក្បាល ៖

- ខ្ញុំក៏ដូចគ្នា... ខ្ញុំបន់ព្រះរាល់ថ្ងៃអោយគេជួបតែសេចក្តីសុខ...

បន្តិចមកនាយខេងក៏ចាក់ទឹកដាំមួយកែវហុចអោយកូនមាន់ ៖

- ណែ៎! ញ៉ាំទឹកសិនទៅ ហើយប្រាប់ខ្ញុំផង ថាបានទទួលក្រដាស ស្នាមពីមីងសឿន ។

នារីលូកដៃទទួលយកពែងទឹកឆ្អិនពីដៃនាយខេង រួចហើយ ឆ្លើយតបថា ៖

- គឺខ្ញុំបានទទួលឯកសារនោះពីមីងសឿនហើយ, អរគុណខេង ណាស់ ដែលមានសមានចិត្តយ៉ាងថ្លៃថ្លាចំពោះខ្ញុំ ។

CHANBOKEO.COM

- ហើយកូនមាន់សំរេចចិត្តយ៉ាងម៉េចដែរ ?
- ខ្ញុំអានមិនទាន់ចប់ផង អោយសម្រេចចិត្តយ៉ាងម៉េចទៅ ?
- ពុទ្ធោ! តែប៉ុន្មានសន្លឹកសោះ អានមិនចប់ដែរ!
- គឺខ្ជិលអានហ្នឹងណាំ!
- ឧស្សាហ៍ខ្លះទៅមិនបានទេហ៍ ?
- ឧស្សាហ៍ក៏បានដែរ តែឧស្សាហ៍រឿងផ្សេង
- រឿងអ្វីទៅ ?
- រឿងជ្រូកលីវ! គឺខ្ញុំចង់ដឹងថា ហេតុអ្វីអ្នកទាំងពីរត្រូវវង្វេងបែកផ្លូវគ្នាមិនដឹងដំណឹងយ៉ាងហ្នឹង ?

ខេងងើបមុខឡើងសម្លឹងមុខកូនមាន់ដោយក្រសែភ្នែកភ្លឺថ្លា៖

- កូនមាន់ដឹងស្រាប់ហើយតើហ៍ថាស្ថានការណ៍តាមជំរំទល់ដែនខ្មែរ វាក្រឡាប់ផ្កាប់ផ្ងារមិនទៀងទាត់យ៉ាងណាខ្លះនោះ ។ ការពិត ខ្ញុំបានបែកពីនាយជ្រូកលីវនៅថ្ងៃមួយនោះ ដែលខ្ញុំចេញទៅរកទិញតវ៉ាន់ រត់ពន្ធក្នុងដីថៃត្រូវទាហានថៃដេញបាញ់រះរិះតែនឹងស្លាប់ ហើយក៏ រត់វង្វេងក្នុងព្រៃធំឆ្លាយរហូតដល់ជំរំគោកឡុង រួចហើយក៏ប្រទះ ការបាញ់ប្រហារនៅជំរំមួយហ្នឹងទៀតរិះតែស្គាល់មច្ចុរាជម្តងៗទៅ ហើយ ។ សំណាងល្អ មានរថយន្តអង្គការចូលមកទម្លាក់អាហារឲ្យអ្នកស្រុក និងមានដឹកជនភៀសខ្លួនពីក្នុងព្រៃចូលជំរំក្នុងដីថៃ ។ ខ្ញុំក៏សម្រេចចិត្តរត់ឡើងរថយន្តមនុស្សធម៌ ដោយមិនបានវិលត្រឡប់ទៅរកនាយជ្រូកលីវឯណាងចាន់វិញ ។ រហូតមកទល់ពេលនេះ ខ្ញុំមិនដែលដឹងដំណឹងពីរូបគេបន្តិចណាទេ ។

កូនមាន់អង្គុយស្តាប់នាយខេងរ៉ាយរ៉ាប់រឿងរ៉ាវ ទាំងទឹកមុខ ស្រងូតស្រងាត់ ។ បន្តិចមក នាងយកដៃឈ្លីថ្ងាស ហើយស្រដីវិញ ថា ៖

- ខ្ញុំបន់ស្រន់អោយគេបានសុខសប្បាយជានិច្ច... ពេលដែលខ្ញុំមក ដល់កន្លែងដែលមានសុវត្ថិភាពខ្ញុំរិតតែនឹកអាណិតជ្រូកលីវឡើង... ចង់អោយគេបានទទួលសុខសុវត្ថិភាពដូចយើងដែរ ។

ខេងងក់ក្បាល ៖

- ខ្ញុំយល់ហើយ ។

CHANBOKEO.COM

កូនមាន់ឈ្ងោកមុខចុះមួយស្របក់ រកអ្វីនិយាយមិនឃើញក៏សុំ លានាយខេងត្រឡប់ទៅវិញ ។ ចំណែកខេងវិញ កាលបើឃើញនារី មានទឹកមុខស្រពោនក្រៀមក្រំ នាយក៏មិនហ៊ាននិយាយអ្វីទៀតដែរ ខ្លាចរំខានចិត្តនាង ។ ចំណែកមីងរបស់ខេង ដែលអង្គុយស្តាប់ការ សន្ទនាក្បែរនោះយូរហើយ ក៏មិនមានមាត់កាអ្វីដែរ ខ្លាចល្អក់ទឹកចិត្តកូនចៅ ។

..........................................

តាមផ្លូវត្រឡប់មកវិញ...

កូនមាន់ដើរឈ្ងោកមុខបណ្តើរ លួចបន់ព្រះក្នុងចិត្តបណ្តើរ តែ ម្នាក់ឯងកណ្តាលថ្ងៃត្រង់ ។ ការពិត ជំរំខៅអ៊ីដាងនេះធំទូលំទូលាយ មានជនភៀសខ្លួនខ្មែររស់នៅបណ្តោះអាសន្ន រាប់ម៉ឺននាក់ មិនដឹង ថានរណាជានរណា មកពីខាងណាទេ ។ ក្រឡេកទៅទីណាក៏ឃើញ សុទ្ធតែមនុស្សពព្យូនពពាក់ មានចាស់មានក្មេង ល្មមអាចដើរវង្វេង រកផ្ទះដែលខ្លួនជ្រកមិនឃើញ បើមិនពូកែចំណាំផ្លូវទេនោះ ។ ថ្ងៃ នេះជាថ្ងៃចែកអង្ករនិងគ្រឿងបរិភោគ ។ មនុស្សម្នាឈរកកកុញ តាមសង្កាត់និមួយៗ រង់ចាំរថយន្ត ដឹកអង្ករ ដឹកទឹកមកចែកចាយ សំរាប់បរិភោគប្រើប្រាស់ប្រចាំថ្ងៃ ។

រំពេចនោះ កូនមាន់ឮសម្លេងមនុស្សឈ្លោះគ្នា ។ នាងក៏ងើប មុខបែរមើល ឃើញមនុស្សប្រុសពីរនាក់ប្រកែកគ្នារួចហើយក៏តាំង យុំរកប្រដាល់វាយតប់ចាញ់ឈ្នះ ។ គ្រាន់តែក្រឡេកឃើញបុរស ទាំងពីរនាក់នោះ នាងចាប់ភ្លឹកភ្លាមថានាងស្គាល់គេទាំងពីរ ក៏ស្ទុះវែកហ្វូងមនុស្សចូលទៅជិតហើយស្រែកហៅ ៖

- មិត្តឆាល់ ! ឈ្លោះគ្នារឿងអីហ្នឹង ?

កាលបើបុរសនោះក្រលេកឃើញនាងភ្លាមក៏ធ្វើមុខភាំង បន្តិចក៏ លាន់មាត់ថា ៖

- កូនមាន់ ?

- ចា៎ស ! គឺខ្ញុំ ! ហើយមានរឿងអ្វីដែរហ្នឹង ?

- គឺអាមេក្រុមមួយនេះ វាចង់កេងប្រវញ្ច័បំបាត់ចំណែករបបរបស់ សមាជិកគ្រួសារខ្ញុំ ។

ស្រាប់តែបុរសម្នាក់ទៀតក៏ភ្ញាក់ក្រញាង ពេលប្រទះឃើញនារី យើង ។ ខណៈនោះ កូនមាន់ក៏ចាប់ភ្លឹកដែរថា បុរសនោះគឺជាអ្នក ដែលជួយសង្គ្រោះនាងនាគ្រាមួយ កាលនៅសេរីសោភ័ណ ប៉ុន្តែក៏ ជាមនុស្សដែលលួចចងជើងនាងជាមួយជ្រូកលីវ ពេលគេទាំងពីរ

CHANBOKEO.COM

គេឯលក់អស់កម្លាំង ហើយក៏លួចឥវ៉ាន់របស់អ្នកទាំងពីរ គេចខ្លួន បាត់រហូតមកដល់ពេលនេះតែម្តង ។ ក្រោយពីប្រមូលស្មារតីបាន វិញ បុរសនោះក៏ឆ្លើយថា ៖

- នែ៎! បើម្ចាស់ខ្លួនមិនមកបើករបបដោយផ្ទាល់ គឺអត់ ។
- ហើយឯងកិបទុកចំណែកគេធ្វើអី ? អាម្ចាស់វាកំពុងដេកឈឺ វាមកបើកអាហារមិនរួច ទើបយើងបើកជំនួសអោយវា ។
- ធ្វើម៉េចនឹងដឹងថា ឯងទុករបបហ្នឹងអោយវា ? ប្រយ័ត្នតែឯង បើកជំនួសវារួចហើយ ល្ងាចវាមកប្រាប់ថាវាមិនបានទទួល តើអញ មានអ្វីសងវាវិញ ហ្ន៎ស ?
- ចុះបើឯងកិបទុកឥវ៉ាន់វាហើយ តើធ្វើម៉េចនឹងដឹងថាឯងអោយវា ពេលវាជាមកបើកយឺតពេលវេលា ?
- ហើយឯងត្រូវជាអ្វីហ្នឹងវាទើបឯងមកឡូឡាជំនួសដែរ ?
- ជាមនុស្សដែលនៅផ្ទះខ្ទមជាមួយគ្នានោះអី ។
- មិនបាន! ម្ចាស់ខ្លួនមិនមកបើក គឺអត់!

ឃើញមេក្រុមនោះមានលក្ខណៈអុងអាត់ ហើយទំនងជាចង់កិបកេងរបបរបស់អ្នកជំងឺដែលមកបើកអង្ករមិនរួច កូនមាន់ក៏លើកដៃ វាធ្វើអន្តរាគមន៍ឡើង ដោយបង្ហាញនាមប័ត្រខ្លួនជាអ្នកធ្វើការនៅ យូអិន ។ ឃើញកាតនោះភ្លាម ពូនោះហាក់ដូចជារអាបន្តិច ព្រោះ គាត់ខ្លាចយូអិនបញ្ជូនមនុស្សអោយមកពិនិត្យស៊ើបការណ៍រឿងចែក របបអាហារអោយអ្នកស្រុក ណាមួយគាត់ធ្លាប់មានពិរុទ្ធជាមនុស្ស មានប្រវត្តិមិនល្អកាលពីមុនផង ។ បុរសនោះក៏ទម្លាក់ដៃ បិទមាត់ ឈប់និយាយហើយក៏ឈរស្ងៀម ។ កូនមាន់ក៏និយាយថា ៖

- ណ្ហើយចុះ! ខ្ញុំធ្វើជាសាក្សីអោយអ្នកទាំងពីរចុះ សូមពូមេក្រុម បើករបបអាហារអោយទៅមិត្តខាងនេះ រួចចាំខ្ញុំដើរតាមទៅកន្លែង របស់គេដើម្បីពិនិត្យថាតើគេយកទៅអោយម្ចាស់សាម៉ីខ្លួនដែរទេ ។ បើប្រសិនជាគេកិបកេងចំណែករបបទាំងនេះ ចាំខ្ញុំរាយការទៅ ការិយាល័យយូអិន ឬចៅសង្កាត់ដើម្បីចាត់ការដាក់ទោសគេ ។

អ្នកស្រុកទាំងអស់នោះយល់ឃើញថាជាយោបល់ល្អ គេក៏ទះដៃ យល់ស្រប ធ្វើអោយពូមេក្រុមនោះធ្វើមុខស្មឿក រួចហើយក៏លើក ចំណែករបបមួយនោះអោយទៅនាយឆាល់ទាំងមួម៉ៅ ។

CHANBOKEO.COM

.....................................

តាមផ្លូវទៅខ្ទមនាយឆាល់...

កូនមាន់ជួយយួរឥវ៉ាន់ ដែលជារបបរបស់មិត្តនាយឆាល់ផង ជជែកលេងជាមួយឆាល់បណ្ដើរផង ៖

- មិត្តឆាល់មកនៅជំរំនេះយូរហើយ មែនទេហ៍ ? (កូនមាន់សួរ)
- គឺប្រហែលជិតមួយខែដែរហើយ
- អូហ៍ មកក្រោយខ្ញុំតែប៉ុន្មានថ្ងៃទេតើហ៍ ។ ខ្ញុំមកដល់ទីនេះ បួន ប្រាំអាទិត្យហើយ ហើយក៏បានជួបមិត្តខេងផង ។
- ថាម៉េច ? ខេងវារស់នៅជំរំខៅអ៊ីដាងនេះដែរ ?
- មែនហើយ ! គេរស់នៅជាមួយគ្រួសារម្ដាយមីងរបស់គេ ។
- យី ! ខ្ញុំតាមស៊ើបដំណឹងវាយូរហើយ ហើយក៏តាមរកកូនមាន់ឯង ដូចគ្នាដែរ ។ តាមពិត យើងនៅជំរំជាមួយគ្នាសោះ បែរជាឃ្លាង មិនដែលប្រទះមុខគ្នាទៅវិញ ។
- មកពីជំរំធំពេក ហើយមនុស្សម្នាច្រើនខ្លាន់ខ្លាប់រាប់ម៉ឺននាក់យ៉ាង នេះ ពីបាកនឹងរកគ្នាណាស់ បើយើងមិនដឹងលេខផ្ទះ លេខក្រុម លេខសង្កាត់នោះ ។
- ថ្ងៃនេះ បើកុំតែមានរឿងតមាត់គ្នាឡូឡាលាន់ឮរំពង យើងទាំង ពីរក៏ប្រហែលជាមិនបានជួបគ្នាផងមិនដឹង ។

មិនទាន់និយាយចប់ផង ឆាល់ក៏នាំកូនមាន់មកដល់ផ្ទះល្វម ។ លុះចូលទៅដល់ក្នុងខ្ទម កូនមាន់ក៏ប្រទះនឹងបុរសម្នាក់ដេកទទូរ ក្រមាបិទភ្នែកស្ងៀមស្ងាត់ ។ ស្រាប់តែបេះដូងរបស់នាងរណ្ដំទិបៗ ក្អកក្អាក់ស្ទើរឆ្លាយដើមទ្រូងមកក្រៅ រួចហើយនាងក៏ឧទានថា ៖

- ជ្រូកលីវ ?

គ្រាន់តែឮសម្លេងនារីយើងហៅឈ្មោះភ្លាម បុរសក៏បើកភ្នែក ឡើងសម្លឹងមើលម្ចាស់សម្លេង ៖

- កូនមាន់ ? កូនមាន់ ?
- ចាស ! គឺខ្ញុំ....
- ពុទ្ធោ ! កូនមាន់ ! ខ្ញុំនឹកនាងណាស់ដឹងទេ ?

CHANBOKEO.COM

មាណពហក់ដើបពីកន្ទេលលឿនដូចព្រួញមកស្រវាឱបកូនមាន់ យ៉ាងណែនពេញរង្វង់ដៃ ធ្វើអោយនាយឆាល់ឈរធ្មឹងមាំងមួយ ស្របក់ រួចហើយក៏គេចខ្លួនចេញទៅក្រៅ ដើម្បីទុកឱកាសអោយ អ្នកទាំងពីរសន្ទនាគ្នា ។

កូនមាន់ស្រក់ទឹកភ្នែកច្រោក យំខ្សឹកខ្សួល ដោយក្តីត្រេកអរ រំភើបផង បារម្ភផងចំពោះសុខភាពរបស់នាយយើងផង ។ គេ ស្រវាឱបគ្នាយំយ៉ាងយូរ មិនអស់មិនហើយ ។ គេនឹករលឹកគ្នាខ្លាំង ឥតព្រំដែន នឹងរកពាក្យរ៉ាយរ៉ាប់ប្រាប់លែងបាន ក្រៅពីបណ្តោយឲ្យ ទឹកភ្នែកនិងសំនៀងបេះដូងចចារឆ្លើយឆ្លងជាជំនួស ។

..............................................

បន្តិចមក ជ្រូកលីវក៏យកដៃផ្ទិតទឹកភ្នែកអោយនារី ៖

- ណ្ហើយ! កូនមាន់ឈប់យំទៅ! យើងជួបគ្នាវិញហើយតើហ៏! យើងគួរតែសើចរីករាយ មិនមែនយំទេ ។

កូនមាន់ងក់ក្បាល តបថា ៖

- មែនហើយ! តែខ្ញុំអារម្មណ៍មិនបានសោះ ដឹងទេហ៏ ថាខ្ញុំនឹក ជ្រូកលីវ រកទីបំផុតគ្មានទេ ។

- ដូចតែគ្នាហ្នឹង! ខ្ញុំនឹកកូនមាន់ស្ទើរតែប្រេះទ្រូងស្លាប់ទៅហើយ ដឹងទេ?... មិនមានថ្ងៃណាមួយដែលខ្ញុំមិនគិតពីនាងទេ ។

កូនមាន់សម្លឹងមុខជ្រូកលីវ ៖

- ហើយចុះ ជ្រូកលីវមកនៅជំរំនេះពីអង្កាល់ ? ជិះឡានអង្គការ មនុស្សធម៌មកជំរំនេះ មែនទេ ?

ជ្រូកលីវគ្រវីក្បាល ៖

- មិនមែនទេ! គឺខ្ញុំរត់កាត់ព្រៃមកជាមួយគ្នីគ្នាបីបួននាក់ ខ្លះត្រូវ ទាហានថៃបាញ់ស្លាប់ ខ្លះទៀតរត់រួចចូលដល់ខៅអីដាង ក៏គេចខ្លួន បែកខ្ញែកគ្នាអស់ មិនដឹងនរណានៅឯណាទេ ពេលនេះ ។ ថៃដន្យ ខ្ញុំក៏បានជួបឆាល់នៅកន្លែងបើកទឹកប្រចាំសង្កាត់ ក៏សុំគេមកស្នាក់ ជាមួយតាំងពីពេលនោះមក ។

- ចំណែក... របួសរបស់ជ្រូកលីវនោះជាហើយឬនៅ ?

- ជាសំណាងល្អរបស់ខ្ញុំ របួសប៉ុន្មានដងហើយ តែមិនដែលប៉ះ កន្លែងសំខាន់អោយគ្រោះថ្នាក់ដល់ជីវិតទេ ។ ពេលនេះ ខ្ញុំបានធូរ ស្រាលវិញហើយ

CHANBOKEO.COM

គ្រាន់តែនៅរស់កម្លាំងល្ហិតល្ហៃ ណាមួយប្រហែល ជាខ្ញុំខូចចិត្តដេកនឹកកូនមាន់ពេកក៏មិនដឹង បានជាមិនមានកម្លាំង នឹងរកធ្វើអ្វីសោះ តាំងពីកូនមាន់បែកពីខ្ញុំទៅ ។

ជ្រូកលីវនិយាយផង ស្រវាដៃនារីផងមកក្តាប់យ៉ាងណែនផង ។

បន្ទាប់មក គេក៏ពោលបន្ថែមទៀតថា ៖

- ប៉ុន្តែពេលនេះ ព្រេងវាសនាបាននាំអោយខ្ញុំមកជួបកូនមាន់វិញ ហើយ ហើយដួងចិត្តខ្ញុំក៏រំភើបឥតឧបមា រកអ្វីថ្លែងអោយសមស្មើ មិនបានឡើយ ។ ចាប់ពីថ្ងៃនេះទៅ ខ្ញុំនឹងពុះពារតស៊ូ មិនបណ្តោយ អោយកូនមាន់បែកឃ្លាតពីខ្ញុំទៅឯណាទៀតឡើយ ។

- នៅជំរំនេះ យើងមានសុវត្ថិភាពច្រើនណាស់ ព្រោះយើងមាន អង្គការអន្តរជាតិមើលការខុសត្រូវ ។ យើងមិនបែកគ្នាទៀតទេណា៎ ជ្រូកលីវ ! ឈប់បារម្ភទៅ !

- ពិតប្រាកដណាស់ ! យើងមិនបែកគ្នាទៀតទេ !

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើង យ៉ាងស្រស់បំព្រង ជាលើក ដំបូង ដោយដួងចិត្តសោមនស្សរំភើបឥតព្រំដែន ។

*oooooooooooooooooo*

*ooooooo*

*o*

CHANBOKEO.COM

# វគ្គទី១៦
# រាសីអណ្ដែត

CHANBOKEO . COM

នៅខ្ទមសំណាក់របស់កូនមាន់....

- មីនាងអើយ! នាំអ្នកណាគេមកផ្ទះយើងហ្នឹង?
- មីងផាទាយទៅមើល ថាគេជានរណា?

មីងផាឈរអេះអុញមួយភ្លែត ក៏ឆ្លើយវិញថា៖

- បុរសនេះ ឈ្មោះជ្រូកលីវ មែនទេ?

កូនមាន់ភ្ញាក់ក្រញាង ពោលថា៖

- ម៉េចក៏មីងដឹង? នរណាគេប្រាប់?
- គឺទឹកមុខញញឹមរបស់ក្មួយឯងហ្នឹងណា ដែលនិយាយប្រាប់មីង!

កូនមាន់យកដៃស្ទាបមុខ៖

- ពុទ្ធោអើយ! ស្បែកមុខមួយនេះអន់ម្ល៉េះ មិនជួយលាក់គ្នាសោះ អោយមីងផាទាយអាថ៌កំបាំងដឹងអស់រលីង លៃងសប្បាយបាត់!
- អញ្ចឹង ឯងទៅឆូរចោល ដាក់ប្លាស្ទិកអ៊ុតជំនួសវិញទៅ

កូនមាន់ក៏សើចកខឹកឡើង។ ជ្រូកលីវ ក៏លើកដៃប្រណម្យ ឡើងសំពះមីងផា៖

- ជំរាបសួរមីង!

- អឺ! អឺ! មិនអីទេ! អាល័យតែឈរនិយាយហ្នឹងឯង មិននាំគ្នា អង្គុយទេ?
មើលទៅក្មួយប្រុសហ្ន៎ ដូចជាស្លេកស្លាំងណាស់ ។ ឯង ឈឺអីមែនទេ?

ជ្រូកលីវញញឹម ហើយដាក់ខ្លួនចុះលើកន្ទេលគេងរបស់កូនមាន់ រួចហើយឆ្លើយថា ៖

- គឺ... ឈឺជម្ងឺបេះដូង.. មីង!
- យី នៅក្មេងសោះ កើតរោគបេះដូងទៅហើយ?

កូនមាន់លើកដៃរា ៖

- គឺគាត់ចង់មានន័យថា រោគស្នេហាណ៎ាមីង!
- អូហ៎អញ្ចឹងទេ? មីងស្មានតែឯងមានជំងឺលើសឈាមតើហ៎!

បន្តិចមក មីងផាក៏ដើរចេញទៅ ទុកអោយអ្នកទាំងពីរសាសង គ្នា កុំអោយមានការរំខានចិត្ត ។

បន្តិចក្រោយមក...

- អូនរើខោអាវយកទៅណាហ្នឹង កូនមាន់?
- គឺចង់ទៅរកងូតទឹករៀបចំខ្លួន ដើម្បីធ្វើការវេនរសៀលនេះ ។
- ហើយចាំបាច់យកខោអាវទៅធ្វើអី?
- យកទុកផ្លាស់នោះអី!
- ផ្លាស់ធ្វើអី ក្នុងបន្ទប់ទឹកសែនមហាចង្អៀតហ្នឹង? ម៉េចមិនផ្លាស់ ពីក្នុងផ្ទះវិញ?
- ផ្លាស់ក្នុងផ្ទះយ៉ាងម៉េចបើមានមនុស្សប្រុសអង្គុយជ្រងោរអញ្ចឹង?
- អូនខ្មាស់បងហ្ន៎ស?
- ជាស្រីមិនអោយខ្មាសខ្លះទេហ៎?
- ខ្មាសធ្វើអី កាលបើបងធ្លាប់ឃើញរូបកាយរបស់អូន ឡើងសឹក ភ្លែករស់ទៅហើយហ្នឹង?

កូនមាន់ឮដូច្នោះ នឹកខ្មាញ់ក្នុងចិត្តណាស់ ក៏យកដៃច្រានស្មា
ជ្រូកលីវផ្តួលខ្លួននាយរឹងទៅលើខ្នើយ ហើយស្រដីថា ៖

- នែ៎! និយាយតែផ្តាស! មាត់ច្រើនមិនបានការ តិចឈប់និយាយ រកឥលូវហ្នឹង!

រួចហើយនាងក៏ចេញទៅងូតទឹកបាត់ទៅ ទុកអោយជ្រូកលីវ
សម្លឹងមើលតាមពីក្រោយញញឹមពព្រាយ បិទមាត់មិនជិត ។

................................

នៅការិយាល័យយូអិន...

CHANBOKEO.COM

កូនមាន់កំពុងឈ្ងោកកត់បញ្ជីកុមារកំព្រាដែលទើបចូលមកដល់ ថ្មី បំពេញជីវប្រវត្តិដើម្បីផ្សាយរកក្រុមគ្រួសាររបស់កុមាររងគ្រោះ ទាំងនោះ ស្រាប់តែបុរសម្នាក់ដើរចូលមក ។ កូនមាន់ងើបមុខឡើង ឃើញបុរសនោះ ក៏ឧទានឡើង៖

- លោកថម ?

- បាទ!

- លោកមករកខ្ញុំ មែនទេ ?

- មែនហើយ! គឺខ្ញុំចង់មកប្រាប់នាងថា ខ្ញុំត្រូវត្រឡប់ចេញទៅ អាមេរិកស្អែកនេះហើយ ។

- ចាស អរគុណដែលលោកមកប្រាប់ខ្ញុំ ។ សូមធ្វើដំណើរអោយ បានសុខសប្បាយ ។

- បាទ! តែខ្ញុំមានរឿងមួយចង់ប្រាប់នាង

- ជាដំណឹងល្អមែនទេ ?

- ត្រូវហើយ! គឺខ្ញុំចង់មកប្រាប់ថា ទូតអាមេរិកកំពុងបើកចំហទ្វារ ទទួលការដាក់ពាក្យសុំជ្រកកោន ពីជនភៀសខ្លួនខ្មែរ ដែលគ្មាន សាច់ញាតិនៅប្រទេសទីបី ។ គេនឹងទទួលយកច្រើនគ្រួសារអោយ ទៅជ្រកនៅបណ្តោះអាសន្ន ទំរាំស្រុកខ្មែរសាន្តត្រាណ ។ ពេលនេះ ជាឱកាសល្អហើយ ដែលនាងត្រូវសរសេរដាក់ពាក្យសុំជ្រកកោន ។ ខ្ញុំឃើញនាងមានចំណេះវិជ្ជា ហើយចូលចិត្តធ្វើការងារដោយមិន រើសអើង គឺសក្តិសមនឹងបានទៅរស់នៅទីនេះណាស់ ។

- រួចចុះខ្ញុំត្រូវដាក់ពាក្យយ៉ាងម៉េចខ្លះទៅ ? លោកមានគំរូពាក្យសុំ នោះដែរទេ ?

លោកថមគ្រវីក្បាល ឆ្លើយថា ៖

- ខ្ញុំបានសួរស្ថានទូតអាមេរិកហើយ ។ គេប្រាប់ខ្ញុំថា ករណីជន ភៀសខ្លួនជាករណីលើកលែង មិនបាច់មានក្រដាសគំរូទេ គឺអាច សរសេរបែបណាក៏បាន អោយតែគេអានប្រវត្តិរបស់យើងយល់ ។ ហើយនេះអស័យដ្ឋានស្ថានទូតអាមេរិកនៅក្រុងបាំងកកប្រទេសថៃ រីឯមួយនេះ ជាអស័យដ្ឋានរបស់ខ្ញុំនៅអាមេរិក ។ បើសិននាងមាន សំណាងបានទៅដល់ ត្រូវការអោយខ្ញុំជួយនាងរឿងអ្វី សូមទាក់ទង ខ្ញុំចុះ កុំខ្លាចចិត្តអី ។ ពេលនាងសរសេរពាក្យសុំហើយ សូមយក ទៅដាក់ផ្ញើក្នុងប្រអប់សំបុត្រកាកបាទក្រហម ដែលគេដាក់ហូរហែ តាមផ្លូវក្នុងសង្កាត់និមួយៗ នោះសំបុត្រនឹងបានដល់ការិយាល័យ ស្ថានទូតអាមេរិកហើយ ។

CHANBOKEO.COM

- រួចចុះខ្ញុំត្រូវបិទតែមដែរទេ ?

លោកថមគ្រវីក្បាល ៖

- បើនាងធ្វើតាមប្រអប់សំបុត្រកាកបាទក្រហមអន្តរជាតិ នាងមិន
បាច់បិទតែមទេ ។ គេនឹងបិទតែមជំនួសនាង មុននឹងផ្ញើចេញទៅ ការិយាល័យស្ថានទូត ។

កូនមាន់ទទួលយកអាសយដ្ឋានពីលោកគ្រូពេទ្យហើយក៏លើកដៃ សំពះឡើង ៖

- ខ្ញុំអរគុណលោកណាស់ ដែលមានសមានចិត្តថ្លៃថ្លាចំពោះខ្ញុំ ។
- បាទ ! មិនអីទេ ! អញ្ចឹង ខ្ញុំលាសិនហើយណា៎
- ចា៎ស !

លោកថមក៏ហាក់ចូលរថយន្តហ្ស៊ីបបរចេញទៅ ។

...............................................

ព្រលប់ថ្ងៃនដែល...

កូនមាន់ត្រឡប់មកដល់ផ្ទះឃើញមីងផាធ្វើមាត់ជីបអូចៗ ដាក់ នាងពីចម្ងាយ មិនដឹងហេតុអ្វី
រួចហើយគាត់ក៏ដើរចេញទៅ ។ នារី យើងក៏ស្ទុះចូលទៅក្នុងខ្ទម
ឃើញជ្រូកលីវអង្គុយធ្វើមុខក្រញូវ ៖

- ជ្រូកលីវ ? មានរឿងអីមែនទេ ?

ជ្រូកលីវសម្លឹងមុខនាងមិនព្រិច បន្តិចមកក៏សួរថា ៖

- ម៉េចក៏អូនមិនប្រាប់បង ? ម៉េចចាំលាក់បងធ្វើអី ?
- ប្រាប់ ? ប្រាប់រឿងអ្វី ? លាក់រឿងអ្វី ?

កូនមាន់សួរទាំងឆ្ងល់ ។ ជ្រូកលីវក៏ស្រាវាសំណុំក្រដាសដែល
នៅក្រោមខ្នើយរបស់កូនមាន់យកមកបោះលើកន្ទេល រួចស្រដីថា ៖

- បែកគ្នាមិនបានប៉ុន្មានផង ដាច់ចិត្តទទួលពាក្យពីអ្នកដទៃ បំភ្លេច បងអញ្ចឹង មែនទេ ?
មួយខែដែលយើងឆ្លងគ្រោះថ្នាក់ ស្លាប់រស់ ជាមួយគ្នា មិនមែនន័យអ្វីចំពោះអូនទេ មែនទេ ?
ទើបអូនធ្វើបែប
នេះចំពោះបងអញ្ចឹង កូនមាន់ ?

មាណវីឱនរើសក្រដាសឡើង ដឹងថាជាសំបុត្រនិងក្រដាសផ្សេងៗ
របស់ខេង ដែលផ្ញើអោយនាងកាលពីថ្ងៃមុន ។ នាងក៏លាន់មាត់ ឡើង ថា ៖

- យ៉ាងម៉េចហ្នឹង ? ចេះមកប្រចណ្ឌជាមួយក្រដាសកើតដែរ ?

CHANBOKEO.COM

- បងមិនបានប្រចណ្ឌនឹងក្រដាសហ្នឹងទេ គឺខឹងនិងម្ចាស់វាទេតើហ៍
- អូហ៍! បើខឹងនឹងគេ ម៉េចក៏មិនទៅស្ដីអោយគេ ? ហេតុអ្វីមក គំហកកំហែងដាក់ខ្ញុំផង ?
ម៉េចហ្នឹង ជ្រូកលីវកំពុងចម្លងភាព យង់ឃ្នងពីខ្មោចខ្មែរក្រហមយកមកដាក់ក្នុងខ្លួនឬអ្វី
បានជានិយាយ ស្ដី ទ្រគោះបោះបោក គ្រោតគ្រាតដូចពួកហ្នឹងបេះបិទ អញ្ចឹង ?
ពូនារីយើងស្ដីបន្ទោសចំចំណុចខ្សោយ គេក៏ទម្លាក់សម្លេងវិញ ហើយតបថា ៖
- គេមានបងប្អូននៅអាមេរិក បន្តិចទៀតគេនឹងបានចេញទៅ រួច
ហើយអូនក៏នឹងចាកចេញទៅព្រមជាមួយគេដែរ ។
- អ្នកណាថា ខ្ញុំទៅជាមួយគេ ?
- ចុះក្រែងគេថា បងប្រុសធានាខេងជាប្អូន ហើយកូនមាន់ជាប្អូន ថ្លៃរបស់គេ មិនថាអញ្ចឹង ?
- នៅក្នុងក្រដាសស្នាមមានបញ្ជាក់ឈ្មោះកូនមាន់ដែរទេ ?
- អត់ទេ! តែគេប្រតិស្ឋនាមផ្សេង អោយបណ្ដោះអាសន្ន ។
- ហើយមិនគិតទេហ្អី ថាគេកំពុងសាកចិត្តខ្ញុំ ដើម្បីចង់នឹងថា
ខ្ញុំនេះលង់នឹងឧត្តមភាពជាសាច់ញាតិអ្នកអាមេរិក ឬក៏អត់ ?
- ចុះហេតុអ្វីគេចាំធ្វើដូច្នេះផង ?
- ខ្ញុំមិនដឹងទេ! តែខ្ញុំត្រូវតែប្រយត្ន័ខ្លួន មិនអោយបុរសគិតថាខ្ញុំ
ទទួលយកគេជាស្វាមីដោយមូលហេតុចង់ទៅនៅអាមេរិក ។
- ហើយអូនចង់ទទួលស្វាមីដោយមូលហេតុអ្វីវិញទៅ ?
- គឺក្ដីស្រឡាញ់និងភាពស្មោះស្ម័គ្រចំពោះគ្នានោះអី!
- មានន័យថា អូនមិនទាន់យល់ព្រមនឹងគេទេហ៍ ?
- ហើយមានកន្លែងណាដែរទៅ ដែលបញ្ជាក់ថាខ្ញុំព្រម ?
- បើអញ្ចឹង ម៉េចចាំបាច់យកក្រដាសលាក់ក្រោមខ្នើយអូនផង ?
- រួចចុះប្រាង្គវិមានប្រក់ស្បូវរខេករខាករបស់ខ្ញុំនេះ មានកន្លែងល្អ ដែរទេ
សំរាប់លាក់ឯកសារនេះ ក្រៅពីក្រោមខ្នើយ ?
ជ្រូកលីវពូដូច្នោះក៏បាត់មាត់ដូចគេចុកតែម្ដង ។ កូនមាន់ក៏ខិន
ចុះស្រវារើសក្រដាសដែលហើររាយប៉ាយលើកន្ទេលគេងរបស់នាង តម្រៀបទុក
ស្រាប់តែជ្រូកលីវពោលបន្តថា ៖
- អូនប្រមូលយកទៅសងគេវិញមែនទេ ?

CHANBOKEO.COM

កូនមាន់ញញឹម ឆ្លើយថា ៖

- ចាំបាច់ទៅសងគេវិញធ្វើអី ?
- អញ្ចឹងប្រមូលយកទៅណា ?
- យកទៅទុកបង្កាត់ភ្លើងដាំបាយ កុំអោយខាត ។

ស្រាប់តែមានសំដីមួយឆ្លើយកាត់ពីក្រោយខ្នងកូនមាន់មកថា៖

- បើមិនទទួលវា ក៏មិនគួរបំផ្លាញវាដែរ! បើកូនមាន់បំផ្លាញវា គឺ មិនខុសពីបំផ្លាញទឹកចិត្តរបស់មនុស្ស ដែលខំបង្ហាញនូវសមានចិត្ត ល្អប្រសើរចំពោះអ្នកដែលខ្លួនស្រឡាញ់នោះឡើយ ។

អ្នកទាំងពីរបែរមើលម្ចាស់សម្លេង ហើយក៏លាន់មាត់ព្រមគ្នា ឡើងថា ៖

- ខេង ?
- មែនហើយ! គឺជាខ្ញុំមែន! ល្អហើយដែលខ្ញុំបានមកឮចម្លើយ របស់កូនមាន់ផ្ទាល់មាត់ ហើយក៏បានមកប្រទះមិត្តរបស់ខ្ញុំម្តងទៀត ដឹងថាគេបានសុខសប្បាយ ។ ខ្ញុំសូមជួយត្រេកអរអ្នកទាំងពីរផង ណា៎ ដែលបានជួបគ្នាវិញ ។

កូនមាន់ឈរភាំង ព្រោះមិននឹកស្មានថានាយខេងមករកនាង ដល់ផ្ទះដូច្នោះ ។ ចំណែកជ្រូកលីវដែលកំពុងហួហ្មងក្នុងចិត្ត ដោយ ការច្រណែនប្រច័ណ្ឌចំពោះនាយខេង គេហាក់ដូចជាមិនចង់អោយ នាយខេងមកសាសងអ្វីជាមួយកូនមាន់នៅពេលនេះទេ ។ ម្ល៉ោះ ហើយ គេគ្រាន់តែញញឹមស្ងួតដាក់ខេង ហើយក៏ស្ងៀមមិនស្រដី ។ ខេងឃើញឥរិយាបថរបស់ជ្រូកលីវក៏កាត់ស្មានបានភ្លាម ។ គេក៏ ពោលឡើងថា ៖

- អញ្ចឹង! ខ្ញុំទៅវិញហើយ មិននៅរំខានអ្នកទាំងពីរទេ ។ ចាំថ្ងៃ ក្រោយយើងនិយាយគ្នាទៀត ព្រោះខ្ញុំមានការប្រញាប់ ។

ថាហើយ នាយខេងក៏ស្រវាប្រមូលក្រដាសធានាដែលនៅលាត រប៉ាត់រប៉ាយលើកន្ទេល ហើយក៏ដើបឡើងដើរចេញទៅ ។

- ឈប់សិន មិត្តខេង!

កូនមាន់ក្រញាស រត់ចេញពីខ្ទម ស្រែកឃាត់នាយខេង ។ នរៈ យើងទុចដ៏ក់ បែរសួរវិញថា ៖

- កូនមាន់ មានការអ្វីទៀតហ្នឹង ?

CHANBOKEO.COM

- គឺ... អំបាញមិញនេះ ខ្ញុំពុំមានចេតនាចង់ដុតឯកសារធានារបស់ មិត្តចោលទេ គ្រាន់តែនិយាយកម្លាចិត្តរបស់ជ្រូកលីវ កុំអោយគេ មួម៉ៅដាក់ខ្ញុំខ្លាំងពេកតែប៉ុណ្ណោះ... អោយខ្ញុំសុំទោសផងណា៎!

ខេងញញឹមឡើង ហើយតបវិញថា ៖

- ខ្ញុំមិនបានប្រកាន់ទុកនៅក្នុងចិត្តទេ កូនមាន់កុំបារម្ភអីណា៎! សូមជូនពរអោយជីវិតអ្នកទាំងពីរបានសុខសប្បាយ មានសុភមង្គលល្អ ចាប់ពីពេលនេះតទៅ ។

- ចា៎ស អរគុណ!

ខេងក៏បែរខ្លួនបំរុងនឹងបោះជំហានបន្តទៅទៀត ស្រាប់តែកូនមាន់នឹកឃើញរឿងមួយ ៖

- មិត្តខេង ឈប់សិន! អោយខ្ញុំសុំអ្វីមួយពីខេងបានទេ ?

- បើខ្ញុំអាចធ្វើបាន ខ្ញុំនឹងធ្វើជូន... ចាត់ទុកថាជាចំណងដៃរបស់ខ្ញុំជូនទៅកូនមាន់និងជ្រូកលីវចុះ ។

- គឺ... ខ្ញុំសូមឲ្យខេងជួយយិតយោងគេម្នាក់ផង

- អ្នកណាគេទៅ ?

- គឺមនុស្សម្នាក់ដែលសក្តិសមនឹងធ្វើដំណើរជាមួយខេងទៅរស់នៅ អាមេរិក ។

- ក្រៅពីកូនមាន់ ខ្ញុំមិនចង់ធានាអ្នកណាទេ ។

- ធានាមនុស្សល្អក៏មិនចង់ជួយដែរ មែនទេ ? កុំធ្វើដំណើរដៃទទេ អីណា៎ បើអាចជួយបានយិតយោងម្នាក់ពីរអោយរួចជីវិតទុក្ខសោក ជួបក្តីសុខសប្បាយ គឺជាទឹកចិត្តមនុស្សធម៌ដ៏ប្រពៃបំផុត រកមិនបាន ទេ ដឹងទេ ?

- ហើយម៉េចដឹងថាគេនោះជាមនុស្សល្អទៅ ?

- អញ្ចឹង ចាំពិនិត្យខ្លួនឯងទៅ! ស្អែក សូមខេងត្រឡប់មកជួប ខ្ញុំវិញ នៅផ្ទះខ្ញុំនេះ កុំខាននា៎ ។

- អោយខ្ញុំគិតមើលសិន!

- មិនអោយគិតទេ! ឆ្លើយពេលនេះមក៉! មិនបាច់រៀបការគ្នាមែន ទែនក៏បានដែរ អោយតែជួយយកគ្នាចេញទៅក្រៅសិនទៅ ។

- យី! បង្ខំខ្ញុំម្ល៉េះ ?

- ម៉េច..ជួយឬមិនជួយ ? គ្រាន់តែជួយ ម៉េចចាំបាច់រើសមុខផង ?

CHANBOKEO.COM

- ណ្ហើយចុះ ចាំស្អែក ខ្ញុំមកជួបកូនមាន់ម្ដងទៀត ។

កូនមាន់ស្ដាប់ឮហើយ ក៏សើចគ្រហាញតែម្ដង ។

................................

ព្រលប់ថ្ងៃដដែល...

- អូនកំពុងគិតអីហ្នឹង កូនមាន់ ?
- អត់បានគិតអ្វីផង !
- ចុះម៉េចបានជាបបួលនាយខេងឲ្យមកទីនេះ នៅថ្ងៃស្អែកធ្វើអី ?
- ជ្រូកលីវ ! កុំរៀនប្រចណ្ឌអញ្ជឹងមើល៍ ពីដើមធ្លាប់ទុកចិត្តគ្នាបាន ហេតុអ្វីឥលូវ បែរជាលែងចេះទុកចិត្តគ្នាទៅវិញ ?
- មិនប្រច័ណ្ឌទេ តែបងឆ្ងល់
- អញ្ជឹងឆាប់ចូលគេងទៅ អាលភ្ញាក់ឡើងដឹងរឿងថ្មីៗទៀត
- មិនប្រាប់បងមែនហ្អែស ?
- ប្រាប់អោយដឹងមុនធ្វើអ្វី នាំតែអស់សប្បាយ
- អូហ៍ គ្រាន់តែប្រាប់បងអោយដឹងផង មិនបានដែហ៍ ?
- មិនប្រាប់ទេ
- បើមិនប្រាប់ បងចាប់អូនថើបហើយ ! ម៉េច ប្រាប់ឬមិនប្រាប់ ?
- មិនប្រាប់....
- បើមិនប្រាប់ បងដាក់ទោសហើយ ចាំមើល៍ ។

សូរសំណើចរអឹកលាន់ឮឡើងជាលើកដំបូងបង្អស់ ក្នុងជីវិត របស់គេ ។

...................................

ព្រឹកស្អែកឡើង...

ខេងដើរមកដល់មុខខ្ទមរបស់កូនមាន់ ដោយមាននាំមីងខៃមក ដែរ ស្រាប់តែគេប្រទះនឹងមនុស្សជាច្រើនអង្គុយចាំនៅទីនេះជា ស្រេច មានទាំងនាយឆាល់ម្នាក់ទៀតផង ។

- ឆាល់ ? ការពិតឯងនៅរស់ទេហ៍ ?
- មែន ! ហើយខេងក៏មិនទាន់ស្លាប់ដែរ មិនថាអញ្ជឹងហ្អ៉ែស ?

ទាំងពីរនាក់ក៏គោះស្មាគ្នាទៅវិញទៅមក យ៉ាងរំភើប ។ ជ្រូក លីវក៏ពោលទៅប្រាប់ខេង ថា ៖

CHIANBOKEO.COM

- គឺ...បើកុំតែបានឆាល់ជួយ កុំអីខ្ញុំគ្មានកន្លែងរស់ទេ ពេលមកដល់ ជំរំនេះដំបូង ។

ខេងញាក់ចិញ្ចើម សើចខឹកៗហើយលាន់មាត់ឡើង ថា ៖

- ពុទ្ធោ! នាយឆាល់មហាអាត្មានិយម កំណាញ់បេះមិនចេញមួយ នេះ
ចេះមានចិត្តសប្បុរសធម៌ដែរ មែនទេ?

ឆាល់គ្រវីក្បាល ៖

- នរណាថាខ្ញុំនេះសប្បុរស? ការពិត ខ្ញុំមិនបានជួយអ្វីគេផងទេ ។ បាយទឹកអ្វីៗ
សុទ្ធតែជាចំណែកពីអង្គការយូអិនទាំងអស់... ខ្ញុំខំ ជួយបើករបបឲ្យជ្រូកលីវ
ព្រោះគិតថាបើវាអាល័យឈើ បរិភោគ មិនបាន ខ្ញុំនេះស្ម័គ្រទទួលយកដោយពេញចិត្ត
មិនឲ្យបង់ខាតរបប ដែលអង្គការមនុស្សចែកនោះឡើយ ។

ខេងគ្រវីក្បាល ៖

- ឆាល់ឯងនេះ ឃើញតែខាងចំណេញសោះហើយ ។

ទាំងអស់គ្នាក៏សើចគិលឡើង ។

រំពេចនោះ កូនមាន់ក៏ណែនាំមីងផា និងម្ដាយមីងរបស់ខេងឲ្យ ស្គាល់គ្នា ។ បន្ទាប់មក
នាងក៏បង្ហាញនារីម្នាក់ទៅខេងនិងម្ដាយមីង
ព្រមទាំងស្រដីថា ៖

- នេះ អូនធា! ហើយខាងនេះប្អូនធី ជាប្អូនប្រុស

មែនហើយ នោះគឺជានាងធាបងស្រីរបស់នាយធី ។ នារីក៏លើក ដៃលំទោនកាយសំពះចាស់ៗ
៖

- ជំរាបសួរចាស!

ស្រាប់តែខេងពោលឡើង ៖

- ខ្ញុំក៏ស្គាល់នាងដែរ គឺខ្ញុំនិងជ្រូកលីវធ្លាប់ជួបនាងនៅជំរំណងចាន់

ធាញញឹមឡើង ៖

- ចាស! មែនហើយ!

ស្រាប់តែមីងខែលាន់មាត់ឡើង ៖

- នាង គឺជាសុធា កូនបងសុផល និងម្ដាយនាងឈ្មោះផលា ហើយ
មានប្អូនប្រុសមួយឈ្មោះសុធីនោះមែនទេ?

- ចាស ពិតណាស់! ម៉េចបានជា អ្នកមីងជ្រាប?

- គឺមីងស្គាល់ប៉ាម៉ាក់របស់ឯងសម័យខ្មែរក្រហម ធ្វើការនៅភូមិ ជាមួយគ្នា ហើយគេធ្លាប់លួចយករូបថតក្រុមគ្រួសារ មកអោយមីង មើលច្រើនដងទៀតផង ហើយនាងមានមុខមាត់ដូចម្តាយណាស់ ទើបមីងឆាប់សំគាល់បានដូច្នេះ ។
- អូហ៍! អញ្ចឹង អ្នកមីងមាននឹងថាគាត់ទាំងពីរនៅឯណាទេហ៍ ?
- នៅរស់ទាំងពីរនាក់ហ្នឹង! មុននឹងមីងចេញមក គាត់ទាំងពីរ នៅមោងឫស្សី ខេត្តបាត់ដំបង ។ យី! បើបាននឹងថាក្មួយឯងនៅ រស់ គាត់ច្បាស់ជាសប្បាយចិត្តស្លាប់ហើយ ។ នឹងទេហ៍ កាលពីសម័យអត់បាយនោះ បើកុំតែបានម្តាយឪពុករបស់ក្មួយ ម៉្លេះសម មីងមិនរស់រានមានជីវិតមកដល់សព្វថ្ងៃនេះទេ ។

នាងធារំភើបចិត្តរហូតស្រក់ទឹកភ្នែកតែម្តង ។

- អីនេ៎! កុំយំអីនាង! (ម្តាយមីងរបស់ខេងពោល) អោយតែមាន ជីវិត គង់ថ្ងៃណាបានជួបគ្នាវិញទេ ឈប់បារម្ភទេ ។ ហើយនាយខេងមានសំបុត្រធានាពីបងប្រុសនៅអាមេរិក មានទាំងដាក់ឈ្មោះ កូនខ្មោចថែមមួយផង ។ បើនាងមិនយល់ទាស់ កាន់ឈ្មោះកូន ខ្មោចហ្នឹងចេញទៅអាមេរិកសិនទៅ រួចហើយចាំធានម្តាយឪពុក ចេញទៅតាមក្រោយ ហើយគ្នាស្រេច មិនថាអញ្ចឹងហ្អែស ?

ស្ត្រីចំណាស់និយាយប្រុយៗយ៉ាងធូរ ដោយគ្មានការទើសទាល់ ក្នុងចិត្ត ធ្វើអោយនាយខេងនឹកខ្មាសនារីយើងឡើងបែកញើសជោគ ខ្លួង ។ ភ្លាមនោះ មីងខែក៏លាន់មាត់ថែមទៀតថា ៖

- យីអើហ៍! មីងដូចជាឃើញឈ្មោះឧបមាហ្នឹងដូចជាឈ្មោះនាងធា ដែរ មែនទេ នាយខេង ?
- បាទ មីង! គឺបងប្រុសខ្ញុំបានប្រតិស្ឋនាមថា ផល សុធា

ស្រាប់តែនាងធាបើកភ្នែកធំៗ ឧទានឡើង ៖

- នោះគឺជាឈ្មោះពិតប្រាកដរបស់ខ្ញុំទេតើហ៍ ?
- យី! អីក៏ចៃដន្យម៉្លេះ ? (កូនមាន់លាន់មាត់)
- ប្រហែលជាគូព្រេងនឹងគ្នាទេនឹង ? (មីងខែបន្ទរ)

ឮដូច្នោះ ខេងនិងនាងធាលួចសម្លឹងមុខគ្នា លុះប្រទះឃើញកែវភ្នែកសម្លឹងចំគ្នាទៅវិញទៅមក គេក៏រអៀសខ្លួនហើយងាកមុខ ចេញយ៉ាងលឿន ។ អ្នកទាំងអស់នៅទីនោះ ឃើញកិរិយារបស់អ្នក ទាំងពីរ ក៏នាំគ្នាហោះចំអន់ឡើងយ៉ាងក្អាកក្អាយតែម្តង ។

CHANBOKEO.COM

នៅពីក្រោយខ្នង កូនមាន់លួចមិចភ្នែកដាក់ជ្រូកលីវ ទំនងជា សញ្ញាចង់ប្រាប់ថា គម្រោងការរបស់នាង ចាប់ខេងអោយជួយធានា នាងធា ពេលនេះ គឺបានសំរេចដូចបំណងប្រាថ្នាតែម្តង ។ ជ្រូកលីវ ក៏ញញឹមដាក់វិញ យ៉ាងបំព្រង ។

រំពេចនោះ មានរថយន្តហ្ស៊ីបមួយបរមកដល់មុខផ្ទះ ។ ទាំង អស់គ្នាបែរទៅឃើញ ជនជាតិអាមេរិកាំងម្នាក់ចុះដើរតម្រង់មកខ្ទម កូនមាន់ ហើយស្រដីជាភាសាអង់គ្លេសថា ៖

- មាននរណាម្នាក់ ឈ្មោះ នួន ផារិនី ទេ ?

ទាំងអស់គ្នាបែរមើលមុខគ្នាឡឹងឡង់ ព្រោះស្តាប់ភាសាមិនបាន មានតែជ្រូកលីវ កូនមាន់ ខេងនិងនាងធាទេដែលស្តាប់យល់ ។

- ចាំសគឺខ្ញុំនេះហើយ (កូនមាន់ពោលឡើង) លោកមានការអ្វីឬ ?

- ស្ថានទូតអាមេរិកមានការចង់ជួបនាង ពេលនេះ ។

កូនមាន់ភ្ញាក់ក្រញាង សួរថា ៖

- អូហ៍! ហេតុអ្វីក៏ស្ថានទូតស្គាល់ខ្ញុំ ?

- គេបានទទួលសំបុត្ររបស់នាងជាច្រើនច្បាប់ ដែលដាក់ពាក្យសុំ ជ្រោកកោននៅអាមេរិក ហើយគេដឹងថា នាងជាបុគ្គលិកធ្វើការងារ ឥតកម្រៃនៅយូអិន ថែមទាំងចេះភាសាអង់គ្លេសច្បាស់លាស់ ទើប គេចង់សម្ភាសន៍នាងទៅប្រទេសទីបី ។

ឮដូច្នោះ កូនមាន់ត្រេកអរស្ទើរហើបជើងពីដីតែម្តង ។

- អញ្ចឹង! តើគេអោយខ្ញុំទៅជួបពេលណាដែរ ?

- គឺទៅជាមួយខ្ញុំឥលូវនេះ ព្រោះមានដំណើរយន្តហោះដឹកជន ភៀសខ្លួនខ្មែរ៤០០នាក់ ទៅអាមេរិក នៅអាទិត្យក្រោយ ប្រហែល ជាគេត្រូវការនាងអោយជួយសម្រួលកិច្ចការទាំងនោះហើយ ។

កូនមាន់ក៏ប្រញាប់ហក់ឡើងរថយន្តចេញទៅជាមួយជនជាតិ អាមេរិកាំងនោះយ៉ាងរហ័ស ទុកអោយអ្នកទាំងអស់ឈរសម្លឹងមើល ពីក្រោយ លួចស្ងើចសរសើរព្រេងសំណាងរបស់នាង...

........................

ច្រើនម៉ោងក្រោយមក...

កូនមាន់ត្រឡប់មកដល់ផ្ទះ ឃើញអ្នកទាំងឡាយត្រលប់ទៅផ្ទះ គេវិញអស់ សល់តែជ្រូកលីវដែលនៅអង្គុយធ្វើមុខស្រងូត ។

- ម៉េចធ្វើមុខអត់រាសីអញ្ចឹង ជ្រូកលីវ ?

CHANBOKEO.COM

- អោយសប្បាយម៉េចទៅ បើអូនជិតទៅចោលបងហើយនោះ ?

ជ្រូកលីវតបវិញ ។ កូនមាន់ញញឹមហើយឆ្លើយថា ៖

- នរណាប្រាប់ ថាខ្ញុំទៅចោលបង ?
- អញ្ចឹង អូនមិនទៅអាមេរិកទេ ?
- ហើយអ្នកណា... ថា ខ្ញុំមិនទៅអាមេរិក ?
- ថាម៉េចហ្នឹង ? អូនទៅអាមេរិក តែអូនមិនទៅចោលបង ? តើ មានន័យថាម៉េចដែរ ?
- ហើយបងគិតថា គួរមានន័យយ៉ាងម៉េចវិញទៅ ?
- គឺ... មានន័យថា យើងនឹងចេញទៅទាំងអស់គ្នា !
- មែនហើយ !

ជ្រូកលីវខមានទាំងភ្ញាក់ ឆ្លើលឡើងថា ៖

- ហើយយ៉ាងម៉េច បានជាគេអនុញ្ញាតិអោយបងទៅជាមួយអូន ដោយងាយៗអីចឹង តើអូនប្រាប់គេថាម៉េចខ្លះ ?
- បងគិតមើលទៅ ថាខ្ញុំប្រាប់គេថាម៉េចខ្លះ ទើបគេអនុញ្ញាត្ត ?
- គឺអូនប្រាប់គេថា... ប្រាប់ថា... អូនមានគ្រួសារហើយមែនទេ ?

កូនមាន់ងក់ក្បាល ។ ជ្រូកលីវញញឹមឡើង សួរបន្តថា ៖

- ហើយអូនចុះឈ្មោះអោយបងថាយ៉ាងម៉េចដែរ បើបងមិនដែល ប្រាប់នាមត្រកូលរបស់បងដល់អូនផងនោះ ?
- គឺ... ដាក់នាមត្រកូលរបស់ខ្ញុំសិនទៅណា ។
- ត្រកូលរបស់អូន ? នាមត្រកូល នួន ហ្នឹងហ្មែស៎ ?
- ចា៎ស !
- នួន លីវ ?
- អត់ទេ ! គឺ នួន ជ្រូកលីវ !
- ស្លាប់ហើយ ដាក់ឈ្មោះបង អីក៏យ៉ាប់ស្តាប់ម្ល៉េះ ? ជ្រូកលីវជាឈ្មោះហៅលេងនៅខាងក្រៅទេតើហ៎ !
- តែឥលូវចូលក្នុងបញ្ជីហើយ ទទួលយកទៅ !
- ការពិត ឈ្មោះបង គឺ តាំង សៀកលីវ !

CHIANBOKEO.COM

- ងាប់! ឈ្មោះអត់ពិរោះអីម៉ាតិចសោះ! ដាក់ថា"តាំងអ៊ា" វិញ
ដូចជាពិរោះជាងរាប់ម៉ឺនដងឯណោះ ។
- ពុទ្ធោ! តាំងអ៊ា ទាអាំង ហ្នឹងហ្អ៊ែស ?
- ចា៎ស! ហ្នឹងហើយ...
- អ៊ូយ! បងមិនយកទេ! យ៉ាប់ជាង នួនជ្រូកលីវ នោះទៅទៀត
- បើមិនយកទេ ខានទៅអាមេរិកហើយ ។
- តែបងខ្មាសគេណាស់អូន ដែលប្ដីកាន់ត្រកូលប្រពន្ធ
- ខ្ញុំអត់មានខ្មាសផង បងខ្មាសធ្វើស្អី ?
- យ៉ាប់មែន អូនឯងនេះ!
- ម៉េច ? យកឈ្មោះដែលខ្ញុំដាក់អោយហ្នឹង ឬមិនយក ?
- នរណាថាមិនយក! បើមិនយក គឺខាននៅក្បែរអូនហើយ!
- បងដឹងខ្លួនអញ្ចឹង ល្អហើយ...
- ដឹង! ពិតជាដឹង! គឺដឹងថា ជាតិនេះ បងមិនអាចបែកពីអូន បានទេ
គឺយើងត្រូវតែរស់នៅជួបជុំគ្នារហូតតទៅ ។
- ហើយកុំភ្លេចថែរក្សានាមត្រកូលប្រពន្ធផងណា៎ ឮហើយនៅ ?
- មិនអីទេ ចាំបងថែ ថែទាំងអស់ ថែតាំងពីម្ចាស់ដែលដាក់ឈ្មោះ ឲ្យបងនោះផងដែរ
មិនអោយខកចិត្តទេ ប្រពន្ធសម្លាញ់!

ទាំងពីរនាក់ក៏ផ្ទុះសំណើចឡើងយ៉ាងរីករាយ ទទួលក្រេបយក
នូវរសជាតិសុភមង្គលក្នុងជីវិតរបស់គេ យ៉ាងផ្អែមត្រកាល ជាលើក ដំបូងក្នុងជីវិត ។

.........................................

ព្រឹកស្អែកឡើង...

មនុស្សម្នារត់មកកុះករជូនដំណើរកូនមាន់និងជ្រូកលីវ ៖

- បងមិននឹកស្មានសោះថាកូនមាន់មានសាច់ញាតិច្រើនដល់ម្លឹង ?

ជ្រូកលីវស្រដីទៅកូនមាន់ដែលកំពុងស្រវាអោបមិត្តភក្តិនិងអ្នក ដែលស្គាល់គ្នា
ដើម្បីលាគ្នាជាចុងក្រោយ មានមីងផា និងអ្នកស្រុក ដែលរស់នៅក្នុងដំបូលខ្ទមជាមួយគ្នា
ខេងនិងម្ដាយមីង សុធា សុធី នាយឆាល់ មីងសឿន ព្រមទាំងបុគ្គលិកឥតកម្រែរួមការងារប៉ុន្មាន
នាក់ទៀត ។

CHANBOKEO.COM

កូនមាន់ញញឹមហើយឆ្លើយថា ៖
- ជាលទ្ធផលនៃនិស្ស័យល្អរបស់យើងណា៎ជ្រូកលីវ ! បើយើងគ្មាន និស្ស័យល្អនឹងគ្នាទេ យើងពិតជាមិនអាចភ្ជាប់ភាពជិតដិតជាញាតិ នឹងគ្នាបានឡើយ មិនថាអ្នកនោះជាប់សាច់សន្តានជាមួយយើង ឬ គ្រាន់តែជាអ្នកដទៃក៏ដោយ ។
ជ្រូកលីវងក់ក្បាល ៖
- អូននិយាយត្រូវ ! ថ្វីបើគេមិនមែនជាប់សាច់ឈាមសន្តានជាមួយ យើង ប៉ុន្តែ កាលបើយើងមាននិស្ស័យល្អនឹងគ្នា មានតែការលើក ទឹកចិត្ត ការជួយជ្រោមជ្រែងគ្នា ការមិនបញ្ឈរភ្នែកមើលបំណាំគ្នា ពេលមានគ្រោះអាសន្ន នោះយើងក៏អាចផ្សាភ្ជាប់និស្ស័យជាញាតិ យ៉ាងជិតដិតនឹងគ្នា ល្អនឹងគ្នា មិនខុសពីសាច់ញាតិរួមលោហិតតែ មួយនោះឡើយ ។
ភ្លាមនោះ ញាតិមិត្តមួយហ្វូងធំធ្វើដំណើរមកដល់ ចោមរោម អ្នកទាំងពីរជុំជិត ។
- សូមអោយជួបតែសំណាងល្អណា៎ក្មួយ ! បានទៅហើយ កុំភ្លេចខំ រៀនសូត្រ ដើម្បីឆាប់បានវិលត្រឡប់មកជួយពួកយើងដែលខ្វះខាត នៅខាងក្រោយផង ។
មីងផាពោលទៅកាន់កូនមាន់ ថែមទាំងយកដៃអង្អែលខ្នងនាង បង្ហាញនូវក្តីស្រឡាញ់ទុកចិត្តយ៉ាងកក់ក្តៅ ។ នារីក៏ឆ្លើយថា ៖
- ចា៎ស ! មីង ! សូមមីងថែរក្សាខ្លួននិងកូនចៅផង !
ខេងដើរទៅជិតអ្នកទាំងពីរ ហើយស្រដីថា ៖
- សូមអោយអ្នកទាំងពីរធ្វើដំណើរប្រកបដោយសុវត្ថិភាព ។ មិន យូរមិនឆាប់ យើងនឹងបានជួបគ្នានៅអាមេរិកមិនខាន ។
ជ្រូកលីវញញឹមហើយឆ្លើយវិញ ថា ៖
- ពិតហើយ ! ចាំយើងជួបគ្នានៅអាមេរិក !
ស្រាប់តែ នាយឆាល់ធ្វើមុខស្ងួត អង្អែលចង្កា និយាយម្នាក់ឯង យ៉ាងខ្លាំងៗ ទំនងចង់ឲ្យគេឯងឮទាំងអស់គ្នា ៖
- គេនិយាយឡើងសុទ្ធតែអាមេរិក មើលទៅ បែបគ្មាននរណាចង់ វិលទៅស្រុករំដោះជាតិទេមើលទៅ ! !
មីងផាអត់មិនបានក៏ឆ្លើយថា ៖

CHANBOKEO.COM

- បើចង់ជួយស្រោចស្រង់ជាតិយើងពិតមែន កុំភ្លេចធ្វើអំពើល្អ ចំពោះខ្មែរគ្នាឯងផង កុំតែគេងប្រវញ្ច័ កុំធ្វើបាប កុំធ្វើទុក្ខបុកម្នេញ កុំជាន់កសម្លាប់គ្នា នោះមានន័យថាជួយជាតិហើយអានាងអើយ!

កូនមាន់អត់មិនបានក៏បន្ថែមថា ៖

- ការជួយជាតិមាតុភូមិ មានច្រើនផ្នែក ច្រើនសណ្ឋាន មិនចាំបាច់ តែកាន់កាំភ្លើងបាញ់ខ្មាំងទើបហៅថាជួយជាតិទេ ។ ពេលនេះ យើង ជួយត្រឹមខ្លួនឯងមិនបានផង ព្រោះអីយើងម្នាក់ៗកំពុងតែចំហមាត់ ពឹងអាហារនិងទឹកដែលអង្គការបន្តក់អោយរស់ពីមួយថ្ងៃទៅមួយថ្ងៃ តើអោយយើងទៅជួយជាតិយើងយ៉ាងណាបានទៅ ? ហេតុដូច្នេះ យើងត្រូវតែរៀនឆក់ឱកាស ស្វែងរកមធ្យោបាយជួយខ្លួនអោយរឹង ប៉ឹង មុននឹងអាចមានលទ្ធភាពជួយបងប្អូនយើងដែលខ្វះខាតនៅ ខាងក្រោយនោះអោយបានផុតពីមហន្តរាយបាន ។ ថ្វីបើយើងមិន បានទៅជួយលើកកាំភ្លើងបាញ់បច្ចាមិត្តដូចខេមរជនអ្នកតស៊ូដទៃៗ ទៀតក៏ដោយ ប៉ុន្តែការប្រព្រឹត្តិត្រឹមតែធ្វើអំពើមនុស្សធម៌ចំពោះខ្មែរ ស្លូតត្រង់ដែលកំពុងរងទុក្ខវេទនា នោះក៏អាចហៅបានថា ជាការ ជួយជាតិដូចគ្នាដែរ...

ឮកូនមាន់ឆ្លើយដូច្នោះ នាយឆាល់ទម្លាក់សម្លេង ៖

- ចុះខ្ញុំមានថាអីឯណា ? ខ្លាចតែអ្នកខ្លះទៅហើយដល់ត្រើយសើយ គួច ភ្លេចជាតិកំណើតខ្លួនតើហ៍!

ខេងអត់មិនបាន ក៏ជ្រៀតមកធ្វើអន្តរាគមន៍បន្តិចនឹងគេដែរ ៖

- បើរៀនស្គាល់ត្រឹមតែទ្រឹស្តី មិនបានន័យថា ចេះនឹងគ្រប់គ្រាន់ទេ ទាល់តែអនុវត្តន៍ផង ដើម្បីអោយដឹងថា តើទ្រឹស្តីនោះមានប្រសិទ្ធិ ភាពយ៉ាងណា ។ ម្យ៉ាងទៀត មុននឹងបង្រៀនគេដទៃ យើងគប្បីតែ ណែនាំខ្លួនយើងមុនគេ មិនថាអញ្ចឹងហ្អែស ឆាល់ ?

ឆាល់ឮហើយញាក់ចិញ្ចើម ៖

- ប្រហែលជាអញ្ចឹងទេដឹង ?

បន្តិចមក កូនមាន់ក៏ដើរទៅជិតខេងនិងសុធាហើយប្រាប់ថា៖

- អង្គការយូអិនកំពុងរៀបចំបង្កបង្កើត អោយមានរបៀបរៀបរយ ក្នុងជំរំ ដើម្បីអោយជនភៀសខ្លួនទាំងឡាយនោះមានស្មារតីទទួល ខុសត្រូវ មិនខ្ជិល

ដេកចាំតែអាហារដែលអង្គការបើកអោយប្រចាំ អាទិត្យនោះទេ ។ មិនយូរមិនឆាប់ គេនឹងមានការរៀបចំអោយមាន ក្រុម សង្កាត់ ប្រៃសណីយ៍ សាលារៀន និងវត្ត បន្តិចម្តងៗ ។ ខេងនិងសុធា កុំភ្លេចបបួលគ្នីគ្នាចូលធ្វើការផង ដើម្បីជួយគ្នាយើង កុំអោយពេលវេលាកន្លងទៅឥតប្រយោជន៍ ។ ជិតបួនឆ្នាំកន្លងទៅ ខ្មែរក្រហមបំបាត់សាលារៀន សម្លាប់បញ្ញវន្តចោលរាប់ម៉ឺនរាប់សែន ពេលនេះ ជាឱកាសល្អសំរាប់យើងទាំងអស់គ្នាស្តារវិជ្ជានិងការចេះ ដឹងទាំងអស់នោះមកវិញហើយ ។ ពេលខ្ញុំទៅដល់អាមេរិក ចាំខ្ញុំរក វិធីសុំសៀវភៅពីសប្បុរសជន ដេម្បីផ្ញើមកជំរុំចែកគ្នាយើងបកប្រែ អោយក្មេងៗបានរៀនសូត្រចេះដឹង មិនល្ងិតល្ងង់តទៅទៀត ។

ខេងនិងសុធាងក់ក្បាល ។ ជ្រូកលីវក៏ពោលបន្តថា ៖

- កុំភ្លេចរក្សាទំនាក់ទំនងរវាងយើងអោយបានជាប់ណា៎! យ៉ាងណា កុំអោយវង្វេងគ្នាអោយសោះ!

រំពេចនោះ សុធីយកបញ្ជីឈ្មោះពីរបីសន្លឹក មកហុចអោយកូន មាន់និងជ្រូកលីវ រួចហើយស្រដីថា ៖

- នេះជាឈ្មោះរបស់ក្មេងៗ នៅមណ្ឌលកុមារកំព្រារសង្កាត់មួយ... យើងទាំងអស់គ្មានបងប្អូនសាច់ញាតិទេ ។ បើសិនជាអាច សូមបង មេត្តាផ្សាយរកអំណោយមនុស្សធម៌ ធ្វើភួយ ធ្វើខោអាវឲ្យពួកយើង បានស្លៀកពាក់ដណ្តប់ខ្លួនផង ។ រាល់ថ្ងៃយើងរងាណាស់ គេងតែ ក្នុងគំនរស្មៅចំបើងទេ ព្រោះគ្មានខោអាវស្លៀកបិទបាំងខ្លួន ។ អឺ... មួយវិញទៀត សូមបងជួយបន្តការផ្សាយរកសាច់ញាតិអោយពួក យើងផង ក្រែងលោបានជួបជុំបងប្អូនឪពុកម្តាយវិញ មិនកំព្រារងា ដូចឥលូវនេះទៀត ។

កូនមាន់ទទួលយកបញ្ជីពីដៃសុធី ទាំងទឹកភ្នែករលីងរលោង ដោយក្តីអាណិតចំពោះក្មេង ហើយក៏ងក់ក្បាល ៖

- ចា៎ស! ចាំបងប្រឹងអោយអស់ពីសមត្ថភាព! ប្អូនទុកចិត្តបងចុះ បងមិនទុកអោយប្អូននៅរងាវេទនាយ៉ាងនេះទេ ។ បងនឹងខំប្រឹង អោយអស់ពីសមត្ថភាព ដើម្បីស្វែងរកជំនួយមនុស្សធម៌មកជួយ ប្អូនៗទាំងអស់គ្នា ។

កុមារសុធីលើកដៃសំពះ ដោយក្តីគោរពស្រឡាញ់ ៖

CHANBOKEO.COM

- អរគុណបងស្រីណាស់! សង្ឃឹមថា ប្អូនៗនឹងបានខោអាវស្លៀក និងភួយដណ្តប់ ឆាប់ៗនេះ ។ បើសំណាងយើងមាន ប្អូនៗច្បាស់ ជានឹងបានជួបជុំក្រុមគ្រួសារ ដែលព្រាត់ប្រាសដោយសង្គ្រាមនោះ វិញជាមិនខាន បើសិនជាពួកគេទាំងនោះ មិនទាន់ស្លាប់បាត់បង់ ជីវិតនៅឡើយ ។

- ចាស! សូមអោយប្អូនៗបានសំរេចដូចបំណងប្រាថ្នាគ្រប់គ្នា!

រំពេចនោះ រថយន្តក៏ស៊ីផ្លេ អោយសញ្ញាចេញដំណើរ ។

- ខ្ញុំត្រូវចេញទៅហើយ! សូមមីង ពូ មិត្ត និងប្អូននៅអោយបាន សុខសប្បាយ! យើងទាំងពីរ ជំរាបលាសិនហើយ ចាស!

ជ្រូកលីវនិងកូនមាន់លើកដៃសំពះលាញាតិមិត្តទាំងឡាយហើយក៏ បោះជំហានឡើងរថយន្តមនុស្សធម៌ចេញដំណើរទៅ ទុកអោយអ្នក ទាំងឡាយឈរសម្លឹងមើលពីក្រោយ ដោយដួងចិត្តរំជួលញាប់ញ័រ ណាមួយជួយត្រេកអរដែលអ្នកទាំងពីរមានឱកាសចេញទៅស្វែងរក ជីវភាពអនាគតភ្លឺស្វាងនៅប្រទេសទីបី ណាមួយអាណិតខ្លួនដែល មិនដឹងថា ជីវិតនៅក្នុងជំរំនោះនឹងក្លាយជាយ៉ាងណា... ហើយក៏មិន ដឹងដែរថា ខ្លួនមានវាសនាដូចកូនមាន់និងជ្រូកលីវដែរឬទេ ។

- មែនហើយ! កាលបើកូនមាន់ប្រឹងជួយខ្លួនឯង ប្រឹងធ្វើការជា បុគ្គលិកឥតកម្រៃយ៉ាងជ្រមុជជ្រមុល មិនព្រមដេកចាំព្រេងសំណាង រហូតដល់បានទទួលការកត់សំគាល់ពីទូតប្រទេសក្រៅ រឿងអ្វីដែល យើងធ្វើអញ្ចឹងដូចគ្នាមិនបាន ? (នាយខេងពោល) តោះយើងទៅ ធ្វើការ! កុំចោលពេលទំនេរឥតប្រយោជន៍អោយសោះ! យើងត្រូវ រៀនឆក់យកសំណាងល្អដូចកូនមាន់និងជ្រូកលីវដែរ មែនទេហ៎!

ខណៈនោះ ទាំងអស់គ្នាក៏ហោរឡើង សាទរជាកម្លាំងចិត្តយ៉ាង ធំធេងចំពោះគ្នាទៅវិញទៅមក ។

# ចប់

CHANBOKEO COM